រឿង

# លិខិតមរតកសម្ងាត់

## ពីជីដូនកម្ពុជាចំពោះចៅអាមេរិក

ប្រលោមលោកមនោសញ្ចេតនា

ដោយ អ្នកស្រី កែវ ចន្ទ័បូរណ៏
P.O.Box 600279
Saint Paul, Minnesota 55106, USA
khmervissal@yahoo.com

រក្សាសិទ្ធិ ២០០៦

CHANBOKEO.COM

## សូមឧទ្ទិសស្នាដៃនោះប្រគេននិងជូនចំពោះ

- ព្រះគ្រូ សេងប៊ុនសង ព្រះគ្រូចៅអធិការ ម៉ីងសាង ភិក្ខុ វុំមភិរម្យ ភិក្ខុ គិមសុវត្ថិ ភិក្ខុ ប្រាក់សាមឿន ភិក្ខុ គង់សុជា វត្តមិនីសូតាម រដ្ឋមិនីសូតា សហរដ្ឋអាមេរិក។
- លោកឪពុក ប៊ុនថង និងអ្នកម្តាយ កែវយឿង
- លោកឪពុកក្មេក មេងសួង និងអ្នកម្តាយក្មេក កូវសារ៉ាន់
- លោក មេង សួង សុវណ្ណធី ជាស្វាមី
- កុមារី សុវណ្ណធី ធម្មិកា បារមីបុណ្យ ជាបុត្រីទោល
- លោក នូ សារិត អ្នកស្រីមេង សុមាលី លោក នូ ឫទ្ធិរិទ្ធ
- កុមារ មេង សុភក្ត្រា និងគ្រួសារ កុមារ ម៉ី សុផល ខេរិន និងគ្រួសារ
- លោកអ៊ុំមសុនាថ លោកជិនសោរិន និងបុគ្គលិកសារពតិមានកោះសន្តិភាព
- មីងពៅនិងពូវៃនៅភ្នំពេញ




អ្នកស្រី កែវ ចន្ទ័បូរណ៌

រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

chanbokeo@yahoo.com

www.angkorwat.com

# វាចាអ្នកនិពន្ធ

រឿងលិខិតមរតកសំងាត់ជាការស្រម័យរបស់អ្នកនិពន្ធសុទ្ធសាធ មិនមានទាក់ ទងពាក់ពន្ធ័ទៅនឹងជីវិតពិតរបស់គូស្នេហ៏ណាមួយឡើយ ។ ខ្លឹមសារនៃសាច់រឿង បានត្រូវប្រតិស្ឋឡើង បញ្ជាក់ពីការតស៊ូរបស់តួអង្គនិងការលះបង់អំពើឆ្គាំឆ្គងរបស់ គេ ដើម្បីមនុស្សដែលខ្លួនស្រលាញ់ ហើយបែរចាប់យកជីវិតដែលប្រកបដោយ សីលធម៌និងគុណធម៌មកវិញ ទោះបីជាជីវិតនោះក្រខ្សត់នឿយលំបាកបន្តិចក្តី ។

អាស្រ័យហេតុនេះ សូមមិត្តអ្នកអានទទួលនូវការកំសាន្តសប្បាយរីករាយ អារម្មណ៏ជាមួយនឹងសាច់រឿងរបស់យើង ។ ចំពោះកំហុសអក្ខរាវិរុទ្ធដែលកើតមាន ដោយអចេតនាទាំងឡាយ សូមមិត្តអ្នកអានមេត្តាជួយកែសំរួល ឱ្យសមរម្យតាម វេយ្យាករណ៏ខ្មែរដោយប្រពៃផង ។ នាងខ្ញុំអ្នកនិពន្ធសូមទទួលនូវមតិយោបល់ពី ប្រិយមិត្តអ្នកអាន តាមរយៈអស័យដ្ឋានដូចខាងក្រោមនេះ :


Chanbo Keo<br>
P.O.Box 600279<br>
Saint Paul, MN 55119<br>
USA<br>
Khmervissal@yahoo.com


សូមប្រិយមិត្តបានជួបប្រទះតែវឌ្ឍនសុខ  និងសុវត្ថិភាព រាល់ទិវារាត្រី ។

អ្នកនិពន្ធ

អ្នកស្រី កែវ ចន្ទ័បូរណ៏

ថ្ងៃទី ២៤មករា ២០០៦

CHANBOKEO.COM

# សង្ខេបរឿង

ខេវិនជាកំលោះខ្មែរសញ្ជាតិអាមេរិក ដែលមានប្រវត្តិមិនសូវស្អាត ហើយមានសង្សារម្នាក់ឈ្មោះផល្លីនដែលចូលចិត្តដឹកដៃនាយចូលសង្គមឧក្រិដ្ឋជានិច្ច ។ ថ្ងៃមួយ ខេវិនបានសំរេចចិត្តធ្វើដំណើរទៅប្រទេសកម្ពុជា ដើម្បីទទួលមរតកដ៏មហាសាល ពីជីដូនរបស់ខ្លួន ។ ប៉ុន្តែ មុនអាចទទួលមរតកបាន ខេវិនត្រូវរៀបការនឹងនារីម្នាក់ ដែលជីដូនរបស់នាយបានជ្រើសរើសទុកអោយ ។ រីឯចំណារសម្បត្តិមរតកទាំងនោះ បានត្រូវលាក់ទុកនៅកន្លែងសំងាត់មួយ ដែលខេវិនត្រូវទៅតាមរកដោយខ្លួនឯង ។ ចៃដន្យ ក្នុងខណៈដែលគេកំពុងតាមរកចំណារមរតក បុរសយើងក៏បានផុងខ្លួនជាមួយក្រមុំស្រុកស្រែមួយរូបនៅព្រះនេត្រព្រះ ហើយក៏បានត្រូវអ្នកភូមិចាប់អោយ រៀបការជាមួយគ្នា ពីរថ្ងៃមុនពេលដែលមាណពយើងបានជួបចៅស្រីក្រមុំដ៏សោភា ដែលជីដូនបានជ្រើសរើសទុកអោយនោះ ។

នៅគ្រានេះ តើខេវិនត្រូវប្រទះនឹងបញ្ហាអ្វីខ្លះ? ហើយគេត្រូវដោះស្រាយ ដំណើរជីវិតរបស់គេយ៉ាងណាទៅវិញ?

សូមតាមដានដូចតទៅ...

CHANBOKEO . COM

# វគ្គទីមួយ
## ដំណើងលាភ

**ថ្ងៃ ១៥មករា ២០០៦**

រ៉ឹង១....សំលេងកណ្ដឹងទ្វារលាន់ឮឡើង។ មីងពៅកំពុងជាប់ដាំស្ល ក៏ កូកហៅពូវៃអោយទៅបើកទ្វារជំនួស :

- ប្រហែលជាខេវិនហើយ បងឆាប់បើកទ្វារអោយផង ខាងក្រៅធ្លាក់ព្រិល អាកាសធាតុត្រជាក់ណាស់។

ពូវៃក៏ស្ទុះទៅយ៉ាងលឿន។ តែលុះគាត់បើកទ្វារទៅ ស្រាប់តែភ្ញាក់ ព្រើត.. គេនោះមិនមែនខេវិនឯណា។ ពូវៃក៏លាន់មាត់ឡើង :

- អូហ៎! ផល្លីនទេហ៎? ចុះឯណាខេវិន?

- Hello ពូ មីង! បងខេវិននៅចាំក្នុងឡាន outside ឯណោះ។ គាត់ថា it's terribly cold ខ្ជិលចុះដើរមក ហើយឱ្យខ្ញុំមកយកសំបុត្រ។

ពូវៃឮដូច្នេះគ្រវីក្បាលហើយតបថា :

- សំបុត្រមួយច្បាប់នោះសំខាន់ណាស់។ ពូមិនអាចអោយផ្ដេសផ្ដាស បានទេ ទាល់តែម្ចាស់ខ្លួនមកទទួល ទើបពូមីងអាចអោយបាន។

- យី! សំបុត្រអីក៏ special ម្ល៉េះ?

- នែ៎ផល្លីន ទៅហៅខេវិនអោយចូលផ្ទះសិនមក៏។

- Okay !

ផល្លីនចេញទៅមួយភ្លែត ក៏នាំខេវិនមកដល់វិញ :

- Pauline គេចង់ឃើញសំបុត្រស្អីគេនោះ...

ពូវៃសំលឹងមុខខេវិន :

- ម៉េចអោយទៅផល្លីនជាអ្នកទទួលទៅវិញ? យើងមិនអោយទេ។

ខេវិនឮដូច្នេះក៏ស្ទុះចេញទៅវិញ :

- អញ្ចឹង ខ្ញុំទៅវិញហើយ ពូមីង!

CHANBOKEO.COM

ខេរីនក៏លើកមួកពាក់ដើរថយក្រោយវិញ ដោយមិនទាន់ទាំងឈាន ជើងចូលក្នុងផ្ទះមួយជំហានផង ។ មីងពៅក៏ស្រែកវ៉ាសតាមពីក្រោយ :

- អើហ៎ បើទៅហើយ កុំមកវិញ! ទៅអោយបាត់រហូតទៅ!

ឮមីងពៅនិយាយដូចខឹង ខេរិនទុចដំណើរង៉ក់ហើយនាយក៏បែរថយ ចូលមកក្នុងផ្ទះវិញយ៉ាងរហ័ស រួចដោះស្បែកជើងដើរចូលទៅក្នុងផ្ទះបាយ តាមក្រោយមីងពៅ ។ នាងផល្លីនក៏ចូលមកដែរ តែមិនហ៊ានដើរចូលតាម ខេរិនទេ គ្រាន់តែដាក់ខ្លួនអង្គុយចុះនៅលើកៅអីមួយ ក្បែរមាត់ទ្វារតែ ប៉ុណ្ណោះ ។ រីឯពូវៃដាក់ខ្លួនក្នុងសាលុងហើយ ក៏បើកទូរទស្សន៍មើលធ្វើ មិនដឹង ។ ភ្លាមនោះ ខេរិនក៏សួរទៅមីងពៅបន្ថែមថា :

- មីងហ្អា? អោយសំបុត្រឥលូវមក៏ ខេរិនខ្ជិលនៅចាំណាស់!

មីងពៅក៏ហាក់មិនសប្បាយចិត្តដែរ ដែលក្មួយប្រុសខ្វះសុជីវធម៌ :

- អឺ! បើឯងប្រញាប់ ឯងទៅវិញសិនចុះ ចាំថ្ងៃក្រោយមានពេល ចាំឯងមកនិយាយជាមួយមីងក៏បានដែរ ។ មីងនិងពូនៅផ្ទះមួយនេះជិត ២០ឆ្នាំ មិនផ្លាស់ប្តូរទៅណាមកណាដូចឯងទេ ។ ដូច្នេះឯងអាចរកយើង ឃើញគ្រប់វេលាដែលឯងចង់រក៏ ។

- My Gosh!! ម្តងហៅអោយចូល ម្តងដេញអោយទៅវិញ! (ខេរិនរអ៊ូ)

- អើហ៎ បើឯងមានការប្រញាប់ដូច្នេះ ឱ្យមីងនិយាយស៊ីកើត? ឯង មិនឃើញទេហ៎ មីងកំពុងជាប់ដាំស្ល មកពីធ្វើការនឿយហត់ មិនទាន់បាន បាយចូលមាត់មួយគ្រាប់ផង ។

ខេរិនឈរធ្វើមុខស្មឿក ស្រាប់តែ ផល្លីនសង្សាររបស់នាយទាញដៃ អាវនាយជាប់ហើយក៏ខ្សឹបខ្សិបដាក់ នាយថា :

- បងខេរិន! Be patient បន្តិចទៅ ដល់គាត់ដាំស្លហើយគាត់ប្រគល់ សំបុត្រនោះអោយបងហើយ ។

ខេរិនឮដូច្នោះ ក៏ទុចដំណើរសាជាថ្មី ។ ពុទ្ធោអើយ... ការរង់ចាំរបស់ នាយ ហេតុអីក៏យូរសែនយូរម្លេះ ។ មីងពៅ ក៏ដាំអាហារមិនចេះឆ្អិនសោះ ។ ម្យ៉ាងទៀត ខេរិនក៏មិនមានចំណូលចិត្តខាងអាហារខ្មែរផង ម្ល៉ោះហើយ បរិយាកាសពេលនោះ រិតតែធុញថប់ឡើង។ ។

មួយស្របក់ក្រោយមក មីងពៅដណ្តាំស្លឆ្អិនហើយរួចក៏រៀបអាហារ ដាក់លើតុបំរុងហៅប្តីរបស់គាត់មកពិសារ ។ ភ្លាមនោះ គាត់ក៏បែរមកខេរិន ហើយស្រដីថា:

- នែ៎! មីងដាំស្លច្រើនណាស់ មកញ៉ាំម៉ាមាត់ពីរសិនទៅ ក្មួយទាំងពីរ ។

ខេរិនគ្រវីក្បាល :

- សុំតែសំបុត្រស៊ីនោះមក់ រួចខ្ញុំទៅវិញហើយ ។

ខេរិនពោលផង សំលឹងទៅផល្លីនផងទំនងដូចជាធុញទឹងនាងដែរ ។

- អញ្ចឹងឯងទាំងពីរចាំម៉ាភ្លែតទៀតទៅ ចាំពូមីងបាយហើយសិន

CHANBOKEO.COM

- អូហ៏? That letter , or whatever, is not here with you?

- សំបុត្រនោះនៅជាមួយមីងពូនេះឯង តែមីងចង់មានពេលនិយាយផ្តាំ ឯងខ្លះៗ មុននឹងឯងធ្វើដំណើរទៅស្រុកខ្មែរដើម្បីទទួលមរតកនោះអី !

មីងពៅនិយាយពួៗទំនងចង់អោយផល្លីនរសើបត្រចៀក ព្រោះគាត់បានសង្កេតឃើញផល្លីនមានកិរិយារសាប់រសល់ណាស់ពេក។ លុះមីងពៅ និងពូវៃពិសារបាយរួច គាត់ក៏ហៅខេវិនអោយមកជួបនៅក្នុងបន្ទប់បិទទ្វារ ជិត ទុកឱ្យផល្លីននៅអង្គុយរង់ចាំតែម្នាក់ឯងខាងក្រៅ លួចដកកអើតអើមដកកចំហមាត់ចង់ដឹងណាស់ថា តើគាត់ទាំងពីរនាក់មានប្រសាសន៍អ្វីខ្លះ ចំពោះខេវិន។ រំពេចនោះ ស្រាប់តែផល្លីនឃើញខេវិនស្ទុះចេញមកវិញ ហើយពោលថា:

- អត់ទេ! បើដូច្នេះពិតមែន ខេវិនអត់ទៅស្រុកខ្មែរទេ មីង!

ថាហើយ ខេវិនក៏ស្ទុះនាំផល្លីនឡើងឡានបរចេញទៅយ៉ាងប្រញាប់ ទុកឱ្យមីងពៅនិងពូវៃឈរមើលមុខគ្នាធ្វើភាំង។ តាមផ្លូវត្រលប់មកវិញ ផល្លីនសួរខេវិនថា :

- What did they talk to you about, Honey?

- គាត់មាននិយាយស្អី? គឺមីងគាត់អានសំបុត្រមួយច្បាប់នោះអោយស្តាប់

- អូហ៏? How come you sounded very upset?

- អន់ចិត្តព្រោះសំបុត្រនោះបានចែងថា បងនឹងទទួលមរតកមហាសាល តែមុននឹងអាចទទួលមរតកបាន បងត្រូវរៀបការនឹងស្រីម្នាក់ដែលត្រូវជា ញាតិសាច់ឆ្ងាយនៅឯខ្មែរសិន។ ពុទ្ធោ! ឱ្យទៅរៀបការយ៉ាងម៉េច បើយើងមិនដែលស្គាល់គ្នាផង? ហើយម្យ៉ាងទៀត បងក៏មានម្ចាស់បេះដូង រួចទៅហើយដែរ។

ឮឃើញដូច្នោះ ឆវីរូបស្រស់ក៏ញញឹម គិតក្នុងចិត្តថា :

- ខេវិន! តើនរណាជាម្ចាស់បេះដូងរបស់បង? ផល្លីនខ្ញុំនេះមែនទេហ៏?

ប៉ុន្មានថ្ងៃក្រោយមក ខេវិនក៏ភ្លេចអស់អំពីរឿងមរតកនោះទៅ តែផល្លីនវិញហាក់ដូចជានៅមិនសុខសោះ ក៏ហៅខេវិនមកពិគ្រោះជាថ្មីថា :

- ខេវិន! បងពិតជាដាច់ចិត្ត មិនទទួលយកមរតកមហាសាល ពីជីដូនរបស់បងពិតមែនហ្អេស?

កាលបើឮផល្លីនសួរដូច្នោះ ខេវិនក៏ឆ្លើយថា :

- មិនចង់បានទេ...!!

ផល្លីននៅស្ងៀមមួយស្របក់ ក៏ពោលបន្តទៀត :

- បងមិនស្តាយទ្រព្យសម្បត្តិអ្វីទាំងនោះទេហ៏?

- អត់ទេ! បងស្តាយជីវិតដ៏មានសេរីភាពនៅអាមេរិកនេះជាជាង

CHANBOKEO . COM

ថាហើយ ខេវិនដើរគេចចេញទៅ ស្រាប់តែផល្លីននិយាយបន្ថែមថា :

- តែ... ខេវិនដឹងទេហ៎? ឥលូវនេះ យើងទាំងពីរអត់ការធ្វើ លុយក៏គ្មានចាយ
ទ្រព្យចុងក្រោយដែលនៅសល់គឺឡានកញ្ចាស់របស់បង។
មិនយូរប៉ុន្មានក៏អស់មានអ្វីលក់ចាយហើយ.. តើនឹងរស់យ៉ាងណាទៅ?

- មានទៅពិបាកអី? យើងវិលទៅលក់អាភៀនទៀតទៅ

- តែរបរនោះគ្រោះថ្នាក់ណាស់ណា៎បង ! ខ្ញុំចង់រកមធ្យោបាយណាដែល
ឆាប់មានលុយចាយហើយមិនមានគ្រោះថ្នាក់ជាមួយច្បាប់រដ្ឋផង។

- ផល្លីនកំពុងគិតពីរឿងអ្វីហ្នឹង?

- គឺ... កំពុងគិតថា ចង់អោយបងទៅស្រុកខ្មែរដើម្បីទទួលមរតកនោះអី !

- ប៉ុន្តែ បងត្រូវរៀបការនឹងចៅស្រីរបស់យាយសិន ទើបមានសិទ្ធិទទួល
មរតកទាំងនោះបាន។

- រៀបការបាន លែងលះក៏បានដែរ។ ការហើយទទួលមរតក ទទួលមរតក
ហើយចាំលែងលះវិញទៅ វាចប់បាត់ទៅហើយ ហើយបងក៏បានមរតក ទាំងនោះត្រលប់មកអាមេរិកវិញដែរ មិនថាអញ្ចឹងឬ
បងខេវិន? បងទៅ ស្រុកខ្មែរសាកមើល៍ ក្រែងជោគជតារាសីរបស់បងឡើងកាំជណ្តើរមកវិញ!

រ៉ឹង១....ស្នូរកណ្តឹងទ្វារផ្ទះលាន់ឮឡើង។ មីងពៅស្ទុះមកបើក ស្រាប់តែ លាន់មាត់ឡើង :

- ខេវិន? ហើយចុះឯងមកដាស់មីងពួងឯងអីទាំងពាក់អាធ្រាតដូច្នេះ?

- អោយខ្ញុំសុំសំបុត្រមរតកនោះបានទេមីង?

- អូហ៎? ចុះក្រែងក្មួយឯងថា មិន...

- គឺ ខ្ញុំដូរចិត្តហើយ មីងអោយខ្ញុំឥលូវនេះបានទេ?

- ចុះឯងបំរុងទៅអង្កាល់?

- ព្រឹកស្អែកនេះហើយ...

- ថាម៉េច? ហើយឯងមានលុយទិញសំបុត្រយន្តហោះដែរ?

- អត់មានទេ តែខ្ញុំគិតថានឹងយកឡានរបស់ខ្ញុំទៅលក់

- រួចចុះ....ផល្លីនសង្សាររបស់ឯងគេមិនខឹងនឹងឯងទេហ៎?

- យើងនិយាយស្តាប់គ្នាបានហើយ មីង...

ពេលនោះ មីងពៅហាក់ដូចជាមានចិត្តសង្ស័យហើយថា ហេតុអ្វីក៏ ផល្លីនសុខចិត្តបណ្តោយឱ្យខេវិនទៅស្រុកខ្មែរងាយៗម្ល៉េះ
កាលបើនាងជា មនុស្សប្រចណ្ឌខេវិនផុតលេខនោះ? ការពិត មីងយើងបានសង្កេតឃើញថា តាំងពីខេវិន

CHANBOKEO.COM

ក្លាយជាសង្សាររបស់នារីរូបស្រស់មួយនេះពេលណាមក នាយ មិនអាចសំលឹងមុខនារីណាបានឡើយ បើមិនដូច្នេះទេ នាយយើងច្បាស់ជា ត្រូវមេធ្នាក្រញៅមុខមិនលែងឡើយ ។

ស្អែកឡើង...

**ថ្ងៃ ១៦មករា ២០០៥**

មីងពៅនិងពូវៃនាំគ្នាសុំឈប់ពីការងារ ដើម្បីជូនដំណើរខេវិនឡើង យន្តហោះចេញទៅស្រុកខ្មែរ ។ នៅវាលចំណតយន្តហោះ ផល្លីនខុទាន ខ្សិប១ដាក់ត្រចៀកខេវិនថា :

- ស្តាយណាស់ដែលឡានរបស់បងចាស់ពេក លក់បានតែ៨០០ដុល្លារ ទើប មិនអាចទិញសំបុត្រយន្តហោះបានពីរនាក់ កុំអីអូនទៅតាមបងដែរហើយ ។

តែ កុំភ្លេចប្រញាប់មកវិញណាំបង អូននៅរង់ចាំ !

ផល្លីនថើបថ្ពាល់ខេវិនជាសញ្ញាលាគ្នាជាចុងក្រោយ ។ ខេវិនក៏បែរមក លើកដៃសំពះលាមីងពៅនិងពូវៃ :

- ខ្ញុំជំរាបលាសិនហើយពូ! មីង!

ពូវៃនិងមីងពៅមើលមុខគ្នាទាំងភ្ញាក់ស្រលាំងកាំង ត្បិតនោះជាលើក ទីមួយហើយដែលខេវិនចេះលើកដៃសំពះគាត់ទាំងពីរព្រមទាំងមានកិរិយា ហាក់ទន់ភ្លន់ចំលែកទៀតផង ។ ខេវិនក៏លើកដៃរាជាចុងក្រោយ ហើយ ចេញដំណើរទៅ ទុកអោយពូមីងឈរមើលសំលឹងមើលពីក្រោយទាំងចិត្ត ក្តុកក្តួល...

៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩៩

៩

CHANBOKEO.COM

# វគ្គទីពីរ
# វិមានកេរ្តិ៍មរតក

ម៉ោងដប់ព្រឹកនៅវាលយន្តហោះភ្នំពេញ ពីរថ្ងៃក្រោយមក....

**ថ្ងៃ១៨មករា ២០០៦**

ខេរិនដើរចេញពីទីវាលចំណតយន្តហោះក្នុងកិរិយាឆ្មើងឆ្មៃផង រអើល ខ្ចងផង ត្បិតនាយទើបតែវិលមកស្រុកខ្មែរជាលើកទីមួយ ។ មែនហើយ ពិតមែនតែនាយ មានកំណើតនៅស្រុកខ្មែរមែនពិត តែនាយបានឃ្លាតពី ស្រុកទៅតាំងពីអាយុបីបួនឆ្នាំម្ល៉េះហើយនាយយើងមិនចាំអ្វីបន្តិចឡើយ ។ រំពេចនោះ ស្រាប់តែមានបុរសម្នាក់ដើរចូលមកជិតមាណពយើង ហើយ ស្រដីថា :

- លោក! ត្រូវការតាក់ស៊ីទេបាទ?
- អូហ៎ ពិតជាត្រូវការ! ហើយចុះបងយកប៉ុន្មានដែរ?

នាយតាក់ស៊ីមិនឆ្លើយទេ បែរជាសួរត្រលប់វិញថា :

- ចុះលោកចង់អញ្ជើញទៅខាងណាដែរ?

ខេរិនក៏ហុចលិខិត ដែលមានសរសេរអាស័យដ្ឋាន ទៅឱ្យនាយតាក់ស៊ី ភ្លាម ត្បិតបុរសយើងមិនចេះអានអក្សរខ្មែរ ហើយក៏ភ្លេចមិនបានសាកសួរ សុំមីងពូជួយអានដើម្បីឱ្យនាយទន្ទេញចាំទុកក្នុងពោះដែរ ។ នាយតាក់ស៊ីនាំ ខេរិនចូលឡានរួចទើបអានលិខិតនោះ ស្រាប់តែបើកភ្នែកធំៗ :

- អីយ៉ា! លោកត្រូវមកទទួលមរតកផង?

ខេរិនឮហើយភ្ញាក់ព្រើត នឹកភ័យព្រួចក្នុងចិត្ត :

- ស្លាប់ហើយ! ដឹងការសំងាត់យើងអស់! តិចលោគេជាចោរទៅ... អីយ៉ូយ... វីវរ គេចាប់យើងជំរិតទារប្រាក់...

ភ្លាមនោះ ខេរិនក៏កញ្ឆក់ក្រដាសមកវិញបត់ទុកក្នុងហោប៉ៅវិញ យ៉ាង រហ័ស រួចហើយនិយាយបន្លប់នាយតាក់ស៊ីថា :

- យាយខ្ញុំក្រីក្រនៅស្រុកស្រែមិនមានអីចែកទេ ក្រៅពីខ្ទមស្រែ ។

នាយតាក់ស៊ីឮហើយក៏ញញឹមស្រដីថា :

- ទោះបីជាខ្ទមស្រែ ក៏មានតម្លៃវាស់មិនបានដែរ ត្បិតនោះជាកេរ្តិ៍មរតក របស់ជីដូនចំពោះចៅប្រុសជាទីស្រលាញ់នោះអី!

CHANBOKEO.COM

ខេវិនឮហើយក៏អង្គុយធ្វើហី ហើយបែរជាគិតក្នុងចិត្តថា :

- ខ្ញុំមិនទុកចិត្តអ្នកទេ ខ្លាចអ្នកយាយីរូបខ្ញុំ បើសិនអ្នកដឹងថា ខ្ញុំនឹងទទួល មរតកយ៉ាងមហាសាល!!

តាមផ្លូវខេវិនមានចិត្តរំភើបរន្ធត់ចំលែកណាស់កាលបើខ្លួនបានវិលមក ដល់មាតុភូមិរបស់ខ្លួនដែលប្លែកពីស្រុកអាមេរិកសព្វបែបយ៉ាង ។ ខែនេះជា ខែមករា នៅរដ្ឋមិនីសូតា ព្រិលកំពុងតែធ្លាក់សពាសដី សីតុណ្ហភាពចុះនៅ ក្រោមសូន្យអង្សារៀងរាល់ថ្ងៃ ។ ចំណែកមនុស្សម្នាវិញ ត្រូវស្លៀកពាក់ ក្រាស់ៗ ខ្លួនឡើងធំប៉ុនក្របីមុននឹងចេញដើរទៅក្រៅម្ដងៗ ។ ពេលហើប មាត់និយាយ ចំហាយហើរចេញពីមាត់ដូចចំហាយទឹកពុះចេញពីឆ្នាំងដូច្នោះ ឯង ។ ចំណែកឯសំបោរក៏ហៀរជាប់ បើស្ដោះទឹកមាត់វិញ ទឹកមាត់នោះវា នឹងហើរកកតាមផ្លូវមុននឹងធ្លាក់ដល់ដី ។ ប៉ុន្តែ មើលចុះ! នៅឯភ្នំពេញវិញ ប្រុសៗដើរដោះអាវ ក្មេងៗរត់ស្រាតលោតទឹកប្រឡូងៗ ។ រីឯរានទឹកកកវិញ មួយណាក៏មានមនុស្សម្នាឈរតំរង់ជួរចាំទិញដែរ ។ គួរអោយប្លែកភ្នែក មែន! ចំណែកចរាចរលើផ្លូវថ្នល់មានសព្វទាំងអស់តាំងពីថ្មើរជើង កង់ ម៉ូតូ រទេះគោ ឡាន គោចរទៅមករអឹកលាយឡំគ្នា មិនដូចស្រុកអាមេរិក ទេ ច្បាប់តឹងអីតឹង! មនុស្សដើរផ្លូវផ្សេង ឡានផ្សេង កង់ផ្សេង ។ ពេល នោះខេវិនទឹកគិតថា ជីវិតស្រុកខ្មែរ អីក៏ងាយស្រួលរស់នៅម្ល៉េះ មិនសូវ មានបំរាមមានវិន័យគួរអោយគោរពរញ៉ីរញ៉ៃ ច្រើនដូចនៅអាមេរិកទេ ។ មាណពយើងបង្ហើរអារម្មណ៍យ៉ាងសប្បាយ ជាមួយទិដ្ឋភាពដ៏ប្លែកៗក្នុងទី ក្រុងភ្នំពេញ ដែលនាយមិនដែលបានឃើញពីមុនមកក្នុងជីវិត ។ មកដល់ផ្លូវ កាច់ចូលទៅទួលគោក ស្រាប់តែនាយទឹកឃ្លានបាយជ្រួចក្នុងពោះតែម្ដង ។ មាណពក៏ប្រាប់នាយតាក់ស៊ី អោយឈប់ចតនៅកន្លែងលក់បាយសំរូបមួយ រួចក៏ចុះពីឡានទៅឈ្ងោកមើលឆ្នាំងសម្លដែលគេដាក់តំរៀបគ្នាលើតុ ប៉ុន្តែ គួរអោយស្ដាយ! គ្មានមុខម្ហូបណាមួយដែលខេវិនចូលចិត្តសោះ ។ ភ្លាម នោះ នាងក្រមុំអ្នកលក់បាយក៏សួរថា :

- ពូ! ចង់ពិសារមុខណា? ខ្ញុំដួសជូន ។

ស្រាប់តែខេវិនភ្ញាក់ព្រើត លាន់មាត់យ៉ាងខ្លាំងថា:

- យី! ខ្ញុំមិនទាន់ចាស់ឯណា ម៉េចហៅខ្ញុំថាពូដូច្នេះ? យ៉ាប់មែន! មើលមុខអ្នកលក់ចុះ មានក្មេងអីជាងខ្ញុំប៉ុន្មានទៅ?

តាមពិតខេវិនមិនដឹងទេ ថានៅស្រុកខ្មែរ ស្រីៗគេទំលាប់ហៅបុរស ដែលមិនស្គាល់គ្នាថាពូ ។ តែខេវិនបែរជាអន់ចិត្តទៅវិញ ត្បិតនាយគិតថា នាងក្រមុំនោះកំពុងនិយាយចំអកថានាយមុខដូចមនុស្សចាស់ ។ ខឹងពេក ខេវិនក៏ដើរត្រុយចូលឡានវិញរួច ក៏ធ្វើដំណើរបន្តទៅទៀត ។ មកដល់មុខ វិឡាដ៏ស្កុកស្កម្ភមួយ នាយតាក់ស៊ីក៏បញ្ឈប់ហ្វ្រាំងង៉ក់ ហើយបែរក្រោយ ពោលប្រាប់នាយថា :

- ដល់ហើយទាន!

កាលបើក្រលេកឃើញវិឡាយ៉ាងស្កឹមស្កៃនោះភ្លាម ខេវិនក៏មានចិត្ត ត្រេកអររំភើបស្ទើរហើបជើងពីដី :

- ល្បងមកត្រូវ address ហើយមែនទេ? (ខេវិនសួរបញ្ជាក់)

- បាទ! ត្រូវហើយ ។

CHANBOKEO.COM

ខេវិនចុះពីរថយន្តទៅចុចកណ្ដឹងផ្ទះ ។ ភ្លាមនោះ ស្រីក្មេងម្នាក់ទំនងជា អ្នកបំរើចេញមកបើកទ្វារ :

- អត់ទោស! លោកមករកពីណាដែរ?

- គឺ... ខ្ញុំឈ្មោះខេវិនមកពីសហរដ្ឋ បានទទួលសំបុត្រមួយច្បាប់នេះ ប្រាប់ ថាឱ្យមក ជួបម្ចាស់ផ្ទះនេះជាការប្រញាប់ ។

ស្រីក្មេងនោះក៏នាំខេវិនចូលទៅក្នុងបន្ទប់សាលុងមួយ ដែលមានតុប តែងដោយគ្រឿងសង្ហារិមដ៏តម្លៃមហាសាល ។ ពេលនោះ ខេវិនកាន់តែ

រំភើបឡើងញ័រដៃទទ្រើកតែម្ដង ។ រំពេចនោះ បុរសចាស់ម្នាក់ក្នុងសំលៀក យ៉ាងថ្លៃថ្នូរចូលមកដល់ ។ កាលបើក្រលេកឃើញភ្លាម នាយក៏លើកដៃ សំពះសួរ ស្រាប់តែបុរសនោះលាន់មាត់ឡើង :

- យីអើ! អ្នកអាមេរិកចេះជំរាបសួរដែរហ្ន៎?

ពេលនោះខេវិនខ្មាសដៃណាស់ ។ នាយមិនដែលសំពះនរណាទេ តាំងពី ក្មេងមក សូម្បីតែមីងពៅនិងពូរ៉េក៏មិនដែលដែរ តែពេលនេះនាយខំធ្វើ ទាំងទើសទាល់ តើព្រោះអ្វីទៅ? គឺក៏ព្រោះតែលិខិតមរតករបស់ជីដូននោះ

កំពុងតែបន្លឺសំនៀងយ៉ាងពិរោះបំផុត ក្នុងត្រចៀករបស់នាយ ។ បុរស ចំណាស់ក៏សួរថែមទៀត :

- ក្មួយឈ្មោះខេវិននោះមែនទេហ៎?

- បាទ! (ខេវិនឆ្លើយយ៉ាងរហ័ស) តើលោកយាយរបស់ខ្ញុំបានផ្ដាំផ្ញើទុកអ្វី ខ្លះដល់រូបខ្ញុំជាចៅដែរ?

បុរសចំណាស់សំលឹងមុខខេវិនរួចក៏យកលិខិតមួយច្បាប់ចេញមក :

- ក្មួយមកទទួលមរតក ហើយមិនចង់ជួបចង់ស្គាល់សាច់ញាតិណាម្នាក់ទេ?

- គឺ... គឺ...

ខេវិនអេះអុញ នឹកថាប្រហែលជាបុរសចំណាស់ចង់បង្ហាញខ្លួនចៅស្រី

មួយរូបនោះហើយមើលទៅ ។ ស្រាប់តែគាត់មានប្រសាសន៍បន្តថា:

- ណ្ហើយ! ទោះបីជាចង់ស្គាល់ ក៏មិនអាចជួបបានដែរ ត្បិតសាច់ញាតិរបស់

ក្មួយនៅឆ្ងាយណាស់ ។ ពេលនេះ ពូមានតែលិខិតមួយច្បាប់របស់លោក យាយទេដែលផ្ញើទុកនៅទីនេះឱ្យក្មួយខេវិនឯង ។

បុរសចំណាស់ក៏ហុចសំបុត្រក្នុងស្រោមពណ៌ប្រផេះមួយ អោយទៅ ខេវិនដែលកំពុងសំដែងកិរិយាងឿងឆ្ងល់បំផុត :

- អញ្ចឹងផ្ទះនេះ មិនមែនជាផ្ទះរបស់ជីដូនខ្ញុំទេហ៎? (ខេវិនសួរ)

បុរសនោះឮសំនួរនាយហើយក៏តបវិញទាំងញញឹមថា :

- អូហ៍ អត់ទេ! លោកយាយរបស់ក្មួយគ្រាន់ តែសុំផ្ដាំផ្ញើទុកសំបុត្រគាត់ ជូនក្មួយនៅទីនេះប៉ុណ្ណោះ ដើម្បីអោយក្មួយងាយស្រួលរក ពេលមកដល់ កម្ពុជាថ្មីៗ កុំអោយវង្វេង ។

ភ្លាមនោះ ខេវិនថ្លោះទឹកមុខ សួរទៀតថា :

- ហើយចុះ ផ្ទះជីដូនរបស់ខ្ញុំនោះនៅឯណាវិញទៅ?

- អាស័យដ្ឋានរបស់លោកយាយស្ថិតនៅក្នុងសំបុត្រនេះហើយ ។ ចូរហែក អានទៅ!

CHANBOKEO.COM

មកដល់ក្រៅរបងពេលណា ខេវិនក៏ហែកសំបុត្រទាញយកមកអាន យ៉ាងរហ័ស ។ តែអនិច្ចា! ខេវិនភ្លេចថាខ្លួនមិនចេះអក្សរខ្មែរទេ ពេលនេះ នាយក៏ត្រូវខកចិត្តសាជាថ្មីម្តងទៀតហើយ ។ ហ៊ឺ! គួរឱ្យស្តាយណាស់ តើនាយទៅពឹងនរណាទៅ? ភ្លាមនោះ នាយតាក់ស៊ីដដែល ក៏ដើរចូលមកដល់
ជិត ហើយសួរនាយថា :

- លោក! តើមានចង់ធ្វើដំណើរទៅខាងណាទៀតដែរទេហ៎?

ខេវិនភ្ញាក់ព្រើត ដែលឃើញនាយតាក់ស៊ីនៅអង្គុយចាំ ។ ភ្លាមនោះ
ខេវិនកើតការសង្ស័យទៀតហើយ ខ្លាចនាយតាក់ស៊ីមានគំរោងអ្វីមួយមក លើខ្លួន ក៏ឆ្លើយតបទៅវិញថា:

- ខ្ញុំមិនអីទេ ប្អូនទៅវិញចុះ ។
- តែខ្ញុំទៅមិនបានទេហ៎!
- ហេតុអ្វីក៏មិនបាន? ឥលូវនេះ ខ្ញុំលែងត្រូវការអោយប្អូនជួយជូនខ្ញុំទៀត ហើយណា៎ ។
- គឺ... មកពីលោកមិនទាន់អោយលុយខ្ញុំថ្លៃធ្វើដំណើរ ពីចំណតយន្តហោះ មកទីនេះនៅឡើយទេ បាទ!

ពុទ្ធោ! បាក់មុខនាយខេវិនអស់រលីង!! ខេវិនអេះត្រចៀកហើយក៏ លូកលុយហុចហើយដើរចេញទៅទាំងខ្មាស ។ មួយភ្លែតក្រោយមក ខេវិន បានមកដល់តូបលក់នំបុ័ងដាក់សាច់មួយ ក៏លូកលុយទិញ ត្បិតនាយយើង
កូរពោះគគ្រូកហេវបាយសឹងតែស្លាប់ម្តងៗទៅហើយ ។ ប៉ុន្តែ រសជាតិនំ បុ័ងដាក់សាច់នោះប្លែកណាស់ ។ បន្ទាប់ពីខាំមួយម៉ាត់ហើយ ខេវិនក៏លេប លែងចូល ។ នាយយើងក៏លើកនំបុ័ងបំរុងបោះចោលទៅហើយ ស្រាប់តែ
មានកុមារតូចៗមួយហ្វូងហក់ស្ទុះមកជិតសំពះសុំ :

- ពូ! ឱ្យខ្ញុំសូមនំបុ័ងនេះញ៉ាំបានទេហ៎?

ខេវិនភ្ញាក់ព្រើត:

- នំបុ័ងដែលមាត់ពូអញ្ចឹងយកញ៉ាំដែរ?
- ដែលមាត់ក៏យកដែរ យើងក្រណាស់ អត់មានបាយញ៉ាំពីរបីថ្ងៃហើយ ។

ខេវិនពូហើយ ទឹកចំលែកក្នុងចិត្តណាស់ ។ នាយមិនទាន់ឆ្លើយថាម៉េច
ផង ស្រាប់តែក្មេងទាញនំបុ័ងពីដៃយកទៅហែកចែកគ្នាបរិភោគអោយរញ៉ី តែម្តង ។ ការពិត ក្នុងមួយជីវិតរបស់នាយយើង ខេវិនមិនដែលស្គាល់អត់ ឃ្លានដល់ម្លឹងទេ ទោះបីនាយជាក្មេងកំព្រាក៏ដោយ ក៏មីងពៅពូវៃហុច បាយហុចទឹកឆ្អែតៗរហូត មិនថានាយមិនចូលចិត្តឬមិនចូលចិត្តអាហារទាំង នោះឡើយ ។ ហោចណាស់ នាយមានអាហារបរិភោគ ដោយមិនបាច់ដើរសូមទានតាមថ្នល់ដូចក្មេងទាំងនោះ ។ ភ្លាមនោះ នាយក៏នឹកគិតដល់គុណ បំណាច់ដែលពូវៃមីងពៅដែលបានផ្គត់ផ្គង់រូបនាយយ៉ាងល្អ ហើយនឹកស្តាយ ក្រោយដែលខ្លួនមិនដែលបានសំដែងនូវចិត្តកត្តញ្ញូចំពោះគាត់សូម្បីបន្តិច...

CHANBOKEO.COM

នៅក្រោមដើមក្រោកមួយ ខេរិនលើកទឹកក្រូចអកផង អានសំបុត្រ ផង ប៉ុន្តែអានមិនដាច់ម៉ាម៉ាត់ណាសោះ ព្រោះសរសេរជាខ្មែរ ។ គិតទៅ គិតមក នាយយើងក៏ដាច់ចិត្តហៅក្មេងប្រុសម្នាក់អាយុប្រហែល១០ឆ្នាំ ដែលទើបចេញពីរៀនឱ្យជួយអាន រួចនាយក៏ហុចប្រាក់ទៅនាយចំនួនពីរ ដុល្លារ តែក្មេងបែរជាគ្រវីក្បាលឆ្លើយថា:

- ខ្ញុំមិនយកទេពូ! ម្តាយខ្ញុំប្រាប់ថាកុំឱ្យទទួលប្រាក់ពីមនុស្សចំលែកក្រែង គេល្បួងនាំយើងយកទៅលក់ ។

ថាហើយ កុមារក៏រត់ចេញទៅ ។ រីខេរិន  ក៏ខំទន្ទេញអាស័យដ្ឋានតាម ដែលក្មេងបានអានឱ្យស្តាប់ ស្រាប់តែមានបុរសម្នាក់បើកម៉ូតូមកឈប់ក្បែរ នាយហើយសួរថា :

- ត្រូវការម៉ូតូឌុបទេ ល្បង?

កំពុងតែរកឱសស្រាប់តែប្រទះឈើងាប់ ។ ខេរិនឮហើយងក់ក្បាល :

- មែនហើយ! ខ្ញុំចង់ទៅបាត់ដំបង បងយកប៉ុន្មាន?

- ស្លាប់! ទៅបាត់ដំបងឆ្ងាយណាស់! ខ្ញុំមិនអាចជូនទៅដល់ទេ    តែខ្ញុំអាច ដឹកបងដល់ចំណតឡានតាក់ស៊ីបាន ។

ដោយដឹងថាខ្លួនថយ៉ាប់ខាងភូមិសាស្ត្រស្រុកទេសខ្លួនឯង ខេរិនក៏ បណ្តោយឱ្យក្មេងកំលោះនោះ ឌុបនាយរហូតដល់ចំណតឡានឈ្នួល ។  ហ៊ឺ!  គួរអោយពិបាកចិត្តអ្វីម្ល៉េះទេហ្ន៎! ពេលនោះ ខេរិនធ្វើមុខដូចស្វាទល់ផ្លុក អញ្ចឹងឥឡូវអីពេលនេះនាយត្រូវឡើងជិះប្រជ្រៀតគ្នានៅខាងក្រោយឡាន ជាមួយអ្នកដំណើរជាច្រើននាក់ ដែលបញ្ចេញចំហាយញើសក្លៀកភាយៗ ដាក់គ្នាទៅវិញទៅមក ។ តាមផ្លូវ អ្នកស្រុកសំលឹងមុខនាយមិនដាក់ភ្នែក ទាល់តែសោះដែលនាយមានកិរិយាប្លែកពាខុសពីគេ គោរសក់ ពាក់ក្រវិល មួយចំហៀងហើយពាក់វ៉ែនតាខ្មៅ ពាក់អាវមួរដៃដល់ក្លៀក បញ្ចេញសាច់ ដុំស្វាដូចអ្នកលេង មើលទៅពិតជាចំលែកមែនហើយ ព្រោះគេឯទៀតសុទ្ធ តែពាក់អាវដៃវែង ដើម្បីការពារកំដៅថ្ងៃមិនអោយរលាកស្បែក ចំលែក តែខេរិនទេ ដែលលេងខ្លួនយ៉ាងសង្ហាតែម្តង ។ ច្រើនម៉ោងក្រោយមក ខេរិនក៏បានមកដល់ក្រុងបាត់ដំបង រួចហើយក៏ឡើងម៉ូតូឌុប ស្វែងរកផ្ទះ ដែលសំបុត្របានពណ៌នា ។ ម៉ោងបីរសៀលហើយ ខេរិនក៏បានមកដល់ ផ្ទះឈើប្រក់ក្បឿងមួយខ្នងនៅជិតវត្តកំផែង ដែលមានដាំសួនផ្កាលំអយ៉ាង ស្រស់ត្រកាល ។ ខេរិនចុះពីម៉ូតូឌុបដើរចូលទៅក្នុងរបងផ្ទះភ្លាម ។ ពេល នោះ មានតាចាស់មួយរូបដើរចេញមកទទួល :

- ចៅមករកពីណាគេដែរ?

- គឺ ខ្ញុំឈ្មោះខេរិន មកពីសហរដ្ឋ   បានទទួលសំបុត្រមួយច្បាប់នេះអោយ មកទទួលបញ្ញើមរតករបស់ជីដូនខ្ញុំ...

- អូហ៎... អញ្ចឹងចូលមកក្នុងសិនមក៏ ។

ខេរិនក៏ដើរតាមតាចាស់ឡើងចូលទៅក្នុងផ្ទះ ។ ពិតមែនតែផ្ទះនោះ ចាស់បន្តិច តែទិដ្ឋភាពសួនច្បារ និងការរៀបចំតុបតែងផ្ទះ តាមរបៀបខ្មែរ បុរាណល្អប្រណិត ឃើញភ្លាមគួរអោយចាប់ភ្នែកតែម្តង ។   ខេរិនគិតតែ ក្នុងចិត្តម្នាក់ឯងថា :

CHANBOKEO.COM

- ថ្វីត្បិតផ្ទះនេះមិនហ៊ីហាដូចវិឡាឯភ្នំពេញមួយនោះទេ  តែក៏មនោរម្យ គួរអោយចង់រស់នៅណាស់ ។ យើងក៏មិនខកចិត្តដែរ បើសិនជាយើងបាន ក្លាយជាម្ចាស់ផ្ទះ១នេះ ។

ពេលនោះតាចាស់ក៏កូកហៅឡើងថា :

- យាយអើយ! អាម៉ិដែលថាមកពីអាមេរិកនោះ គេបានមកដល់ហើយ ឆាប់ មកទទួលគេបន្តិចទៅ ។

ដូនចាស់មួយក៏ដើរចូលមកដល់ ឃើញខេវិនហើយក៏លាន់មាត់ :

- ពុទ្ធោ! កូនអាមេរិកមានមាឌធំដំបងណាស់ហ្ន៎! ហើយចុះម៉េចបានជា ពាក់ក្រវិលមួយចំហៀងដូច្នេះផង? អាង៉ាឯងកើតជំងឺកោបម្ខាងមែនទេ?

ខេវិនធ្វើភ្នែកឡឹងឡង់ ព្រោះនាយមិនយល់ពាក្យដូនចាស់ថា ចង់សួរ ពីអ្វីទេ ។ ស្រាប់តែ តាចាស់នោះឃាត់យាយភ្លាម :

- យីអើ! យាយសួរអញ្ចឹងមិនខ្លាចអាម៉ិវាខ្មាស់ទេហ្អី? រួចចុះឯណា ឥវ៉ាន់ ដែលជីដូនរបស់គេផ្ញើទុកនោះ?  យាយឆាប់ទៅយកអោយគេទៅ!

ខេវិនឮដូច្នោះ ក៏ភ្ញាក់ព្រើត លាន់មាត់ឡើងថា :

- បានន័យថា ផ្ទះនេះមិនមែនជាផ្ទះរបស់ជីដូនខ្ញុំនោះទេ មែនទេ?

- មិនមែនទេ! ផ្ទះរបស់ជីដូនឯងនោះនៅឆ្ងាយណាស់ ត្រូវបន្តដំណើរទៅ មុខទៀតប្រហែលជាងពីរម៉ោងឯណោះ ។

អឺយ៉ូយ! ខេវិនធ្វើមុខស្វាយល្អក នឹកខកចិត្តស្លុកតែម្តង :

- ហើយចុះផ្ទះយាយនៅឆ្ងាយដល់ណាទៅហ្ន៎? ហ៊ឺ! ហេតុអីក៏រញ៉ីរញ៉ៃបែប នេះអញ្ចឹងហ្ន៎?

ខេវិនលាន់មាត់តែម្នាក់ឯង ។ បន្តិចមក យាយចាស់ក៏ត្រលប់មកដល់ វិញ នៅដៃមានកាន់ស្រោមសំបុត្រពណ៌ប្រផេះមកជាមួយផង :

- នេះជាសំបុត្រពីជីដូនរបស់ចៅ ដែលអាស័យដ្ឋានរបស់គាត់ដូចការនៅ ខ្នងសំបុត្រនេះស្រាប់ ។

គ្រាន់តែឈ្ងោកអានអាសយដ្ឋានរបស់ជីដូននាយខេវិនហើយ នាយ ម៉ូតូឌុបលាន់មាត់ឡើង :

- ព្រះអើយ! ផ្ទះនេះនៅឯភូមិព្រះនេត្រព្រះឯណោះ? ឆ្ងាយណាស់! បើជិះម៉ូតូដូចរបស់ខ្ញុំនេះ ប្រហែលពីបីម៉ោងទើបដល់ ។ ពេលនេះម៉ោងជាង ៣រសៀលហើយ ទំរាំដល់ព្រលប់ថ្ងៃលិចល្ងម ។ ខ្ញុំមិនទៅទេ បើល្បងចង់ ទៅពិតមែន ចាំស្អែកព្រឹក ចាំចេញដំណើរទៅ បានទេ?

តែខេវិនកំពុងមានចិត្តអន្ទះសាណាស់មិនអាចនៅរង់ចាំបានទេ ។ នាយ យើង ក៏ហុចប្រាក់២០ដុល្លារទៅនាយហើយសួរថា :

- តើ២០ដុល្លារនេះអាចអោយអាប្អូនឯងដូរចិត្តទេហ៎?

ឃើញ២០ដុល្លារភ្លាម នាយម៉ូតូឌុបលេបទឹកមាត់ក្អឹកតែម្តង :

- អញ្ចឹង ទៅក៏ទៅដែរ ។

CHANBOKEO.COM

ខេវិនក៏ហក់ពីក្រោយផ្លាញចេញដំណើរភ្លាម ។ តាមផ្លូវខេវិនសង្កេត ឃើញជីវភាពអ្នកស្រុកកាន់តែប្លែកភ្នែកឡើងៗ ខុសពីជីវិតនៅឯភ្នំពេញ ។ ពេលនេះខេវិនមិនដឹងថាម៉ូតូដឹកនាយពីណាទៅណាទេ គ្រាន់តែដឹងថា ជាង ពីរម៉ោងក្រោយមក គេក៏បានមកដល់ជើងភ្នំព្រះនេត្រព្រះ ។ ខេវិនចុះពី ម៉ូតូ សំលឹងមើលជុំវិញខ្លួន ហើយបែរសួរនាយម៉ូតូឌុបថា :

- ហេតុអ្វី នៅម្ដុំនេះ គ្មានផ្ទះអ្នកស្រុកអញ្ចឹង ឃើញតែដើមឈើត្រឈឹង ត្រឈៃទៅវិញ?

- មិនដឹងដែរល្បង! ខ្ញុំក៏មកដល់ទីនេះជាលើកដំបូងដែរ អញ្ចឹង យើងបក ទៅក្រោយរកភូមិអ្នកស្រុក សួរគេសិនទៅ យ៉ាងម៉េចដែរ?

ខេវិនកំពុងតែទាល់ច្រកដូចគ្នា កាលបើឮដូច្នោះ នាយយើងក៏ងក់ ក្បាលភ្លាមតែម្ដង ។ រំពេចនោះ ស្រាប់តែមានស្រីចាស់ម្នាក់ដើរមកដល់ ។

នាយម៉ូតូឌុបងាកសួរ គាត់ភ្លាម :

- អត់ទោសមីង! តើផ្ទះយាយភួងចូលតាមផ្លូវណាដែរ?

ស្រាប់តែមីងម្នាក់នោះធ្វើភ្នែកឡឹងឡង់ ហើយចង្អុលទៅម្ខាង រួច វាចាថា :

- ទៅតាមសញ្ញាព្រួញមួយនោះទៅដល់ហើយ... តែ...

- តែ... យ៉ាងម៉េចទៅមីង?

- ជិះម៉ូតូទៅមិនកើតទេ ទាល់តែថ្មើរជើង ព្រោះត្រូវឆ្លងទឹក ។

ថាហើយគាត់ក៏ទូលអុសចេញទៅ ។ នាយម៉ូតូឌុបក៏បែរមកខេវិន និយាយថា:

- អត់ទោសទៅចុះល្បង ខ្ញុំជូនបានតែត្រឹមហ្នឹងទេ ។

ពេលនោះថ្ងៃជ្រេណាស់ទៅហើយ ។ ខេវិនក៏តទូចថា :

- ប្អូនចតម៉ូតូចោលនៅទីនេះសិនហើយ ។ យើងចង់បានរូបឯងមករួម ដំណើរគ្រាន់នឹងបានជាគ្នា ត្បិតខ្ញុំនេះមិនស្គាល់ភូមិស្រុកគេទេ ។

- តែ... ខ្ញុំត្រូវទៅផ្ទះវិញហើយ មិនអាចជូនល្បងបានទេ ខ្លាចត្រលប់ ដល់ផ្ទះវិញ ពេលយប់អាធ្រាតជ្រុលនាំតែប្រពន្ធរករឿង ។

នាយម៉ូតូឌុបថាហើយក៏បរម៉ូតូត្រលប់វឹងទៅបាត់ រកតែខេវិននិយាយ អ្វីទៀតមិនទាន់ផង ។ ពេលនោះ ខេវិនក៏ឈរនៅតែម្នាក់ឯងក្បែរជើងភ្នំ ដែលគ្មានផ្ទះអ្វីម៉ាក់មួយសោះក្រៅពីដើមឈើខ្ពស់ៗតែប៉ុណ្ណោះ ។ ក្រៅពី នោះមានផ្លូវឡើងទៅខាងលើភ្នំ តែមិនដឹងថានៅលើភ្នំមានអ្វីទេ ។ ម្យ៉ាង ទៀត ព្រះអាទិត្យក៏រៀបពន្លិចខ្លួនពួនកាយក្រោយភ្នំព្រះសុមេរុ សន្សឹមៗ ទៅហើយ ។ ខេវិនមិនអាចនៅដំអក់យូរបានឡើយ គឺត្រូវរូតរះស្រូតដំណើរ ទាន់នៅភ្លឺ ។ នាយក៏លើកសំពៀតខ្សែវដាក់លើស្មាហើយដើរទៅមុខទៀត យ៉ាងលឿនតាមទិសសញ្ញាព្រួញដោតចង្អុលតាមផ្លូវ ។ ដំបូង កំលោះយើង ដើរកាត់ព្រៃដែលមានដើមឈើធំៗ រួចហើយក៏ដើរកាត់ចំការឫស្សី ដែល មានឫស្សីដុះយ៉ាងក្រាស់ ផុតបន្តិចមកក៏មកដល់មាត់ប្រឡាយទឹក តែគ្មាន ស្ពានឆ្លងទៅមកសោះ ។ ខេវិនត្រូវបង្ខំចិត្តដោះស្បែកជើងមូរជើង ខោដើរ លុយទៅមុខទៀត ។ បន្តិចក្រោយមក

CHANBOKEO.COM

នាយយើងក៏មកដល់វា ស្រែល្វឹង ល្វើយមួយ ។ លុះដើរតាមភ្លឺឆ្លងប្រហែលបីបួនស្រែ មាណពក៏បានមកដល់ដីទួលធំមួយទំនងជាលានបញ្ជាន់ស្រូវ ដែលមានដើមអំពិលនិងដើមត្នោត ដុះបួនប្រាំដើម មានពំនូកចំបើង និងរទេះគោចាស់ដាក់ចោលក្រោមដើម អំពិល ។ នៅក្បែរនោះ មានខ្ទមកំពុកមួយសង់ផ្ទាល់ដីដំបូលប្រក់ស្លឹក ត្នោត ។ នាយក៏បែរមើលជុំវិញខ្លួន រកមើលសញ្ញាព្រួញបំរុងធ្វើដំណើរ តទៅទៀតតែមិនឃើញអ្វីសោះ ។ ពេលនោះ គេជ្រួញចិញ្ចើមនឹកអន្ទះសា ពិភាល់ក្នុងចិត្តយ៉ាងចំលែក ព្រមទាំងរអ៊ូរទាំ២ក្នុងមាត់ថា :

- ហេតុអ្វីទៅហ្ន៎ បានជាយើងធ្លាក់ខ្លួនមកដល់ថ្នាក់នេះ? យើងក៏មិនជឿ ដែរថាកូនខ្ទមកញ្ចាស់នេះជាកន្លែងដែល.... ទេ! ហ៊ឹ...!!

ខេវិនដើរពីរបីជុំទួលហើយ នៅតែរកមិនឃើញសញ្ញាព្រួញជាតម្រុយ ឱ្យនាយចេញទៅណាទៀតសោះ ។ ម្តងនេះ នាយរិតតែខកចិត្តមែនទែន :

- ឬក៏... ខ្ទមកញ្ចាស់នេះជាចំណុចមរតកដែលយើងត្រូវទទួលនោះទេដឹង?

ស្រាប់តែខេវិនអស់កំលាំងចិត្តស្រលេតតែម្តង ។ នាយដាក់ខ្លួនប៉ុក លើ ដង្គត់ឈើក្រោមដើមអំពិល ចង់យំបន្តិច ចង់ស្រែកបន្តិច រួចយកដៃឈ្លី ថ្ងាស ត្អូញត្អែថា :

- ពុទ្ធោអើយ... នាយខេវិន!! នេះឯងកំពុងតែយល់សប្តិ ឬក៏កំពុងប្រទះ ការពិតជាក់ស្តែង?

ពេលនោះថ្ងៃក៏លិចល្ហម ស្រាប់តែខេវិនកូរពោះគ្រូក ។ មែនហើយ! អាល័យតែខ្វល់តាមរកផ្ទះជីដូន នាយក៏ភ្លេចរឿងបាយទឹកអោយឈឹង ។ ភ្លាមនោះ មាណពនឹកភ្ញាករកបកក្រោយ ស្រាប់តែភ្លេចផ្លូវដែលខ្លួនដើរចូល មកមិនដឹងថា ត្រូវដើរតាមភ្លឺស្រែណាមួយដើម្បីត្រលប់ទៅផ្លូវដើមវិញ បើ ជុំវិញដីទួលនោះសុទ្ធតែភ្លឺស្រែខ្វែងខ្វាត់វីរមរវាមយ៉ាងហ្នឹង ។ មេឃកាន់តែ ចាប់ងងិតបន្តិចម្តង២ ពោះក៏កាន់តែកូរគ្រូក២មិនឈប់ឈរសោះ ។ ខេវិនក៏ ស្រវាទាញយកនំសូកូឡា ដែលនៅសល់ពីលើយន្តហោះមកខាំទំពារកំដរ គំលាន ។ ពេលនោះ នាយយើងកាន់តែមានអារម្មណ៍ ខកចិត្តឡើង២ នឹក សោកស្តាយអាណិតខ្លួនឯងបំផុត ។

ដោយធ្វើដំណើរឆ្ងាយពីរបីថ្ងៃមកហើយ ព្រោះតែចិត្តអន្ទះសាចង់ដឹង ពីមរតកជីដូន ខេវិនមិនបានធ្មេច តាំងពីចេញដំណើរមកពីអាមេរិកម្ល៉េះ ។ ពេលនេះ មាណពរបស់យើងអស់កំលាំងហេវតែម្តង ទាំងផ្លូវកាយ និងផ្លូវ ចិត្ត ។ លុះអង្គុយផ្អែកនឹងដើមអំពិល សំងំធ្មេចយកកំលាំង មិនសូវស្រួល មាណពក៏ងើបដើរទៅក្នុងខ្ទម ហើយប្រាសខ្លួនលើរនាបឬស្សីកំពុកមួយ ។ ខ្យល់បក់រហើយរសៀក២ចូលមកតាមចន្លោះជញ្ជាំងរហែក បានបបោស កាយបុរសយើងយ៉ាងថ្នម២បន្ថើរ២ ធ្វើឱ្យខេវិនហាក់ដូចជាមានអារម្មណ៍ ក្សេមក្សាន្តធូរស្រាលក្នុងចិត្តជាងមុន ។ មួយស្របក់ក្រោយមក នាយក៏ លង់លក់ក្នុងដំណេកទៅ...

**ថ្ងៃ១៩ មករា ២០០៦**

មាន់រងាវលាន់ខ្ទើយ២លាន់ឮពីនាយមកល្វើយ៍... ថ្ងៃក៏រះព្រឿង២ ង

CHANBOKEO.COM

ទិសខាងកើតមកបំភ្លឺសកលលោកសាជាថ្មីម្តងទៀត ។ ខេវិនប្រែខ្លួនបើក ភ្នែកឡើងច្រលំស្មានថាខ្លួននៅអាមេរិក ក៏បំរះយ៉ាងខ្លាំងហើយស្ទុះយកដៃ ច្រត់ងើបយ៉ាងរហ័ស ។ ចៃដន្យ រនាបឫស្សីទ្រង់ពុក១បន្តិច មិនអាចទ្រាំទ្រ នឹងទំងន់ដៃរបស់នាយយើងបាន ក៏បាក់ប្រេស ធ្វើអោយខេវិនស្ទុះដៃចុះទៅ ដួលផ្កាប់មុខធ្លាក់ទាំងជំហរ ។ មាណពខឹងណាស់ក៏ស្ទុះងើបម្តងទៀត តែ រាងដូចជាប្រយត្ន័ប្រយែងជាងមុន ។ ភ្លាមនោះ នាយយើងនឹកភ្ញាកដល់ សំពៀតខ្សែរដាក់តវ៉ាន់របស់ខ្លួន ក៏ងាករកមើល ស្រាប់តែបាត់មិនឃើញ សោះ ។

ខេវិនស្ទុះតាំង១ទៅមើលនៅក្រោមដើមអំពិលក៏មិនឃើញទៀត ។ កំលោះយើងជ្រួលច្របល់ក្នុងចិត្តរិតតែខ្លាំងហើយ ព្រោះអីទាំងលុយកាក់ លិខិតឆ្លងដែន និងរបស់របរផ្ទាល់ខ្លួន ដែលដាក់នៅក្នុងសំពៀតបានបាត់ អស់រលីងគ្មានសល់ ។ មាណពស្ទុះស្ទាររត់ទៅរត់មកតែម្នាក់ឯង ដូចមនុស្ស ឆ្កួត យំមិនចេញ និយាយមិនរួច បានត្រឹមតែអន្ទះសាកន្ទះរា ក្នុងចិត្ត មិន ដឹងជានឹកចង់និយាយថាម៉េច ធ្វើយ៉ាងម៉េចទៀត បើខ្លួនកំពុងស្ថិតនៅ ក្នុងពិភពដ៏ចំលែកមួយ ។ មួយស្របក់ក្រោយមក នាយក៏ដាក់ខ្លួនអង្គុយ លើកាំរទេះកំបាក់កំពុកមួយដែលនៅផ្តេកចោលនៅខាងក្រោយខ្ទម យក ដៃច្រត់ចង្កាអង្គុយគិតសាជាថ្មីម្តងទៀតថាត្រូវដោះស្រាយយ៉ាងណា ។ គ្រា នោះ នាយដាក់ភ្នែកក្រលេកឃើញក្មេង១ឃ្វាលគោបីបួននាក់ កំពុងបណ្តើរ ហ្វូងគោមកដល់វាលស្រែក្បែរ១នោះ ។ ខេវិនក៏ស្ទុះងើប បំរុងសួរពួកគេ ទៅហើយ ស្រាប់តែក្មេង១ទាំងនោះស្រដីមករកនាយមុនថា:

- ពូ! មកពីណា? មុខចំលែកម្ល៉េះ? ជាខ្មែរ  ឬជាសាសន៏អី?  ឬក៏ពូជាជន បរទេសដើរលេងវង្វេងផ្លូវ?

ខេវិនឮហើយងក់ក្បាល :

- មែនហើយ! ពូវង្វេងផ្លូវមិនដឹងថាត្រលប់ទៅវិញតាមណាទេ ។

- ហើយចុះផ្ទះពូនៅឯណាដែរ ចាំខ្ញុំទៅប្រាប់ពុកអោយបររទេះ នាំពូទៅ ផ្ទះវិញ?

- គឺ... នៅឯសហរដ្ឋឯណោះ ។

- ហើយសហរដ្ឋហ្នឹងនៅដល់ណាទៅ? តាមមើល ប្រហែលជាឆ្ងាយហើយ មិនដឹងថារទេះគោរបស់ពុកខ្ញុំអាចបរទៅដល់ដែរឬក៏អត់ទេហ្ន៎...?

ភ្លាមនោះ ក្មេងម្នាក់ទៀតសួរនាយថា :

- យប់មិញពូសំរាន្តនៅក្នុងខ្ទមនោះមែនទេ?

- មែនហើយ ហើយចុះប្អូនរាល់គ្នាស្គាល់ម្ចាស់ខ្ទមទេ?

ទាំងអស់គ្នាគ្រវីក្បាល ហើយឆ្លើយស្រុះគ្នាថា :

- មិនស្គាល់ទេ ឮតែចាស់១ធ្លាប់ហៅថា ខ្ទមយាយភួង

ពេលនេះ ខេវិនកាន់តែខកចិត្តខ្លាំងថែមទៀតហើយ កាលបើឮក្មេង១ បញ្ជាក់យ៉ាងច្បាស់ដូច្នេះទៅហើយ ។ នាយយកដៃទះថ្ងាសគិតក្នុងចិត្តថា :

CHANBOKEO.COM

- មិនគួរណាសំរេចចិត្តលាអាមេរិក ដើម្បីមរតកកំពុកបែបនេះទេ! ឥលូវ ផុងខ្លួនយ៉ាងជ្រៅ តើយើងត្រូវដោះស្រាយយ៉ាងម៉េច ដើម្បីអោយទៅដល់ សហរដ្ឋវិញទៅ?

ភ្លាមនោះក្មេងៗនាំគ្នាដកកមើលទៅក្នុងខ្ទម ហើយក៏សួរខេវិនថា :

- ពូសំរាន្តនៅក្នុងខ្ទមយប់មិញ មានត្រូវខ្មោចលងទេហ៍?

- អត់មានទេ ពូគេងលក់ស្រួលណាស់! យ៉ាងម៉េច? ទីនេះមានខ្មោចលង ផងហ្អែស?

- ពួកយើងមិនដឹងទេ តែពូចាស់ៗគាត់ហាមមិនអោយចូលយកអ្វីពីខ្ទម នោះទេត្បិតវិញ្ញាណដូនតានៅចាំយាមរាល់យប់រាល់ថ្ងៃ។ តែគួរឱ្យឆ្ងល់ ដែរ ប្រសិនបើវិញ្ញាណដូនតានៅយាមទីនេះមែន ម៉េចបានជាគាត់មិនចេញ មកលងបងកាលពីយប់មិញអញ្ចឹង?

ពូដូច្នោះខេវិនក៏សើចខឹកៗឡើងហើយឆ្លើយតបវិញថា :

- ព្រោះពូមិនចង់បានទ្រព្យរបស់របរទាំងនេះ បានជាគាត់មិនចេញមុខមក លងពូនោះអី ។

- ពូមិនចង់បានអ្វីរបស់គាត់ពិតមែន... តែពួកខ្ញុំចង់ព្រោះពួកខ្ញុំក្រីក្រណាស់ ឃើញឥវ៉ាន់ទុកទំនេរចោល ចេះតែចង់បានយកមកប្រើ គ្រាន់តែមិនហ៊ាន ចូលយក ។

- ពួកក្មួយពិតជាចង់បានមែនហ្អែស?

- បាទ ! (ក្មេងទាំងនោះឆ្លើយព្រមគ្នាឡើង)

- អញ្ចឹងចាំពូចូលយកមកអោយ បើវិញ្ញាណដូនតារករឿង ទុកអោយគាត់ មករករឿងនឹងពូចុះ ។

ថាហើយ ខេវិនក៏ស្ទុះចូលទៅក្នុងខ្ទមរកមើលឥវ៉ាន់ តែមិនឃើញ មានអ្វីល្អៗសំខាន់គួរសំលឹងអ្វីមួយសោះ ក្រៅពីខ្មើយកញ្ចាស់បួនប្រាំ មុង កណ្តាច ឆ្នាំងដី ពាងកំបែក និងកញ្ជ្រែងល្អីកញ្ជើជាលកំពុកៗ ដែលត្រូវ ពីងពាងរុំពទ្ធ័ជុំជិតតែប៉ុណ្ណោះ ។ ភ្លាមនោះ នាយក៏ចេញមកក្រៅវិញ ហើយ ស្រែកប្រាប់ក្មេងទាំងនោះថា :

- នៅទីនេះ មានតែរបស់កញ្ចាស់ៗ កំពុកៗ យកប្រើមិនកើតទេ ។

ស្រាប់តែក្មេងៗឆ្លើយវិញ :

- ប៉ុន្តែ នៅផ្ទះខ្ញុំក្រណាស់ រកតែអាម៉ាកកំពុកបែបនេះប្រើមិនបានផង

- អូហ៍ ពិតមែនហ្អែស? (ខេវិនលាន់មាត់)

ខេវិនមិននឹកស្មានទេ ថាក្មេងទាំងនោះក្រីក្រដល់ម្លឹង ។ រំពេចនោះ នាយក៏ស្ទុះទៅប្រមូលឥវ៉ាន់ទាំងឡាយ ដែលនាយឃើញមាននៅក្នុងខ្ទម កញ្ចាស់នោះ មកចែកឱ្យក្មេងអស់គ្មានសល់ ។ ពួកគេសើចសប្បាយរីករាយ ណាស់កាលបើបានទទួលឥវ៉ាន់របស់របរទាំងនោះ ។ មួយស្របក់ក្រោយ មក ពួកក្មេងៗឃ្វាលគោក៏ទៅបាត់រលីង ។ ម្តងនេះ នាយក៏ត្រូវនៅអង្គុយ ម្នាក់ឯងត្រមង់ត្រមោចទៀតហើយ ។ ស្រាប់តែពោះនាយកូរគ្រូកៗសាជា ថ្មី

CHANBOKEO . COM

ទើបនឹកឃើញថាខ្លួនកំពុងតែហោះបាយដល់កំណត់ហើយ ។ នាយយើង យកដៃឈ្លីថ្ងាសទះតិចៗ ត្បិតមិនដឹងថាត្រូវជួយខ្លួនឯងយ៉ាងណាឡើយ ។ ពេលនោះ នាយក៏ប្រាសខ្លួនលើគ្រែនាបឬស្សីកំពុកវិញ យកដៃគងថ្ងាស គិតសាជាថ្មី ស្រាប់តែដាក់ភ្នែកទៅចំរូបថតដូនចាស់ម្នាក់ដែលមានទឹកមុខ ញញឹមពព្រាយដាក់ព្យួរនៅពីលើមាត់ទ្វារខ្ទម ។ មាណពឧទានថា :

- ហ្អឹងឬ យាយភួង ជីដូនរបស់យើង?

ខេរិនក៏ស្ទុះទៅទាញរូបថតនោះចេញពីជញ្ជាំងយកមកមើល ស្រាប់ តែជំពប់ជើដួលទាំងជំហរ ។ រូបថតក៏របូតពីដៃជ្រុះទៅដីព្រុស ។ កញ្ចក់រូប ថតបែកខ្ចាយព្រោង ឯសន្លឹករូបថតក៏ខ្ទាតប៉ើងឡើង ហើរចេញតាមទ្វារខ្ទមទៅធ្លាក់នៅធ្លាមុខផ្ទះ ។ រំពេចនោះ ខេរិនបែរភ្នែកទៅតាមរូបថតក៏ ចាប់ភ្លឹកថា នៅលើខ្នងរូបថតមានស្នាមចារដោយអក្សរល្អិតៗស្មេរ ទំនង ចង់ពន្យល់អ្វីច្រើនហើយ ។ នាយក៏ស្ទុះទៅ រើសរូបថតយកមកវិញយកមក អាន តែឥតប្រយោជន៍ទេ ត្បិតចំណារនោះបានសរសេរជាភាសាខ្មែរ ។ មាណពឈរកាន់រូបថតធ្វើធ្មឹង ខកចិត្តតែម្នាក់ឯង ។ ភ្លាមនោះ ស្រាប់តែ

មានសំលេងមនុស្សស្រីម្នាក់ពោលពីក្រោយខ្នងនាយមកថា :

- អ្នកមកពីណា ទើបហ៊ានចូលបំផ្លាញរបស់របរនៅទីនេះ?

ខេរិនងាកផាំង ឃើញស្រីក្មេងម្នាក់ស្លៀកពាក់ស្រមែកស្រមក យួរ ចានស្រាក់មកដល់ ។ នាងទទួរក្រមា បាំងមុខ បាំងសោភ័ណអស់ ហើយ ពាក់អាវដៃបំពង់ពណ៌ប្រផេះ ដើរចូលក្បែរខ្ទម ថែមទាំងស្រដីទៀតថា :

- អ្នកស្រុកម្ដុំនេះ គេគោរពម្ចាស់ខ្ទមនេះណាស់ សូម្បីតែគាត់បានចែកឋាន ទៅហើយក្ដី ក៏អ្នកស្រុកនៅតែផ្ដល់ក្ដីគោរពដល់គាត់ដដែល ។ ម្យ៉ាងទៀត គេរាល់គ្នាតែងនាំគ្នាយកបាយសម្លមកសែនព្រេនជូនគាត់ជាអលជ្ជី ត្បិត កូនចៅគាត់ព្រាត់ទៅឆ្ងាយអស់ គ្មាននរណាគេធ្វើបុណ្យអោយទេ ។ ខុស ប្លែកអ្វីតែអ្នក... មិនត្រឹមតែមិនថ្វាយសំណែនទេ ថែមទាំងបំផ្លាញរបស់ របរអ្វីៗដែលជាកេរ្ដិ៍របស់គាត់ថែមទៀតផង ។ អ្នកពិតជាយ៉ាប់មែន!!

ឃើញវត្តមាននាងភ្លាម ស្រាប់តែខេរិនត្រេកអរភើតពោះតែម្ដង ។ ប៉ុន្តែ ដោយអាល័យតែភ្ញាក់ផ្អើលនឹងវត្តមានរបស់ធិតាពេក ខេរិនឈរធ្មើ ភាំងមិនបានឆ្លើយតបទៅនាងវិញទេ គ្រាន់តែឈរសំលឹងមើលមុខនាង ដោយរំភើបក្នុងចិត្តតែប៉ុណ្ណោះ ។ មែនហើយ!.... នារីនោះពិតជានិយាយ ត្រូវណាស់ ។ ខេរិនរកពាក្យអ្វីតបមិនបានឡើយ ។ ភ្លាមនោះមាណវីក៏ដោះស្រាក់បាយតំរៀបនៅមុខខ្ទម ហើយអុជធូបក្រាបសំពះ ។ ខេរិនក៏លើក រូបថតដូនចាស់យកមកមើលម្ដងទៀត រួចក៏សំលឹងទៅស្រីក្មេងមួយរូប នោះ ស្រាប់តែនាងក្រលេកមកកទាន់ ក៏លាន់មាត់សើចខឹកៗឡើង :

- អ្នកកំពុងផ្ទៀងថា ខ្ញុំជាខ្មោចកំពុងប្រែកាឡាមកលងអ្នក ឬក៏អ្នកគិតថា ខ្ញុំនេះជាកូនចៅសាច់ញាតិរបស់ម្ចាស់ខ្ទមនេះ?

ខេរិនភ្ញាក់ព្រើត លាន់មាត់តតាក់តតុបថា :

- គឺ... គឺ...

CHANDBOKEO.COM

- សង្ស័យទាំងពីរយ៉ាងមែនទេហ៎? (នាងសួរផ្ទាន់អ្នកកំលោះយើង)

- គឺ... គឺ...

ខេរិននៅតែសំលឹងមុខនាងហើយឆ្លើយមិនរួចដដែល ។ ហេតុអ្វីទៅហ្ន៎ បានជា នាយយើងត្រូវប្រាបជាន់ទាំងថ្ងៃ តាំងអណ្តាត និយាយមិនរួចបែប នេះ? ស្រីស្រុកស្រែម្នាក់នោះ ក៏លាន់សំណើចខឹកៗឡើងម្តងទៀត :

- កុំសង្ស័យអី! គឺមិនមែនទាំងពីរយ៉ាងហ្នឹង ។ ខ្ញុំគ្រាន់តែជាអ្នកស្រុក ធម្មតាៗនៅទីនេះ កើតទីនេះ រស់នៅទីនេះ ស្គាល់យាយភួងច្បាស់ជាងគេ ព្រោះខ្ញុំធ្លាប់ជាអ្នករែកទឹកឱ្យគាត់ងូតរាល់ថ្ងៃ ។ ការពិត គួរអោយអាណិត យាយភួងណាស់ដែលចាស់ជរាទៅ គ្មានកូនចៅនៅក្បែរថែរក្សាអ្វីម្នាក់ សោះ ។ ឮដំណឹងថា មានសាច់ញាតិនៅរស់ដែរ តែមិនដែលឃើញនរណា ម្នាក់អើតមុខមកមើលគាត់ទេ ។ អូហ៎មែនហើយ! ឥលូវនេះ អ្នកជាមនុស្ស ចំលែក ដែលអើតមុខមកដល់ទីនេះជាលើកដំបូង... តើអ្នកត្រូវជាអ្វីនឹង យាយភួងដែរ?

ត្រូវមាណវីសួរចំចំណុចខ្សោយរបស់ខេរិន រកតែនាយនឹកឆ្លើយថា យ៉ាងណាក៏មិនសម ។ នាយយើងឈ្ងោកមុខសំលឹងរូបថត ដែលកំពុងកាន់ នៅក្នុងដៃហើយ ហើយបែរសំលឹងមាណវីម្តងទៀត ទើបសួរនារីយើង ត្រលប់ទៅវិញថា :

- នាង... ចេះអានអក្សរខ្មែរទេ?

- ជាជាតិខ្មែរទៅហើយរឿងអីមិនចេះអានភាសាជាតិខ្លួនឯងនោះ ពុទ្ធោ!

ធិតាឆ្លើយតបវិញអោយព្រងើយ ។ នាងសំលឹងទៅរូបថតដែលខេរិន កំពុងកាន់នោះ ហើយក៏ឧទានឡើង :

- ចង់អោយខ្ញុំអានអក្សរដែលចារនៅពីក្រោយរូបនេះមែនទេហ៎?

ខេរិនងក់ក្បាល ។ ស្រាប់តែនាងសួរឡើង :

- តើអ្នកត្រូវជាអ្វីនឹងគាត់ បានជាហ៊ានបោករូបថតគាត់ចោលខ្ចាត់ខ្ចាយ យ៉ាងនេះ?

- គឺ... គឺ... អោយសូមទោសផងដែលមិនបានប្រយត្ន័...

- ចេះដឹងខ្លួនខុសអញ្ចឹង ក៏គង់នៅគ្រាន់បើដែរ អាចនិយាយស្តាប់បាន ប៉ុន្តែ អ្នកត្រូវបោសសំអាតកំទេចកវ៉ាន់ ដែលអ្នកធ្វើបែកបាក់ទីនេះឱ្យអស់សិន ទើបខ្ញុំអានអោយស្តាប់ ។

ខេរិនដឹងកំហុសខ្លួនក៏ស្ទុះទៅធ្វើតាមភ្លាម ។ មាណពសំអាតកំទេច អំបែងកញ្ចក់បណ្តើរ លួចគយគន់មើលនារីស្រុកស្រែមួយរូបនោះបណ្តើរ ក្នុងចិត្តដូចជារំភើបញាប់ញ័រយ៉ាងណាមិនដឹង ដែលនាយបានជួបមុខសន្ទនា ជាមួយមាណវីមួយរូបនោះ ។ មាណពហាក់ដូចជាចាប់អារម្មណ៍នឹងឆរីអ្វី ម្លេះទេ ថែមទាំងនឹកក្នុងចិត្តថា :

- អរគុណណាស់ ទេពធិតាដែលចុះមកសង្គ្រោះរូបខ្ញុំនៅពេលនេះ!!

ខេរិនលួចញញឹមតែម្នាក់ឯង ។

ម្ហូបសំណែនបានជះក្លិនភាយៗកាត់ច្រមុះបុរសយើង ធ្វើឱ្យនាយលួច លេបទឹកមាត់ជាញយដងតែមិនហ៊ានមាត់ ។ រីឯនាងក្រមុំយើងវិញក៏លួច សង្កេតមើលមាណពយើងដូចគ្នា ។ កាលបើប្រទះកែវភ្នែករបស់នាយយើង ពីរបីដង ធិតាហាក់ដូចជាយល់ចិត្តក៏ពោលឡើង :

CHANBOKEO.COM

- អ្នកហេវបាយមែនទេហ៎? ផ្ទះខ្ញុំនៅជិតនេះទេ ត្រឹមបាយមួយពេល យើងមិនខ្សត់ មិនកំណាញ់នឹងចែកអ្នកទេ ។ សូមអ្នកដើរតាមខ្ញុំមក ។

កំពុងហេវសឹងស្លាប់ កាលបើឮនាងស្រដីបើកផ្លូវដូច្នោះ បុរសយើងក៏ មិនស៊ូទ្រាំនៅធ្វើមុខស្ដើងតទៅទៀតដែរ ។ នាយក៏ស្ទុះងើបយ៉ាងរហ័សដើរ តាមក្រោយនាងភ្លាមដោយឥតប្រកែកមួយម៉ាត់ឡើយ ហើយថែមទាំងសប្បាយចិត្តនឹងដើរតាមនាងទៅដែរ ។ តាមផ្លូវ មាណពលួចសង្កេតរូបរាងរបស់នាងពីក្រោយ ហើយនឹកក្នុងចិត្តថា :

- នាងគឺ... ជាទេពធិតាក្នុងសុបិនរបស់ខ្ញុំ ពិតមែនទេ?

ស្រីក្មេងបាននាំខេវិនដើរតាមភ្លឺស្រែកាច់កុងចុះឡើងៗ ។ ថ្វីបើនាងមាន មាឌតូចស្ដើងល្វតល្វៃ តែនាងដើររហ័សរហួនណាស់ រកតែខេវិនដើរតាម ស្ទើរមិនទាន់ ។ មួយសន្ទុះក្រោយមក ខេវិនក៏បានមកដល់ផ្ទះតូចមួយ ប្រក់ ស្លឹកត្នោតសង់ផ្ទាល់ដី ។ មាណពមិនដែលឃើញផ្ទះបែបនេះពីមុនមកទេ សូម្បីតែខ្លួនជាជាតិខ្មែរដែរក៏ដោយ ក៏មិនដែលដឹងថាខ្មែររស់នៅរបៀបណាឡើយ ។ នេះជាការពិសោធន៍មួយដ៏ពិតៗរបស់កំលោះយើងជាលើក ដំបូងបង្អស់ ។ ភ្លាមនោះ ខេវិនយកដៃកេះជញ្ជាំងផ្ទះទាំងនឹកឆ្ងល់ក្នុងចិត្ត ត្បិតឃើញផ្ទាំងដីពណ៌ប្រផេះក្រម៉ៗ មានព្រុយរសាត់ចេញមក ទំនងដូចជា កំទេចស្មៅងាប់ ហើយក៏សួរថា :

- តើជញ្ជាំងផ្ទះនេះធ្វើពីអ្វីទៅ ដូចជាប្លែកណាស់...?

នាងក្រមុំយើងសើចខឹកៗហើយឆ្លើយថា :

- សង្ស័យតែអ្នកទើបតែមកពីឋានផ្សេងហើយ បានជាមិនដឹងថា ជញ្ជាំង ផ្ទះអ្នកស្រែធ្វើអំពីដីអិដ្ឋបូកអាចម៍គោលាយកំទេចចំបើងដូច្នេះ ។

- អូហ៎... មែនហ្អែស? (ខេវិនលាន់មាត់ដោយការភ្ញាក់ផ្អើល) ហើយចុះ... អាចនៅប្រើជាប់បានយូរដែរទេ?

- យូរឆ្នាំដែរ ទើបត្រូវជួសជុលធ្វើសាថ្មី ។ ជាអ្នកក្រគ្មានដើមទុន គេសង់ ផ្ទះរបៀបនេះឯង សសរឫស្សី ដំបូលស្លឹកត្នោត ជញ្ជាំងដីអិដ្ឋ គឺអ្វីៗសុទ្ធ តែមិនត្រូវការទុនធំៗមកសាងសង់ទេ តែយើងអាចមានជំរកជ្រកនៅបាន ដោយមានសេចក្ដីសុខបំផុត ។

ខេវិនយកដៃស្ទាបជញ្ជាំងហើយនឹកសង្វេគតែម្នាក់ឯង :

- យើងនៅដេកពូកទន់ៗឯអាមេរិក សុខៗ ហេតុអ្វីក៏ជីវិតយើងប្រែ ក្រលាប់ចក្រមកប្រទះជីវិតបែបនេះទៅវិញ? ហើយយប់នេះ..យប់ស្អែក.. និងយប់តទៅទៀត... តើដំណើរជីវិតរបស់យើងនឹងក្លាយជាយ៉ាងណា?

កំពុងតែគិតស្លុងអារម្មណ៍ ស្រាប់តែមានសំលេងមួយមកពញ្ញាក់ :

- អានាងមកពីខាងណាដែរ មុខមាត់ដូចជាប្លែកណាស់ សមតែជា អនិកជនមកពីបរទេស...

ខេវិនបែរផាំង ឃើញស្ត្រីចំណាស់មួយរូបដើរចូលមកដល់ ។ ស្រាប់តែស្រីក្មេងមួយរូបនោះពោលតបទៅគាត់ថា :

- គាត់ច្បាស់ជាអនិកជនណាស់ទៅហើយណាំម៉ែ! មើលតែសាច់ឈាមនិង

CHANBOKEO.COM

ការស្លៀកពាក់ទៅដឹងហើយ មិនដូចអ្នកស្រុកយើងដែលក្រខ្សត់ខ្វះព្រឹក ខ្វះល្ងាចនោះទេ។

នាងនិយាយផង ដួសបាយដាក់ចានហុចអោយនាយផង ថែមទាំង វាចាថា :

- នេះបាយ! អញ្ជើញពិសារទៅ! ថ្ងៃនេះមានតែត្រីកញ្ចុះងៀតអាំងទេ។ ចំណែកនេះជាស្ងោរផ្សិតចំបើងសាប១អត់ដាក់អំបិល សំរាប់ហុតពេលអួល បាយ។ នៅស្រុកស្រែមិនមានអ្វីសំបូរបែបដូចនៅទីក្រុងទេ។

- នេះជាបាយ? ហេតុអ្វីក៏ពណ៌ក្រហមដូច្នោះ? (ខេរិនសួរ)

- គឺដាំពីអង្ករស្រូវវារ... គឺស្រូវដែលគេដាំនៅវាលស្រែជំរៅ អង្ករវាពណ៌ ក្រហមដូច្នោះឯង។

ពេលនេះ ខេរិនឃ្លានណាស់។ ទោះបាយពណ៌ក្រហម នាយក៏ត្រូវតែ ស្រវាចុកឱ្យស្រន់គំលានដែរ។ ព្រះអើយ! បុរសប្រឹងលេបយ៉ាងពិបាក បំផុត ត្បិតបាយនោះរឹងចំលែកយ៉ាងណាមិនដឹង។ ចំណែកឯកូនត្រីកញ្ចុះ អាំងវិញក៏ប្រៃអើយសែនប្រៃ!! នាយអកបាយបណ្តើរ ហុតទឹកស្ងោរផ្សិត ចំបើងបណ្តើរ ប៉ុន្តែគួរអោយឆ្ងល់ណាស់ ទោះបីជាអាហារមើលទៅមិនគួរ អោយឆ្ងាញ់ទាល់តែសោះ តែនាយបរិភោគអស់ដល់ទៅបីចានឯណោះ គឺ អស់បាយពីឆ្នាំងគ្មានសល់អ្វីសំរាប់ម្ចាស់ផ្ទះអ្វីបន្តិចឡើយ។ ក្បែរនោះ ពីរ នាក់ម្តាយកូន ក៏អង្គុយសំលឹងមុខគ្នាទៅវិញទៅមកដោយចំលែកចិត្ត។ គ្រាន់តែទទួលទានបាយឆ្អែតមិនទាន់ នាយក៏លូកយករូបថតដូនចាស់ពី ហោប៉ៅ ហុចអោយទៅមាណវីភ្លាម :

- នាងជួយអានអក្សរនៅខ្នងសំបុត្រនេះបន្តិចមក៏?

- យី! មិនទាន់អរគុណថ្លៃបាយមួយពេលនេះផង ហ៊ានប្រើម្ចាស់ផ្ទះ ថែមទៀត? ថ្លើមធំមែន!

ខេរិនលេបទឹកមាត់ផ្សើមបំពង់កតែមិនហ៊ានតបវិញទេ។ រំពេចនោះ ស្រីចំណាស់ក៏វាចាឡើង:

- ចាន់អើយ! អានសំបុត្រអានអោយឆាប់ៗទៅ នឹងអាលជូនម៉ែទៅភូមិ ជប់ម៉ាភ្លែត។

- ចាំសម៉ែ!

ថាហើយស្រីចំណាស់ក៏ដើរចេញទៅក្រៅផ្ទះបាត់ទៅ។ នាងចាន់ឆ្លើយ ហើយក៏ទាញក្រមាចេញពីក្បាល ទំលាក់សក់ខ្មៅរលើបរលោងរំសាយចុះ មកលើស្មារបស់នាង។ ខេរិនក្រលេកឃើញនាងពីចំហៀងមុខភ្លាម ក៏បើក ភ្នែកធំៗ ហើយខ្សិបក្នុងមាត់តិចៗ តែម្នាក់ឯង ថា :

- ដូចណាស់... ដូចណាស់...!!

ស្រាប់តែខេរិនលួចញញឹមតែម្នាក់ឯង។ នាងចាន់ក៏ទទួលយករូបថត ពីដៃខេរិន ក៏ប្រទះកែវភ្នែករបស់នាយ ដែលសំលឹងមកនាងយ៉ាងភ្លឹថ្លា។ នាងភ្ញាក់ព្រើតបែរមុខគេចយ៉ាងរហ័ស រួចទាញយកក្រមាមកទទូរក្បាល វិញ ហើយឧទានថា :

- នែ៎ សំលឹងមើលអី? តិចឈប់អានអក្សរលើរូបថតអោយឥលូវហ្នឹង...!!

ខេរិនឮដូច្នោះក៏ទំលាក់ទឹកមុខ ឈប់ញញឹម ហើយនៅស្ងៀម។ ធិតា ក៏ចាប់យករូបថតពីមាណព អានដូចតទៅ :

- *មកដល់ឫទ្ធីរិន្ទ ចៅប្រុសតែមួយរបស់ជីដូន...*

CHANBOKEO.COM

ស្រាប់តែនាងងើបមុខឡើងសំលឹងមុខខេវិនរួចសួរថា :

-អ្នកឈ្មោះអ្វីដែរ?

- ខេវិន! (បុរសយើងតបវិញ)

- ដូច្នេះ អ្នកមិនមែនជាចៅប្រុសរបស់យាយភួងទេ ព្រោះឈ្មោះខុសគ្នា។ ហើយ... បើអ្នកជាអ្នកក្រៅ កុំចង់ដឹងរឿងក្នុងគ្រួសាររបស់គេអី...

- គឺ... ឫទ្ធិរិទ្ធជាឈ្មោះខ្មែររបស់ខ្ញុំ លុះខ្ញុំចូលសញ្ជាតិអាមេរិកាំង ក៏ដូរជា ខេវិនវិញ។

- អូហ៏ អញ្ចឹងទេហ៏... ដូច្នេះ ខ្ញុំអានអោយអ្នកតទៅទៀតចុះ។

គ្រានេះ ខេវិនលួចសំលឹងមុខធិតាស្រុកស្រែដោយឥតពព្រិច មិនដឹង ថាកំពុង ផ្ទៀងត្រចៀកស្តាប់នាង ឬកំពុងលួចគយគន់សំរស់របស់នាងទេ។ ថ្វីបើនាងមានមុខមាត់ធម្មតាៗ តាមរបៀបអ្នកជនបទ តែក៏ផ្ទៃមុខរបស់នាងមានលាក់នូវគំនួចសោភ័ណ ដ៏ស្រស់បំព្រងមួយ ដែលកំពុងអង្រួន បេះដូងខេវិនអោយរំភើបញាប់ញ័រតែម្នាក់ឯង។ ចាន់ក៏ចាប់អានបន្ត :

- *យាយនឹកចៅណាស់! ឮដំណឹងថា ចៅនៅអាមេរិកជាមួយមីងពៅដែល ជាកូនធមិរបស់យាយ តែយាយមិនដឹងថាហេតុអីចៅមិនដែលមករក យាយម្តងណាសោះ ឃើញតែនាងពៅនិងប្តីរបស់គេមកលេងម្តងម្កាល...*

មកដល់ត្រង់នេះ ខេវិននឹកដល់អតិតកាល ដែលមីងពៅធ្លាប់បបួល នាយមកលេងយាយនៅស្រុកខ្មែរ តែនាយមិនដែលនឹកខ្វល់សោះឡើយ ម្យ៉ាងដោយ មិនដឹងថាយាយដែលមីងពៅប្រាប់នោះជាជីដូនពិតមែន ឬក៏ គ្រាន់តែជាការឆ លលេងរបស់គាត់ដើម្បីកុហកនាយអោយមកស្រុកខ្មែរ។ នាយភិតភ័យក្រែងមីងពៅមានគំរោងការចាប់នាយ អោយរៀបការស្រី ខ្មែរ នៅស្រុកខ្មែរដែលនាយមិនដែលស្គាល់។ ម្យ៉ាងទៀតនាយក៏មិន ស្គាល់ស្រុកខ្មែរ មិនស្គាល់ញាតិសន្តានរបស់ខ្លួន ម្ល៉ោះហើយ ចំណងនៃ សេចក្តីស្រលាញ់ចំពោះញាតិសន្តានក៏គ្មានរូបអ្វីបន្តិចសោះនៅក្នុងបេះដូង របស់ខេវិន។ គេមិនខ្វល់ទេថា មីងពៅរំលឹកនាយយ៉ាងណា ត្បិតកាលនោះនាយបានលង់ក្នុងជីវិតឈោមរាវ ដ៏ភ្លើតភ្លើនយ៉ាងវង្វេងស្មារតីទៅហើយ។ ភ្លាមនោះចាន់លួចដៀងភ្នែកទៅមើលខេវិនដែលកំពុងមានទឹកមុខប្រែ ប្រួល រួចហើយក៏ដំអក់ឈប់មិនអានមួយភ្លែត ទើបអានបន្ត :

- *ឪពុកម្តាយចៅបានស្លាប់អស់កាលពីសម័យប៉ុលពត។ យាយបានរស់ នៅតែម្នាក់ឯងរហូតមករង់ចាំថ្ងៃណាដែលឯងបានត្រលប់មកស្រុកយើង រកយាយវិញ។ តែអនិច្ចា! យាយមិនអាចរង់ចាំ ដល់ថ្ងៃនោះបានឡើយ ត្បិតយាយកាន់តែជរាមួយថ្ងៃបន្តិចៗ...*

ឮមកដល់ត្រង់នេះ ខេវិនរលីងរលោងទឹកភ្នែក នឹកស្តាយក្រោយដែលខ្លួនមិនដែលគិតដល់ជីដូនម្តងណាសោះ ក្នុងឱកាសដែលគាត់តែងតែគិត ដល់នាយជានិច្ច។ ចាន់ក៏អានតទៅទៀត :

- *ណ្ហើយចុះ! បើនិស្ស័យមិនបានអោយយាយបានជួបនឹងចៅនៅមុនថ្ងៃ ដែលយាយអស់បុណ្យទៅ យាយសូមកប់បញ្ញើលិខិតមរតករបស់យាយ លាក់នៅក្នុងខ្នើយចាស់ៗទាំងបួនដែលយាយដេរទុកដោយខ្លួនឯង។ យាយ*

CHANBOKEO.COM

*បានយកខ្មើយទាំងនោះ ទៅទុកនៅខ្ទមចាំស្រែលើខ្នងទួល កណ្ដាលស្រែ*

*ដោយមាននាងចាន់និងម្ដាយជាអ្នកថែរក្សាខ្ទមជំនួសយាយបណ្ដោះអាសន្ន ទំរាំឯងអាចវិលត្រលប់មកទទួលមរតកទាំងនោះ ។*

*ស្រលាញ់ចៅបំផុត... យាយភួង...*

ខេរិនឈ្ងោកមុខនៅស្ងៀមស្ងាត់យ៉ាងយូរ មិនដឹងជានឹកគិតអ្វីខ្លះទេ ឃើញតែធ្វើមុខយ៉ាងស្រងូតក្រៃលែង ។ ស្រាប់តែមាណពលាន់មាត់ថា :

- ព្រះអើយ!! (ខេរិនលាន់មាត់ខ្លាំងៗ) ខ្ទេចអស់បាត់ទៅហើយ...!

ស្រាប់តែខេរិនលូកស្រវាចាប់ដៃនាងចាន់ អូសរត់ចេញទៅក្រៅផ្ទះ រឹងយ៉ាងរហ័ស ។ ចាន់ក៏ភ្ញាក់ព្រើត ស្រែកផង ទាញដៃនាយយើងបេះ ចេញផង :

- នែ៎ៗៗ លែងដៃខ្ញុំមើល៍ ហើយនាំខ្ញុំទៅ ណាហ្នឹង?
- គឺជូនខ្ញុំត្រលប់ទៅខ្ទមចាំស្រែនោះវិញជាប្រញាប់!!
- ទៅធ្វើអី? ខ្ទមវាមិនរត់ចោលអ្នកទៅណាទេ ដើរតាមសំរួលក៏បានដែរ មិនចាំបាច់ កាន់ដៃខ្ញុំទេ... នែ៎! លេងមើល៍! យី! បើមានគេឃើញ ខ្ញុំច្បាស់ជាវីវរហើយ...
- គឺនាងត្រូវជូនខ្ញុំត្រលប់ទៅរកក្មេងៗឃ្វាលគោមួយហ្វូងនោះ!!
- ហើយចុះធ្វើម៉េចខ្ញុំនឹងដឹងថាជាក្មេងនោះជាណាទៅ? ហេតុអ្វីចាំទៅរក ក្មេងទាំងហ្នឹងផង?
- គឺ... កាលពីព្រឹកមិញនេះ ខ្ញុំបានកកាយយកឥវ៉ាន់ទាំងឡាយ នៅក្នុងខ្ទម យាយ ចែកក្មេងទាំងនោះអស់បាត់ទៅហើយ...
- អស់ទាំងខ្មើយប្អូននោះទៀតដែរមែនទេហ៎?
- មែនហើយ!
- អុំញ! ស្រេចបាត់! អញ្ចឹងអ្នកទៅតាមរកក្មេងៗឯណាទៅ?
- គេមិនទាន់ទៅណាឆ្ងាយទេ ទើបតែជាងពីរម៉ោងប៉ុណ្ណោះ ម៉ោះ! ឆាប់ ទៅជួយខ្ញុំរកក្មេងៗទាំង នោះបន្តិចណាំ!

នាងចាន់ក៏បណ្ដោយអោយខេរិនអូសដៃប្រទាញប្រទង់ ទីងណាត់ទីងណែង ត្រលប់ទៅស្រែវិញ ។ កាលបើក្រលេកឃើញមាណពយើងអូសដៃ កូនក្រមុំគាត់ចេញទៅទាំងតក្កហលមិនដឹងរឿង មីងចាបដែលកំពុងបាច ស្រូវអោយចំណីមាន់ ក៏ស្រែកវ៉ាងឡើងថា :

- វ៉ើយ! ជួយផង!... មានប្រុសកំលោះចាប់ជំរត់កូនស្រីយើងហើយ ជួយផង! ជួយផង!

សំលេងមីងចាប បានឮទៅដល់អ្នកស្រុកក្បែរខាង ។ គេក៏នាំគ្នារត់ព្រួ មកដល់ហើយសួរថា :

- ហើយចុះអាកំលោះមួយហ្នឹងវានាំនាងចាន់ទៅខាងណា?
- គឺប្រហែលជាវានាំនាងចាន់សំដៅទៅឯទួលខ្ទមយាយភួងហើយ!

CHANBOKEO.COM

អ្នកស្រុកទាំងអស់ក៏នាំគ្នារត់ឈូឆរ មានទាំងលីដងរែក កាំបិតផ្គាក់ អង្កត់ឱស ឬក៏សូម្បីតែទំពក់បេះត្របែក ក៏នាំគ្នាកាន់គ្រប់ដៃរត់តាមពី ក្រោយដែរ ។ ប៉ុន្តែខេវិននិងចាន់មិនបានចាប់ភ្លឹកទេ ។ គេទាំងពីរចេះតែនាំ គ្នារត់កាត់ស្រែផង និយាយគ្នាផងតាមផ្លូវរហូត ។ ពេលនោះ ខេវិនហាក់ ដូចជាចាប់ភ្លឹកថា ដៃរបស់នាងចាន់មានភាពទន់ល្មើយយ៉ាងចំលែក មិន សក្តិសមជាដៃកូនអ្នកស្រែធ្វើការនឿយហត់ឡើយ ។ ធិតាឃើញនាយចេះ តែលួចសំលឹងនាងមិនដាក់ភ្នែក ហើយមិនព្រមលែងដៃនាងចេញ ក៏នឹក ខ្មាសក្នុងចិត្តណាស់ ។ នាងស្រវារលាស់ដៃចេញហើយវាចាឡើង ថា :

- យើងដើរតាមសំរួលក៏បានដែរ ។ លែងដៃខ្ញុំសិនទៅណា៎!

ខេវិនឮដូច្នោះក៏ព្រលែងដៃវិញ ហើយខាំបបូរមាត់ធ្វើអេះអុញៗ ។ រំពេចនោះ នាងចាន់សួរនាយយើងបន្តថា :

- ហើយចុះអ្នក... មានចាំមុខ ឬស្គាល់ឈ្មោះក្មេងទាំងនោះទេ?

- អត់ទេ តែចាំថាមានគ្នាប្រាំនាក់ ឃ្វាលគោម៉ាហ្វូង ។ អូហ៎! មានពីរ នាក់មុខដូចគ្នាទំនងជាកូនភ្លោះ ។

- អូហ៎ បើអញ្ចឹងប្រហែលជាក្រុមអាត្នោតនិងអាដួងហើយ អញ្ចឹង ម៉ោះ! យើងទៅតាមផ្លូវផ្សេងវិញ រហ័សឆាប់ដល់ជាង ។

ថាហើយ នាងចាន់ក៏នាំខេវិនរត់ផ្លូវកាត់ផ្សេងទៀត ដើម្បីទៅរកក្មេង ឃ្វាលគោទាំងនោះ ។

ចំណែកក្រុមអ្នកភូមិដែលរត់តក្រុក តាមមករកអ្នក ទាំងពីរក៏ជ្រុលហួសសំដៅទៅខ្ទមយាយភួងបាត់អស់ទៅ ត្បិតមិនដឹងថា អ្នកទាំងពីរកំពុងដូរចិត្តទៅផ្លូវផ្សេង...

៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩

៩

CHANBOKEO.COM

# វគ្គទី៣
# អាពាហ៍ពិពាហ៍ចៃដន្យ

**ថ្ងៃ ១៩ មករា ២០០៦** ដដែល

ក្បែរជើងភ្នំព្រះនេត្រព្រះ...

លុះប្រទះក្មេងឃ្វាលគោមួយរូបនៅឯវាលស្រែមួយ នាងចាន់ក៏សួរ :

- អាព្រីង! ឯងមានឃើញអាត្នោតនិងអាដូងទេ?

- បាទ ឃើញ! តែវាទៅផ្ទះវិញបាត់ទៅហើយ ។ ឮថា វាបានយកឥវ៉ាន់គេ ចែកនៅខ្ទមយាយភួងទៅទុកនៅផ្ទះ ។

ឮដូច្នោះ ចាន់ក៏ចាប់ដៃនាយខេរិនអូសរឹងបំរុងបន្តដំណើរទៅទៀត ស្រាប់តែក្មេងឃ្វាលគោនោះក្រលេកឃើញទាន់ក៏ស្រែកសួរពីក្រោយថា :

- បងចាន់! បានប្តីពីអង្កាល់បានជាមិនឮហៅម៉ែពុកទៅស៊ីការ?

ចាន់ឮហើយភ្ញាក់ព្រើត បែរមើលមុខខេរិនហើយក៏រលាស់ដៃយ៉ាង រហ័ស រួចក៏ឆ្លើយរឹងថា :

- និយាយតែផ្តាស! តិចដង្កូវចោះធ្មេញឯងអស់រលីងទៅ!

ថាផង ចាន់ទំលាក់កន្ទុយភ្នែកបែរមើលទៅខេរិន ដែលកំពុងតែ សំលឹងមុខនាង ធ្វើឱ្យនារីយើងនឹកខ្មាសខេរិនឡើងក្តៅមុខភាយតែម្តង ។ មាណវីក៏ទាញក្រមាយកមកបាំងស្ទើរតែជិតមុខអស់ សល់តែគ្រាប់ភ្នែក ហើយក៏និយាយបន្ទប់ថា :

- អ្នកនៅឈរទ្រឹងដល់ណាទៀត មិនចង់ទៅតាមរកខ្មើយទាំងនោះទេហ៏?

ខេរិនហាក់ដូចជារំភើបចិត្តញាប់ញ័រក្នុងឱរាយ៉ាងណាមិនដឹងទេ តាំងពី នាយបានពេបប្រទះស្រីក្មេងមួយរូបនេះមក ។ នាយមិនដែលមានអារម្មណ៍ យ៉ាងនេះពីមុនមកទេ សូម្បីជាមួយផល្លីនជាសង្សារ ។ ឮចាន់ស្រដីដូច្នោះ មាណពក៏បោះជំហានតាមក្រោយនាងក្រមុំយើងយ៉ាងលឿន ទំនងខ្លាច ក្រែងនាងដើរចោលបាត់ នោះជីវិតនាយច្បាស់ជាយ៉ាប់ធំហើយ មិនដឹងថា ទៅពឹងនរណាអោយជួយទេ ។ មកដល់ផ្ទះឈើកំពុកមួយខ្នង សង់កណ្តាល វាលស្រែដោយមានបឹងព្រលិតតូចមួយនៅក្បែរ នាងចាន់ក៏ដើរចូលទៅ ហើយកូកហៅខ្លាំងៗថា :

- អាដូង!  អាត្នោត! នៅផ្ទះទេហ៏?

CHANBOKEO.COM

- ចឹក៏មិននៅ! បងចាន់មានការអីហ្អែស?

ក្មេងប្រុសម្នាក់ស្ទុះចេញមក។ ពេលនោះ ខេវិនចំណាំបានថា នោះគឺ ជាក្មេងម្នាក់ដែលនាយដួបកាលពីព្រឹកមិញ។ នាងចាន់ឃើញហើយក៏សួរ :

- អាដួង! ព្រឹកមិញ ឯងមានបានទទួលខ្មៅយចាស់៧ពីខ្ញុមយាយភួងទេ?

នាយដួងសំលឹងមុខខេវិន រួចហើយក៏តបវិញថា :

- តែខ្ញុំមិនបានលួចទេ... គឺពូខាងនេះ គាត់អោយខ្ញុំតើហ៎!

- អឺ! បងដឹងហើយថាឯងជាក្មេងល្អមិនបានលួចទេ ប៉ុន្តែតើឯងទទួលមក ប៉ុន្មាន ឱ្យបងសុំទិញវិញបានទេហ៎?

- យកមកតែមួយទេបង!... តែបងចាន់មិនបាច់ទិញទេ បើបងចង់បាន ចាំពីរបីថ្ងៃទៀត ខ្ញុំយកទៅអោយបង។

- ហ្អាក? ម៉េចអញ្ចឹង?

- ព្រោះអីម៉ែគាត់បានយកខ្មៅយទុកកល់ធ្វើកែបអង្គុយ ជិះរ៉ឺម៉កទ្រុងដឹក

មាន់ទៅលក់នៅឯភ្នំពេញជាមួយពុកខ្ញុំ ។គាត់ទើបចេញដំណើរទៅប្រហែល ជាងមួយម៉ោងមុននេះឯង។

- ស្រេចហើយ! (នាងចាន់លាន់មាត់)

ខេវិនយកដៃកេះចាន់ហើយនិយាយថា :

- បើដូច្នេះ យើងទៅតាមរកខ្មៅយបីដែលនៅសល់នោះវិញសិនទៅ។

ចាន់ពូហើយ ក៏បែរសួរនាយដួង :

- អញ្ចឹង អាអូនឯងមានដឹងថា ខ្មៅយចាស់បីទៀតនៅឯណាទេ?

- ចឹក៏មិនដឹង! អាសំវាយក៏មួយ អាង៉ែតយក៏មួយ ហើយអាកណ្តុប យក៏មួយ។ បងតាមទៅយកពីវាទៅ។ បើខ្ញុំបានជួបវា ចាំខ្ញុំប្រាប់អោយ វាយកទៅសងបងវិញណាំ។

- អឺ! អរគុណហើយណាំអាដួង។

ថាហើយ នាងចាន់ទះស្មានាយដួងហើយក៏នាំខេវិនត្រលប់ទៅវិញ។ នាយដួងយកដៃច្រត់ចង្កេះ មើលតាមអ្នកទាំងពីររួចលាន់មាត់ថា :

- ចេះមានដែរ ដែលមនុស្សចាស់អោយឥវ៉ាន់ក្មេងហើយតាមសុំទារយក

ទៅវិញ ! គួរអោយចំលែកមែន! ធ្វើយ៉ាងនេះមិនខ្លាចពកកទេឬអីហ្ន៎?

នាយដួងយកដៃអេះក្បាលហើយដើរចូលទៅក្នុងផ្ទះវិញ។

តាមផ្លូវ ខេវិនសួរនាងចាន់ថា :

- នាងស្គាល់ក្មេងនោះទាំងអស់មែនទេហ៎?

- ចាស មែនហើយ! យើងស្គាល់គ្នាពីដើមភូមិដល់ចុងភូមិ រស់នៅស្និទ្ធ ស្នាលដូចបងប្អូនអញ្ចឹង។

CHANBOKEO.COM

- ខ្ញុំក៏ឃើញអញ្ចឹងដែរ ។ គិតទៅអ្នកស្រុកស្រែចំការ គេរាប់អានគ្នាទៅ វិញទៅមកយ៉ាងកក់ក្តៅក្រៃលែង ហើយចេះជួយដោះស្រាយទុក្ខធុរៈគ្នា ដោយឥតមើលបំណាំ... គួរឱ្យកោតសរសើរពន់ពេកតែម្តង ។

ខេរិនញញឹមដាក់ចាន់បញ្ចេញនូវភាពរីករាយ ។ ចាន់ក៏ញញឹមតបវិញ ហើយឆ្លើយថា :

- អរគុណ! តែចំពោះអ្នកក្រុងវិញ មិនដឹងជាគេគិតយ៉ាងម៉េចទៅហ្ន៎ ចំពោះអ្នកស្រែដែលក្រីក្រម៉្លឹង១?

- ក្រមែនតែសម្បត្តិទ្រព្យ តែមានសន្តានចិត្តថ្លៃថ្លាណាស់ ។ ខ្ញុំពិតជា...

- យ៉ាងម៉េច? (នាងចាន់សំលឹងមុខខេរិន)

- គឺ... គឺ...

គ្រាន់តែនាងចាន់សំលឹងចំក្រសែភ្នែករបស់នាយភ្លាម ខេរិនក៏ត្រូវ ច្រាបជាន់ជាថ្មី គាំងអណ្តាតស្ទូក និយាយលែងចេញទៀតហើយ ក្រៅតែពី ឈរសំលឹងកែវភ្នែកដ៏ភ្លឺថ្លារបស់នាងទាំងដួងចិត្តញាប់ញ័រ ។ នាងចាន់ឃើញ ដូច្នោះក៏លួចញញឹមហើយហើយនាំមុខខេរិនដើរទៅមុខទៀត ។ មួយ ស្របក់ក្រោយមក គេក៏បានមកដល់ផ្ទះមួយសង់ខ្ពស់ពីដី មានសួនដំណាំដាំ ដុះជុំវិញ ។ ចាន់ដើរចូលទៅដល់កូកហៅ :

- អាសំអើយ! នៅផ្ទះទេ?

- មិននៅទេ មីង៉ាអើយ ។ នាងរកអាសំមានការអ្វីដែរ? (ដូនចាស់ម្នាក់ លេចឆ្លោចេញមក)

- គឺខ្ញុំមកសុំខ្មើយចាស់របស់យាយភួងទៅវិញណាំយាយ ។

- យីអើ! គេទើបតែអោយវាព្រឹកមិញ ឥលូវនេះមកទាររទៅវិញហើយ? ពីណាគេចិត្តអាក្រក់ម្ល៉េះ អោយហើយយកវិញ?

- មិនមែនមកទាររទេ គឺមកសុំទិញទៅវិញ ។

- សុំទិញ? មានរឿងអ្វីហ្ន៎ស? ម៉េចបានចាំរកទិញទៅវិញផង? យើងមិន លក់ទេ បើចង់បានយកទៅវិញចុះ អោយតែរកវាឃើញ ។ អញមិនចង់ បានលុយរបស់ឯងទេ ។

តែចាន់មិនឆ្លើយទេ បែរជាសួរបញ្ច្រាសទៅវិញថា :

- យាយ! ហើយចុះ ខ្មើយនោះនៅឯណា?

- តែ... អញមិនប្រាប់មីង៉ាឯងទេវ៉ើយ!

- ហេតុអ្វីទៅយាយ?

- ព្រោះអញកំពុងតែមានកែបកល់គូថ ស្រួលត្បាញកន្ទេលណាស់ មិនសូវ ឈឺគូថដូចរាល់ថ្ងៃនោះអី ។ អញទៅប្រាប់ឯងធ្វើអី នាំតែឯងរកឃើញ យកទៅវិញអស់អីប្រើទទេ១ (គាត់និយាយផង ឈរច្រត់ចង្កេះផង ធ្វើ ឫកយ៉ាងព្រងើយ)

នាងចាន់ឮហើយសើចខឹក១ រួចស្ទុះចូលទៅក្រោមផ្ទះសំដៅទៅកី តម្បាញកន្ទេលកក់ឃើញខ្មើយចាស់មួយនៅទីនោះមែន ។ មាណវីយើងក៏ ស្ទុះឆក់រឹងអោបរត់ចេញមក រួចអូសដៃនាយខេរិនចេញទៅវិញយ៉ាង លឿន ព្រមទាំងស្រែកពីចំងាយថា :

- អរគុណណាស់យាយ! ខ្ញុំយកខ្មើយរបស់យាយភួងវិញហើយ!

ស្រាប់តែដូនចាស់រត់តាមពីក្រោយ បបោយដៃហៅ :

CHANBOKEO.COM

- នែ៎មីងា! ឈប់សិនវើយ! ឯងយកកែបគរសំរាប់អង្គុយរបស់យាយទៅ ណា? ឆាប់យកមកវិញ! ថ្ងៃនេះ អញអង្គុយត្បាញកន្ទេលឈឺគូថទៀត ហើយ ។ នែ៎ មើល៎ អោយអញវិញមក៏វើយ!

តែនាងចាន់នៅតែកាន់ដៃខេរិនផង រត់ផង សើចកក្អឹក១ តាមផ្លូវ រហូតមក ។ គ្រានោះ ខេរិនក៏មានអារម្មណ៍ថាខ្លួននាយសប្បាយរីករាយ រំភើបក្នុងចិត្តចំលែកយ៉ាងណាមិនដឹងទេ ។ ក្នុងមួយជីវិតនេះ នាយតែងតែមានអារម្មណ៍អផ្សុកតប់ប្រមល់គិតមិនចេញ រៀនមិនចូល សូម្បីតែមីងពៅ ពូរ៉េបានថែនាយយ៉ាងល្អ ក៏នាយនៅតែមានអារម្មណ៍ថាជីវិតរបស់នាយ គ្មានសេចក្តីសុខពេញលេញឡើយ ។ នាយធ្លាប់ជាមនុស្សឆាប់ធុញ ឆាប់ ខឹង ឆាប់ច្រលោត ហើយមិនសូវចេះស្តាប់នរណាទេ ។ ស្រាប់តែពេលនេះ ស្រីក្មេងចំលែកម្នាក់ បានធ្វើអោយនាយរំភើបចិត្តសប្បាយរីករាយ ខុស ប្លែកធម្មតាតែម្តង ។ នាយបានបណ្តោយអោយនាងចាន់អូសដៃរបស់ខ្លួន រត់ចុះរត់ឡើង១ដោយមិនធុញទ្រាន់ ។ ស្របពេលជាមួយគ្នានេះដែរ នាយ យើងក៏ភ្លេចគិតពីផល្លីន ដែលជាសង្សារនៅអាមេរិកនោះ ឱ្យសូន្យឈឹង រលីងគ្មានសល់ពីបេះដូងតែម្តង ។

ចាន់អោបខ្មើយរត់បណ្តើរ សើចខឹកបណ្តើរ ទន្ទឹមគ្នាជាមួយខេរិន យ៉ាងហត់គឃូស រហូតមកដល់ផ្ទះរបស់នាងវិញ ។ ស្រាប់តែអ្នកទាំងពីរ ភ្ញាក់ព្រើតត្បិតមានអ្នកភូមិប្រុសស្រីមួយហ្វូងធំ កំពុងតែនៅឈរវង់ចាំនៅ មុខផ្ទះរបស់នាងជាស្រេច :

- នែ៎ ក្មេងព្រហើន! ឯងទើបនាំនាងចាន់មកពីណា? ហេតុអ្វីឯងថ្លើមធំ ហ៊ានចាប់ជិះរត់កូនក្រមុំគេទាំងថ្ងៃដូច្នេះ?

បុរសមាឌធំម្នាក់ស្រែកឡើងហើយយកដៃចង្អុលមុខខេរិន ។ ចាន់បែរ មើលទៅខេរិន ហើយក៏បែរមកគាត់វិញសួរទាំងភ្ញាក់ផ្អើលថា :

- ពូគ្រុឌ! មានរឿងអីហ្នឹង?

- ម៉ែឯងប្រាប់អញថា អាអន្ទិតមួយនេះវាចាប់ជិះរត់ឯងទៅ ។

- ស្លាប់ហើយ! ម៉េចក៏ម៉ែខ្ញុំនិយាយបែបនេះ ចុះឯណាម៉ែខ្ញុំ?

- ម៉ែនៅខាងនេះ ( មីងចាបដើរចេញមក)

- ម៉ែ! ម៉េចក៏ចោទថាគេចាប់ជិះរត់ខ្ញុំដូច្នេះ? ( ចាន់សួរ)

- អើ ! បើម៉ែឃើញអាអន្ទិតនេះ វាចាប់ដៃអូសឯងយកទៅយ៉ាងរហន់ អន្ទះសា ដោយមិននិយាយមុខក្រោយអ្វីអោយម៉ែដឹងរឿងសោះ ទើបម៉ែ ភិតភ័យហៅគេហៅឯងអោយជួយទៅ ។

- ពុទ្ធោអើយម៉ែ! ការពិត គាត់កំពុងរត់តាមរកលិខិតមរតករបស់យាយ ភួងតើហ៎!!

- ហ្ន៎ស? ថាម៉េច? មរតកយាយភួង? ( មីងចាបលាន់មាត់)

អ្នកភូមិក៏បែរមើលមុខគ្នាធ្វើឡឹងឡង់ ។ មីងចាបបែរមើលទៅខេរិន ក៏សួរថា:

- អាអន្ទិតមួយនេះ... ឈ្មោះឫទ្ធីរិន្ទចៅប្រុសយាយភួងនោះមែនទេ?

- ចា៎ស! មែនហើយម៉ែ!

CHANBOKEO.COM

- ពុទ្ធោ! ហេតុអីក៏កូនមិនប្រាប់ម៉ែអោយដឹងផងហ្នាស?

- ព្រោះកូនជំរាបម៉ែមិនទាន់ ក៏ត្រូវគាត់អូសទៅមុនបាត់ទៅ

- ហើយអូសយកទៅណា?

- គឺ ទៅតាមរកខ្មៅឪយដែលមានបង្កប់លិខិតមរតកនោះអី ។

- គឺតាមរកអាខ្មៅឪយដែលឯងកំពុងអោបយកមកវិញនេះ មែនទេ?

- ចាំស! តែមានដល់ទៅបួនឯណោះ ខ្ញុំទើបរកឃើញខ្មៅឪយមួយទេ ។

- បើអញ្ចឹងហែកមើលទៅ តើសំបុត្រសរសេរថាម៉េចខ្លះ ។

ទាំងខេរិន នាងចាន់ មីងចាប និងអ្នកភូមិ  សុទ្ធតែមានអាការៈជ្រួល ច្រាលចង់ដឹងណាស់ថា តើលិខិតខាងក្នុងខ្មៅឪយរបស់យាយភួង សរសេរថា ម៉េច ។ បន្ទាប់ពីហែកយកសំបុត្របានហើយ នាងចាន់ក៏ចាប់យកមកអាន យ៉ាងឮខ្លាំងៗ ទោះបីជាខេរិនចង់ឃាត់ក៏ឃាត់មិនជាប់ដែរ ។ ការពិត ខេរិន មិនចង់អោយមនុស្សច្រើនដឹងថានាយទទួលមរតកទេ ព្រោះនាយចង់រក្សា សុវត្ថិភាពផ្ទាល់ខ្លួនរបស់នាយ តែបើចង់ហាមឃាត់ក៏ទៅមិនរួច មើលទៅ អ្នកភូមិ គេហាក់ដូចជាស្រុះគ្នាណាស់ ។ ខេរិនក៏បណ្តោយអោយនាងចាន់ អានខ្លាំងៗបន្តទៅទៀតថា :

*- ចំពោះ ឫទ្ធិរិន្ទ ចៅប្រុសទោលរបស់យាយ!!     កុំភ្លេចយកចង្ហាន់ទៅ ប្រគេនលោកនៅវត្ត លើភ្នំព្រះនេត្រព្រះ រួចហើយបង្សុកូលជូនឪពុក ម្តាយរបស់ចៅផង! យាយភួង!*

- តែប៉ុណ្ណឹងទេ? អីក៏ខ្លីម្ល៉េះ? ( មីងចាបលាន់មាត់)

ពូគ្រុឌឆក់យកសំបុត្រមួយនោះមកពិនិត្យមើលសាថ្មី ហើយក៏លាន់ មាត់ដែរ:

- មែនហើយ មិនឃើញមានគំនូរផែនទីអ្វីទេ ។

- ប្រហែលជាមានកប់នៅក្នុងខ្មៅឪយផ្សេងៗទៀតទេដឹង? ( មីងចាបតប)

ខេរិននៅស្ងៀមធ្វើមុខស្មើៗ មិនដឹងថានាយកំពុងខកចិត្ត ឫយ៉ាងណា ទេ ។ ពូគ្រុឌឃើញដូច្នោះ ក៏ពោលឡើងថា :

- នែ៎អាអន្ទិតអើយ! សំបុត្រនេះក៏ជាមរតកដ៏ល្អបំផុតហើយ ដែលយាយ គាត់រំលឹកឯងឱ្យយកចង្ហាន់ទៅវត្តបង្សុកូលជូនម៉ែឪដែលចែកឋានទៅ បើ ឯងមិនដែលធ្វើអ្វីជូនគាត់ពីមុនមកទេ ល្មមដល់ពេលដែលឯងធ្វើជូនគាត់ ហើយ ដើម្បីអោយវិញ្ញាណគាត់បានទៅចាប់ជាតិកំណើតជាថ្មីផង ។ ម្យ៉ាង ទៀត ឯងក៏នឹងបានទទួលរាសីខ្ពស់ដែរ បន្ទាប់ពីធ្វើបុណ្យរួចហើយ ។

មែនហើយ! ពូគ្រុឌនិយាយត្រូវ ។ ខេរិនមិនដែលបាននឹកឃើញធ្វើអ្វី រំលឹកដល់វិញ្ញាណក្ខន្ធ័របស់ឪពុកម្តាយនាយម្តងណាទេ ពីមុនមក ។ នេះ ប្រហែលជាដល់ពេលដែលនាយត្រូវប្រព្រឹត្តខ្លួនជាកូនកតញ្ញូហើយទេដឹង?

បន្តិចមកអ្នកស្រុកក៏ដើរចេញអស់ទៅ ។   មីងចាបក៏ចេញទៅជាមួយ អ្នកភូមិបាត់ទៅដែរ ខុសតែខេរិនទេដែលនៅអង្គុយធ្វើមុខស្ងួត ។ នាងចាន់ ឃើញដូច្នោះក៏សួរថា :

- ខកចិត្តហ្អែស ដែលមិនបានទទួលមរតក?

CHANBOKEO.COM

ខេរិនទៅស្ងៀមមិនស្រដី ។ នាងចាន់ក៏ពោលបន្តថា :

- អ្នកនៅសល់ខ្មើយបីទៀតមិនទាន់រកឃើញនៅឡើយ ។ ម៉េចក៏ឆាប់អស់ ទឹកចិត្តម្ល៉េះ កំលោះអនិកជនអើយ?

ខេរិនឮដូច្នេះក៏ភ្ញាក់ព្រើត :

- មែនហើយ! ខ្ញុំត្រូវចេញតាមរកខ្មើយបីទៀត ។ ប៉ុន្តែ នាងអាចជួយខ្ញុំ តាមរកវាបានទេហ៎?

ខ្ញុំពិតជាមិនអាចតាមរកឃើញដោយសមត្ថភាព របស់ខ្លួនឯងបានឡើយ ។

ចាន់សំលឹងមុខនាយមួយស្របក់ ក៏ពោលថា :

- តើអ្នកមានអ្វីជាសគុណទេ?

- តើ... នាងចង់បានអ្វីទៅ?

- គឺអ្នកត្រូវយកចង្ហាន់ទៅវត្តប្រគេនព្រះសង្ឃ ហើយបង្សុកូលជូនឪពុក ម្តាយរបស់អ្នកតាមលិខិតមរតកកុំខាន ។

- តែខ្ញុំមិនចេះដាំបាយធ្វើម្ហូបទេ

- អញ្ចឹង ចាន់សុខចិត្តដាំបាយធ្វើម្ហូបជូនអ្នកទៅវត្តចុះ ។ ឃើញអ្នកមាន មាឌធំដូច្នេះ បើហៅទៅភ្ជួរស្រែច្រូតស្រូវសងវិញ ក៏មិនជាខាតអីដែរ ។

ខេរិនឮហើយ ក៏ញញឹមឡើងវិញយ៉ាងត្រកាល រួចហើយក៏សួរថា:

- នាង! យើងចេញទៅរកខ្មើយបីទៀត ឥលូវនេះយ៉ាងម៉េចដែរ?

ចាន់កំពុងតែកើបស្រូវយកមកលាងទឹកដាក់ត្រាំ ឮខេរិនសួរក៏បែរ ឆ្លើយវិញថា :

- ខ្មើយអស់នោះវាចាស់ៗណាស់ គ្មានចោរណាលួចទេ ហើយក្មេងអស់ នោះ ក៏ជាក្មេងនៅរស់ភូមិម្តុំនេះឯង ទៅរកពេលណាឃើញពេលហ្នឹង ។ សំរាកបន្តិចសិនក៏មិនអីដែរណា៎!

- តែខ្ញុំចង់ទៅឥលូវនេះ...

- ហ៊្មើយ! យ៉ាប់មែន! អញ្ចឹង ចាំម៉ាភ្លែត ខ្ញុំដាក់ស្រូវត្រាំទឹកសិន ។

- នាងត្រាំស្រូវធ្វើអ្វី?

- ធ្វើតាំងម៉ែសំរាប់បរិភោគនោះអី!

- អូហ៎? គេយកស្រូវធ្វើតាំងម៉ែកើតដែរ?

- ម៉េចថាមិនកើត? តាំងម៉ែស្រូវក្រអូបហើយផ្អែមផង ។ ចាំស្អែក ខ្ញុំធ្វើ អោយអ្នកទទួលទានសាកមើលក្រែងជាប់ចិត្ត ។

មើលទៅចាន់ជាមនុស្សរួសរាយហើយមានសន្តានចិត្តទូលាយណាស់ ។ ពិតមែនតែនាងក្រីក្របន្តិច តែជីវិតនាងហាក់ដូចទទួលសុភមង្គលយ៉ាងល្អ បំព្រង សូម្បីតែខេរិនដែលទើបបានមកប្រទះនាងនៅថ្ងៃនេះសោះ ក៏នាយមានអារម្មណ៍ថា ហាក់ដូចជាបានទទួលនូវកក់ក្តៅក្នុងចិត្ត យ៉ាងចំលែក ដែរ ។ បន្តិចមក

CHANDBOKEO.COM

នាងចាន់ក៏ខេវិនដើរសំដៅទៅផ្ទះក្មេងម្នាក់ទៀតឈ្មោះ អាង៉ែត ។ មិនទាន់ដល់ផ្ទះក្មេងនោះផង ស្រាប់តែអ្នកទាំងពីរប្រទះអ្នកភូមិមួយហ្វូង កំពុងតែរត់ប្រជេញគ្នាហុយដីទ្រលោមមកពីនាយ សំដៅមក អ្នកទាំងពីរ ។  ខេវិនលាន់មាត់សួរចាន់ថា :

- ចាន់! តើគេកំពុងហែអ្វីហ្នឹងឆ្អើលអស់ទាំងភូមិ?
- ខ្ញុំក៏មិនដឹងដូចគ្នាដែរ (ចាន់តបវិញ)
- មើលទៅពួកគេដូចជារីករាយណាស់!

រំពេចនោះអ្នកស្រុកក៏បានមកដល់ចំពោះមុខអ្នកទាំងពីរ ដែលមានពូ គ្រុឌដែលជាអ្នកនាំក្បួនដង្ហែផង ។ ចាន់ឆ្ងល់ណាស់ក៏សួរឡើងថា :

- ពូគ្រុឌ! ហែក្បួនទៅណាហ្នឹង អីក៏គគ្រឹកគគ្រេងម្ល៉េះ?

ពូគ្រុឌសើចហិសៗយ៉ាងរីករាយហើយក៏មានប្រសាសន៍តបវិញថា:

- គឺយើងនាំពួកអ្នកភូមិតាមរកខ្មើយចាស់របស់យាយភួងនោះអី ។

ខេវិនភ្ញាក់ព្រើត នឹកក្នុងចិត្តថា :

- ព្រះអើយ!    ហេតុអ្វីក៏គេមានសន្ដានចិត្តម្ល៉េះ?  មិនដូចនៅអាមេរិកទេ សក់អ្នកណា ក្បាលអ្នកហ្នឹង!

រំពេចនេះ ស្រាប់តែនាងចាន់សួរថា :

- ហើយចុះពូរកឃើញហើយឬនៅ?
- ឃើញមួយហើយ! (ពូគ្រុឌឆ្លើយ)

ខេវិននិងចាន់ឮហើយនឹកអរភើតហើយ ក៏ស្ទុះចាប់ដៃគ្នាហោរឡើង ព្រមគ្នាទាំងពីរនាក់តែម្ដង :

- ជយោ!

ស្រាប់តែពូគ្រុឌស្ទុះមកបេះដៃនាយខេវិនចេញពីនាងចាន់ ហើយស្រដី ខ្លាំងៗស្ដីអោយទៅខេវិនថា:

- នែ៎ វើយ! កុំសូវបន្ដំចាប់ដៃចាប់ជើងកូនក្រមុំគេពេកវើយ! តិចថា យើងមិនបានប្រាប់!

ចាន់ឮដូច្នោះ   នឹកអៀនគ្រលួចក្នុងពោះតែម្ដង ។ ចំណែកខេវិន ក៏ដក
ដៃចេញយ៉ាងរហ័ស រួចហើយបោះកន្ទុយភ្នែក លួចដៀងមើលទៅភ័ក្ត្រ មាណវីភ្លៀកៗសំដែងឫកពាអេះអុញៗ
ទំនងកំពុងតែខ្មាសខ្លួនខ្លាំងណាស់ ដែរ ។ ដើម្បីបន្លប់ នាងចាន់ក៏សួរពូគ្រុឌថា :

- ហើយចុះឯណាខ្មើយនោះពូ? មានហែកមើលឃើញសំបុត្រសរសេរ ថាម៉េចទេ?
- វើយ! អ្នកណាទៅហ៊ានហែកសំបុត្រមុនម្ចាស់គេវ៉ី? យើងទើបតែទៅ យកបាន ពីអាកណ្ដូបអំបាញមិញនេះ
ទើបមកតាមរកអារអន្ទិតវិន្ទ អោយ
វាហែកមើលខ្លួនវា ។

ភ្លាមនោះ អ្នកភូមិម្នាក់បានយកខ្មើយមកហុចអោយខេវិន ។  មាណព
លូកដៃទទួលទាំងមុខញញឹមហើយស្រដីថា :

CHANBOKEO.COM

- អរគុណ... អរគុណណាស់!!

ខេវិនរំភើបចិត្តពេកនិយាយអ្វីមិនចេញទេ ក្រៅតែពីពាក្យអរគុណពីរ ម៉ាត់។ បន្ទាប់មក ខេវិនក៏ចាប់ហែកខ្មៅយឡើងទាញយកសំបុត្រមួយច្បាប់ ចេញមក។ អ្នកភូមិដែលនៅឈរជុំវិញនោះ ក៏ទះដៃហោរកញ្ជ្រៀវឡើងយ៉ាងសប្បាយ តែខេវិនបែរជាហុចសំបុត្រទៅចាន់ទៅវិញហើយវាចាថា :

- ពេលនេះ ខ្ញុំត្រូវពឹងភ្នែករបស់នាងម្តងទៀតហើយ។

ចាន់សំលឹងមុខខេវិនទំនងដូចជាយល់ចិត្ត រួចក៏ទាញសំបុត្រមកអាន :

*- ចំពោះចៅឫទ្ធីរិទ្ធិ! ចៅត្រូវរៀបចំប្រារព្ធពិធីមង្គលការ៧យប់៧ថ្ងៃ នៅភូមិព្រះនេត្រព្រះនេះតាមទំនៀមបុរាណជាមួយកូនក្រមុំម្នាក់ដែល ជីដូនបានរើសទុកដាក់សំរាប់ចៅរួចហើយ។... យាយភួង!*

ចាន់អានចប់សេចក្តីកាលណា អ្នកស្រុកក៏ហោរកញ្ជ្រៀវសាជាថ្មី។ ប៉ុន្តែខេវិនបែរជាដាក់ទឹកមុខជ្រប់លែងសប្បាយទៅវិញ។ នាងចាន់ឃើញ ដូច្នោះ ក៏ដើរទៅជិតរួចខ្សិបសួរនាយថា :

- ហេតុអ្វីមិនសប្បាយចិត្តដូច្នេះ? អ្នកមានសង្សារដែលកំពុងរង់ចាំឱ្យអ្នក វិលវិញ ទៅរកគេវិញមែនទេ?

- ហ្ហ៎ស? ម៉េចក៏នាងដឹង? (ខេវិនលាន់មាត់)

- ចាន់មិនដឹងទេ តែកិរិយារបស់អ្នក និយាយប្រាប់ចាន់ដោយខ្លួនឯង។

ខេវិនងក់ក្បាល។ ចាន់ក៏លាន់មាត់ឡើង :

- ស្លាប់ហើយ! ដូច្នេះ អ្នកត្រូវធ្វើដូចម្តេចទៅពេលនេះ? (ចាន់លាន់មាត់)

- ខ្ញុំមិនដឹងទេ... ប្រហែលស្រេចលើទេវតាចារផ្លូវតំរូវអោយដើរទេដឹង!!

រំពេចនោះ ស្រាប់តែមីងចាបឧទានឡើង:

- ហើយចុះ កូនក្រមុំរបស់អទ្ធិតរិទ្ធចៅយាយភួងនោះជានរណាទៅ? មាន នរណាស្គាល់ទេ? គ្រុឌ! ឯងមានស្គាល់ទេ ហ្ហ៎ស?

- អត់ស្គាល់ទេ បងចាប! សួរតាជីវ៍មេភូមិមើល ក្រែងគាត់ដឹង!

ភ្លាមនោះ តាជីវ៍ឆ្លើយឡើងថា :

- តាជីវ៍ក៏មិនដឹងដូចតែគ្នាហ្នឹង! យាយភួងមិនដែលផ្តាំអ្វីជាមួយខ្ញុំទេ។

- ធ្វើម៉េចទៅហ្ន៎ទើបយើងដឹងថា ចៅប្រសារស្រីរបស់យាយភួងជា នរណា? (មីងចាបហាក់ដូចជាឆ្ងល់ជាងគេ)

- ទាល់តែដើរសម្ភាសន៍អស់ចាស់ៗក្នុងភូមិនេះហើយ (ពូគ្រុឌឆ្លើយ)

តាជីវ៍ជាមេភូមិក៏បែរទៅមើលមីងចាប :

- ម៉េចហ្ហ៎ស នាងចាប? ចង់ស៊ីការណាស់មែនទេ?

- និយាយមិនចង់ល្មេច តាអើយ? បានស៊ីការ ឡកឡាំថូន ភូមិយើងពិតជា សប្បាយណាស់ណាំ! ៧យប់៧ថ្ងៃ យើងនាំគ្នារាំអោយផ្អើលដូនតាម្តង។

CHANBOKEO.COM

អ្នកស្រុកក៏នាំគ្នាហ៊ោគិលឡើង។ បន្តិចក្រោយមក ពួកគេក៏នាំគ្នា ចេញទៅបាត់។ ខេវិននិងចាន់អង្គុយនៅក្រោមដើមដូងមួយពិគ្រោះគ្នា ៖

- នាងអស់កំលាំងហើយនៅ? (ខេវិនសួរចាន់)

- ស្បើយកំលាំងបន្តិចហើយ តែអាចនៅបន្តទៀតបាន។ អ្នកចង់អោយខ្ញុំជូនទៅរកខ្មោយទីបីមែនទេហ៎?

ដំបូង ខេវិនហាក់ដូចនឹកចង់ទៅតាមរកខ្មោយពីរទៀត ភ្លាមៗ អោយសមចិត្តរបស់នាយដែលកំពុងក្តៅអន្ទះសា។ តែលុះក្រលេកឃើញមាណវី យើងហាក់ដូចជាមានអាការៈអស់កំលាំងណាមួយអាកាសធាតុពេល រសៀលក៏ក្តៅខ្លាំងទៀតផង ខេវិនក៏នឹកអាណិតធិតាព្រួចក្នុងចិត្តតែម្តង! នាយយើងគិតក្នុងចិត្តតែម្នាក់ឯងថា ៖

- នេះយើងប្រើគេហ៎ហួសហេតុពេកទេដឹង? មើលទៅនាងដូចជាហេវ ហត់អស់កំលាំងហើយ។

ខេវិនក៏ប្តូរចិត្តវិញហើយក៏វាចាទៅចាន់ថា ៖

- យើងទៅផ្ទះរកសំរាកសិនទៅ ចាំមេឃត្រជាក់បន្តិច ចាំយើងចេញទៅ រកបន្តទៀតណាំ

ចាន់ឮដូច្នោះក៏បែរសំលឹងមុខខេវិន ញញឹមហើយងក់ក្បាល ៖

- តោះ! អញ្ចឹងយើងទៅផ្ទះវិញ ព្រោះខ្ញុំក៏កំពុងហេវបាយដែរ។

ខេវិនភ្ញាក់ព្រើតកាលបើឮនាងនិយាយដូច្នោះ។ មែនហើយ! ឆវីមិន ទាន់បរិភោគបាយឯណាហើយនាយក៏បានយិតបាយរបស់នាងអស់ពីឆ្នាំង ទៀតផង។ ម្យ៉ាងទៀត មាណពក៏ទាញអូសនាងទៅនេះទៅនោះទីងណាត់ទីងណែង មិនឈប់សោះមួយថ្ងៃមកហើយ ប៉ុន្តែ នាយយើងបែរជាមិនបាន ចាប់ភ្លឹកនឹកគិតដល់សុខទុក្ខរបស់នាងអ្វីបន្តិចសោះ។ នឹកឡើងកាលណា ខេវិនហាក់ដូចជាអាណិតធិតាថែមទ្វេឡើង ហើយក៏បន្ទោសខ្លួនឯងពិតតែ ខ្លាំងដែរ។ បន្តិចមក ខេវិនក៏នាំនាងចាន់មកដល់ផ្ទះវិញដោយសុវត្ថិភាព។

មួយសន្ទុះក្រោយមក...

ចាន់មុជទឹកជំរះខ្លួនហើយក៏ដើរចេញមក ស្រាប់តែប្រទះនឹងខេវិន ដែលកំពុងអោនផ្លុំភ្លើង។ ចាន់ក៏សួរឡើងថា ៖

- អ្នកកំពុងធ្វើអ្វីហ្នឹង?

ខេវិនបែរមកនាងហើយញញឹម ៖

- បង្កាត់ភ្លើងដាំបាយអោយនាងញ៉ាំនោះអី!

- អូហ៎! កំលោះអ្នកទីក្រុងចេះដាំបាយខ្លួនឯងដែរ?

- អត់ចេះទេ តែកំពុងរៀនធ្វើ។

- ចុះនៅស្រុកអ្នក គេដាំបាយយ៉ាងណាដែរ?

- គឺដាក់អង្ករដាក់ទឹក ចុចកុងតាក់ ឆ្អិន!

CHANBOKEO.COM

- ងាយដល់ម្លឹងឬអ្នក?

- មែនហើយ!

- អ្នកពិតជាសំណាងណាស់!

- តែឥលូវយីអ៊ុនដាក់វិញហើយ!

- ម៉េចអញ្ចឹង?

- ដូចនាងឃើញស្រាប់នឹងភ្នែកហើយតើហ៎...!

រំពេចនោះ ចាន់ក៏ញញឹមឡើង :

- មិនអីទេ! ដល់អ្នករកខ្មៅយពីរទៀតឃើញ យីអ៊ុនរបស់អ្នកនឹងឡើងដល់ ឋានសួគ៌តែម្តង!!

- សូមអោយពិតដូចវាចារបស់នាងទៅចុះណាំ!!

ខេវិនក៏ញញឹមឡើង ។ ចាន់ក៏ដេញអោយខេវិនចេញពីចង្ក្រាន :

- អ្នកទៅអង្គុយលេងនៅខាងក្រៅចុះ ចាំខ្ញុំដាំបាយដោយខ្លួនឯង

- មិនអីទេ! ខ្ញុំចង់នៅទីនេះជាមួយនាង... សុំធ្វើកូនកាំបិតផងណាំ!

ចាន់ងើបមើលមុខខេវិន ឃើញនាយសំលឹងមកនាយដោយក្រសែ ភ្នែកដ៏មានទឹកដមមន្តស្នេហ៍ពណ្ណរាយ ធ្វើអោយនាងនឹកខ្មាសយ៉ាងណាមិន ដឹងស្រាប់តែញ័រដៃឯង១ ។ រីឯខេវិនវិញ បែរជាមានអារម្មណ៍ថា ទោះបីជា ពេលនោះ នាយកំពុងស្ថិតក្នុងខ្ទមស្លឹកត្នោត ជញ្ជាំងដីអិដ្ឋបូកអាចម៍គោ ក៏ ដោយ ក៏នាយមានអារម្មណ៍ថា ជីវិតនាយបានជួបប្រទះនូវសុភមង្គលមួយ យ៉ាងមនោរម្យបំផុត ។

រសៀលថ្ងៃដដែល...

ចាន់ទទូរក្រមាដើរចេញពីផ្ទះមក  ឃើញខេវិននៅអង្គុយមើលមេមាន់ បណ្តើរកូនក្រុក១នៅក្រោមដើមស្វាយ ។ គ្រាន់តែក្រលេកឃើញចាន់កាល ណា ខេវិនក៏ញញឹមពព្រាយដាក់នាងឡើង ។ ចាន់ឃើញហើយសួរថា :

- ញញឹមស្រស់យ៉ាងនេះ ប្រហែលជាជិតមានយីអ៊ុនវិញហើយ ។

ថាហើយនាងក៏ដាក់ខ្លួនអង្គុយចុះក្បែរនាយ ហើយវាចាបន្តថា :

- អ្នកនៅសល់ខ្មៅយពីរទៀតដែលត្រូវតាមរក ចង់ទៅពេលឥលូវនេះទេ? ខ្ញុំជូនទៅ ព្រោះផ្ទះអាង៉ែតក៏នៅមិនឆ្ងាយពីនេះប៉ុន្មានទេ ។

ស្រាប់តែខេវិនបែរជាយកដៃទប់មាត់នាង មិនអោយនិយាយទៅវិញ ធ្វើអោយមាណវីយើងនឹកឆ្ងល់ណាស់ ក៏បែរសំលឹងមុខនាយដោយក្រសែ ភ្នែកយ៉ាងមុត ហាក់ដូចជាចង់ដឹងថាតើហេតុអ្វីបានជានាយដូរចិត្ត ។ ខេវិន ហាក់ដូចជាយល់ជំរៅចិត្តនាង ក៏ឆ្លើយឡើងថា:

- ចាន់មិនបាច់បន្ទីរបន្ទាន់ពេកទេ ។ កាលពីព្រឹក ខ្ញុំដូចជាអន្ទះសាបន្តិចមែន តែឥលូវខ្ញុំផ្លាស់ចិត្តហើយ ហើយខ្ញុំមិនចាំបាច់ប្រញាប់តាមរកលិខិតមរតក នោះពេកដែរ ។

CHANBOKEO.COM

- ហេតុអ្វីទៅ?

- គឺ... គឺ... ដូចនាងថាអញ្ចឹង... ក្មេងឃ្វាលគោអស់នោះជាអ្នកភូមិម្តុំនេះ ទៅរកពេលណាក៏បានដែរ ខ្មែយចាស់ទាំងអស់នោះច្បាស់មិនរត់ទៅណា។ ម្យ៉ាងទៀត...

ខេវិននិយាយផង បែរសំលឹងកែវភ្នែករបស់ចាន់ផង ទំនងដូចជាចង់ ប្រាប់នូវអារម្មណ៍របស់នាយចំពោះនាងអញ្ចឹង។ បន្តិចមក នាយយើងក៏ ងើយមើលទៅចុងដូងហើយក៏មានវាចាបន្តថា:

- ខ្ញុំចង់អោយពេលវេលារត់ថយយឺត១មកវិញ... មិនចង់អោយវាលឿន ហួសទៅមុខឆាប់រហ័សពេកទេ។

- ព្រោះហេតុអ្វីទៅ?

ខេវិនមិនឆ្លើយទេ គ្រាន់តែញញឹមដាក់នាងហើយនៅស្ងៀម។ ចាន់ នឹកឆ្ងល់ណាស់ដែលនាយនិយាយអាក់១មិនច្បាស់លាស់។ នាងបំរុងនឹងសួរ តទៅទៀតទៅហើយ ស្រាប់តែមានស្នូរសំលេងសិរបជើងគគ្រឹកគគ្រេង មកដល់ទីធ្លាដល់បរិវេណផ្ទះនាងចាន់។ អ្នកទាំងពីរបែរមើលតាមទិស សំលេង ក៏ប្រទះនឹងមីងចាបកំពុងប្រកែកគ្នាជាមួយអ្នកស្រុកថា :

- មិនបានទេ! មិនបានដាច់ខាត។ ខ្ញុំមិនអោយធ្វើទេ។

- ម៉េចក៏មិនបាន? យើងថាត្រូវតែបាន!

តាដីរមេភូមិស្រែកតប។ អ្នកស្រុកក៏ហោរឡើងតាមពីក្រោយ។ ចាន់ ស្ទុះហក់រឹងទៅជិតម្តាយនាងហើយសួរថា :

- មានរឿងអ្វីហ្នឹងម៉ែ?

មីងចាន់បែរមកតបថា :

- គឺតាមេភូមិ កំពុងនាំអ្នកស្រុក មកចាប់កូនអោយរៀបការជាមួយអា អន្ទិត ចៅយាយភួងនោះអី!

- ចាំស? ម៉ែមានប្រសាសន៍ថាម៉េច? (ចាន់សួរទាំងរន្ធត់)

សូម្បីតែខេវិនក៏ភ្ញាក់ដូចគេចាប់គ្រវែងដែរ។ ភ្លាមនោះតាដីរក៏មាន ប្រសាសន៍ឡើងថា :

- មែនហើយ! អ្នកភូមិបានឮខ្ចរខ្ចាយគ្រប់គ្នាថា ឯងទាំងពីរបានជំរត់គ្នា ថ្មី១នេះ។ ហើយអំបាញ់មិញនេះ សុខ១កូនប្រុសអញវាខ្យល់គប្រកាច់ ទើប តែដឹងខ្លួនឡើងវិញ។ ដូច្នេះអ្នកស្រុកអ្នកភូមិយើងត្រូវតែចាប់ឯងរៀបការ ដើម្បីកុំអោយដូនតា ខឹងសម្បារមកកាច់កកូនចៅដែលមិនដឹងរឿងអោយ មានទុក្ខភ័យទទេ១អញ្ចឹង។

មីងចាបក៏ប្រកែកឡើងថា :

- ក្រែងមេភូមិនិងអ្នកស្រុកដឹងស្រាប់ហើយតើថា អាអន្ទិតមួយនេះវាត្រូវ រៀបការនឹងចៅស្រីដែលយាយភួងទុកដាក់អោយ។ បើមេភូមិធ្វើដូច្នេះ យាយភួងមិនខឹងសម្បារនឹងពួកយើងស្លាប់ហើយទេ ដែលយើងមិនគោរព តាមបំណងរបស់គាត់។

-បើយាយភួងខឹងចង់មួលក អោយគាត់ទៅមួលកអន្ទិតដែលមិនគោរព តាមដូនតារបស់វានោះទៅ កុំមកកាច់កអ្នកដទៃដែលមិនដឹងរឿងអី!

- ចុះបើចៅយាយភួងលេចមុខមក តើអោយយើងធ្វើម៉េចទៅ? (មីងចាប សួរឡើង)

CHANBOKEO.COM

- មានធ្វើម៉េច? គឺចាប់កំលោះៗ ក្នុងភូមិអោយឈរតំរៀបជួរ ហើយឱ្យ នាងរើសយកមួយរៀបការជំនួសទៅ!

តាមេភូមិនិយាយចប់ អ្នកស្រុកក៏ហ៊ោរខ្សៀវខ្សាឡើងខ្លាំងៗសាជាថ្មី។ ពេលនេះ ទាំងមឹងចាប ទាំងនាងចាន់ ទាំងខេវិន ទោះបីជាខំស្រែកឬខំ និយាយអ្វីក៏ដោយ ក៏ស្តាប់លែងឮទៀតហើយដែរ។ ក្នុងមួយពព្រិចភ្នែក អ្នកស្រុកបានរៀបចំកូនវេទិកាមួយយ៉ាងស្អាត នៅមុខផ្ទះរបស់មឹងចាប ដែលត្រូវគេចងមាត់ មិនអោយនិយាយអ្វីឡើយហើយត្រូវគេចងដៃទាំងគូ ផ្តោបអោយឈរសំពះមេភូមិនៅមួយកន្លែងក្បែរវេទិកា។ ចំណែកខេវិន ក៏ត្រូវពូគ្រុឌនិងអ្នកស្រុកចាប់ប្តូរសំលៀកបំពាក់ថ្មី អោយក្លាយទៅជាកូន កំលោះអ្នកភូមិម្នាក់យ៉ាងសង្ហារប្លែកតែម្តង។ ពេលនោះ នាយយើងក្លាយ ជាភន្តំភាំងស្មារតីអស់រលីងតែម្តងហើយ មិនដឹងថាត្រូវធ្វើយ៉ាងម៉េចឱ្យ សមទេ គឺប្រកែកមិនកើត តវ៉ាមិនបាន ក៏ចេះតែបណ្តោយអោយទៅតាម តែដំណើរអញ្ចឹងទៅ។ ភ្លាមនេះ តាដឺរ ដែលជាមេភូមិ ក៏ចាប់មេក្រូផ្ទពិល ឡើងប្រកាសបើកពិធី ដូចតទៅ :

- ជំរាបពុកម៉ែតាយាយអ្នកស្រុកអ្នកភូមិយើងនេះទាំងអស់! ជំរាបដល់ យាយភួងនិងម្ចាស់ទឹកម្ចាស់ដី! ថ្ងៃនេះវេលានេះ ពួកយើងសូមបើកពិធី រៀបមង្គលការកូនចៅ ដើម្បីអោយគេបានក្លាយជាគូស្រករយ៉ាងពេញ លក្ខណៈតាមប្រពៃណីទំនៀមទំលាប់។ សូមដូនតា ជួយដឹងឮផង!... ហក់! សូមអញ្ជើញកូនក្រមុំបើកវាំងននា!

ឃ្មោះក៏ចាប់លាន់ឮឡើង ព្រមជាមួយនឹងភ្លេងបើកវាំងននយ៉ាង ពិរោះគ្រលួច។ កូនក្រមុំក៏លេចធ្លោឡើងនៅឯមាត់ទ្វារផ្ទះ ដោយមានស្រី ក្រមុំក្នុងភូមិក្មេងៗហែហមកជាមួយផង។ ខេវិនងើបមុខឡើង បែរមើល ទៅនាងចាន់... ស្រាប់តែនាយបើកភ្នែកធំៗយកដៃឈ្លីភ្នែកពីរបីដង ត្បិត មិនជឿថានារីដែលមាណពកំពុងឃើញនោះ ជានារីដ៏មានរូបឆោមយ៉ាង សោភាគួរឱ្យចាប់ចិត្តបំផុត។ នាយលាន់មាត់ខ្សិបៗថា :

- ចាន់...! នាងពិតជាទេពធិតា ដែលបេះដូងរបស់ខ្ញុំកំពុងដង្ហោយហៅជា យូរមកហើយនោះ មែនទេហ៎?

ពេលនោះ ខេវិនរន្ធត់ចិត្តផង រំភើបផង សប្បាយផង ច្របូកច្របល់ ក្នុងចិត្តផង ព្រោះអីពេលនេះរូបនាយកាន់តែរសាត់ឆ្ងាយពីគំរោងការដែល បានគិតត្រៀមទុកនោះហើយ។ ខេវិនសំលឹងចាន់មិនដាក់ភ្នែក សឹងតែភ្លេច ដកដង្ហើមម្តងៗទៅហើយ សូម្បីតែអ្នកស្រុកអ្នកភូមិទាំងឡាយនោះក៏ចំហ មាត់មើលនាងមិនព្រិចភ្នែកដែរ។ ភ្លាមនោះ តាដឺរជាមេភូមិក៏ប្រកាសបន្ត ទៅទៀតថា :

- សូមជូនពរអោយអ្នកទាំងពីរចាប់ដៃគ្នាជាគូគ្រង រក្សាគ្នាដោយចិត្តស្មោះ ស្មគ្រភក្តិបំផុត។ ឥលូវនេះ សូមអញ្ជើញលោកមេបានិងចាស់ទុំទាំងឡាយ ឡើងចងដៃកូនប្រុសកូនស្រីរបស់យើង។

ពូគ្រុឌក៏ចាប់មឹងចាបអោយមកចងដៃកូន ហើយខ្សិបដាក់ត្រចៀក គាត់ថា :

-ថ្ងៃនេះជាថ្ងៃជោគថ្ងៃជ័យ កុំធ្វើអ្វីអោយជោគជតារាសីកូនស្រីកូនប្រុស របស់យើងចុះឱនថយអីណាបងចាប! តោះ! ទៅចងដៃកូនទៅណា៎!

មឹងចាបទើសទាល់ក្នុងចិត្តក៏ពិតមែន តែលុះឃើញអ្នកស្រុកគេស្រុះគ្នា មេភូមិក៏ជ្រោមជ្រែង ហើយបែរមើលទៅកូនៗក៏ហាក់ដូចជាសក្តិសមគ្នា ឥតខ្ចោះ មឹងយើងក៏ប្តូរចិត្តបែរញញឹមដាក់ពូគ្រុឌយ៉ាងស្រស់ រួចក៏ងក់

CHANBOKEO.COM

ក្បាលឡើង ។ ពូក៏ស្រាយកន្សែងចេញពីមាត់របស់មីង ព្រលែងគាត់អោយ មានសេរីដើម្បីមកចងដៃកូន ។ មីងចាន់ស្រវាអំបោះសបីសរសៃ មកចង ដៃកូនទាំងពីរព្រមទាំងខ្សិបផ្តែផ្តាំថា :

- សូមកូនបីបាច់ថែរក្សាគ្នា ទៅវិញទៅមក លុះថ្ងៃចុងក្រោយនៃជីវិត ណាំកូនណាំ! សូមមានខន្តីចំពោះគ្នា មិនថាមានអ្វីកើតឡើងក្នុងជីវិតទេ!

ចាន់ឮម្តាយជូនពរដូច្នោះ ក៏រលីងរលោងទឹកភ្នែកភ្លាមមួយរំពេច ។ ខេវិនឃើញដូច្នោះ ក៏នឹករំជួលចិត្តអាណិតធិតាណាស់ ។ បុរសយើងក៏លូក ទាញដៃរបស់នាងមកកាន់ផ្តោបជាមួយដៃរបស់ខ្លួន ហើយអោនសំពះមីង ចាបព្រមគ្នាជាមួយនឹងចាន់ទាំងគូតែម្តង ។ អ្នកស្រុកឃើញដូច្នេះក៏នាំគ្នា ទះដៃហ៊ោរកញ្ច្រៀវឡើង សើចក្អាកក្អាយផង ច្រៀងផង បន្ទរគ្នាទៅវិញ ទៅមកយ៉ាងសប្បាយក្រៃលែង ។ រាត្រីនេះ អ្នកស្រុកទាំងឡាយបានចូលរួមរាំលេងតន្ត្រីស្គរដៃដែលប្រគំបទភ្លេងស្រុកស្រែ យ៉ាងសប្បាយឥតទោ ម្នេញ ។ ពិធីបានចប់សព្វគ្រប់ទៅដោយបរិយាកាសសែនរមនាក្រៃលែង ។

នៅរាត្រីផ្សំដំណេក...

មីងចាន់រៀបផ្តិលទឹកមានផ្កាម្លិះអប់យ៉ាងក្រអូបមកប្រស់ព្រំលើខ្នើយ មង្គលនិងកន្ទេលក្រហមក្នុងបន្ទប់ផ្សំដំណេក រួចហើយក៏បែរមកជូនពរកូន ទាំងពីរដែលកំពុងសំពះប្រណម្យទទួលពរជាពិសេសចុងក្រោយពីគាត់:

- ម្តាយសូមផ្ញើកូនស្រីផងណាំខេវិន! សូមកូនរក្សានាងដោយក្តីអាណិត ស្រលាញ់ តែប៉ុណ្ណោះគ្រប់គ្រាន់នឹងអោយម្តាយស្ងប់ចិត្តហើយណាំកូន ។

ថាចប់មីងចាបក៏ដើបដើរចេញទៅ ។ ទុកអោយអ្នកទាំងពីរនៅអង្គុយ សំលឹងមើលមុខគ្នាធ្វើអេះអុញៗ មិនដឹងថាខ្លួនត្រូវប្រព្រឹត្តកិរិយាឫកពា យ៉ាងណាអោយសម ។ បន្តិចក្រោយមក ខេវិនក៏ស្រដីទៅចាន់ថា :

- បងដឹងហើយថា អ្វីៗទាំងអស់ជាកំហុសរបស់បង ដែលធ្វើអោយជីវិត នាងក្លាយទៅជាយ៉ាងនេះ... អោយបងសូមទោសផងណាំចាន់!

ចាន់ឮហើយក៏បែរមកខេវិនហើយឆ្លើយមកវិញថា:

- វាជារឿងថៃដន្យជាជាង យើងមិនគួរបន្ទោសនរណាទេ ។

បន្ទាប់មក អ្នកទាំងពីរក៏នៅស្ងៀមស្ងាត់យ៉ាងយូរ ព្រោះត្បិតម្នាក់ៗ សុទ្ធតែមានអារម្មណ៍រំជើបរំជួលក្នុងចិត្តតែរៀងៗខ្លួន ។ កាលពីបួនថ្ងៃមុន ខេវិនស្ថិតនៅសហរដ្ឋអាមេរិក បររថយន្តកាត់សរសៃព្រិលធ្លាក់សក្បុស មានពូកដេកស្រួល មានសង្សារដើរជាមួយ ។ ពីរយប់បន្ទាប់មក នាយធ្មេច នៅលើយន្តហោះ ។ យប់ម្សិល នាយយើងដេកលើគ្រែរនាបឫស្សីរកំពុក ស្រាប់តែយប់នេះ បែរជាបានមកផ្សំដំណេកជាមួយក្រមុំស្រុកស្រែម្នាក់... ហ៊ឹ! គិតទៅគិតមក ខេវិនចេះតែគិតថា ខ្លួនកំពុងតែយល់សុបិនដ៏ចំលែក មួយ ។ ចំណែកនារីយើងវិញក៏រិតតែភ្ញាក់ផ្អើលណាស់ទៅទៀត ។ នៅសុខៗ ស្រាប់តែបានមករៀបការជាមួយបុរសចំលែកម្នាក់ដោយមិនបានព្រាង ទុក ។ ពេលនេះ នាងចេះតែសួរខ្លួនឯងដដែលៗថា តើនាងកំពុងស្ថិតនៅក្នុងយល់សប្តិឬក្នុងការពិត? តើនាងត្រូវបត់បែនខ្លួន ត្រៀមចិត្ត យ៉ាងណាចំពោះបុរសចំលែកម្នាក់នោះ ។

CHANBOKEO.COM

ច្រើនម៉ោងកន្លងទៅ...

ខេវិនឃើញនាងចាន់អង្គុយច្រងុកមិនព្រមចូលគេង ក៏គិតថានាង ប្រហែលជាទើសទាល់នឹងវត្តមានរបស់នាយហើយ ។ បុរសយើងក៏ងើប ឈរឡើងរួចស្រដីថា :

- ចាន់គេងនៅលើគ្រែនេះចុះណា៎ ចាំបងទៅគេងនៅខាងក្រៅវិញ ។

ថាហើយនាយយើងក៏បើកទ្វារផ្ទះចេញទៅបាត់ ។ នាងចាន់ក៏ស្ទុះរឹង ងើបឡើងចងមុងយ៉ាងរហ័ស រួចប្រាសកេសាលើខ្នើយមង្គលភឹង សំងំរក គេងភ្លាម ត្បិតអីនាងកំពុងតែងងុយដល់សូរហើយ ។ រំពេចនោះ ស្រាប់តែមានគេបញ្ជូនខេវិនឱ្យចូលមកក្នុងបន្ទប់វិញយ៉ាងរហ័ស ។ នាងក្រមុំយើង ឃើញហើយក៏ស្ទុះងើបភឹង ។ ខេវិនឃើញចាន់មានកិរិយាភ្ញាក់ផ្អើល ក៏នៅ ឈរអេះអុញ ហើយស្រដីថា :

- គឺ... ចាស់ៗ គាត់ច្រានបងអោយចូលមកវិញទេ... ការពិត... បងពិតជាមិនហ៊ានទៅរំខានអូនមែនណា៎ចាន់!

ចាន់នៅអឹមអៀនមួយស្របក់មិនចេញស្តី តែលុះឃើញខេវិនត្រូវ មូសរោមរញ៉ី នាងនឹកអាណិត មិនដាច់ចិត្តអោយខេវិនត្រូវមូសខាំ ក៏វាចាឡើងទៅនាយថា :

- មិនអីទេ គ្រែនេះក៏ទូលាយដែរ ។ អ្នកចូលមកសំរាន្តនៅម្ខាងនេះចុះណា៎!

ថាហើយ នាងគោះជាយខ្នើយម្ខាងទៀត ជាសញ្ញាអនុញ្ញាតអោយ ខេវិនរួមខ្នើយជាមួយនាងយប់នេះ បណ្តោះអាសន្នសិន ។ ខេវិនឃើញ ដូច្នោះ នឹកអរព្រួចមិនចេញស្តី ។ បន្តិចមក នាយក៏ដាក់ខ្លួនប្រាសក្បែរចាន់ ដែលកំពុងគេងបែរខ្នងមកអោយនាយ ។ រាត្រីនោះ បុរសយើងមាន អារម្មណ៍រំភើបចំលែកណាស់ ។ ពិតមែនតែខ្លួននាយកំពុងគេងនៅលើគ្រែរនាបក្រាលកន្ទេលកក់ពណ៌ក្រហម កើយខ្នើយបញ្ជូកផ្កាគរ ក្រោមស្បៃ មុងដ៏ចង្អៀតមួយ តែនាយបែរជាមានអារម្មណ៍រំភើបញាប់ញ័រហាក់បីដូច ខ្លួនរបស់នាយកំពុងហោះអណ្តែតនៅកណ្តាលសួគ៌ាវេហាស៍ឥតចឹង ។ យូរៗម្តង នាយលួចងើបបែរមើលទៅចាន់ដែលគេងនៅសំងំស្ងៀម ហើយនឹក គិតទៅឆ្ងាយសែនឆ្ងាយ ។ យប់នោះខេវិនរសាប់រសល់ណាស់ ។ មាណព យកដៃគងថ្ងាសនឹកដល់ជីវិតកុមារភាពមួយដែលនាយធ្លាប់រស់ជ្រកក្រោមអង្គការកុមារកំព្រាតាមជំរំទល់ដែនអស់ពេលជាយូរឆ្នាំ ទំរាំមីងពៅនិង ពូវៃតាមរកនាយឃើញ ហើយធានាយកនាយអោយបានមកនៅអាមេរិក រួចគាត់ក៏ចិញ្ចឹមបីបាច់ថែរក្សាជាកូនជាចៅរហូតមក ។ ប៉ុន្តែ មីងពៅពូវៃខិតខំធ្វើការណាស់ មិនសូវនៅផ្ទះទំនេរមានឱកាស សប្បាយជុំគ្នាជាមួយ នាយជាគ្រួសារប៉ុន្មានទេ ឃើញតែធ្វើការឱ្យតត្រុក ។ លុះនាយមានលំហាត់ ពីសាលា មានចំងល់ឬការខ្វះខាតអ្វី នាយក៏មិនដឹងទៅសួរនរណាដែរ ។ ម្ល៉ោះហើយខេវិនចេះតែរៀនធ្លាក់រាល់ឆ្នាំ ធ្វើឱ្យពូវៃមីងពៅបន្ទោសនាយ ឥតឈប់ឈរ ។ លុះតប់ប្រមល់ចិត្តពេក ខេវិនក៏ចេះតែដើរ លេងប៉ៅឡែ ជាមួយក្មេងៗដទៃរហូតដល់បានជួបផល្លីននិងមិត្តភក្តិ ដែលបបួលនាយដើរលក់អាភៀនលៀងជីវិត ។ បន្ទាប់មក នាយក៏ចេះតែលង់ខ្លួនឆ្ងាយទៅៗ ហើយក៏ប្រែជាមិនហ៊ានត្រលប់ចូលផ្ទះ

CHANBOKEO.COM

ជួបមិងពៅពូរ៉េវិញ ខ្លាចគាត់ដឹងនូវ ការប្រព្រឹត្តដ៏ខុសឆ្គាំឆ្គងរបស់ខ្លួន ម្ល៉ោះហើយក៏ ចេះតែគេចមុខគេចច្រមុះ
ពីគាត់តែអញ្ចឹងទៅ ។ ចៃដន្យអ្វី ថ្ងៃនេះ នាយក៏បានធ្លោយមកដល់ស្រុក ខ្មែរហើយបានជួបនារីស្រុកស្រែចំលែកម្នាក់
ដែលដឹកនាំជីវិតរបស់នាយ អោយទៅជួបរឿងហេតុប្លែកៗអស្ចារ្យថែមទៀត ។ ប៉ុន្តែទោះជាយ៉ាងណា
នាយយើងបែរជាមានអារម្មណ៏រំភើបរីករាយចំពោះឧប្បដ្ឋិហេតុទាំងឡាយ ដែលបានកើតឡើងនៅថ្ងៃនេះ
ហើយក៏ពេញចិត្តនឹងទទួលនូវលទ្ធផលដែល ដំណើររឿងហុចអោយដល់នាយនៅពេលនេះណាស់ ទោះបីជានាយមិន
អាចទាយស្មានដឹងមុននៅឡើយថា ថ្ងៃស្អែកនេះ   ជីវិតរបស់នាយនឹងប្រែ
ប្រួលបែបណាក៏ដោយ...

រំពេចនោះ ចាន់ក៏ប្រែខ្លួនឡើង ។ ខេរិនក្រលេកឃើញហើយ ក៏ធ្វើពើ ជាសំងំគេងទៅវិញ ។ ការពិត
ចាន់ក៏គេងមិនលក់ដូចតែគ្នាដែរ ព្រោះនាង កំពុងតែមានអារម្មណ៏ភ្ញាក់ផ្អើល ចំពោះហេតុការណ៏    ដែលមិនបានព្រាង
ទុកទាំងឡាយនោះ ។

រាត្រីនោះ គ្មាននរណាគេងលក់មួយស្រលេតទេ  ។ គេទាំងពីរនាក់ចេះ តែលួចបើកភ្នែកអើតមើលគ្នាទៅវិញទៅមក ទាល់ភ្លឺ...

នៅខាងក្រៅ ធាងដូងយោលយោគតាមជំនោរខ្យល់រាត្រី បញ្ចេញ សំលេងខ្សាកៗ លាយឡំនឹងសំលេងឆ្កែលួងចុងភូមិល្វើយៗ
រឹងរិតតែធ្វើឱ្យ បុរសនារីយើងទាំងពីរកាយ រឹងរឹតតែព្រឺព្រួចក្នុងហឫទ័យថែមឡើងកាន់ តែខ្លាំង... ប្លែកតែមិងចាន់ទេ
ដែលនិទ្រាយ៉ាងមានសេចក្តីសុខឥតកង្វល់ ។

៩៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩

៩

# វគ្គទី៤
# រាហូគូចន្ទ័

**ថ្ងៃទី២០មករា ២០០៦**

ព្រហាមឡើង ថ្ងៃរះចាំងពន្លឺ...

ខេវិនភ្ញាក់ភ្ញាក់ស្មារតីឡើង ស្រាប់តែបាត់ចាន់ពីបន្ទប់ ។ ស្រាប់តែនាយ យើងនឹកបារម្ភពីនាងចំលែកតែម្តង មិនដឹងជានាងក្រោកទៅណាទាំងព្រឹក ព្រលឹមដូច្នោះ ។ ខេវិនក៏ស្ទុះចេញទៅក្រៅផ្ទះយ៉ាងរហ័សតាមរកចាន់ភ្លាម ក៏ប្រទះនាងកំពុងស្ងៃអង្ករ:

- ចាន់! អូនកំពុងធ្វើអ្វីហ្នឹង?

- ចាស់! ស្រិតអង្ករ ដាំបាយ!

គ្រាន់តែឃើញមុខចាន់ភ្លាមពេលណា នាយយើងសប្បាយចិត្តណាស់ រួចញញឹមឡើងភ្លាមៈ

- អោយបងសុំរៀនស្រិតអង្ករផងបានទេ?

- មានអី! សាកបន្តិចមើលទៅ ។

ខេវិនទាញអង្រែមួយមក ក៏ដាក់ផាំងមួយទំហឹងដៃ ។ អង្ករក៏ហើរ ខ្ចាយព្រោងចេញពីត្បាល់ ។ នាយយើងលាន់មាត់ :

- ពុទ្ធោ!.. គឺ.... អោយបងសុំទោសផងណាំចាន់! បងគ្មានបំណងធ្វើអោយ កំពប់អង្ករទេ ។

ចាន់ឃើញហើយសើចខឹក១ :

- រៀនយូរ១ទៅចេះហើយណាំអ្នក!

ឃើញចាន់មិនខឹងនឹងនាយដែលធ្វើឱ្យអង្ករកំពប់ខ្ចាត់ខ្ចាយ ខេវិនធូរ ទ្រូងបន្តិច ។ ភ្លាមនោះ ចាន់ក៏លើកថាសបបរមកដល់ :

- អ្នកអញ្ជើញពិសារបបរទៅទាន់ក្តៅ១! ហើយនេះ ត្រាំងម៉ែស្រូវ ខ្ញុំងើប កកូរវាតាំងពីព្រហាមម្ល៉េះ ។

ខេវិនលួចសង្កេតគ្រប់កិរិយាទាំងអស់របស់ចាន់ ។ មិនដឹងហេតុអ្វីទេ ដែលមាណពយើងទាក់ភ្នែកទាក់ចិត្តទាក់អារម្មណ៏នឹងនារីមួយរូបនេះយ៉ាង

CHANBOKEO . COM

ជ្រាលជ្រៅបំផុតហើយមានអារម្មណ៍ ដូចជានាយបានស្គាល់នាងជាយូរមក ហើយតចឹង គឺមាននិស្ស័យទំនាក់ទំនងមនោសញ្ចេតនា យ៉ាងជិតស្និទ្ធិ ជាមួយធិតាស្រុកស្រែមួយនេះរកថាមិនត្រូវសោះ ។ លុះក្រលេកទៅស្តក ឃើញបបរសជាមួយនៃពៅ នាយយើងគ្រវីក្បាល :

- បងមិនដែលបរិភោគអាហារបែបនេះទេ

- តែពេលនេះ អ្នកត្រូវតែខំពិសារហើយ ។ ទោះបីចង់ហ៊ីហាជាងនេះ ក៏មិន អាចទៅរួចដែរ ព្រោះផ្ទះខ្ញុំអាចមានសមត្ថភាពរកបានត្រឹមប៉ុណ្ណឹងឯង ។

មែនហើយ! ខេរិនមិនអាចត្អូញត្អែ រើសចំណីតទៅទៀតបានទេ ត្បិត នាយបានរំខាននាងច្រើនណាស់ទៅហើយ ក្នុងឱកាសដែលនាយមិនទាន់ បាននាំប្រយោជន៍អ្វីដល់នាងចាន់វិញបន្តិចសោះ ។ ពេលនេះ ខេរិនត្រូវតែ ប្រឹងលេបបបរសទាំងត្រដរ ។ ប៉ុន្តែគួរឱ្យឆ្ងល់ណាស់ ពេលខេរិនលើកបបរ មកទទួលទាន ស្រាប់តែអស់ពីរបីចានបន្តកន្ទុយគ្នាតែម្តង ។ មួយស្របក់ ក្រោយមក នាយយើងក៏យកស្លាបព្រាចូកតាំងម៉ែមកភ្លក្ស ហើយក៏បើក ភ្នែកធំៗលាន់មាត់ថា :

- យី! ស្ករនេះពិតជាឈ្ងុយឆ្ងាញ់ប្លែកណាស់ ។

មែនហើយ ខេរិនមិនធ្លាប់បរិភោគទេពីមុនមក ។ រសជាតិតាំងម៉ែ ស្រូវពិតជាមានឱជារសប្លែកមែន ដាក់មួយម៉ាត់ហើយចង់ថែមមួយម៉ាត់ ទៀត ។ ភ្លាមនោះ ចាន់រៀបចំបាយមួយស្រាក់យ៉ាងរៀបរយ ហើយក៏បែរ មកបបួលខេរិនថា :

- ខ្ញុំបានដណ្តាំអាហាររៀបចំបំរុងជូនអ្នកទៅវត្តថ្ងៃនេះ អ្នកត្រៀមខ្លួន ហើយឬនៅ?

- ទៅវត្ត? ទៅធ្វើអី?

ខេរិនអេះអុញ ត្បិតខ្លួនមិនដែលទៅវត្តធ្វើបុណ្យម្តងណាឡើយ ។ កាលពីនៅសហរដ្ឋ នាយចូលចិត្តដើរហើរកន្លែងសប្បាយៗ ហើយចេះតែ គិតថា វត្តគឺជាមណ្ឌលសំរាប់មនុស្សចាស់តែប៉ុណ្ណោះ ។ ភ្លាមនោះ ស្រាប់តែ នាងចាន់ពោលបន្តថា :

- អ្នកចាំទេ? កាលពីម្សិល ពេលអ្នកអានសំបុត្រមរតកទីមួយរបស់យាយ តើគាត់សុំអោយអ្នកធ្វើអ្វីខ្លះ?

ពេលនោះ ខេរិនភ្ញាក់ដូចគេចាប់គ្រវែងតែម្តង ។ ហេតុអ្វីនាយដែល ជាចៅបង្កើតបែរភ្លេច មិនចាំពាក្យបណ្តាំរបស់យាយអ្វីសោះអញ្ចឹង ចាញ់ ទាំងស្រីក្មេងម្នាក់ដែលមិនមែនជាសាច់ញាតិឱ្យមកចងចាំជំនួស ។ គួរឱ្យ អាមាសមែន! គិតឃើញដូច្នោះ ខេរិនក៏ស្ទុះប្រញិបប្រញាប់ រៀបចំខ្លួន ចេញដើរទៅតាមចាន់ឡើង រហូតដល់វត្តខាងលើខ្នងភ្នំព្រះនេត្រព្រះ ។

នៅចំពោះមុខព្រះភក្ត្រព្រះពុទ្ធអង្គ និងព្រះសង្ឃចៅអធិការវត្ត ចាន់ លួចឱ្យបបង្រៀនខេរិន អំពីកិរិយាគារវកិច្ចល្អសមសួននៅក្នុងវត្តអារាម ។ ខេរិនប្រឹងធ្វើតាមទាំងបែកញើសសស្រាក់ ប៉ុន្តែ នាយក៏សប្បាយចិត្តប្លែក ណាស់ដែរដែលនាយមានឱកាសទទួលស្គាល់នូវមរណភាពរបស់ឪពុកម្តាយ ខ្លួនហើយក៏បានមកច្រូចទឹកបង្សុកូល ជូនដល់វិញ្ញាណក្ខន្ធ័របស់លោកទាំង ពីរនៅស្រុកកំណើតដោយផ្ទាល់ដៃឯងដូច្នោះ ។ ពេលនោះ ខេរិនសង្កេត

CHANBOKEO .COM

ឃើញជូនជីមួយអង្គនៅក្បែរនោះ សំលឹងនាយមិនដាក់ភ្នែកសោះឡើយ ហើយថែមទាំងញញឹមដាក់នាយយ៉ាងស្រស់ទៀតផង តែជូនមិនញវាចាអ្វី មកនាយយើងឡើយ ឃើញតែនៅស្ងៀមស្ងាត់ធ្វើមុខញញឹមតែប៉ុណ្ណោះ។

លុះនាយប្រគេនចង្ហាន់ព្រះសង្ឃរួចហើយ ចាន់ក៏នាំខេរិនដើរមកកាន់ខ្ទម យាយភួងវិញ។ ខេរិននឹក ឆ្ងល់ ក៏សួរចាន់ឡើងថា :

- ចាន់! អូននាំបងមកទីនេះធ្វើអ្វី?

ចាន់សំលឹងមុខខេរិនហើយញញឹម រួចឆ្លើយថា :

- អ្នកមិនចង់ថ្វាយសំណែនឬអុជធូបឧទ្ទិសជូនទៅដល់ជូនតាខ្លះទេឬអ្វី? ឬក៏អ្នកមកទីនេះ ដើម្បីទទួលយកមរតកតែម្យ៉ាង?

ឮចាន់និយាយចំចំណុចខ្សោយ ខេរិននៅស្ងៀមមិនហ៊ានមាត់ក។ ការ ពិតទៅ គឺដូច្នោះមែន!

ខេរិនមិនដែលបានគិតមួយដងសោះ ថានឹងមកធ្វើ បុណ្យជូនជីដូន ឬសូម្បីជូនឪពុកម្តាយរបស់នាយម្តងណាឡើយ។ នេះបើកុំតែបានចាន់រំលឹកម្ល៉េះសមនាយច្បាស់ជាភ្លេចរហូតរៀងទៅហើយ។ ដឹងខ្លួន ថាយ៉ាប់

ខេរិនក៏ស្ទុះទៅជិតនាងក្រមុំយើងរួចសំរុតខ្លួនចុះ ស្រវាធូបអុជ ព្រមគ្នាជាមួយធិតាយើង

បន្ទាប់មកក៏អោនថ្វាយបង្គំបីដងហើយឧទ្ទិសនៅ ក្នុងចិត្តស្ងាត់ៗ។ ចាន់ក៏លួចមើលខេរិន រួចហើយញញឹមយ៉ាងបំព្រងតែ ម្នាក់ឯង ដោយបានដឹងថានាយក៏នៅមានចិត្ត គោរពនិងទទួលស្គាល់ជូនតា របស់ខ្លួន ដោយគ្មានរើសអើង។ ពេលនោះ

ខេរិនបែរមកឃើញនាង ចាន់ញញឹម ក៏ញញឹមតបវិញ ទំនងហាក់ដូចជាចង់ថ្លែងនូវអំណរគុណយ៉ាង

ជ្រាលជ្រៅដែលនាងបាននាំមាណពមកអុជធូបជូនបុព្វការីជនរបស់ខ្លួន។

ថ្ងៃនេះ ខេរិនមានអារម្មណ៍ថា នាយគឺជាមនុស្សថ្មីម្នាក់ដែលកំពុងតែ ចាប់កំណើតម្តងទៀត នៅលើស្រុកដីប្រទេសខ្លួនឯង។ បុរសយើងមាន ស្មារតីស្រស់ថ្លាណាស់ ហើយក៏មានសេចក្តីសុខក្នុងចិត្តឥតឧបមា រកពាក្យ ណាមកថ្លែងឱ្យសមមិនបានឡើយ។ មួយស្របក់ក្រោយមក នាយយើងក៏ ដើរទៅរកចាន់ ដែលកំពុងអង្គុយឈរមើលក្មេងបង្ហោះខ្លែងឯកណ្តាលវាល ស្រែ ហើយឧទានខ្សិបហៅនាងតិចៗ :

- ចាន់!...

ធិតាងាកមកឃើញខេរិនញញឹមពព្រាយ ក៏ញញឹមតបវិញ ស្រាប់តែ សង្កេតឃើញថា

នាយកំពុងតែកាន់អ្វីមួយលាក់នៅក្រោយខ្នង។ នាងនឹក

ឆ្ងល់ពេកក៏សួរទៅនាយយើងថា :

- អ្នកមានអ្វីលាក់នៅក្រោយខ្នងហ្នឹង?

- គឺ... បងមានរបស់អ្វីមួយ... ចង់អោយចាន់នោះអី

- គឺ អ្វីទៅ?

ខេរិនទាញដៃចេញមកពីក្រោយខ្នង។ ចាន់តាមសំលឹងមើលមិនដាក់ ភ្នែក ស្រាប់តែប្រទះឃើញនាយកាន់ផ្កាត្រកួនមួយទង។ នាងលាន់មាត់ សួរខេរិនថា :

- ស្លាប់ហើយ! ទៅបេះកូនផ្កាត្រកួនយកមកធ្វើអីហ្នឹង?

CHANBOKEO.COM

ខេវិនញញឹមហើយតបវិញថា :

- មែនហើយ! ផ្កាត្រកួនដ៏ទន់ភ្លន់មួយទងនេះ ពិតមែនតែដុះកណ្តាលវាល ស្រែ មើលទៅហាក់ដូចជាគ្មានតម្លៃអ្វីសោះ ប៉ុន្តែ ចំពោះវាលស្រែដ៏ខៀវ ស្រស់បំព្រង បើគ្មានផ្កាត្រកួនជួយរីកលំអផងទេនោះ ធម្មជាតិទាំងឡាយ ប្រាកដជាពុំមានអត្ថន័យពេញលក្ខណៈឡើយ ។ ដូចគ្នានេះដែរ បើកុំតែបាន រូបចាន់មកជួយស្រោចស្រង់ ម្ល៉េះសម ជីវិតរបស់ខេវិនពេលនេះ មិនដឹងជា ក្លាយទៅជាយ៉ាងណាទៅហើយទេ...

ថាហើយ ខេវិនក៏យកដៃទៅទាញក្រមារបស់នាងចេញពីកេសាហើយ ក្បៀសផាត់សក់របស់នារីយើងចេញពីវង្វង់ភក្ត្រដោយថ្នមៗ ហើយក៏យក ផ្កាត្រកួនទៅសៀតអោយនាងដោយដួងចិត្តរំភើបញាប់ញ័រ ព្រមទាំងវាចា បន្ថែមថា :

- ចាន់! បងអរគុណអូនណាស់ ដែលនាំអោយជីវិតបងភ្លឺស្វាង មានរស្មី យ៉ាងល្អត្រកាល ដែលបងមិនដែលស្គាល់រសជាតិជីវិតបែបនេះពីមុនមក

មើលទៅក្រមុំយើងក៏ហាក់ដូចជារីករាយណាស់ដែរ កាលបើបាន ទទួលការថ្នាក់ថ្នមពីបុរសម្នាក់ដែលនៅក្បែរខ្លួន ។ ថ្វីបើនាងទើបតែបាន ជួបខេវិនមិនទាន់បានពីរថ្ងៃពេញផង ប៉ុន្តែ នាងបែរជាមានអារម្មណ៍ថា នាងបានជាប់ជំពាក់ផ្លូវចិត្តជាមួយបុរសរូបនេះ យ៉ាងជ្រាលជ្រៅរកប្រកែក មិនបានឡើយ ។ នាងងើបសំលឹងមុខខេវិន ដែលកំពុងសំលឹងមករកនាង ដោយក្រសែភ្នែកដ៏មានមន្តស្នេហ៍កប់ជំរៅក្នុងដួងចិត្ត ធ្វើអោយបេះដូង របស់នាងរណ្តំខុសចង្វាក់ឱបខាក់ៗ រហូតទំលាក់មុខចុះលែងហ៊ានសំលឹង កែវភ្នែករបស់នាយយើងតទៅទៀត ។ រីឯខេវិនវិញ គេសំលឹងផ្ទៃមុខនាង មិនដាក់ភ្នែក ឡើយ ។ គេគិតតែម្នាក់ឯងនៅក្នុងចិត្តស្ងាត់ៗថា :

- កែវភ្នែកនេះហើយ វង្វង់មុខនេះហើយ ដែលបងបានគេងសុបិនរង់ចាំជួប អស់ពេលជាយូរមក... អូនគឺជាទេពធិតាម្ចាស់ដួងចិត្តរបស់បងពិតប្រាកដ ណាស់ មិនអាចប្រកែកបានទេណាំព្រលឹងមាសបង ។

បន្តិចមក ខេវិនក៏ហុចដៃអោយចាន់ ។ នាងឃើញហើយក៏ហុចដៃឱ្យ នាយត្រលប់វិញ ។ ខេវិនទទួលដៃរបស់ធិតាហើយស្រវាក្តាប់យ៉ាងណែន ហាក់ដូចជាចង់ប្រាប់ថានាយកំពុងតែលង់ស្នេហ៍ របស់នារីយើងយ៉ាងជ្រាលជ្រៅធំធេងបំផុត ។ គូស្នេហ៍ទាំងទ្វេហាញញឹមដាក់គ្នាទៅវិញទៅមក រួច ក៏ដើរកាន់ដៃគ្នាត្រសង ត្រលប់ពីស្រែសំដៅទៅលំនៅវិញ ប្រកបដោយ ដួងចិត្តក្តីរីករាយនិងរំភើបរំជើបរំជួលញាប់ញ័រឥតព្រំដែន ។

តាមផ្លូវ អ្នកទាំងពីរចោលកន្ទុយភ្នែកលួច មើលគ្នាភ្លែកៗ មិនដាច់ សោះ ផ្ទៃមទាំងលួចញញឹមលាក់គំនួចដាក់គ្នា មួយដងមួយកាលទៀតផង តែគ្មាននរណាចចារសួរនរណាទៀតឡើយ ក្រៅពីបណ្តោយអោយក្រសែ ភ្នែករបស់គេវាចាសាសងគ្នាជាជំនួសពាក្យពេចន៍ទាំងឡាយ ដែលគេចង់ រៀបរាប់ប្រាប់គ្នាអំពីអារម្មណ៍បេតីប្រតិពទ្ធ័ ដែលគេមាននៅក្នុងចិត្តចំពោះ គ្នាទៅវិញទៅមក ។

លុះអ្នកទាំងពីរមកដល់ផ្ទះវិញ ស្រាប់តែមីងចាបក៏មកដល់ព្រមជា មួយគ្នា ដែរ ។ ខេវិនលើកដៃសំពះសួរ :

- អើហ៎ ល្អហើយកូន! ទើបមកពីវត្តមែនទេ? (មីងចាន់សួរ)

CHANBOKEO.COM

- បាទ... ម៉ែ... !

ខេរិនហៅគាត់ទាំងទាក់ៗ តែក៏អាចនិយាយចេញល្មមអោយមីងចាប ឮពេញត្រចៀកយ៉ាងច្បាស់ ។ នេះជាលើកទីមួយក្នុងជីវិតហើយ ដែលនាយ ប្រើពាក្យនេះសំរាប់ហៅនរណាម្នាក់ ។ នាយក៏ចង់ហៅពាក្យនេះយូរមក ហើយដែរ តែនាយគ្មានមនុស្សសំរាប់ហៅសោះ ។ ថ្ងៃនេះ ពាក្យ " ម៉ែ " មួយម៉ាត់បានធ្វើអោយខេរិនមានសេចក្ដីសុខក្រៃលែង ។ មីងចាប ឮកូន ប្រសារហៅគាត់ថាម៉ែ ស្រាប់តែត្រេកអរកខិបកខុបតែម្ដង :

- អឺហ៎! កូនប្រុសមកណេះ! ម៉ែចង់ប្រាប់រឿងមួយ ។

ខេរិនក៏ដើរចូលទៅជិត ។ គាត់មានប្រសាសន៍បន្តថា :

- កូនចង់ទៅភ្នំពេញទេហ៎?

ខេរិនភ្ញាក់ព្រើតឆ្លើយយ៉ាងរហ័ស:

- ទៅធ្វើអ្វី... ម៉ែ?

- ទៅតាមរកខ្មោយចាស់របស់យាយភួងនោះអី?

ស្រាប់តែនាងចាន់ស្ទុះចូលមកដល់ហើយឧទានឡើងថា :

- ម៉ែចក៏ម៉ែជ្រាបកើតថាខ្មោយចាស់នៅភ្នំពេញ?

- គឺអាដួងវាប្រាប់ ។ វាថាម៉ែឪវានៅលក់មាន់យូរថ្ងៃទៀតទំរាំដាច់អស់ ។ បើកូនចង់ទៅតាមយកខ្មោយមកវិញ ចាំម៉ែជូនកូនទៅ ។

ខេរិនងើបមើលមុខនាងចាន់ ហាក់ដូចជាចង់ពិគ្រោះយោបល់ជាមួយ នាង ។ ធិតាយើលយល់ភាសាតាមរយៈក្រសែភ្នែករបស់នាយ ក៏ឆ្លើយ ជំនួសនាយរឹងថា :

- អីចឹងយើងទៅទាំងអស់គ្នាឥលូវនេះតែម្ដងទៅ កុំឱ្យយឺតការ ។

ឃើញចាន់គិតអ្វីទូលាយៗមិនគិតស្ទុះគ្រស្មាញច្រើនដូច្នោះ នាយក៏ ញញឹមឡើងដាក់នាងយ៉ាងផ្អែមល្ហែម ។ ឃើញក្រសែភ្នែករបស់ខេរិន ដែលសំលឹងនាងចាន់ភ្លាម មីងចាន់ក៏គ្រហែមឡើង :

- អាហ៊ែម! យ៉ាងណាៗក៏សូមកុំអោយតែកូនទាំងពីរ ដើរចោលភ្លេចម៉ែឱ្យ ឯកាបានហើយ!

ចាន់និងខេរិនក៏លួចមើលមុខគ្នាញញឹមទាំងអៀនប្រៀន កាលបើបាន ឮពាក្យចំអែចំអន់របស់ម្ដាយ ។ រំពេចនោះ ស្រាប់តែគាត់ពោលឡើងថា :

- តែពេលនេះដូចជារសៀលហើយ បើនឹងចេញដំណើរទៅឥលូវ ទំរាំដល់ វាយប់ពេក ក្រែងពិបាករកកន្លែងស្នាក់ណាស់ ។ ចាំស្អែកចាំយើងក្រោកពី ព្រលឹមចេញដំណើរវិញ ដូចជាល្អជាង ។

- បាទ ម៉ែ!

នៅរាត្រីថ្ងៃដដែល...

CHANBOKEO.COM

នេះជាយប់ទីពីរហើយ ដែលខេរិនបានគេងនៅលើខ្នើយមង្គលតែមួយ ជាមួយនាងចាន់ក្រមុំស្រុកស្រែ។ តែយប់នេះនាយយើងរិតមែនអារម្មណ៍ ញាប់ញ័រឡើង១ លើសពីយប់មុនទៅទៀត។ យូរ១ម្តង នាយលួចងើប សំលឹងមើលវង្វង់ភក្ត្រចាន់ ដែលកំពុងសំងំនិទ្រា។ មាណពយើងលើកដៃ គងថ្ងាស សួរចិត្តខ្លួនឯងថា :

- រូបខ្ញុំពិតជាលង់ក្នុងអន្លង់ស្នេហាផ្កាត្រកួនស្រែមួយនេះ ដល់ម្លឹងឬអ្វី? ហេតុអ្វីទៅដែលនាំអោយបេះដូងរបស់ខេរិនឈ្លក់ស្នេហ៍រូបនាងយ៉ាងនេះ កាលបើយើងទើបតែជួបគ្នាពីរថ្ងៃសោះ?

កាលបើឮសូរសំលេងខេរិន ដកដង្ហើមយូរ១ជាញឹកញាប់ មិនដាច់សូរ ចាន់ក៏ប្រែខ្លួនបែរមកមើលនាយ ហើយសួរថា :

- អ្នកកំពុងគិតអ្វីហ្នឹង? មានរឿងអ្វីក្នុងជីវិត ដែលលំបាកដោះស្រាយ មិនចេញមែន ទេហ៎?

ឮដូច្នោះ ខេរិនក៏ទំលាក់ដៃយ៉ាងរហ័ស ឈប់គងថ្ងាស ហើយបែរមុខ មករកចាន់ រួចសួរទៅនាងថា :

- ចាន់! តើអូនអាចប្រាប់បងរឿងមួយបានទេ?

- អ្នក... ចង់អោយចាន់ប្រាប់ពីរឿងអ្វីទៅ?

- ចាន់! បើបងសួរ សូមអូនកុំខឹង អន់ចិត្តអីណា៎ !

- មិនខឹងទេ អ្នកសួរមកចុះ!

- គឺបង..ចង់ដឹងថា... ថាតើអូនគិតយ៉ាងណាដែរ ចំពោះរូបបងពេលនេះ?

ចាន់សំលឹងមុខខេរិន... មួយស្របក់ទើបឆ្លើយថា:

- អ្នកគឺជាមនុស្សដែលទេវតាប្រទានអោយមកចាន់ដោយចៃដន្យ...

- តែប៉ុណ្ណឹងទេហ៎?

- ចាស! (ចាន់ងក់ក្បាល)

ខេរិនក៏វាចាទៅនាងទៀតថា :

- ហើយចុះអូនមិនចង់សួរបងវិញទេហ៎ ថាបងមានអារម្មណ៍យ៉ាងណា ចំពោះអូនដែរ?

ម្តងនេះចាន់នៅស្ងៀម ហើយនឹកក្នុងចិត្តថា :

- នរណាទៅហ៊ានសួរលោកអើយ បើទើបតែឃើញពីរបីថ្ងៃអញ្ចឹង?

ពេលនេះ ខេរិនហាក់ដូចជាយល់នូវការខ្មាស់អៀនរបស់នាងណាស់។ មាណពយើងមិនរង់ចាំអោយនាងសួរនាយឡើយ។ គេក៏ងើបមុខឡើង ញញឹមដាក់នាង យកដៃម្ខាងទៅផាត់សក់ចេញរង្វង់ភក្ត្ររបស់ធិតាយើង ដោយបន្ថើ១ បង្ហាញនូវសេចក្តីស្នេហាយ៉ាងរំភើបមួយក្នុងដួងចិត្ត រួចហើយ ក៏ពោលទៅកាន់នាងដោយវាចាយ៉ាងស្រទន់ថា:

- ចាន់! អោយបងសុំផ្ញើជីវិត ផ្ញើបេះដូងរបស់បងជាមួយចាន់ផងណា៎!!

ចាន់ភ្ញាក់ក្រញាងកាលបើឮមាណពពោលដូច្នេះ។ រំពេចនោះ បេះដូង របស់នាងបែរជារណ្តំខុសចង្វាក់តែម្តង។ នាងបែរសំលឹងក្រសែភ្នែករបស់ ខេរិនដែលកំពុងតែរង់ចាំចំលើយពីនាង ប៉ុន្តែមាណវី បែរជារកពាក្យមួយ

CHANBOKEO.COM

ម៉ាត់ស្អិតបរកនាយមិនបានសោះ ក្រៅតែពីការរន្ធត់ញាប់ញ័រក្នុងចិត្តទ្វេ ឡើងប៉ុណ្ណោះ ។
ខេរិនយកដៃអង្អែលកេសានាងថ្នមៗហើយពោលបន្តថា :
- ចាន់! បងនិយាយពិតមែនណា!! មិនថាថ្ងៃស្អែកមានអ្វីកើតឡើងទេ... បងសូមឱ្យអូនចងចាំជានិច្ចផងណា
ថាបងសូមផ្ញើដួងចិត្តនិងជីវិតរបស់បង ទុកក្នុងដៃអូនហើយ ។ ចំពោះបង អូនគឺជាពន្លឺពណ្ណរាយនៃព្រះអាទិត្យ
ដែលរះបំភ្លឺជីវិតដ៏អាប់អួររបស់បង អោយភ្លឺថ្លាឡើងវិញយ៉ាងត្រកាល...

ថាហើយនាយក៏ឈ្ងោកនាសាផ្ទិតលើថ្ពាល់ធិតា ដោយសេចក្ដីស្នេហា យ៉ាងធំធេងមួយ ដែលមិនអាចរកពាក្យអ្វីមកថ្លែងអោយសមស្មើមិនបាន ឡើយ ។ រីឯចាន់ក៏បិទនេត្រាទទួលយកនូវការថៃថើបថ្នាក់ថ្នម យ៉ាងផ្អែមត្រជាក់របស់មាណពយើង ដោយក្ដីរំភើបក្នុងចិត្តក្រៃលែង ។ គ្រានេះ ខេរិនញាប់ញ័ររន្ធត់ក្នុងចិត្តអ្វីម្ល៉េះទេ នាយយើងលែងទប់ចិត្ត ទប់អារម្មណ៍ តទៅទៀតបានហើយ ។ បែរទៅនាងចាន់វិញក៏មិនខុសគ្នាដែរ កាលបើបាន ស្ដាប់ពាក្យពេចន៍មន្តស្នេហ៍របស់បុរសយើងដ៏សែនស្រទន់ ចាន់ក៏ហាក់ដូច ជាធ្លោយចិត្តធ្លោយអារម្មណ៍លែងគិតអ្វីទាំងអស់ ក្រៅពីបណ្ដោយអោយ បេះដូងរបស់នាងកញ្ជ្រោលយោលយោគ ទៅតាមចង្វាក់ចំរៀងស្នេហា ដែលទើបនឹងប៉ិចពន្លកជាលើកដំបូងបង្អស់ក្នុងជីវិតរបស់នាង ។ លុះឃើញ មាណវីទទួលយកនូវក្ដីស្រលាញ់របស់នាយដោយសេចក្ដីពេញចិត្ត ខេរិនក៏ ស្រវាលូកត្រកងកាយរបស់ឆវី មកអោបផ្ទាប់នឹងទ្រូងរបស់នាយយ៉ាង ណែនពេញរង្វង់ដៃ ដើម្បីទទួលយកសុភមង្គលដ៏សែនរមនាបំផុត ។ គ្រា នេះ បុរសយើងបានស្គាល់រសជាតិច្បាស់ហើយថា ឋានសួគ៌ស្នេហាមាន ឱជារសនិងអត្ថន័យជ្រាលជ្រៅយ៉ាងណា ។ មាណពពិតជាមានសេចក្ដីសុខ លើសពេលណាៗទាំងអស់ ក្នុងជីវិតទាំងផ្លូវកាយទាំងមនោសញ្ចេតនា ។ នៅឯខាងក្រៅផ្ទះ សំលេងឆ្កែលូល្ងើយៗ លាយឡំនិងសំលេងស្លឹកដូង យោលយោគខ្សាកៗទៅមក តាមជំនោរខ្យល់ បានមកបន្លាចអារម្មណ៍គូស្នេហ៍អោយកាន់តែព្រឺព្រួចក្នុង ទ័យាឡើង ។ ព្ធដ៍វេហាស៍ដ៏សែនខ្ពស់សន្លឹម ដួងចន្ទ័មួយវង់កំពុងខំប្រឹងរះ បញ្ចេញរស្មីយ៉ាងស្រទន់ មកលើធរណីជាចុង ក្រោយ មុននឹងត្រូវអំណាចរាហូឆក់លេបយកទៅលាក់ទុកកំបាំងបាត់ពី ក្រសែភ្នែកមនុស្សម្នាផង ទាំងឡាយ...
។

## ហត្ថាអម្រិត

រង្វង់ហត្ថាដ៏កក់ក្ដៅ គេងកើយយប់ជ្រៅនៅនៃបរិត្យ ហត្ថាត្រកងលោមកៀកស្និទ្ធ
អង្រួនដួងចិត្តអររំភើប ។ ហត្ថាមាសមន្តពន់សណ្ដំ ក្លិនក្លែបឧត្ដមអារម្មណ៍ស្រើប ហឫទ័យត្រអាលកាលជំពើប
ភ្លើងស្នេហ៍រើរើបពេញឱរា ។ ហត្ថាទាំងទ្វេបំពេរចិត្ត ហាក់មន្តអម្រឹតប្រស់ឱរា ឱ្យចិត្តរីករាយឥតឧបមា
ស្រើម្ពាលោការូមភិសម័យ ។ ហត្ថាត្រជាក់ស្នាក់ដួងចិត្ត ឱ្យលង់គំនិតគិតរំពៃ ប្រាថ្នាដៃគូរួមភិសម័យ
លុះជីវិតក្ស័យអម្រិតស្នេហ៍ ។

CHANDBOKEO.COM

៚៚៚៚៚៚៚៚៚៚៚៚៚៚

៚៚៚៚៚

៚

CHANBOKEO.COM

# វគ្គទី៥

# មេឃប្រែពណ៌

**ថ្ងៃទី២១មករា ២០០៦**

មាន់រងាវខ្ញៀយៗ...

ខេវិនក្រោកឡើងពីព្រហាម ដើម្បីចេញដំណើរទៅភ្នំពេញជាមួយមីង ចាបនិងប្រពន្ធថ្មីថ្មោងរបស់នាយ ។ នៅមុខកូនកញ្ចក់កញ្ចាស់មួយ ចាន់ កំពុងអង្គុយសិតសក់ក្រងយ៉ាងស្អាត ។ នាយយើងក៏ដើរទៅពីក្រោយ ឱនថើបកញ្ចឹងកភរិយាលាន់ខ្សឺត ដោយចិត្តស្រលាញ់យ៉ាងធំធេង ។ បន្ទិចមក ខេវិនក៏ដោះក្រវិលមាសពីត្រចៀករបស់នាយ រួចហុចទៅអោយចាន់ហើយ ស្រដីប្រាប់នាងថា :

- ចាន់! បងសុំផ្ញើក្រវិលនេះទុកផង!

ចាន់បែរមើលទៅខេវិនហើយសួរថា :

- អ្នក ឈប់ចង់ពាក់វាទៀតហើយមែនទេ?
- គឺ... បងគិតថា បងលែងត្រូវការជីវិតជាក្មេងឈាមរាវទៀតហើយ... មិនចង់ធ្វើអ្វីប្លែកៗ ដូចពីដើមទៀតទេ ។

ចាន់សំលឹងមុខខេវិន ហើយញញឹមទទួលយកក្រវិលទៅទុកបាត់ទៅ ។ រំពេចនោះ មីងចាបមកគោះទ្វារហៅអោយចេញដំណើរ ។

ខេវិនកាន់ដៃ ចាន់ដើរតាមពីក្រោយមីងចាបសំដៅទៅរថយន្តឈ្នួល ដែលកំពុងរៀបចេញដំណើរទៅភ្នំពេញទាំងព្រហាម ។ ប៉ុន្តែ ថ្ងៃនេះ ខេវិន បានក្លាយជាមនុស្សថ្មីម្នាក់យ៉ាងប្លែក ខុសពីខេវិនកាលពីប៉ុន្មានថ្ងៃមុនឱ្យ សលះតែម្តង ។ តាមផ្លូវ មីងចាន់លួចសង្កេតមើលអ្នកទាំងពីរជាញយៗ ។ កាលបើឃើញខេវិនថ្នាក់ថ្នមកូនស្រីរបស់គាត់យ៉ាងផ្អែមល្ហែម មីងចាបក៏លួចញញឹមតែម្នាក់ឯង ។ ចំណែកចាន់ក៏រីកថ្ងើមប្រមាត់មិនតិចដែរ ដែល ខេវិនបានយកចិត្តយកថ្លើមនាងក្រៃលែង ។

មកដល់ភ្នំពេញ...

អ្នកទាំងបីក៏នាំគ្នាជិះស៊ីក្លូតាមរកម៉ែពុកអាដូង ។ ចៃដន្យថ្ងៃនោះ មាន គេហែក្បួនយ៉ាងធំមួយកណ្តាលក្រុងធ្វើអោយចរាចរស្ទះគ្រប់កន្លែង ។ មីង ចាបសួរពូស៊ីក្លូ :

- ប្អូន! តើគេធ្វើបុណ្យអីហ្នឹង បានជាហែក្បួនធំដុំម្ល៉េះ?
- បាទ! គឺជាក្រសួងកាកបាទក្រហមសង្គ្រោះកុមារ ។ គេហែក្បួន ដើម្បី ស្វែងរកការឧបត្ថម្ភដល់កុមាររងគ្រោះនោះអី ។

CHANBOKEO.COM

- អូហ៎! បើយើងចង់ដាក់ទានចូលបុណ្យនឹងគេបានទេ ប្អូន?

- បាទ ប្រហែលជាមានគេទទួលទេដឹង?

- អញ្ចឹង ប្អូនចាក់ស៊ីក្លូអែបខាងៗ ទៅតាមក្បែរក្បួនដង្ហែគេមើល៍ ក្រែង លោមានកន្លែងណាដែលយើងអាចចូលបុណ្យនឹងគេបាន ។

មួយស្របក់ក្រោយមក ស្រាប់តែអ្នកទាំងបីបានមកដល់កន្លែងមួយ ដែលមានចរាចរស្ទះកកកុញ ។ អ្នកទាំងបីក៏អោយថ្លៃស៊ីក្លូហើយ ក៏ចុះដើរ ទៅរកមើលក្បួនដង្ហែនឹងគេ ស្រាប់តែប្រទះនឹងម៉ែអាដួងនៅអង្គុយយាម មេមាន់ចងជើងមួយហ្វូង ។ មីង ចាបក៏ស្រែកហៅ:

- អឺ! ម៉ែអាដួង!

ម៉ែអាដួងក៏ងាកមកក៏ឃើញមីងចាបក៏សើចស្វាញទ្បើង :

- ហើយចុះបងចាបឯងដើរបានឆ្ងាយម្ល៉េះ ថ្ងៃនេះ?

- គឺមកតាមរកម៉ែអាដួងឯងហ្នឹងណ៎!

- អូហ៎? មកតាមរកខ្ញុំធ្វើអ្វីទៅ?

- គឺកូនប្រសារខ្ញុំនេះវាចង់មកតាមរកម៉ែអាដួងឯងហ្នឹងណ៎ ។

- អីយ៉ា! បែកគ្នាតែពីរបីថ្ងៃស្រាប់តែមានកូនប្រសារ!! អីក៏តក្កហលម្ល៉េះ បងចាប?

ម៉ែអាដួងបែរមកនាយខេវិនហើយនិយាយសើចកក្អឹក :

- ឯងមានរូបរាងសង្ហារអញ្ចឹងតើ បានជាបងចាបលើកកូនស្រីអោយរហ័ស ម្លឹងៗ! ដឹងទេហ៎ អាង៉ា ឯងមានសំណាងដល់សូរហើយ!

ខេវិនធ្វើមុខញឹមៗ កាន់ដៃនាងចាន់ នៅស្ងៀមមិនហ៊ានឆ្លើយទេ ។ ភ្លាមនោះ ម៉ែអាដួងបែរមកសួរមីងចាប :

- ហើយបងចាបឯងជូនកូនប្រសារមកតាមរកខ្ញុំមានការអ្វីដែរ?

- បងមិនមែនតាមរកម៉ែអាដួងឯងទេ គឺតាមរកខ្មើយចាស់របស់យាយភួង ដែលម៉ែអាដួងឯងយកធ្វើកែបអង្គុយក្នុងរ៉ឺម៉កទ្រុងដឹកមាន់មកនោះអី ។

- អូហ៎ ហើយចុះ រកអាខ្មើយកញ្ចាស់នោះធ្វើអ្វី?

- គឺយាយភួង គាត់បានលាក់លិខិតមរតកនៅក្នុងខ្មើយគរ ហ្នឹងណ៎...

- មែនហ្អេសបងចាប? ពុទ្ធោ! ងាប់ម៉ែអាដួងបាត់!

- ហេតុអីបានជាត្រូវងាប់ម៉ែអាដួងផង?

- ព្រោះអី ពេលក្បួនហែគេដើរអង្គាសលុយជួយកុមាររងគ្រោះនោះ ខ្ញុំលក់ មាន់មិនទាន់ដាច់ អត់លុយចូលបុណ្យ ក៏យកខ្មើយដាក់ជាអំណោយ អោយគេបាត់ទៅហើយ ។

- ស្រេចហើយលោកអើយ...!!

CHANBOKEO.COM

មីងចាបនិងនាងចាន់លាន់មាត់ព្រមគ្នាឡើង ។ ឯខេវិនបែរមើលតាម ក្បួនដង្ហែរបស់គេ ដែលកំពុងចរយាត្រាគ្រឿនៗទៅមុខ ប៉ុន្តែមនុស្សម្នា ក៏កកកុញ ក្បួនក៏វែងអន្លាយ មិនដឹងថា ត្រូវទៅតាមរកខ្មោចនោះ នៅឯ ណាទេ ។ អ្នកទាំងបីសំលឹងមុខគ្នា សំដែងនូវការអស់សង្ឃឹមគ្រប់គ្នា ។ តែ ម៉ែអាដួងបែរជានិយាយកម្ចាទៅវិញថា :

- ប្រហែលជាមរតកដែលចារទុកនៅក្នុងខ្មោច ជាបំណងរបស់យាយភួង ហើយទើបទេវតាបណ្តាលផ្លូវអោយខ្មោច ចេះតែរត់គេចពីដៃចៅប្រុស របស់គាត់យ៉ាងនេះ ។

ឮដូច្នោះអ្នកទាំងអស់ហាក់ដូចជាធូរទ្រូងបន្តិច ។ មួយស្របក់ក្រោយ មក គេក៏នាំគ្នាលាម៉ែអាដួង ដើម្បីរកឡានតាក់ស៊ីជិះត្រលប់ទៅភូមិ ព្រះនេត្រព្រះវិញ ។ ភ្លាមនោះ ខេវិននឹកភ្នកចង់ទិញចំណីអោយភរិយា និងម្តាយក្មេកពិសារ ក៏បបួលគ្នាចូលតូបបាយមួយ ។ កំពុងតែបរិភោគ ស្រាប់តែមានរថយន្តមួយបរមកដល់ក្បែរតុ ដែលអ្នកទាំងបីកំពុងបរិភោគ ហើយចាប់ហ្វ្រាំងង៉ក់ ហុយដីទ្រលោម ។ ខេវិនងើបមុខឡើង សំលឹងមុខ សូហ្វ័រឡាន ស្រាប់តែនាយតាក់ស៊ីនោះរាដៃ ហើយចង្អុលទៅខាងក្រោយ ជាសញ្ញាថានាយត្រូវគេបញ្ជាមកទេ ។ ខេវិនមើលទៅតាមដៃនាយតាក់ស៊ី ស្រាប់តែប្រទះនឹងនារីឆើតឆាយស៊ិចស៊ីមួយរូបពាក់វ៉ែនតាខ្មៅ កំពុងហាក់ ចេញពីឡានហាក់យ៉ាង លឿនសំដៅមកខេវិនថែមទាំងស្រែកថា :

- Kevin, Oh my dear sweetheart ! I miss you very much! How've you been the last several days?

ខេវិនភ្ញាក់ស្រលាំងកាំងលាន់មាត់ខ្សឹបៗ :

- Oh Gosh! Pauline? How d'you get here?

ស្រាប់តែនារីនោះចាប់ខេវិនថើបមាត់ឮសូផ្លក់ ធ្វើអោយមីងចាបនិង នាងចាន់ភ្ញាក់ស្ទើរគាំងបេះដូងស្លាប់ឈរទាំងកណ្តាលថ្ងៃ ។ កាលបើឃើញ គេនិយាយដាក់គ្នាសុទ្ធតែភាសាអង់គ្លេសមីងចាបក៏ស្រែករវ៉ាងឡើង :

- ណៃ៎ៗ! មកបារាំងសេះ បារាំងគោក្របីអីនៅទីនេះវ៉ើយ ។ ឈប់ភ្លាម មើល៍! នែ៎ អន្ទិតវិន! ហើយចុះ នាងនេះជានរណាដែរហ្ន៎ស?

ខេវិនធ្វើអេះអុញឆ្លើយទាំងតពាក់តតុប :

- បាទ... នាងគឺ... ឈ្មោះនែ៎....

- ឈ្មោះផល្លីន (នារីស៊ិចស៊ីស្រដីកាត់) ជាសង្សារបងខេវិនមកពីអាមេរិក នោះអី ចាំស..!

ភ្លាមនោះ ស្រាប់តែចាន់បើកភ្នែកធំៗ សំលឹងមុខខេវិន ហើយបែរទៅ ផល្លីនឆវីសិចស៊ីរួចហើយស្រាប់តែខាំមាត់ក្រោកដើរចេញទៅយ៉ាងរហ័ស ។ ខេវិនឃើញ ដូច្នោះក៏ស្ទុះរត់ទៅតាមក្រោយ :

- ចាន់! អូនទៅណា? ចាន់! ឈប់សិនអូន!

CHANBOKEO.COM

តែនាងមិនឆ្លើយទេ គិតតែពីដើរយ៉ាងលឿនឆ្ងាយទៅៗ ។ រីឯមីងចាប
វិញឃើញស្ថានការណ៍មិនស្រួលក៏រត់តាមកូនពីក្រោយទៅដែរ ។ លុះឃើញ ខេវិនរត់គេចពីនាង
ផល្លីនក៏ហក់តាមប្រដេញកិតៗពីក្រោយដែរ ធ្វើអោយ អ្នកស្រុកឈរមើលរហង់តាមដងផ្លូវ ។ មានអ្នកដំណើរខ្លះលាន់មាត់ថា :
- ថ្ងៃនេះ មានក្រុមហ៊ុនគេចុះមកថតកុនរឿងថ្មីហើយមើលទៅ បានជា សាច់រឿងដូចជាល្អមើលប្លែកភ្នែកតែម្តង!

មកដល់កាច់ជ្រុងវិថីមួយ... ខេវិនក៏វង្វេងបាត់ប្រពន្ធរកលែងឃើញ ។ មីងចាបរត់មកដល់សំដែងកិរិយាភិតភ័យ :
- អន្ទិតវិន្ទ! កូនឯងទៅឃាត់មិត្តស្រីរបស់ខ្លួនសិនទៅ ទុកអោយម៉ែតាម រកចាន់ចុះ ។ គេប្រហែលជាអន់ចិត្តនឹងកូនហើយ ។ ឃើញស្រីផ្សេងមក ថើបមាត់គ្នាជាមួយប្តីរបស់ខ្លួននៅចំពោះមុខស្រស់ៗបែបនេះ ស្រីណាក៏ទប់ ចិត្តមិនបានដែរណាំខេវិន!

ខេវិនអន្ទះសាណាស់ ។ នាយរត់ររកមើលចុះឡើង មួយស្របក់ហើយ នៅតែមិនឃើញចាន់ដដែល ។ ពេលនោះ
ផល្លីនក៏មកដល់ភ្លាមដែរ ។ ហ៊ឺ! ពេលនេះតើឱ្យនាយធ្វើដូចម្តេចទៅ? មីងចាន់ក៏ដើរចេញទៅទិសម្ខាង
តាមរកនាងចាន់បាត់ទៅទុកអោយខេវិននៅទទួលនាងផល្លីនតែម្នាក់ឯង ។
- បងខេវិន! យ៉ាងម៉េចហ្នឹង? បែកអូនជិតមួយអាទិត្យហើយមិននឹកអូន
ខ្លះទេ បងសំលាញ់?

ខេវិនឈរធ្មឹងហាក់ដូចជាមិនឮ ។ ពេលនេះ អារម្មណ៍របស់នាយស្ថិត នៅជាមួយប្រពន្ធរបស់នាយឯណោះ ។
គេមិនបានឮសំដីរបស់ផល្លីនដែល និយាយមករកនោះឡើយ ។ ផល្លីនក៏និយាយបន្ត :
- សុខសប្បាយទេ ខេវិន? ហេតុអ្វីក៏តុបតែងកាយប្លែកម្ល៉េះ ឥលូវនេះ?

ឃើញផល្លីនបញ្ចេញអាការៈបែបនារីបរទេសជ្រុលពេក នាយយើងក៏ នឹកខ្មាសមនុស្សដែលនៅឈរមើលជុំជិតនៅទីនោះ
នាយក៏នាំស្រីស្រស់ ឡើងតាក់ស៊ីចេញទៅ ។

នៅក្នុងសណ្ឋាគារតូចមួយម្តុំសន្ធរម៉ុក...

ផល្លីននៅអង្គុយផ្អែកខ្លួនលើគ្រែ ចំណែកខេវិននៅឈរអោបដៃក្បែរ បង្អួច បែរមុខសំលឹងទៅក្រៅ សំដែងទឹកមុខតប់ប្រមល់
:
- ហេតុអីក៏អូនមកដល់ទីនេះបាន ផល្លីន?
- គឺអូនទទួចសុំលុយមីងពៅពូវៃ ទិញសំបុត្រ មកតាមរកបងហ្នឹងណាំ! យ៉ាងម៉េច?
បងមិនចង់អោយអូនមកជួបបងនៅទីនេះទេហ៎?

ខេវិនដកដង្ហើមធំ... ហើយសួរទៅវិញថា :
- តើអូនមកនេះ ព្រោះបារម្ភពីសុខទុក្ខរបស់បង ឬក៏អូនចង់ដឹងថា បង ទទួលសម្បត្តិមរតកច្រើនប៉ុណ្ណា?
- គឺ... ទាំងពីរយ៉ាងហ្នឹងណាំបង!
- ចុះបើបងមិនបានទទួលមរតកអ្វីទាំងអស់... តើអូនគិតយ៉ាងម៉េចវិញ?
- អូនស្រលាញ់បងយូរហើយ ។ យើងកំសត់កម្រដើរលក់អាភៀនដើម្បីរក

CHANBOKEO.COM

លុយរស់ ទាំងអស់គ្នា... ម៉េច? បងភ្លេចហើយហ្មែស?

ខេរិននៅស្ងៀម ។ មែនហើយ! ការពិត មិនមែននរណាទេ ជាអ្នកចង បញ្ហា គឺមានតែនាយម្នាក់គត់ ហើយពេលនេះក៏មានតែនាយម្នាក់ដែរដែល ត្រូវប្រឈមមុខដោះស្រាយបញ្ហាទាំងនេះដោយខ្លួនឯង ។ បន្តិចមកនាយក៏បែរមើលផល្លីនហើយស្រដីថា :

- ផល្លីន! អោយបងសូមទោសអូនផងណា៎! ពេលនោះ បងបានជ្រុលខ្លួន រៀបការជាមួយស្រីផ្សេងម្នាក់ទៅហើយ...

ស្រាប់តែ ផល្លីនលាន់សំណើចខឹកៗ ហើយតបថា :

- បងចាំបាច់សុំទោសអូនធ្វើអ្វី? ក្រែងនោះជាគំរោងរបស់បង ក្នុងការ ទទួលយកមរតកមហាសាលពីជីដូនរបស់បង មិនមែនទេហ៎?

- ខុសហើយផល្លីន! គឺ... បងមិនបានរៀបការជាមួយនារីដែលជីដូនរបស់ បងបានរៀបចំទុកដាក់អោយបងនោះទេ...

- ថាម៉េច? (ផល្លីនស្ទុះហក់ចុះពីលើគ្រែ) ពន្យល់អោយខ្ញុំស្តាប់ផងមើល៍!

- គឺបងមិនទាន់បានទទួលលិខិតមរតកនៅឡើយ ហើយក៏មិនទាន់ជួប ចៅស្រី ដែលលោកយាយរៀបចំទុកដាក់អោយបងដែរ ។

- ហើយចុះនារីដែលបងរៀបការជាមួយនោះជានរណាដែរទៅ?

- គឺជាមនុស្ស ដែលនាំរូបបង អោយមកចាប់កំណើតសាជាថ្មី ក្នុងជីវិតដ៏ភ្លឺស្វាងមួយ..

- បងចង់មានន័យថាម៉េចហ្នឹង? គ្រាន់តែបែកពីអូនមិនបានមួយអាទិត្យផង បងក៏រៀបការនឹងស្រីម្នាក់ហើយលើកដំកើងរូបគេដល់ថ្នាក់នេះ? អូនមិនជឿទេ! មិនជឿ! (ផល្លីនគ្រវីក្បាល ហួសចិត្ត)

- បងនិយាយពាក្យពិតណា៎ផល្លីន ។ ពេលនេះ បងជាមនុស្សជាថ្មីហើយ...

- អត់ទេ បងនិយាយដោយងាយៗដាក់ផល្លីនអញ្ចឹងមិនបានទេ ។ អូនបាន ស៊ូទ្រាំជាមួយនឹងបងយូរឆ្នាំហើយ... ហេតុអ្វី? ហេតុអ្វី...? ក្នុងកំលុងបួន ប្រាំថ្ងៃសោះ ស្រីខ្មែរម្នាក់អាចផ្លាស់ប្តូររូបបងបានយ៉ាងប្លែកដល់ថ្នាក់នេះ? ហើយ...បើបងមានម្ចាស់ដួងចិត្តថ្មី... ចុះរូបអូនវិញ? តើបងយករូបអូន ទៅទុកនៅឯណា? បងឆ្លើយមក... ឆ្លើយមក៏...!

ខេរិនទ្រោបមុខនឹងកញ្ចក់បង្អួច មិនឆ្លើយមួយម៉ាត់សោះ ។ មែន ហើយ! នាយតែម្នាក់គត់ដែលជាអ្នកមានកំហុសជាងគេ ត្បិតបុរសយើង បានក្បត់ចិត្តសង្សារ ។ ប៉ុន្តែ តើនាយត្រូវដោះស្រាយយ៉ាងណាវិញ? ចំពោះ ចាន់ នាយពិតជាមិនអាចដកចិត្តពីនាងបានទេ ។ នាងជានារីដ៏ស្លូតត្រង់ មួយរូប តើអោយនាយបោះបង់រូបនាងម្តេចបាន? ឯផល្លីនវិញក៏ធ្លាប់ជា ដៃគូកំសត់កម្រមកយូរឆ្នាំ អត់ឃ្លានមានស៊ីជាមួយគ្នា ទោះបីជានាងជា មនុស្សឆេវឆាវកាចឆ្នាសបន្តិចមែនក៏ដោយ ។ តែអ្វីដែលផ្ទុយស្រលះពីគ្នា រវាងផល្លីននិងនាងចាន់គឺការប្រព្រឹត្តរបស់គេទាំងពីរ ។ ផល្លីនតែងតែនាំ ខេរិនដើរចូលសង្គមឧក្រិដ្ឋ គេចការសិក្សា ទៅលក់អាភៀន ដើរស៊ីចាយ ប៉ោឡែគ្មានគិតអនាគតឡើយ គិតតែពីដោះស្រាយអោយបានសប្បាយពី

CHANBOKEO.COM

មួយថ្ងៃទៅមួយថ្ងៃប៉ុណ្ណោះ ។ តែចំណែកចាន់វិញ នាងបែរជានាំខេរិនឱ្យ ដើរចូលក្នុងជីវិតដ៏មានសុក្រឹតភាពទៅវិញ ។ ពេលនេះខេរិនត្រូវតែសំរេច

ចិត្តយ៉ាងដាច់ខាតហើយ ថានាយត្រូវជ្រើសរើសផ្លូវជីវិតណាមួយអោយ

ជាក់ច្បាស់ ។ ភ្លាមនោះ ផល្លីនស្រដីមកខេរិនថា :

- ណ្ហើយចុះ! បើបងមិនបានទទួលកេរ្តិ៍មរតកទេក៏ហីទៅ... សុំតែបង ត្រលប់ទៅអាមេរិកវិញជាមួយអូនចុះ

ព្រោះអូនពិតជាមិនដាច់ចិត្តលះបង់ រូបបងអោយនារីដទៃឡើយណាបង!

ថាហើយផល្លីនលូកដៃស្រវាអោបខេរិនពីក្រោយ ស្រាប់តែនាយលូក ដៃបេះនាងចេញហើយគេចយ៉ាងរហ័ស

រួចឆ្លើយតបវិញថា :

- តែបងមិនអាចត្រលប់ទៅបានទេ... បងបាត់សំបុត្រស្នាមអស់ហើយ ហើយក៏គ្មានប្រាក់កាសនៅសល់មួយកាក់ក្នុងខ្លួនដែរ ។

- បងជាសញ្ជាតិអាមេរិកាំង គ្រាន់តែចូលទៅការិយាល័យទូតដាក់ពាក្យ សាថ្មី

បងនឹងបានទទួលលិខិតឆ្លងដែនថ្មីមួយទៀតវិញហើយ ។

- តែបងមិនចង់ធ្វើ...

- បងមិនចង់ធ្វើ... គឺព្រោះតែនារីម្នាក់នោះមែនទេហ៎?

- មែនហើយ... បងពិតជាអាចបោះបង់អ្វីទាំងអស់ ដើម្បីនាង...

- បងខេរិន...! ( ផល្លីនស្លុតចិត្តដាក់ខ្លួនលើកៅអីឈ្ងោកមុខយំខ្សឹកខ្សួល)

ផល្លីនឈឺចិត្តណាស់ ស្ទើរតែតាំងបេះដូងស្លាប់ទាំងថ្ងៃតែម្តង ។ នាងយំ

នាងសោកសង្រេង... នាងខ្សឹកខ្សួលយ៉ាងយូរ... លុះអស់ចិត្តហើយ ក៏ងើបជូតទឹកភ្នែកហើយបែរមកសួរខេរិនថា :

- ខេរិន! អោយអូនសុំស្គាល់នារីថ្មីរបស់បងបានទេហ៎?

បុរសហើយបែរសំលឹងមកផល្លីន មួយស្របក់ទើបឆ្លើយថា :

- ប៉ុន្តែ... តើអូនសន្យានឹងបងបានទេ ថាអូនមកបង្ករឿងឱ្យរំខានដល់ចិត្ត

របស់នាង?

- ត្រូវដាក់លក្ខខណ្ឌផង?

- មែន!...ព្រោះគេមិនដែលធ្វើអ្វីអោយល្អក់កករដល់ចិត្តបងម្តងណាទេ ដូច្នេះ

បងក៏មិនគួរនាំអ្វីដែលក្តៅក្រហាយរំខានដល់ចិត្តរបស់នាងដែរ ។

- ចុះដែលចិត្តអូនកំពុងឈឺចាប់ខ្លោចផ្សាពេលនេះ តើបងគិតយ៉ាងណា ទៅវិញ?

ភ្លាមនោះ ខេរិន រលីងរលោងទឹកភ្នែក :

CHANBOKEO.COM

- បងជាអ្នកសាងបាបកម្មតែម្នាក់ឯង... ដូច្នេះ សូមអូនទុកអោយបង
ជាមនុស្សបៀមវិប្បដិសារីនេះនៅក្នុងចិត្តបងឈឺចាប់តែម្នាក់ឯងទៅចុះ កុំ អោយវេរានេះធ្លាក់ទៅដល់មនុស្សថ្មី
ដែលមិនដឹងរឿងអីផងនោះណា៎ ផល្លីន!.... អោយបងសូមទោសអូនផង!

ឮដូច្នោះ ផល្លីនក៏មិនដឹងពោលយ៉ាងណា ដើម្បីបន្ទោសនាយយើង តទៅទៀត
កាលបើនាយបានទទួលស្គាល់កំហុសរបស់ខ្លួនទៅហើយ ។ ម្យ៉ាងទៀត មើលទៅកិរិយារបស់ខេវិនពេលនេះ ផល្លីនហាក់ដូចជាយល់
ច្បាស់ហើយថា ទូកជីវិតរបស់ខេវិនកំពុងផ្លាស់ប្តូរទិសដៅរបស់ខ្លួនហើយ ។ ខេវិនឥលូវនេះហាក់ដូចជាម៉ឹងម៉ាត់
ចំលែកជាងខេវិនម្នាក់ទៀតដែលនាង ធ្លាប់ស្គាល់ពីមុនមក ។ នារីយើងដកដង្ហើមយូរបន្ទូរទ្រូងមួយយ៉ាងធំ រួចក៏ នឹកគិតក្នុងចិត្តថា :
- ណ្ហើយចុះ   យើងជាមនុស្សពេញវ័យ   អាចគ្រប់គ្រងជីវិតដោយខ្លួនឯង
បានយ៉ាងងាយ ចាំបាច់អីដែលទៅឈ្លោះគ្នាដណ្តើមរកបុរស ដើម្បីយកមក
ជាបង្អែកក្នុងជីវិតនាំអោយតែអាប់ឱនយសនោះ? ផល្លីនគួរណាស់តែរក្សា កត្តិយសជាស្ត្រីដ៏រឹងប៉ឹងម្នាក់... មិនមានខេវិន
ក៏ផល្លីនអាចរស់នៅបាន ដោយពេញមុខនិងមានសេចក្តីសុខដូចគេឯងដែរ ។ បើយើងនៅតែលិចលង់ ខកចិត្តនឹងរឿងស្នេហាក្បត់ចិត្ត
ជីវិតយើងច្បាស់ជាគ្មានថ្ងៃនឹងរកពន្លឺ សុភមង្គលជីវិតឃើញឡើយ ។ ក្នុងលោកនេះ មិនខ្វះទេបុរសល្អៗដែល
យើងអាចចាប់ដៃសាងអនាគតបានយ៉ាងភ្លឺស្វាង!!... ណ្ហើយ! បណ្តោយឱ្យ កំលាំងទឹកជំនន់ថ្មី ហូរគួចខេវិនទៅចុះ!!!

កាលបើគិតដល់ត្រង់នេះ ផល្លីនក៏ញញឹមឡើងវិញ ហើយលើកដៃ ស្ទាំហុចទៅខេវិនព្រមទាំងស្រដីថា :
- យើងចាប់ដៃជាមិត្តវិញ យ៉ាងម៉េចដែរខេវិន?

ខេវិនភ្ញាក់ព្រើតបែរមើលមកផល្លីនហើយលាន់មាត់:
- ផល្លីន...?

ផល្លីនងក់ក្បាលហើយឆ្លើយថា :
- បើយើងមិនអាចក្លាយជាគូស្នេហ៍ប្រចាំជីវិតបាន យើងគួរតែរក្សាភាពជា មិត្តវិញ
ប្រហែលជាប្រសើរជាងសាងចិត្តជាសត្រូវនឹងគ្នាដែរមែនទេហ៎?

ខេវិនសំលឹងមុខផល្លីន ឃើញនាងញញឹមដាក់នាយយ៉ាងស្រទន់ ហាក់
បីដូចជាគ្មានភាពឫស្យាប្រទុស្តនៅក្នុងចិត្តចំពោះនាយ ។ ខេវិននឹកស្ងើច សរសើរនាងក្នុងចិត្តហើយក៏ត្រេកអរឥតឧបមាដែរ ។
មាណពយើងក៏បែរ
ញញឹមរកនាងហើយលូកចាប់ដៃផល្លីនរលាក់ ព្រមទាំងវាចាថា :
- ផល្លីន! អរគុណណាស់ដែលអូនអភ័យទោសអោយបង!

ខេវិនស្រដីទាំងរលីងរលោងទឹកភ្នែក ដោយការត្រេកអរអនេកដែល
ផល្លីនបានដោះលែងរូបនាយអោយមានសេរីភាពផ្លូវចិត្តមកវិញ តែនាយក៏ មានចិត្តអាណិតស្រណោះផល្លីនមិនតិចដែរ ។ បន្ទាប់មក
ខេវិនក៏បើកទ្វារ ដើរចេញទៅ ។ ផល្លីនក៏បែរទ្រោបមុខលើខ្នើយខ្សឹកខ្សួលសាជាថ្មី...

CHANBOKEO.COM

មួយស្របក់ក្រោយមក...

តុក១ តុក១.... ស្នូរគោះទ្វារ ។ ផល្លីនជូតទឹកភ្នែកយ៉ាងរហ័សហើយក៏ ងើបទៅបើកទ្វារ ស្រាប់តែនាងលាន់មាត់ឡើង :

- ខេរិន?

ខេរិនឈ្ងោកមុខដើរចូលមក ។ ផល្លីននឹកឆ្ងល់ក៏សួរ :

- កុំប្រាប់ណាំថាខេរិនដូរចិត្ត...

- អត់ទេ.... (ខេរិនឆ្លើយទាំងស្ងួតស្ងប់)

- អញ្ចឹងមានរឿងហេតុអ្វីទៅ?

- គឺខ្ញុំមិនស្គាល់ភូមិសាស្រ្តទីក្រុង ហើយក៏...

- យ៉ាងម៉េច? អត់ប្រាក់មែនទេហ៏?

- ត្រូវហើយ... ខ្ញុំគ្មានប្រាក់មួយសេនទេ ហើយមិនដឹងថានឹងត្រលប់ទៅ ព្រះនេត្រព្រះវិញតាមណាផង ។

- ព្រះអើយ...!

ផល្លីនស្ទុះទៅបើកកាបូបរាវរកលុយ យកមកហុចអោយខេរិន :

- ខ្ញុំមានពីររយដុល្លារដែរ ។ ខេរិនយកមួយរយទៅ ។

- អរគុណណាស់ ផល្លីន... ដែលនៅតែយកចិត្តទុកដាក់ ចំពោះសុខទុក្ខ របស់ខ្ញុំដដែល!

ខេរិនទទួលយកប្រាក់របស់នាងទាំងខ្លាចចិត្ត ។ បន្ទាប់មក នាយក៏ បែរមើលទៅផល្លីន ឃើញមានស្នាមទឹកភ្នែកដក់នៅជាប់រង្វង់មុខនៅ ឡើយ ។ នាយក៏សួរថា:

- ហើយចុះផល្លីន នឹងត្រលប់ទៅអាមេរិកវិញ ឬក៏យ៉ាងណា?

- ខ្ញុំមិនដឹងទេ (ផល្លីនឈ្ងោកមុខ) ឥលូវកំពុងវិលវល់អារម្មណ៍...

លុះឃើញខេរិនធ្វើមុខស្រងូតស្រងាត់ នាងក៏និយាយកម្សាថា:

- តែមិនអីទេ ពីរបីថ្ងៃទៀត ខ្ញុំភ្លេចខេរិនឯងហើយ ។

ទោះបីជានាងខំប្រឹងនិយាយកម្សាយ៉ាងណា ក៏មិនអាចលាក់ជិតនូវ អារម្មណ៏ដ៏សែនសោកសៅរបស់នាងបានដែរ ។ ខេរិនហាក់ដូចជានឹក អាណិតផល្លីនណាស់ ក៏លូកដៃទះស្មានាងបន្ថើរ១ ថែមទាំងលួងលោមថា :

- ផល្លីនជាមនុស្សរឹងប៉ឹងតាំងពីដើមមក... ខ្ញុំដឹងជីវិតនាងនៅថ្ងៃស្អែកនឹង បានប្រសើរជាមិនខាន ។

ខេរិននៅស្ងៀមមួយស្របក់ ក៏ពោលបន្តថា :

- ក្រែងនាងចង់ស្គាល់ប្រពន្ធរបស់ខ្ញុំមែនទេហ៏?

- មែនហើយ! (ផល្លីនងក់ក្បាល)

CHANBOKEO.COM

- អញ្ចឹង ផល្លីនចង់រួមដំណើរជាមួយខ្ញុំត្រលប់ទៅព្រះនេត្រព្រះទេ?

ផល្លីនញញួរដូច្នោះក៏ញញឹមឡើង ហើយឆ្លើយថាៈ

- ខេវិនទុកចិត្តខ្ញុំហើយ ថាខ្ញុំមិនទៅអុកឡុកភរិយារបស់ខេវិន?

- ទុកចិត្តទាំងស្រុង! (ខេវិនញញឹម) ព្រោះខេវិនស្គាល់ផល្លីនច្បាស់ណាស់ គឺនិយាយយ៉ាងម៉េច ធ្វើយ៉ាងហ្នឹង!

ទាំងពីរនាក់ ក៏ញញឹមដាក់គ្នាយ៉ាងបំព្រងឡើង បន្ទាប់មកក៏នាំគ្នា ត្រលប់ទៅម្តុំដែលគេបានជួបម៉ែអាដូងកាលថ្ងៃត្រង់ តែបាត់មនុស្សអស់ ឃើញតែអ្នកផ្សេង។ ខេវិននាំផល្លីនដើរពីបីជុំមិនឃើញនរណាសោះ ក៏សំរេចចិត្តរកឡានឈ្នួលជិះតំរង់ទៅព្រះនេត្រព្រះវិញតែម្តង។

៩៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩

៩

CHANBOKEO . COM

# វគ្គទី៦

# ស្នេហាពិត

**ថ្ងៃទី២១មករា២០០៦** ដដែល

ខេរិននាំផល្លីនចុះពីតាក់ស៊ី ដែលឈប់ចតនៅទីប្រជុំភូមជប់ ។ ពេល នោះព្រលប់ងងិតព្រាល១ទៅហើយ ។ មនុស្សម្នាក៏បិទទ្វារឈប់លក់តវ៉ាន់ ដែរ ។ ចំណែកចរាចរវិញគឺស្ងួន្យហើយ មិនដឹងថាទៅរកម៉ូតូឌុបជិះនៅ ឯណាទេ ។ ខេរិនក៏ងាកសួរមិត្តស្រី:

- ផល្លីនអាចដើរបានទេ ប្រហែលពីរបីគីឡូ?

- ជ្រុលដំណើរដល់ថ្នាក់នេះទៅហើយ... អោយវាទៅម៉ាដំណើរវាទៅ ។

ឮដូច្នោះ ខេរិនញញឹមឡើង ហើយក៏ដើរនាំមុខផល្លីនទាំងប្រថុយ ប្រថាន ស្រាប់តែបានប្រទះនឹងអ្នកស្រុកកំពុងបររទេះគោម៉េតង៉ត១ ក៏សុំ គេជិះរហូតដល់ក្នុងភូមិ ។ រួចហើយ គេនាំគ្នាចុះដើរមួយស្របក់ទៀតទើប ដល់ផ្ទះរបស់ចាន់ ។ គ្រានោះ ផល្លីនលាន់មាត់សួរទៅខេរិនថា :

- យី! ខេរិនមកទីនេះតែប៉ុន្មានថ្ងៃ ហេតុអីក៏ស្គាល់ភូមិសាស្ត្រស្រុកភូមិនេះ ច្បាស់អីច្បាស់ម្លេះ?

- គឺមកពីចាន់គេនាំខ្ញុំរត់ចុះរត់ឡើងតាមរកលិខិតមរតកនោះអី បានជា ស្គាល់ច្រើនច្រកល្ហកអញ្ចឹង ។

ខេរិនបើកទ្វារចូលទៅក្នុងផ្ទះ ។ ផល្លីនក៏ឧទានថែមទៀតថា :

- ផ្ទះអត់ចាក់សោរទេហ៎?

- អត់ទេហ៎! ប្រហែលជាម៉ែឬអូនចាន់ភ្លេចចាក់ហើយ... ឬក៏ប្រហែលជា ទំលាប់ស្រុកគេមិនចាក់សោរក៏មិនដឹង ព្រោះភូមិគេគ្មានចោរខ្មួញ...

តាមពិតខេរិនមិនដឹងទេ ចេះតែថា១អោយតែផុតពីមាត់ទៅ ។ ខេរិន បើកទ្វារចូលទៅក្នុងផ្ទះ អុជចង្កៀងបំភ្លឺផ្ទះហើយក៏ដើរចេញទៅក្រៅ ។ ផល្លីនឃើញខេរិនកាន់ពិលដើរចេញមក ក៏សួរថា :

- ខេរិនទៅណាហ្នឹង?

- មិនឃើញចាន់នៅផ្ទះមិនដឹងថាគេមកពីភ្នំពេញហើយនៅ? ខ្ញុំគិតថាទៅ តាមរកចាន់ នៅកន្លែងមួយទៀតក្រែងលោគេបានមកដល់ផ្ទះមុខពួកយើង

CHANBOKEO.COM

- នៅឯណា? អោយខ្ញុំទៅផងបានទេ?

- មិនបាច់ទេ! ផល្លីននៅចាំទីនេះហើយ...

- ពុទ្ធោ! អោយនៅចាំក្នុងផ្ទះងងិតបែបនេះ.. មិនស្រួលទេដឹង?

- ដើរទៅស្រែពេលយប់ពិបាកជាងហ្នឹងទៅទៀត! ផល្លីននៅទីនេះហើយ បន្តិចទៀត ខ្ញុំមកវិញហើយណា៎!

ថាហើយ ខេរិនស្ទុះចេញទៅយ៉ាងលឿន រកតែផល្លីនរត់តាម ក៏មិនទាន់ដែរ។ មួយស្របក់ក្រោយមក ខេរិនក៏បានមកដល់ខ្ទមយាយភួង។ នាយក៏ស្រែកកូកហៅឡើង :

- ចាន់! អូននៅទីនេះទេ?.... ចាន់.!!... ខេរិនមកវិញហើយណា៎អូន... ចាន់...!!.

ស្ងាត់ច្រៀប គ្មានចំលើយតបសោះ។ ខេរិនដើរទៅដើរមកមួយសន្ទុះ ធំ ឆ្វៃលជុំវិញដីទួល ប៉ុន្តែនៅតែមិនឃើញស្រមោលចាន់ដដែល។ ដោយ អស់សង្ឃឹមថានឹងរកនាងឃើញ ខេរិនក៏គិតថា ប្រហែលជាចាន់និងមីងចាបមិនទាន់ចេញដំណើរពីភ្នំពេញមកទេ។ មាណពក៏ត្រលប់មកផ្ទះទាំង រសេះរសោះដៃជើងអស់កំលាំងចិត្តរលីង។ លុះនាយមកដល់ផ្ទះវិញ បើក ទ្វារចូលក្នុងបន្ទប់ ស្រាប់តែប្រទះផល្លីនគេងអោបដៃក្រវៀន នៅលើគ្រែ គេងរបស់ចាន់។ នាយបើកភ្នែកធំៗ ហើយឧទានថា :

- ផល្លីន! ខ្នើយមួយនោះជាខ្នើយមង្គលរបស់ខ្ញុំនិងអូនចាន់ទេ។ អោយ ខ្ញុំស៊ុំវិញយកវិញណា៎...!

ផល្លីនឮហើយ ក៏ងើបអង្គុយឡើង :

- ចុះបើយកខ្នើយទៅ តើខ្ញុំមានអីកើយ...? ទៅរកមួយទៀតមកអោយខ្ញុំ សិនម៉ោ។

- អត់ទេ! អោយខ្នើយនោះមកខ្ញុំសិនមក ចាំខ្ញុំទៅរកថ្មីមកអោយ។

- ចុះបើរកមិនបាន...?

- មានតែយកដៃខ្លួនកើយជាខ្នើយម៉ាយប់ទៅ។

ផល្លីនឮដូច្នេះក៏អន់ចិត្តស្រលេតតែម្តង។ នាងក៏ស្រវាខ្នើយមង្គលនោះ លើកគប់ចំមុខខេរិនទាំងឃ្នាន់ខ្នាញ់ :

- នេះ៎ យកទៅ របស់សំលាញ់ចិត្ត!

តែខេរិនមិនខឹងទេ។ បានទទួលខ្នើយកាលណា នាយយើងក៏ញញឹមះ

- អរគុណណាស់ មិត្តសំលាញ់!!

ថាហើយខេរិនក៏អោបខ្នើយដើរចេញទៅ។

ផល្លីនអង្គុយសំលក់តាមពីក្រោយ តែដោយកំពុងហត់អស់កំលាំង ឆវី រូបស្រស់ក៏ប្រាស់ខ្លួនកើយដៃសំងំគេងលក់ទៅ។

រាត្រីនោះ ខេរិនគេងនៅលើគ្រែរានហាលមុខផ្ទះ អោបខ្នើយមង្គល ស្រម័យនឹកទៅដល់ចាន់មួយយប់ទល់ភ្លឺ ហើយមានអារម្មណ៍ថា រូបនាយ បានមកប្រទះនឹងភាពកណ្តោចកណ្តែងក្នុងចិត្តសាជាថ្មីទៀតហើយ កាលបើ បាត់រូបចាន់ទៅ។

CHANBOKEO.COM

ពេញមួយរាត្រី ខេរិនគេងសំលឹងមើលមេឃ បែបទន់សូម អោយចាន់ឆាប់ត្រលប់មករកនាយវិញយ៉ាងលឿនបំផុត ។ ព្ធដ៏វេហាស៍ពពកខ្មៅមីរខ្មាន់ខ្មាប់បាំងបិទជិតអស់រស្មីដួងចន្ទ័ ប្លែកខុសពីធម្មតា មិនខុស ឡើយពីដួងឱរាខេរិន ដែលពោរពេញទៅដោយភាពធុញថប់តប់ប្រមល់ ឥតឧបមានោះឡើយ ។

**រាត្រីបាត់ដួងចន្ទ័**

រាត្រីសែនជ្រៅមេឃខ្មៅងងិត សូរសៀងចម្រិតអង្រួនអារម្មណ៍ ទឹកស្ទឹងហូរទៅកាត់ព្រៃជ្រងំ
បេះដូងថ្ងូរយំត្បិតបាត់ចន្ទ័ថ្លា ។ យាងទៅណាហើយដួងចន្ទ័វរលក្ខណ៍ ចិន្តាជំពាក់ពន្លឺនភា ធ្លាប់រះចែងចាំងលើដែនពសុធា
រង្សីសោភាគ្មានអ្វីឡើយផ្ទឹម ។ យប់នេះបាត់ចន្ទ័មេឃអាប់រស្មី ឱរាកវីឃ្លាតក្តីសង្ឃឹម រង់ចាំចន្ទ័យាងនាំភាពញញឹម
ទិដ្ឋភាពប៉ប្រឹមក្រោមពណ្ណរាយចន្ទ័ ។ ចន្ទ័អើយឆាប់វិលមករកវេហាស បំភ្លឺទ័យាតិសម័យក្សេមក្សាន្ត
រៀមរង់ចាំចន្ទ័ញាប់ញ័រក្នុងប្រាណ ចាំចន្ទ័កល្យាណបំភ្លឺចិត្តបងម្តងទៀត...

ព្រហាមស្អែកឡើង...

**ថ្ងៃទី២២មករា ២០០៥**

ខេរិនអង្គុយបើកភ្នែកភ្លិះៗ រង់ចាំមើលផ្លូវចាន់បណ្តូលចិត្តពេញមួយ យប់ទល់ភ្លឺ ឡើងផ្សាភ្នែកទៅហើយ តែចាន់មិនឃើញត្រលប់មកដដែល ។ ដោយក្តីអន្ទះសាពេក នាយយើងក៏ត្រលប់ទៅខ្មុំស្រែម្តងទៀត ។ ប៉ុន្តែគួរ អាណិតខេរិន គឺនាយបានត្រឹមតែខកចិត្តប៉ុណ្ណោះ ត្បិតគេមិនបានយល់ វត្តមានរបស់ចាន់នៅទីនោះឡើយ ។ បុរសយើងសំរូតខ្លួនអង្គុយក្រោមដើមអំពិលទាំងរសេះរសោះដៃជើង ។ ពេលវេលាក៏កន្លងទៅយ៉ាងយឺតៗ បំផុត ។ ខេរិននៅតែអង្គុយសំកុកតែម្នាក់ឯងយ៉ាងស្រងូតស្រងាត់...

ស្រាប់តែ មានក្មេងឃ្វាលគោម្នាក់រត់មកហៅ :

- ពូរិនៗ! មានមនុស្សប្លែកៗ មករកពូនៅឯផ្ទះ គ្នាច្រើនណាស់ ឮថាមកពី ភ្នំពេញផង!

ខេរិនភ្ញាក់ព្រើតកាលបើឮក្មេងឃ្វាលគោប្រាប់នាយដូច្នោះ ថែមទាំង នឹកងឿងឆ្ងល់ថា តើនរណាទៅជាមនុស្សចំលែកៗមកពីភ្នំពេញ ដើម្បីតាម រកនាយ បើនាយមិនដែលមានញាតិមួយគ្រាប់នៅភ្នំពេញផង? ខេរិនក៏ស្រវាកាន់ខ្មើយមង្គលដើរត្រលប់ទៅផ្ទះវិញយ៉ាងរហ័ស ។ មកដល់មុខផ្ទះ ភ្លាម នាយយើងបានឃើញមនុស្សម្នាជាច្រើនណែនណាន់ខ្មាន់ខ្មាប់ ពេញ មុខផ្ទះតែម្តង មានទាំងមនុស្សក្នុងសំលៀកទីក្រុង មានទាំងអ្នកភូមិពាក់ អាវខ្លះអត់អាវខ្លះ មានចាស់មានក្មេង មានប្រុសមានស្រីគ្រប់វ៏យ ទាំង អស់ ។ រំពេចនោះ បុរសស្រ្តីពីររូបក៏បានលេចធ្លោមកដល់ចំពោះមុខខេរិន ។ បុរសយើងក្រលេកឃើញភ្លាមក៏លាន់មាត់ឡើង :

- មីងពៅ! ពូវៃ!

- មែនហើយ! (មីងពៅឆ្លើយឡើង) មកដល់ស្រុកខ្មែរប៉ុន្មានថ្ងៃ សុខ សប្បាយជាទេ ខេរិនក្មួយសំលាញ់របស់មីង?

ស្រាប់តែ ខេរិនលើកដៃឡើង សំពះអ្នកទាំងពីរ ។ ទាំងមីងពៅ ទាំងពូវៃភ្ញាក់ក្រញាងពេលដែលឃើញខេរិនលើកដៃសំពះគាត់ ។ មីងពៅក៏ ពោលបន្តទៀតថា :

CHANBOKEO.COM

- ឯងមិនមាត់មិនស្តីដូច្នេះ បានន័យថាឯងសុខសប្បាយទេ មែនទេហ៎?

ស្រាប់តែខេរិនស្រវាំអោបមីងពៅដោយរលីងរលោងទឹកភ្នែក ហើយ អួលដើមកនិយាយមិនចេញសោះ ។ មីងក៏មានប្រសាសន៍បន្តថា :

- ពុទ្ធោ! ឯងនឹកមីងរហូតដល់ស្រក់ទឹកភ្នែកបែបនេះឬក្មួយ?

ការពិត ខេរិនកំពុងតែអាណិតខ្លួនដែលបាត់រូបចាន់មិនដឹងដំណឹងនោះ ទេតើ ។ រំពេចនោះ តាដីរមេភូមិបានមកដល់ដែរ ។ កាលបើក្រលេកឃើញ មីង ពៅនិងពូវៃ តាដីរក៏លាន់មាត់ឡើងថា :

- អ៊ឺយ! អន្ទិតវៃ នាងពៅ? មកលេងស្រុកម្តង ម៉េចមិនប្រាប់ដំណឹងឱ្យ យើងជាមុន ដូច្នេះហ្អាស?

ពូវៃមីងពៅក្រោកឡើងសំពះសួរភ្លាម ។ តាដីរក៏សួរថែមថា :

- ហើយចុះថ្ងៃនេះ មានក្បួនហែមកស្រុកភូមិយើងអីក៏ធំដុំម្លេះ?

ពូវៃក៏ឆ្លើយវិញថា :

- បុរសពីរបីនាក់ខាងនេះ ជាបុគ្គលិកក្រសួងសង្គ្រោះកុមារ បាននាំសារពី ក្រសួងមករកមេភូមិអោយជួយចាត់ចែងរឿងមួយ ហើយកុមារខាងនេះ ជាក្រុមរបងកត្តិយស...

- ហើយចុះអ្នកឈរខាងនេះវិញ?

តាដីរបួញមាត់ចង្អុលទៅនារីសោភាមួយរូប ដែលឈរក្បែរបុរសស្ត្រី ពីររូបដែលស្លៀកពាក់យ៉ាងថ្លៃថ្នូរ ហើយមានអ្នកបំរើហែហមពីរបីនាក់ ។ មីងពៅក៏ឆ្លើយភ្លាមៈ

- តាដីរភ្លេចគេហ៎ហើយហ្អឹងតា? នេះគឺ លោកសារិត នាងសុមាលី ក្មួយ យាយភួងនោះអី!

ហើយនេះជាកូនស្រីរបស់គេឈ្មោះសាលីរតន៍ ដែល យាយភួងបំរុងទុកដាក់រៀបចំអោយទៅឫទ្ធិរិទ្ធជាគូស្រករ...!

ខេរិនឮដូច្នោះ ក៏ភ្ញាក់ស្មារតីព្រើត លួចសំលឹងទៅនាងក្រមុំសោភា ម្នាក់នោះ ។ ធិតានោះពិតជាមានសម្ផស្សគួរអោយគយគន់ណាស់ ហើយ មានឫកពារសុភាពទន់ភ្លន់មានសណ្តាប់ធ្នាប់ថ្លៃថ្នូរ គួរអោយចាប់អារម្មណ៍ បំផុត ។ នាយនឹកក្នុងចិត្តថា :

- ហេតុអ្វីទៅហ្ន៎? យើងមានសំណាងមកជួបមាណវីយ៉ាងស្អាតសោភា តែ ចិត្តយើងបែរជាធុញថប់តប់ប្រមល់ទៅវិញ? ហើយហេតុអ្វីបានជាយើង សុខចិត្តលះបង់សេរីភាពដែលយើងមានគ្រប់សព្វទាំងអស់នៅអាមេរិក រួច ស្ម័គ្រចិត្តដើរចូលក្នុងជីវិតមួយទៀតនៅស្រុកខ្មែរ ដែលយើងគ្មានសេរីភាព អ្វីទាំងអស់ សូម្បីតែការជ្រើសរើសគូស្រករសំរាប់ខ្លួនឯងផ្ទាល់?

រំពេចនោះ តាដីរឧទានខ្លាំងៗថា :

- ឱ! ទេវតាអើយ! ក្មួយសារិត! នាងសុមាលី! បែកទៅច្រើនឆ្នាំ លេច មុខមកវិញស្រាប់តែសង្ហារប្លែក ធ្វើអោយតាដីរមើលក្មួយទាំងពីរលែង ស្គាល់តែម្តង!

CHANDOKEO.COM

តាដីវីស្ទុះទៅជិតលោកសារិត ហើយទះស្មាសំដែងសេចក្តីរាប់អាន និងនឹករលឹកបំផុត ។ ខេរិនក្រលេកឃើញមុខលោកសារិត ក៏ចាប់ភ្លឹកថា នាយហាក់ដូចជាធ្លាប់ស្គាល់គាត់ពីមុនមក ។ មាណពនឹកចុះនឹកឡើងមួយ ស្របក់ទើបយកដៃទះថ្ងាសសំដែងអាការៈហួសចិត្ត ។ មែនហើយ! លោក សារិតមិនមែនជានរណាក្រៅពីបុរសម្ចាស់វិឡាដ៏ស្កឹមស្កៃ នៅឯទួលគោក ម្នាក់នោះទេ ។ កាលណោះ នាយយើងអាល័យ តែនឹកទៅដល់រឿងមរតក ច្រើនពេក ក៏ភ្លេចមិនបានគួរសមនឹងគាត់អ្វីបន្តិចសោះ ។ ដល់មកប្រទះ ផ្ទាល់ម្តងទៀត ខេរិននឹកហាក់ដូចជាខ្មាស់ក្រោយណាស់ដែលខ្លួនមិនមាន សុជីវធម៌ចំពោះចាស់ទុំ ជាពិសេសទៅទៀត គាត់ក៏ជាសាច់ញាតិរបស់នាយផង ។ ប្រសិនបើចៃដន្យមិនបាននាំនាយអោយមកជួបចាន់ទេនោះ ប្រហែលជាមាណព ត្រូវធ្លាក់ក្នុងអន្លង់ស្នេហ៍របស់កញ្ញាប្រិមប្រិយ៍ឈ្មោះ សាលីរតន៍នោះផងក៏មិនដឹងផង ព្រោះនាងស្រស់ស្អាតគួរអោយស្រលាញ់ណាស់ ។ គិតទៅគិតមក៏ គឺបានត្រឹមតែគិត... ខេរិនមិនមានអារម្មណ៍ រីករាយអ្វីទាល់តែសោះ ។ ភ្លាមនោះ ពូគ្រុឌរំរែកហ្វូងអ្នកភូមិដែលកំពុងឈរ មើលដើរចូលមក ព្រមទាំងស្រែកថា :

- សូមប្រកាសរឿងមួយសិន បានទេ?

ទាំងអស់គ្នាភ្ញាក់ក្រញាង បែរមើលពូគ្រុឌ គ្រប់ៗគ្នា ។ គាត់ក៏មាន ប្រសាសន៍តទៅទៀតថា :

- គឺថា រឿងយាយភួងផ្សំផ្គុំអាអន្ទិតឫទ្ធិរិន្ទ អោយទៅចៅស្រីសាច់សន្តាន លោហិតរបស់គាត់នោះ ឥលូវនេះត្រូវចាត់ជាមោឃៈ!!!

- ហ្អាក! ម៉េចអញ្ចឹង? (មីងពៅពូរីលាន់មាត់ព្រមគ្នា)

- ព្រោះអាអន្ទិតរិន្ទ វាបានរៀបការជាមួយកូនស្រីអ្នកភូមិរបស់យើងរួច ហើយ អាស្រ័យហេតុនេះ វាមិនអាចរៀបការប្រពន្ធមួយទៀតបានដែរ ។

ភ្លាមនោះ ស្នូរមាត់អ៊ូអរជជែកគ្នាឡើង ។ ខេរិនឈ្ងោកមុខចុះមិន និយាយស្តី តែក្នុងចិត្តអន្ទះសាណាស់មិនដឹងថាចាន់សុខទុក្ខយ៉ាងណាហើយ ថ្ងៃនេះ នាងនៅឯណា? នាយយើងរន្ធត់ញាប់ញ័រក្នុងចិត្តនឹកព្រួយបារម្ភ តែម្នាក់ឯងថ្លាថ្លែងមិនរួច ។ រីឯ លោកសារិតនិងភរិយា ក៏បែរមើលមុខគ្នា ធ្វើឡឹងឡង់ៗ ។ បែរមើលទៅកញ្ញាសោភានាមសាលីរតន៍វិញ ក៏ហាក់ដូច ជាសំដែងកិរិយាធម្មតាៗមិនជាភ្ញាក់ផ្អើលអ្វីឡើយ ។ ពេលនោះ ស្រាប់តែ មីងពៅបែរមកខេរិនហើយក៏សួរថា :

- ខេរិន! ទើបតែមកដល់ស្រុកខ្មែរមិនបានមួយអាទិត្យផង ឯងក៏រៀបការ ប្រពន្ធទៅហើយ?

ខេរិនងក់ក្បាលហើយនៅស្ងៀម ។

- ពុទ្ធោពុទ្ធំធម្មំ! (មីងពៅយកដៃរិតដើមទ្រូង) ហេតុអីក៏លឿនដូចផ្លេក បន្ទោរយ៉ាងនេះ? ខេរិន! ឯងត្រូវបណ្តាសាដូនតាទេដឹងបានជាធ្វើអ្វីប្លែកៗ ដែលឯងមិនដែលធ្វើពីមុនមក.. ?

ខេរិនមិនទាន់ឆ្លើយផង តាដីវីក៏ពោលកាត់ឡើង :

- ហើយវាយ៉ាងម៉េចហ្នឹង? កូនចៅរៀបការហើយ មិនព្រមជូនពរទេ គិតតែពីសួរច្រើននេះច្រើន!! យ៉ាប់មែនរឿយ!

CHANDOKEO.COM

ពូតាដឺវីរសំលុត មីងពៅក៏នៅស្ងៀមវិញ ។ ពេលនោះពូវៃក៏ឡើង និយាយម្តងថាៈ

- ណ្ហើយចុះ! រឿងគូស្រករកូនចៅ យើងអាចពិគ្រោះនៅពេលក្រោយ ក៏បានដែរ តែពេលនេះ គណកម្មការក្រសួងសង្គ្រោះកុមារគេបានមកដល់ ថែមទាំងមានកុមារជាច្រើនសិបនាក់ហែហមមកផង ។ តាមេភូមិមិនចង់ដឹងទេហ៎ ថាគេមកភូមិយើងក្នុងគោលបំណងអ្វីដែរ?

ពូដូច្នេះ តាដឺវីក៏បំបែរអារម្មណ៍ :

- អូហ៎មែនហើយ! ភ្លេចគួរសមអោយឈឹង! ហើយចុះលោកទាំងអស់មក ដល់ទីនេះ មានការអ្វីដែរ?

បុរសម្នាក់ក៏មានប្រសាសន៍ឡើងថា :

- បាទ! ខ្ញុំបាទឈ្មោះភក្ត្រា ជាប្រធានគណៈប្រតិភូប្រចាំក្រសួងបានហែ ហមយកលិខិតមរតកមួយច្បាប់របស់លោកយាយភួង ដែលបានធ្វើជា អំណោយសប្បុរសធម៌ចំពោះក្រសួងសង្គ្រោះកុមារ មកជូនលោកឫទ្ធីវិទ្ធ ដែលជាចៅដើម្បីចុះហត្ថលេខាអនុញ្ញាតអោយទៅបើកប្រាក់នៅធនាគារ

ស្រាប់តែតាដឺវីនិងពូគ្រុដលាន់មាត់ព្រមគ្នាឡើងថា :

- លិខិតមរតករបស់យាយភួង?

ពេលនេះ នរណាៗក៏ភ្ញាក់ផ្អើលដែរ សូម្បីតែខេវិនដែលជាម្ចាស់មរតក ផ្ទាល់ ។ មែនហើយ! កាលពីម្សិលម៉ែអាដួងបានប្រាប់ថាគាត់បានយកខ្មើយ ចាស់របស់យាយភួង ទៅដាក់ជាអំណោយអោយទៅគេបាត់ទៅហើយ ។ អស្ចារ្យណាស់! ថ្ងៃនេះលិខិតមួយច្បាប់នេះក៏បានវិលមកម្ចាស់ដើមវិញ ។ ប៉ុន្តែ... ចៃដន្យអី... មរតកទាំង អស់នោះបានក្លាយទៅមានម្ចាស់ថ្មីហើយ គឺក្រសួងសង្គ្រោះកុមារ ។ ពេលនោះដែរ ខេវិនក៏លែងមានចិត្ត មាន អារម្មណ៍ចង់តាមដានហើយថា តើលិខិតនោះចារពីអ្វីខ្លះ ហើយមរតកនោះ មានតម្លៃមហាសាលកំរិតណា? អ្វីដែលនាយកំពុងបែបន់នៅក្នុងចិត្តនៅ ពេលនេះ គឺការវិលត្រលប់របស់ចាន់មកផ្ទះវិញដោយសុវត្ថិភាពប៉ុណ្ណោះ ។ ទោះជាយ៉ាងណា អ្នកទាំងឡាយដែលនៅប្រជុំគ្នាមុខផ្ទះមីងចាប សុទ្ធតែ មានកិរិយាអើតអើមដកកឡើងវែងដូចកុកទៅហើយដោយសារតែចង់ដឹង ណាស់ថា តើលិខិត របស់យាយភួងចារពីអ្វីខ្លះ?

រំពេចនោះតាដឺវីក៏ស្ទុះចេញមុខភ្លាម :

- តាដឺវីខ្ញុំនេះជាមេភូមិ សូមទទួលយកលិខិតនេះទៅជូនម្ចាស់ដើមគេអាន ហើយចុះហត្ថលេខាត្រឹមត្រូវជូនក្រសួង!

លោកភក្ត្រាក៏លើកជើងពានប្រាក់មួយ ដែលពង្រាយត្របកផ្កាចំរុះ ពណ៌យ៉ាងប្រណិតទ្រលិខិតមួយច្បាប់នៅលើនោះ ហុចជូនទៅតាដឺវីភ្លាម ។ តាមេភូមិទទួលហើយក៏យកទៅហុចអោយខេវិន :

- ហាក់! នេះ! ស៊ីញ៉េទៅ!

ស្រាប់តែខេវិនគ្រវីក្បាល ។ តាមេភូមិលាន់មាត់ :

- ស្តាយមរតកឬអ្វីបានគ្រវីក្បាលមិនចង់ស៊ីញ៉េ?

CHANBOKEO.COM

- មិនមែនទេ... (ខេរិនតបវិញ) គ្រាន់តែខ្ញុំមិនចេះអានអក្សរខ្មែរ ប៉ុណ្ណោះ ។

- អូហ៎! ហ៊ែសៗ! គាត់ភ្លេចអោយយើងដែរថា អាចៅឯងជាអនិកជន មកពីបរអាតេះ ។ ហាក់! មើល៎! ក្មេងក្មាងភ្នែកភ្លឺៗ ជួយអានមរតក អោយនាយខេរិនបន្តិចមើល៎!

ភ្លាមនោះ ស្រាប់តែខេរិនចាប់ភ្លឹកនឹកឃើញរឿងមួយ ក៏ស្ទុះកញ្ឆក់ យកលិខិតមកពីជើងពាននោះយ៉ាងរហ័ស ធ្វើអោយអ្នកទាំងឡាយភ្ញាក់ ក្រញាង ។ តាជីវ៉ិឃើញហើយក៏សួរឡើង :

- ហ្អើយនែ៎! អាអន្ទិតវិន្ទ! ឯងកំពុងលេងស្នៀតអីហ្នឹង?

ខេរិនក៏កាន់លិខិតដើរចូលមកកណ្តាលហ្វូងមនុស្សទាំងឡាយនោះ រួច ស្រែកប្រកាសខ្លាំងៗថា :

- បើសិនណាអ្នកទាំងអស់អាចជួយរកអូនចាន់ អោយត្រលប់មកអាន លិខិតនេះបាននៅវេលាណា ខេរិននឹងស៊ីញ៉េក្រដាសនេះជូនអ្នកទាំងអស់ ភ្លាម នៅវេលានោះដោយឥតស្តាយក្រោយឡើយ ។

ទាំងអស់គ្នាបែរមើលមុខគ្នាធ្វើភាំងរវៀងៗខ្លួន ។ ពូគ្រុឌក៏ស្រែករំពង ឡើង :

- មិនបាច់ទៅរកនាងចាន់នៅឯណាទេ នាងបានមកដល់ទីនេះតាំងពីយូរ មកហើយ!

ខេរិនឮដូច្នោះ ក៏ងាកផាំងបែររកនាងចាន់ភ្លាម តែមិនឃើញនាង សោះ ។ នាយបែរមើលចុះឡើង ស្រាប់តែឃើញជាវកន្សែងបក់រិចៗ នៅពីក្រោយខ្នងរបស់អ្នកស្រីសុមាលី ។ នាយយើងនឹកអរភើតពោះ ត្បិត នោះជាកន្សែងដែលចាន់តែងតែទទូររាល់ថ្ងៃ មុនពេលចេញដើរទៅក្រៅ ។ នាយក៏ស្ទុះទៅទាញដៃនាងចាន់អូសចេញមកយ៉ាងរហ័ស :

- ចាន់!... អូនមកវិញហើយ... ព្រះអើយ! បងត្រេកអរអ្វីម្លេះទេ!

មែនហើយ! នោះគឺជាចាន់ពិតមែនឥតក្លែងក្លាយឡើយ ។ ខេរិនរំភើប ចិត្តរកអ្វីប្រៀបមិនបានទេ ។ នាយក៏ស្រវាអោបនាងយ៉ាងណែនពេញរង្វង់ ដៃ ។ ទឹកភ្នែកពីរដំណក់បានស្រក់ចុះចាកនេត្រារបស់ខេរិន ជំនួសសេចក្តី ត្រេកអរ និងទឹកចិត្តសប្បាយរីករាយហួសព្រំដែន ដែលចាន់បានវិល ត្រលប់មកវិញ ។ ពេលវេលាក៏ធ្វើដំណើរទៅយ៉ាងស្ងៀមស្ងាត់ ។ អ្នកភូមិ អ្នកស្រុកទាំងឡាយដែលកំពុងឈរចោមរោមទីនោះ ក៏នាំគ្នាប្រឹងអត់ ដង្ហើមរង់ចាំតាមដានសាច់រឿងគូស្នេហ៍មួយគូដ៏ថ្មីថ្មោង ។ ពេលនោះគ្មាន នរណាហ៊ានហើបមាត់និយាយអ្វីទេ ក្រៅតែពីបណ្តោយអោយខេរិនសំដែង នូវមនោសញ្ចេតនាដ៏មានជំរៅធំធេង ចំពោះធិតាម្ចាស់ស្នេហ៍ ។ ខេរិន យើងហាក់ភ្លេចអស់ហើយ ថានាយកំពុងស្ថិតនៅក្រោមក្រសែភ្នែកជា ច្រើន ។ បុរសយើងគិតតែពីឈរអោបភរិយា ញញឹមផង រំភើបចិត្តផង រលីងរលោងទឹកភ្នែកផង សំដែងអាការៈហាក់ដូចខ្លាចបាត់រូបនាងសាជា ថ្មីដូច្នោះឯង ។ ផ្ទុយទៅវិញ ចាន់បែរជាមានឫកពាហាក់ដូចជាស្ងើយការ ទុកចិត្តចំពោះខេរិនណាស់ ។ នាងមិនព្រមនិយាយអ្វីតបចំពោះនាយវិញ ឡើយ ។ នៅខាងក្រោយខ្នងរបស់ចាន់ មីងចាបឈរញញឹមបិទមាត់មិនជិត កាលបើឃើញខេរិន លាតត្រដាងដួងចិត្តមនោសញ្ចេតនារបស់ខ្លួន ចំពោះ កូនស្រីរបស់គាត់យ៉ាងចំហ នៅចំពោះមុខញាតិទាំងឡាយក្នុងភូមិ ។

មួយស្របក់ក្រោយមក តាជីវ៉ិក៏គ្រហែមឡើង :

CHANBOKEO.COM

- ហ៊្អែម! ហើយម៉េចនេះ? ថតកុនចប់ហើយនៅ? ល្មមដល់នាទីសំរាក ហើយទើដឹងហ្អាស អាអន្ទិតវិន្ទ?

ខេរិនភ្ញាក់ស្មារតីព្រើត ងើបមុខឡើងងាកបែរក្រោយទៅតាដឺរី ក៏ ញញឹមឡើងទំនងដូចជាអៀនខ្មាសបន្តិចដែរ ដែលនាយអាល័យតែរំភើប ចិត្តភ្លេចខ្លួន ។ ភ្លាមនោះ នាយក៏ទាញដៃចាន់ទៅឈរនៅកណ្ដាលវង់ហើយ ហុចក្រដាសសំបុត្រទៅឱ្យនាង រួចក៏ពោលឡើងយ៉ាងស្រទន់ទៅនាងថា :

- ចាន់! បងជាមនុស្សខ្វាក់ ត្រូវការអោយប្រពន្ធដឹកដៃនាំផ្លូវ.. តើចាន់ អាចធ្វើជាភ្នែកឱ្យបងបានដែរឬទេហ៎អូន?

ចាន់ងើបឡើងមើលមុខមកខេរិន ឃើញនាយសំលឹងនាងដោយកែវ ភ្នែកដ៏មានទឹកដមមន្តស្នេហ៍យ៉ាងទន់ភ្លន់... ទោះនឹងចង់ប្រកែក ក៏នាង ហើបមាត់លែងចេញដែរ មិនដឹងជាហេតុអ្វីទេ ពេលនេះបេះដូងរបស់នាង ក្លាយជាទន់ជ្រាយដូចតៅហ៊ូស្ងោរអស់រលីងតែម្ដង ។ ចាន់ក៏លូកដៃទទួល យកក្រដាសមួយសន្លឹកនោះពីដៃខេរិញមកអានភ្លាម ។ កាលបើឃើញ ភរិយាព្រមធ្វើតាម ខេរិនក៏ញញឹមទាំងរំភើបរហូតនិយាយលែងចេញ ។ ចាន់ក៏ចាប់ក្រដាសអានដូចតទៅ :

*- ចំពោះឫទ្ធិវិន្ទចៅប្រុសទោលរបស់ជីដូន ។ ជីដូនមានសំណូមពរពីរយ៉ាង សំរាប់ឱ្យចៅជ្រើសរើស ។ ទីមួយ បើចៅព្រមរៀបការជាមួយចៅស្រីដែល យាយបានជ្រើសរើសទុកដាក់អោយចៅ នោះយាយនឹងប្រគល់ទ្រព្យ មរតកទាំងអស់របស់យាយ ទៅអោយចៅទាំងពីរ ជាចំណងដៃ អាពាហ៍ពិពាហ៍ ។ ទីពីរ បើចៅប្រុសប្រកែកមិនព្រមរៀបការវិញនោះ ទ្រព្យសម្បត្តិពាក់កណ្ដាល នឹងក្លាយទៅជារង្វាន់អោយទៅចៅស្រីដែល យាយបានជ្រើសរើសទុក ។ ចំណែកពាក់កណ្ដាលទៀត សូមប្រគល់ជូន ទៅអង្គការមនុស្សធម៌ជាអំណោយ សំរាប់បំរើជនរងគ្រោះទាំងឡាយក្នុង ប្រទេសរបស់យើង.... យាយភួង!*

ភ្លាមនោះ អ្នកទាំងឡាយក៏នាំគ្នាមាត់ញូអ៊ូអរឡើង ចង់ដឹងថាតើខេរិន គេសំរេចចិត្តយ៉ាងណា ។ ប៉ុន្តែ ថៃដន្យអ្វី ខេរិនមិនបានស្ដាប់ឮពាក្យបណ្ដាំ ទាំងនេះទេ ក្រៅតែពីឈរកាន់ដៃភរិយារបស់ខ្លួនដោយក្ដីត្រេកអរតែ ម្យ៉ាងប៉ុណ្ណោះ ពេលនេះអ្វីៗ ក៏លែងសំខាន់ចំពោះខេរិនហើយ កុំថា ឡើយត្រឹមទ្រព្យសម្បត្តិមរតកអីទាំងនោះ ទោះច្រើនជាងនោះមួយរយ មួយពាន់ដងក៏នាយលែងគិតដែរ កាលបើនាយបានរូបចាន់វិលត្រលប់មក វិញដោយសុខសប្បាយ ។ ភ្លាមនោះ តាដឺរីក៏ពោលឡើង :

- ម៉េចហើយអាអន្ទិត? ឯងសំរេចចិត្តយ៉ាងណាដែរ?

ខេរិនបែរមើលមុខចាន់ ហើយកាន់ដៃនាងយ៉ាងណែន រួចបែរទៅ តាដឺរីមេភូមិ ហើយឆ្លើយវិញថា :

- ខ្ញុំមិនរៀបការទេ ហើយក៏មិនចង់បានមរតកទាំងនេះដែរ ។

ស្រាប់តែមីងពៅសួរនាយវឹងថា :

- ហើយចុះក្មួយឯងមិនចង់ដឹងទេហ៎ថា មរតកដែលឯងត្រូវទទួលនោះ មានអ្វីខ្លះ?

ខេរិនសំលឹងទៅកញ្ញាសាលីរតន៍ រួចហើយក្រុមកុមារទាំងឡាយនោះ មានខ្លះ ក៏ពិការ ខ្លះក៏ស្គាំងស្គម ខ្លះក៏មានទឹកមុខគួរអោយអាណិត ក៏នឹក ទៅដល់អតិតកាលមួយដែលខ្លួនធ្លាប់ជារស់នៅក្នុងមណ្ឌលកុមារកំព្រាតាមជំរំទល់ដែន ។

CHANBOKEO.COM

បុរសយើងនឹកអាណិតក្មេងទាំងនោះណាស់ ។ ចំពោះធិតា សាលីរតនីវិញ
នាងក៏ជាធិតាដែលមានកិរិយាប្រពៃមានសណ្ដាប់ធ្នាប់ម្នាក់ ថៃដន្យខេវិនមិនបានស្គាល់ចិត្តនាងសោះឡើយ ។ ម្យ៉ាងទៀត ពេលនេះ បេះដូងរបស់នាយក៏មានម្ចាស់រួចទៅហើយដែរ ។ ចំលើយគឺ មានតែចុះ ហត្ថលេខាប្រគល់ចំណែកមរតកទាំងពីរចំណែក ឱ្យទៅអ្នកដែលសមរម្យ នឹងទទួលយកចុះ ។ ខេវិនក៏បែរទៅមីងពៅហើយតបថា :

- តើសំខាន់អ្វីទៅ បើខ្ញុំមិនទទួលយកមរតកទាំងនោះដដែល ។ មាន ចំនួនប៉ុន្មាន ក៏មិនបានធ្វើអោយចិត្តខ្ញុំរំភើបដែរណាំមីង!

ភ្លាមនោះ តាដីរមេភូមិស្ទុះទាញក្រដាសពីដៃនាងចាន់យកទៅអាន ស្រាប់តែលាន់មាត់យ៉ាងខ្លាំងថា :

- ស្លាប់ហើយ! មរតកជាពេជ្រមួយរយគ្រាប់ តម្លៃ៥សែនដុល្លារ?

ទាំងអស់គ្នាជុំវិញនោះពូហើយបើកភ្នែកធំៗហើយឧទានបន្ទរថា :

- ៥សែនដុល្លារ?

ស្រាប់តែមីងពៅដែលមានឫកពាពិភាល់ក្នុងចិត្តជាងគេ ក៏ដើរមកជិត នាយយើងហើយសួរបញ្ជាក់ជាថ្មី:

- ៥សែនមិនតិចទេណាំក្មួយ! ឯងមិនស្ដាយទេហ៍?

- អត់ទេហ៍ (ខេវិននៅតែគ្រវីក្បាលឆ្លើយប្រកែកដដែលជាដដែល)

ពូវៃបញ្ជាក់ម្ដងទៀត :

- ខេវិន! ក្មួយច្បាស់ក្នុងចិត្តហើយដែលថា ឯងសំរេចចិត្តមិនរៀបការ ហើយមិនទទួលយកមរតកដ៏សំបើមនេះ?

ភ្លាមនោះ ស្រាប់តែមានសំលេងស្រីម្នាក់ឆ្លើយកាត់ពីក្រោយខ្នងពូវៃ ឡើងថា:

- ហេតុម៉េចទៅហ្ន៎? បានជាចាស់ៗ ចូលចិត្តបង្ខំក្មេងអោយដើរតាមផ្លូវ ដែលលោកគូសឱ្យដូច្នេះ? កូនចៅ ក៏ជាមនុស្សមានសាច់ មានឈាម មាន អារម្មណ៍ដូចជាលោកចាស់ៗដែរ តែហេតុដូចម្ដេចបានចាស់ៗនាំគ្នាគោរព តែអារម្មណ៍របស់ខ្លួនហើយរំពឹងយកតែទ្រព្យសម្បត្តិជាគោលចំបង ដើម្បី ចងរិតចិត្តកូនអោយរៀបអាពាហ៍ពិពាហ៍? ចុះឯណាទៅសេចក្ដីស្រលាញ់? តើកូនចៅរបស់យើងនឹងបានទទួលសេចក្ដីសុខដែរឬទេ កាលបើគេរៀប ការដោយខ្វះក្ដីស្រលាញ់ចំពោះគ្នាទៅវិញទៅមក?

ទាំងអស់គ្នាភ្ញាក់ព្រើតម្ដងទៀត ហើយក៏បែររកមើលម្ចាស់សំលេង ។ ស្រាប់ តែមីងពៅលាន់មាត់ឡើងថា :

- ផល្លីន?

មែនហើយ ការពិតផល្លីននៅឈរទីនោះយូរហើយ តែគ្មាននរណា ម្នាក់ចាប់ភ្លឹកចំពោះវត្តមានរបស់នាងឡើយ ត្បិតគេម្នាក់ៗអាល័យតែផ្ចង់ ស្មារតីលើនាយខេវិននិងលិខិតមរតកតែម្យ៉ាងប៉ុណ្ណោះ ។ ឃើញផល្លីនដើរ ចូលមកក៏ នាងចាន់ក៏ងរប៉េវ បំរុងដើរគេចចេញទៅ ស្រាប់តែខេវិនចាប់ដៃ នាងជាប់រួចស្រវាប្រកៀកអោបចាន់ផ្ទាប់នឹងខ្លួននាយយ៉ាងណែន ។ ពេល នោះ នាងចាន់ខំបំរះយកដៃបេះនាយចេញ ហើយនិយាយខ្សិបៗថា :

- អ្នក..! លែងខ្ញុំទៅ!

CHANBOKEO.COM

- បងមិនលែងទេ! (ខេវិនឱនខ្សិបដាក់ត្រចៀកនាង) ខ្លាចអូនគេចបាត់ពី បងដូចកាលពីម្សិលទៀត នោះបងច្បាស់ជារងរស្លាប់មិនខានឡើយ ។

- ស្លាប់ក៏ស្លាប់ទៅ! មានទាក់ទងអីនឹងចាន់?

- ម៉េចថាអត់? បើបងស្លាប់ទៅ អូននឹងនៅម៉េម៉ាយគេងយំស្តាយរូបបង នោះអី!

- តែផ្តាស! យ៉ាប់មែន!

ចាន់ស្រដីផងលូកដៃមួលចង្កេះខេវិនផង ។ ខេវិនឈឺណាស់តែខំទ្រាំ ហើយក៏ខ្សិបវិញថា :

- មិនផ្តាសទេ! លេងឈឺបែបនេះ តិចបងចាប់ថើបមុខគេតលូវហ្នឹងហើយ

ចាន់ឮដូច្នោះក៏ឈប់ភ្លាមហើយនៅស្ងៀម ហើយបែរសំលក់ខេវិនទាំង ឃ្មាន់ខ្នាញ់ ។ ឃើញភរិយារបស់ខ្លួនខ្មាសឡើងថ្ពាល់ក្រហម ខេវិនហាក់ដូច ជារិតតែបេតីនាងចាន់កាន់តែខ្លាំងឡើង១ ស្ទើរតែលេបនាងបាត់ទៅក្នុង បេះដូងទៅហើយ ។

រីឯពូគ្រុឌ កាលបើឃើញវត្តមានផល្លីនភ្លាម ក៏លាន់មាត់ឡើងថា :

- ហើយចុះ មានតួយីកេចំលែកមកពីណាហ្នឹង ស្លៀកពាក់អីក៏ប្លែកភ្នែក យ៉ាងហើយ!...

ពិតជាប្លែកដូចពូគ្រុឌថាមែន ត្បិតអីផល្លីនគេស្លៀកពាក់ស៊ិចស៊ីរបៀប ក្មេង១ប៉ោឡែស្រុកអាមេរិក ដែលពូគ្រុឌនិងអ្នកភូមិម្តុំនោះមិនដែលឃើញ
ពីមុនមកទេ ។ ពេលនោះ តាជីវក៏សួរនាងថា :

- តើនាងជានរណាដែរ ដែលចេះមកហៃហៃរឿងគេទីនេះ?

ផល្លីនក៏ឆ្លើយរឹងថា :

- ជានរណាមិនសំខាន់ទេចាស! ដែលសំខាន់នោះគឺ...

ផល្លីនបែរមករកខេវិននិងចាន់ហើយក៏ពោលឡើងថា :

-នៅវេលានេះ ខេវិននិងនារីកំពូលដួងចិត្តរបស់គេកំពុងរង់ចាំទទួលពរជ័យ សាធុការពីយើងទាំងអស់គ្នា ត្បិតគេបានស្វែងរកឃើញស្នេហាពិត ដោយ គ្មានទឹកប្រាក់ទ្រព្យសម្បត្តិជាចំណងមកបង្ខំចិត្តគេឡើយ ។

ឮដូច្នោះ អ្នកស្រុកអ្នកភូមិព្រមទាំងភ្ញៀវទាំងឡាយ ក៏ទះដៃហ៊ោរ រំពងឡើងយ៉ាងទ្រហឹងអឺងកង ត្បិតនាងផល្លីនមានវាចាសមហេតុសមផល ពិតមែន ។ ប៉ុន្តែ មីងពៅមិនសុខចិត្តទេ ។ គាត់ក៏តបទៅវិញថា :

- ប៉ុន្តែ បើខេវិនមិនព្រមធ្វើតាមបំណងល្អចុងក្រោយរបស់ជីដូន នោះ ចិត្តគាត់មិនបានស្ងប់ឡើយ ។

ស្រាប់តែផល្លីនឆ្លើយរឹងថា :

- ម៉េចក៏មីងពៅគិតថា មិនស្ងប់កើត កាលបើលោកយាយរបស់ខេវិនមិន បានបង្ខំចៅប្រុសរបស់គាត់ផងនោះ? លោកបានទុកផ្លូវពីរសំរាប់ចៅឱ្យ ជ្រើសរើសហើយតើ ។ បានន័យថា គាត់ក៏បានខ្លួនត្រៀមទទួលស្គាល់ការ

សំរេចចិត្តរបស់ចៅប្រុសទាំងពីរបែបជាមុនរួចស្រេចហើយ ។ បើមិនដូច្នេះ ទេ ម៉េចក៏គាត់ចារលិខិតបែបនេះធ្វើអ្វី? តាមពិតខ្ញុំគិតថា អ្នកដែលមាន អារម្មណ៍មិនស្ងប់នោះគឺជាអ្នកដែលមានជីវិតឯណោះទេ ជាពិសេអ្នក ដែលមានគំនិតផ្តោតទៅលើទ្រព្យសម្បត្តិជាចំណងភ្ជាប់ជីវិតគូស្រករ...!

មែនហើយ! ពេលនេះ នរណាក៏នៅស្ងាត់ស្ងៀមទាំងអស់គ្នាដែរ កាល បើនាងវែកញែកពិរោះដល់ម្លឹង ។ មីងពៅក៏ដកដង្ហើមយូរបន្ធូរការតានតឹង នៅក្នុងចិត្ត រួចហើយក៏បែរទៅលោកសារិតនិងភរិយា ព្រមទាំងមាន ប្រសាសន៍ថា :

- ទោះជាខេវិនគេសំរេចចិត្តបែបណាក៏ដោយ ក៏កូនស្រីរបស់លោក ស្ថិតនៅក្នុងក្រឡាវិជ្ជមានជានិច្ច ។ ខ្ញុំសង្ឃឹមថា សមាជិកក្នុងក្រុមគ្រួសារ របស់លោកមិនខកចិត្តពេកទេណា!

លោកសារិតនិងភរិយាញញឹមឡើង ។ លោកសារិតក៏ឆ្លើយថា :

- បាទ! មិនទេ អ្នកបង!

មីងពៅលួចក្រលេកមើលទៅកញ្ញាសាលីរតន៍ ដែលនៅឈរស្ងៀម ស្ងាត់មិននិយាយស្តីតាំងពីដើមមក ឃើញនាងក៏សំដែងទឹកមុខញញឹមដែរ ក៏ធូរទ្រូងខ្សាក ។

តាដីវីដែលនៅឈរស្ងាត់យូរហើយ ក៏មានប្រសាសន៍ប្តូរបរិយាកាស :

- ហាក់! អន្ទិតវិន្ទអើយ! នៅចាំអីទៀត! បើសំរេចចិត្តហើយ ប្រញាប់ មកស៊ីញ៉េក្រដាសទៅ! មើលហ្ន៎! ក្មេងៗគេឈរចាំអំណោយមនុស្សធម៌ ឡើងស្កកស្រូវអស់រលីងទៅហើយ ។

ខេវិនឮដូច្នោះក៏បែរមើលទៅផល្លីន ញញឹមដាក់នាងហើយពោលថា :

- អរគុណណាស់ផល្លីន! នាងជាមិត្តដ៏ល្អពិតមែន!

ផល្លីនញញឹមដាក់ខេវិននិងចាន់តបវិញ ដោយកែវភ្នែកភ្លឺថ្លាពណ្ណរាយ សំដែងនូវការរាប់អានយ៉ាងស្មោះស្ម័គ្រ ចំពោះគូស្នេហ៍ទាំងទ្វេដូចពាក្យ ដែលនាងបានសន្យាជាមួយខេវិន ។ រីឯនាងចាន់វិញកាលបើបានឈរស្តាប់ ស្ថានការណ៍ទាំងឡាយនោះ ដោយផ្ទាល់ភ្នែកផ្ទាល់ត្រចៀករបស់នាង ហើយក៏ហាក់ដូចជាធូរចិត្ត ស្បើយអារម្មណ៍ពីការខឹងម៉ក់ងរចំពោះខេវិន របស់នាងដែរ ។ អ្វីៗក៏បានធូរស្រាលឡើងវិញដោយឯកឯង ។ បន្តិចមក ខេវិនក៏កាន់ដៃភរិយាដើរសំដៅទៅលោកភក្ត្រា ហើយ ហុចលិខិតមរតក នោះទៅលោកព្រមទាំងវាចាថា :

- ខ្ញុំបានស៊ីញ៉េក្រដាសជូនហើយ ។ សូមជូនពរឱ្យក្រសួងមានជោគជ័យ គ្រប់មុខនាទីទាំងអស់ក្នុងការបំរើពលរដ្ឋតូចៗរបស់យើងក្នុងប្រទេស ។

ភ្លាមនេះ ក្រុមកុមារបានបន្លឺសំនៀងយ៉ាងពិរោះ ក្នុងបទចំរៀងខ្លីមួយ ដើម្បីជាការថ្លែងអំណរគុណទៅម្ចាស់អំណោយ ដែលបានយល់នូវសេចក្តី ត្រូវការរបស់ពួកគេទាំងឡាយ ។ ខេវិនឈរកាន់ដៃនាងចាន់ញញឹមផង រលីងរលោងទឹកភ្នែកផង ដោយក្តីរំភើបចិត្តឥតឧបមា ដែលគេមានឱកាស បានផ្តល់ក្តីសង្ឃឹមមួយទៅក្រុមកុមាររងគ្រោះអោយគ្នាបានជួបពន្លឺភ្លឺស្វាងក្នុងជីវិត ។

CHANBOKEO.COM

នៅព្រលប់នាថ្ងៃដដែល អ្នកភូមិទាំងអស់ព្រមទាំងភ្ញៀវពីភ្នំពេញបាន ប្រារព្វពិធីជប់លៀងជូនពរដល់ខេវិននិងចាន់សាជាថ្មី ដែលគេបានស្វែងរក ឃើញស្នេហាពិតដ៏សែនស្មោះស្ម័គ្រភក្តីបំផុតក្នុងជីវិត ។ ការពិតទៅ គ្មាននរណារំភើបត្រេកអរជាងគេក្រៅពីខេវិនយើងទេ ។ ថ្ងៃនេះ វេលានេះ មាណពគិតថា ជីវិតរបស់នាយដែលធ្លាប់តែមានចន្លោះប្រហោង ធ្វើអោយ នាយវង្វេងកើតទុក្ខសោកសៅក្នុងចិត្តរាប់ឆ្នាំមកនោះ បានប្រែក្លាយមកជា ជីវិតដែលមានសុភមង្គល និងសេចក្តីសុខយ៉ាងពេញលេញក្រៃលែង ។ បេះដូងរបស់នាយបានទទួលនូវភាពកក់ក្តៅអស្ចារ្យមួយ ថ្វីបើពេលនេះ នាយបានមករស់នៅហិតក្លិនអាចម៍គោ លាយក្លិនម្អមស្រែនិងក្លិនស្ករត្នោត ក៏ដោយ ។ ជាពិសេស កាលបើបុរសយើងមានចាន់នៅឈរក្បែរខ្លួន អ្វីៗក្នុងជីវិតរបស់នាយមានសភាពស្រស់បំព្រងហើយភ្លឺថ្លាជានិច្ច ។

នៅក្រោមដើមដូងចំហៀងលំនៅ គូស្នេហ៍ទាំងទ្វេហា បានគេចខ្លួនពី ហ្វូងអ្នកភូមិដែលកំពុងទះដៃច្រៀងរាំកំសាន្តសប្បាយក្នុងពេលជប់លៀង នោះ មកអង្គុយសាសងគ្នាស្ងាត់ៗតែពីរនាក់ ក្រោមពន្លឺដួងចន្ទ័ដ៏មានរស្មី យ៉ាងពណ្ណរាយ ។ ជំនោររំភើយមកពីទិសឧត្តរក្នុងរដូវចំរូត បានបក់នាំ អាកាសត្រជាក់មនោរម្យមួយ មកបបោសថ្នាក់ថ្នមគូគាប់ទាំងពីរកាយា អោយមានអារម្មណ៍យ៉ាងស្រស់ថ្លាឥតគណនា ។

## ទេពមន្តរាត្រី

**ស្រី:**

ចន្ទ័រះចុងខ្មៅតស្រស់ឆើតភ្លឺថ្លាពណ្ណរាយ ក្រអូបក្លិនផ្កាឯនាយ សាយភាយជិត ជាប់នាសា ជំនោររាត្រីអង្អែលថ្នាក់ថ្នមទ័យា ព្រឺព្រួចកាយាឱ្យរំភើបគ្មានថ្លែង ។

**ប្រុស:**

ហ្វូងផ្កាយព្រិចៗរំលេចអមដួងច័ន្ទថ្លា អណ្តែតឰដ៏វេហាស៍ លួងលោមចិន្តាចំបែង ឱ្យស្រោនគ្នុងល់អំពល់វិយោគសង្រេង ស្មារតីវង្វេងភាពក្សេមក្សាន្តនៃរាត្រី ។

**ស្រី:**

នៅក្នុងរង្វង់ហត្ថាអម្រិត រំជួលដួងចិត្តញាប់ញ័រពេញហឫទ័យ
យប់យន់សែនស្ងាត់ ខ្យល់ផាត់សន្សើមរាត្រី ប្រស់ព្រំពរជ័យដល់គូមេត្រីកល្យាណ

**ពីរនាក់:**

លើកហត្ថប្រណម្យបង្គំឥន្ទទេវតា សូមលោកយាងថែរក្សាស្នេហានៃយើងពីរប្រាណ ឱ្យភ្លឺពណ្ណរាយដូចផ្កាយនិងដួងព្រះច័ន្ទ រុងរឿងក្សេមក្សាន្តលុះអវសានរៀងអើយ ។

**រាត្រីថ្ងៃ២២មករា ២០០៦...**

ក្នុងបន្ទប់ដំណេក

CHANBOKEO.COM

នាងចាន់បានសង្កេតឃើញខេវិនស្ដាយខ្មៅដៃមិនដាក់ពីដៃ មួយថ្ងៃមក ហើយ ។ លុះពេលរៀបចំចូលដំណេក បុរសយើងក៏យកខ្មៅដៃមករៀប ដាក់លើគ្រែវិញដូច ដើម ។ ចាន់នឹកឆ្ងល់ពេកក៏វាចាសួរថា:

- ថ្ងៃនេះ អ្នកមានកិរិយាចំលែកណាស់!
- អូនឆ្ងល់អីឬចាន់? (ខេវិនសួរ)
- ខ្ញុំឃើញអ្នកកាន់ខ្មៅដៃចុះឡើងម៉ាង៉ៃហើយ មានរឿងអីហ្មែស?

ខេវិនឮនាងសួរដូច្នោះក៏នឹកអៀនដៃបន្តិចដែរ តែក៏កាត់ចិត្តឆ្លើយ ប្រាប់នាងតាមត្រង់ថា :

- ការពិត បងខ្លាចអូនខឹងនឹងបងនោះអី!
- អូហ៎! ហេតុអ្វីបានខ្ញុំត្រូវខឹងនឹងអ្នកដោយសារខ្មៅដៃមួយនេះផង?
- គឺបងខ្លាចមានមនុស្សទីបីច្រឡំខ្ចីប្រើ
- នរណាគេជាមនុស្សទីបី?
- នរណាដែលអូនប្រចណ្ឌដាក់គេនោះណាំ!

ចាន់ឮហើយនឹកខ្មាញ់ណាស់ក៏លូកក្ដិចស្មាខេវិន :

- តែផ្ដាស! នរណាគេប្រចណ្ឌអ្នក?
- គឺនរណាដែលងង៉ក់រត់ចោលអោយបង ឱ្យបងគេងកើតទុក្ខស្ទូវសក់ អស់ម៉ាយប់ ម៉ាង៉ៃនោះអី អូនមានស្គាល់គេដែរទេហ៎?

ចាន់នឹកខ្មាស់ខេវិនពេក ក៏ប្រាសខ្លួនផ្កាប់មុខទៅលើខ្នើយ បិតបាំង ថ្ពាល់ដែលកំពុងតែឡើងពណ៌ក្រហមទុំដោយការអៀនខ្មាស ។ កាលបើ ឃើញដូច្នោះ ខេវិនក៏ចំអន់លេងទៀតថា :

- ចាន់! អូនអោបខ្នើយយកអស់ មិនអោយបងកើយទេឬអី យប់នេះ?
- មិនបាច់កើយទេ កើយដៃម៉ាយប់ទៅអោយសមមុខមនុស្សចិត្តមិនស្មោះ
- ម៉េចអូននិយាយបែបនេះ? អូនមិនឃើញទេ បងសុខចិត្តលះបង់មរតក របស់យាយទាំងអស់ ក៏គឺដើម្បីអូនមួយ... អូននៅមិនយល់ចិត្តបងទៀត ឬពៅព្រលឹង?

ចាន់ឮហើយងើបបែរមុខមកវិញ :

- ខ្ញុំនិយាយលេងតើហ៎ ។ នេះ ខ្នើយ! អ្នកគេងមក!

ចាន់ក៏លើកបំបែរខ្នើយទុកអោយខេវិនគេងម្ខាង ខ្លួននាងនៅម្ខាង ។

- បងមិនសុខចិត្តទេ (ខេវិនវាចាឡើង)
- ចែកខ្នើយអោយគេងហើយតើហ៎ ម៉េចមិនសុខចិត្តទៀត?
- ព្រោះបងចង់បានខ្នើយនេះកើយតែម្នាក់ឯង!
- ពុទ្ធោ! អីក៏ចិត្តអាក្រក់ម្ល៉េះលោក! អញ្ចឹង ខំអួតថាស្រលាញ់ចាន់ផង! បើអ្នក យកខ្នើយអស់តើចាន់បានអីកើយទៅ?

ឃើញចាន់រអ៊ូដូច្នោះ ខេរិនក៏សើចខឹកៗ ឡើងយកដៃបូតច្រមុះភរិយា ហើយពោលថា :

- គឺអូនគេងកើយលើទ្រូងបងនោះអី ព្រលឹងមាសបង!

ថាត្រូវចំណុច ចាន់ខ្មាស់ឡើងក្រហមថ្ពាល់ម្តងទៀតហើយ ។ ខេរិន ក៏និយាយសួរទៅប្រពន្ធថា :

- ចាន់! យើងជាប្តីប្រពន្ធនិងគ្នាយ៉ាងពេញលក្ខណៈទៅហើយ ។ តើអោយ បងសុំអ្វីមួយពីអូនបានទេ?

- អ្នកចង់សុំអ្វីទៅ?

- គឺមេត្តាកុំបងថាអ្នកទៀតអី ស្តាប់ទៅចំលែកត្រចៀកណាស់ ។ អូនហៅ ថា "បង" ៗ វិញបានដែរទេ?

- មិនហៅទេ (ចាន់យកដៃខ្ទប់មាត់)

- បើមិនហៅបងនឹងចាប់ថើប.. គ្រញិចព្រឹកល្ងាច... យ៉ាងម៉េចដែរ?

- មិនហៅ... មិនហៅទេ... មិនហៅដាច់ខាត...

- មិនហៅថាបងទេហ៎? មិនហៅទេ ចាំមើលណា៎! ចាំបងគ្រញិចអូន ឱ្យមើល!

ទាំងគូប្រលែងសាសងចំអន់គ្នា សើចលាន់ព្វកខឹកៗ យ៉ាងរីករាយសប្បាយក្រៃលែង ។ រីកង្វល់ទាំងអំបាលម៉ានក៏រលាយអស់ពីដួងចិត្តអ្នក ទាំងពីរគ្មានសល់ឡើយ ។ គ្រានេះខេរិនលែងគិតអ្វីឡើយក្រៅតែពីទទួល ស្គាល់នូវក្តីរំភើបសប្បាយចំពោះស្នេហាថ្មីតែម្យ៉ាងប៉ុណ្ណោះ ។

ព្រឹកស្អែកឡើង ផល្លីន មីងពៅពូវៃ ព្រមទាំងញាតិសន្តាននិងភ្ញៀវទាំងឡាយក៏នាំគ្នាចាកចេញទៅភ្នំពេញវិញ ។ មុននឹងចេញដំណើរ មីងពៅ បែរមកសួរ ខេរិន ជាចុងក្រោយថា :

- ខេរិន! សំរេចចិត្តច្បាស់លាស់ហើយឬថាមិនត្រលប់ទៅអាមេរិកវិញ?

- បាទមីង! គឺ... ខ្ញុំចង់នៅទីនេះជាមួយចាន់ប្រពន្ធរបស់ខ្ញុំ!

- បើឯងសំរេចចិត្តដូច្នេះ មីងក៏សូមជូនពរ អោយឯងរស់នៅសុខ សប្បាយហើយរក្សាប្រពន្ធកូនអោយមានសេចក្តីសុខផងណា៎ ។ ចាំមីងពូ ឧស្សាហ៍មកលេងអ្នកទាំងពីរ ។

មីងពៅពូវៃនិងផល្លីនក៏ឡើងរថយន្តចេញទៅ ទុកអោយខេរិននិង ចាន់ឈរលើកដៃបោយលាជាចុងក្រោយ...

៩៩៩៩៩៩៩៩៩៩៩៩៩៩



CHANBOKEO.COM

# វគ្គទី៧

# ពពកខ្មួលខ្មាញ់

ចាប់តាំងពីថ្ងៃនោះមក ខេវិនក៏ត្រូវផ្លាស់ប្តូរ សំរបសំរួលកាយឱ្យបត់ បែនទៅតាមបែបបទនៃការរស់នៅក្នុងភូមិ ដែលផ្ទុយខុសស្រលះពីជីវិត ដែលនាយធ្លាប់ជួបប្រទះនៅអាមេរិក ។ រាល់ថ្ងៃនាយបានត្រូវចាន់ដាស់ អោយក្រោកពីព្រលឹម រែកទឹក ពុសអុស ស្រិតអង្ករ បុកដើមចេកលាយ កន្ទក់អោយបាយជ្រូក កើបអាចម៍គោ ច្រូតស្មៅចំណីគោ ។ ថៃដន្យ រដូវ នោះជារដូវចំរូត ស្រូវកំពុងតែឡើងលាន ។ ខេវិនបានត្រូវពូគ្រុឧបង្រៀន អោយដឹកគោបញ្ជាន់ស្រូវ ហាលស្រូវ ឆាយចំបើង ដឹកជញ្ជូនស្រូវដាក់ជង្រុក គឺនាយត្រូវធ្វើការទាំងយប់ថ្ងៃមិនឈប់ដៃទេ ។ ដំបូង នាយយើង គិតថានាយធ្វើការសប្បាយណាស់ តែលុះច្រើនថ្ងៃទៅ មាណពក៏ចាប់ផ្តើម មានអារម្មណ៏ថាហត់នឿយក្នុងកាយយ៉ាងម៉េចមិនដឹង គ្រាន់តែមិនហ៊ាន រអ៊ូចេញមកអោយនរណាឮប៉ុណ្ណោះ ។ រៀងរាល់ថ្ងៃ ខេវិនតែងតែលួចសួរ ចិត្តខ្លួនឯងសាជាថ្មីជាញឹកញយថា :

- តើយើងសំរេចចិត្តឈោងចាប់យកជីវិតជាប្តីរបស់ចាន់នេះ ខុសឬក៏ត្រូវ? នៅទីនេះ យើងមានការរស់នៅក្រីក្រនឿយហត់ណាស់ ប៉ុន្តែ ចាន់ជាភរិយា ដ៏ល្អមួយរូបដែលចាំតែលើកទឹកចិត្តយើងរហូតមក ។ នាងមិនដែលបាន ធ្វើអ្វីអោយយើងមានអារម្មណ៏មិនសប្បាយចិត្តនោះទេ ។ ប៉ុន្តែ យើងត្រូវ រស់នៅជីវិតបែបនេះរហូតដល់ស្លាប់ឬអ្វី? ចុះឯណាទៅ អនាគតរបស់ យើង? រស់នៅបែបនេះ គេហៅថាជាជីវិតភ្លឺស្វាងដែរឬទេ? ចុះបើយើង មានកូនមានចៅ តើត្រូវអោយគេរស់នៅក្រីក្រយ៉ាងម៉េចកើត? ចុះការរស់ នៅឯអាមេរិកវិញ? យើងរៀនមិនបានចប់មធ្យមសិក្សាផង ។ ស្រុកគេ មានអ្នកចេះដឹងមានបរិញ្ញាបត្រ័រាល់លាននាក់ រង់ចាំប្រជែងគ្នារកការធ្វើ ហើយចុះត្រឹមតំរេះតូចទាបថ្នាក់ដូចយើង ទៅធ្វើការអ្វីទៅ? នៅអាមេរិក ចំណេះត្រឹមយើងនេះគឺបានត្រឹមជាកម្មករគេ ធ្វើការនឿយហត់ជាងអ្នក ស្រែនៅទីនេះច្រើនដងណាស់ទៅទៀត ។ មើលតែពូរ៉ៃមីងពៅទៅដឹង ហើយ ។ គាត់មិនមានការសិក្សាធំដុំ ម៉្លោះហើយ គាត់ត្រូវធ្វើការជាកម្មករ នឿយលំបាកយប់ថ្ងៃ មិនដែលមានពេល សូម្បីតែមកជួបពិគ្រោះជាមួយ គ្រូ ពេលយើងរៀនធ្លាក់ច្រើនមុខវិជ្ជា ហើយទោះបីជាធ្វើការពីរនាក់ ក៏ ជីវភាពគាត់បានត្រឹមតែ" ម៉ារស់ " មិនអាចឈានដល់ចំណុចហ៊ឺហាដូចអ្នក គេមានតំរេះខ្ពង់ខ្ពស់បានឡើយ ។ បើត្រលប់ទៅរត់ពន្ធអាភៀនវិញ យើង អាចរកលុយបានច្រើនហើយឆាប់រហ័សក៏ពិតមែន តែយើងក៏ត្រូវយក ជីវិតរបស់ខ្លួនទៅលលេងនឹងចុងកាំភ្លើង ព្រមទាំងគុកច្រវាក់រាល់ថ្ងៃថែម ទៀតផង ។ ហ៊ឺ! ខេវិនអើយ! តើត្រូវជ្រើសរើសជីវិតមួយណាទៅ?... ល្ហើយចុះ!

CHANBOKEO.COM

ហោចណាស់នៅស្រុកខ្មែរនេះ យើងមានភរិយាជាទីស្រលាញ់ មួយរូបនៅក្បែរ មិនមែនរស់នៅកណ្តោចកណ្តែងពេកនោះទេ ។ នាងក៏ជា មនុស្សមានសីលធម៌ មានសន្តានចិត្តត្រជាក់ អាចជួយរំលត់ភាពឆេវឆាវ របស់យើងបាន ។ បើគ្មាននាង យើងក៏មិនស្គាល់ពាក្យថា ធ្វើបុណ្យ ពាក្យ ថាស្រលាញ់ និង ការមិនមើលបំណាំនោះឡើយ...

ថ្ងៃខែចេះតែកន្លងទៅ...

**ថ្ងៃ១២មេសា២០០៦**

នៅក្នុងផ្ទះ ចាន់អង្គុយដេរអាវថ្មីមួយតែម្នាក់ឯង ។ មីងចាបបានទៅ ស្នាក់សុំសីលឯវត្តលើភ្នំព្រះនេត្រព្រះតាំងពីម្សិល ។ ថ្ងៃត្រង់ ខេវិនក៏ត្រលប់ មកពីជួយស្តារជីកស្រះនៅឯជើងភូមិ ត្បិតប៉ុន្មានឆ្នាំនេះ ឈូកដុះច្រើនពេក បណ្តាលអោយទឹករាក់ម៉្លោះហើយ ស្រះនោះមិនសូវមានទឹកសំរាប់ឱ្យអ្នក ភូមិដងប្រើប្រាស់ទេ ។ ខណៈនោះ នាយយើងហត់អស់កំលាំងហេវបាយណាស់ ។ គ្រាន់តែឃើញខេវិនមកដល់ ចាន់ក៏ដាក់អាវចុះ រួចស្ទុះទៅរៀបចំ អាហារដាក់ស្លកអោយខេវិនភ្លាម ។ នាយយើងក៏ដើរទៅជំរៀងផ្ទះ យកទឹកលប់មុខប្រស់ខ្លួនអោយត្រជាក់បន្តិច ទើបដើរត្រលប់ចូលផ្ទះ បំរុងនឹងចូលរួមស្លកបាយជាមួយភរិយាទៅហើយ ស្រាប់តែមានក្មេងប្រុសម្នាក់ ជិះកង់មកដល់មុខផ្ទះ ហើយស្រែកឡើងថា :

- បងចាប! នៅផ្ទះទេហ៎! តាដីរីមានប្រសាសន៍អោយទៅជួយមើលកូន ប្រុសគាត់ជាប្រញាប់ ព្រោះកំពុងប្រកាច់បែកពពុះមាត់កាច់ដៃកាច់ជើង ខ្លាំងណាស់ ។

ចាន់ឮដូច្នោះក៏ដាក់ស្លកបាយចុះ ហើយឱនប្រាប់ខេវិនថា :

- បងពិសារបាយមុនទៅ! បន្តិច ចាន់ត្រលប់មកវិញហើយ!

ថាហើយ ចាន់ក៏ហក់ឡើងកង់ឌុបក្មេងនោះចេញទៅ ។ ខេវិនដែល កំពុង តែហេវបាយហើយចង់អោយប្រពន្ធនៅបំរើ កាលបើឃើញដូច្នេះ ក៏ ឈប់លែងចង់បរិភោគម្នាក់ឯង ។ ភ្លាមនោះ នាយក៏ស្រវារកកង់កញ្ចាស់ មួយក្បែរនោះហក់ជិះដេញតាមពីក្រោយចេញទៅដែរ ។ លុះនាយទៅដល់ ក៏ឃើញចាន់វែកមនុស្សចូលទៅក្បែរអ្នកជំងឺដែលជាក្មេងកំលោះស្អាតបាត មួយរូប ។ ធិតាយើងក៏យកចិត្តទុកដាក់មើលថែទាំកំលោះ នោះយ៉ាងជិត ដិតទំនងហាក់ដូចជាសាច់ឈាម ឬក៏ជាគិលានុបដ្ឋាកមួយរូបដូច្នោះឯង ។ រី ឯអ្នកស្រុកដែលឈរមើល ក៏ហាក់ដូចជាផ្តល់ការគោរពដល់នាងដែរ ។ ពេលនោះ អ្នកជំងឺកំពុងអន្ទះអន្ទែងមិនដឹងស្មារតីឡើយ ។  ចាន់ស្រវាចាប់ ដបថ្នាំមកអាន ហើយក៏ជំរាបតាដីរីថា :

- តាមេភូមិ! ប្រហែលជាអោយថ្នាំចៅបរិភោគលើសកំរិត ឬក៏មកពីរាងកាយអ្នកជំងឺមិនរឹងប៉ឹងល្មមអាចទទួលសារជាតិរបស់ថ្នាំនេះក៏មិនដឹង ទើប ធ្វើឱ្យមានប្រតិកម្មលើរូបកាយបែបនេះ ។ យើងមិនគួរបណ្តែតបណ្តោយទេ ត្រូវតែនាំនាយទៅមន្ទីរពេទ្យដើម្បីសង្គ្រោះជាបន្ទាន់ ។

តាដីរីក៏ស្ទុះហៅរ៉ឺម៉កម៉ូតូមកភ្លាម ចាន់ក៏ស្ទុះឡើងរ៉ឺម៉កពីក្រោយតាដីរី នាំអ្នកជំងឺចេញទៅ ។ កាលបើឃើញចាន់យកចិត្តទុកដាក់ ចំពោះបុរស កំលោះស្អាតបាតមួយរូបនោះ ខេវិនហាក់ដូចជាមានអារម្មណ៍ល្អក់កករក្នុងចិត្តពន់ពេករកថាមិនត្រូវ ។ នាយក៏រពឹសដើរទៅរើសយកដបថ្នាំយកមក អាន

CHANBOKEO.COM

ស្រាប់តែភ្ញាក់ព្រើតព្រោះផ្កាកវិធីប្រើនោះលើដបនោះ សរសេរជា ភាសាអង់គ្លេសសុទ្ធសាធ ។ មួយស្របក់ក្រោយមក ខេវិនឡើងធាក់កង់ ត្រលប់មកផ្ទះវិញ ។ ស្លកបាយដែលចាន់រៀបទុក នៅលើរានឫស្សី ក៏នៅ ទីនោះដដែល ។ មាណពដាក់កង់បញ្ឈរហើយ ក៏អង្គុយផ្អែកជញ្ជាំងសំលក់ ចានបាយធ្វើទឹកមុខហាក់ដូចជាកំពុងធុញថប់ក្នុងចិត្តណាស់ ។ បន្តិចក្រោយ មក នាយក៏ងើបដើរត្រេះត្រុះចុះឡើង មិនដឹងថាចង់ធ្វើអ្វីទេ ។ អផ្សុកក្នុង ចិត្តពេក នាយក៏ចាប់អំបោសបោសពីងពាងក្នុងផ្ទះរៀបចំទុកដាក់ឥវ៉ាន់ ដែលនាយមិនដែលបានជួយចាន់សោះតាំងពីមករស់នៅទីនេះ ។ កំពុងតែ បបោសពីងពាង ស្រាប់តែខេវិនធ្វើអោយធ្លាក់ប្រអប់កន្ទាំងម្ជុលដេររបស់ ចាន់មកដីកំពប់អស់ ។ ខេវិនក៏ស្ទុះទៅរើសប្រមូលទុកវិញ ស្រាប់តែប្រទះ ផ្កាកុលាបក្រៀមមួយដែលមានទងកាច់បត់ជាបីបួនកំណាត់ឈ្មោលចូលគ្នា ថែមទាំងមានចងផ្លាកលឿងមួយចារអក្សរជាភាសាអង់គ្លេស ដោយមាន គូរគំនូរវង្វង់ភក្ត្រព្រះអាទិត្យញញឹមមួយយ៉ាងធំទៀតផង ។ មាណពភ្ញាក់ ព្រើត ហើយក៏ប្រញាប់រៀបអ្វីៗទុកដាក់នៅកន្លែងដើមដដែល ។ បន្តិចមក ខេវិនក៏ដើរបោសដើររៀបតទៅទៀត ដើម្បីបំបាត់អារម្មណ៍ធុញថប់ ស្រាប់ តែនាយដើរទាត់ជាលល្អាក់មួយរិះដួល ។ គំរបជាលក៏របូតឡើង ។ ខេវិន ដាក់ភ្នែកទៅឃើញសំពៀតពណ៌ខៀវមួយនៅក្នុងនោះ ។ នាយយើងក៏ ភ្ញាក់ព្រើតម្តងទៀត ស្ទុះអូសយកសំពៀតចេញមកភ្លាម ហើយក៏លាន់មាត់ តែម្នាក់ឯងថា :

- នេះជាសំពៀតយើងដែលបាត់នោះតើហ៎ ហេតុអ្វីក៏នៅទីនេះទៅវិញ?

ខេវិនទាញសំពៀតមកកកាយមើល ឃើញរបស់របរឥវ៉ាន់របស់នាយ នៅគ្រប់ ទាំងអស់មិនមានបាត់មួយណាទេ ។ ខេវិនថ្លោះទឹកមុខ :

- ចាន់! ហេតុអ្វីនាងលួចសំពៀតរបស់ខ្ញុំយកមកលាក់ទុកអញ្ចឹង? ហើយ នាងធ្វើបែបនេះចំពោះខ្ញុំធ្វើអ្វី?

ខេវិនដើរទៅដើរមកក្នុងផ្ទះទាំងអន្ទះសា រង់ចាំមើលផ្លូវប្រពន្ធឡើង ផ្សាភ្នែកទៅហើយ នៅតែមិនឃើញនាងត្រលប់មកវិញដដែល ។ ទ្រាំមិន បាន នាយក៏ឡើងជិះកង់ទៅផ្ទះតាដីរី ជួបប្រពន្ធគាត់ហើយក៏សួរថា :

- យាយ! តើថ្មើរណាទើបតានិងចាន់ត្រលប់មកវិញ?

- អូហ៎! តាគាត់នាំអាអន្ទិតពៅទៅមន្ទីរពេទ្យឯស្វាយឯណោះ ទៅមកមិន ជិតទេ ។ ប្រហែលជារសៀលថ្ងៃជ្រេបន្តិចហើយទើបត្រលប់មកដល់វិញ ។

ខេវិនឮហើយ ក៏សំពះលាហើយឡើងធាក់កង់មកផ្ទះវិញ ។ ប៉ុន្តែ ហេតុអ្វីពេលវេលាដើរយឺតម្ល៉េះទេហ្ន៎? ខេវិនចាំនាងចាន់យូរអើយសែនយូរ រហូតដល់កើតមានអារម្មណ៍ម៉ួម៉ៅខ្លាំងឡើងស្ទើរតែទប់មិនបាន ។ នាយ អន្ទះសាចង់ជួបចាន់ណាស់ ចង់ដឹងនូវចំលើយដើម្បីជំរះចំងល់ទាំងឡាយ ដែលនាយកំពុងមាននៅពេលនេះ ។ថ្ងៃជ្រេគងភ្នំបន្តិចទើបខេវិនឃើញចាន់ ត្រលប់មកដល់វិញដោយទឹកមុខអស់កំលាំងល្វិតល្វៃ ។ ប៉ុន្តែ នាយយើង ដែលកំពុងមានអារម្មណ៍តក្កហលនោះ មិនបានចាប់ភ្លឹកទេ បែរជាស្ទុះទៅ ចាប់កញ្ឆក់ដៃនាងអូសរឹងចូលទៅក្នុងផ្ទះហើយគំហកដោយសំដីខ្លាំងៗថា :

CHANBOKEO.COM

- ចាន់! តើអូនមានរឿងអ្វីលាក់នឹងបងខ្លះ?

ចាន់ឃើញខេរិនមានឥរិយាបថចំលែកក៏ធ្វើមុខភាំងរួចសួរវិញថា :

- បង! មានរឿងអ្វីហ្នឹង បានជាម៉ូម៉ៅម្ល៉េះ?

- គឺបងចង់ដឹង.. ថាអូនលាក់បងរឿងអ្វីខ្លះ?

ខេរិនក៏ទប់សំដីត្រឹមណេះ រួចស្ទុះទៅកញ្ឆក់សំពៀតខ្សែវពីក្នុងជាល ល្អាក់ចេញមកបោះនៅចំពោះមុខប្រពន្ធ ហើយគំហកដាក់នាងសាជាថ្មី:

- បងចង់ដឹង... ថាហេតុអ្វី សំពៀតផ្ទាល់ខ្លួនរបស់បង បែរជាមកពួននៅ ទីនេះ កន្លែងនេះ ដែលជាផ្ទះអូនទៅវិញ?

ចាន់ក្រលេកឃើញសំពៀតហើយក៏ធ្វើមុខភាំង ឆ្លើយតតាក់តតុប :

- អូនមិនដឹងទេ!...

- កុហក! បើអូនមិនស្គាល់ មិនដឹង ហេតុអ្វីក៏សំពៀតរបស់បងដែលបាត់ ទៅពីទួលខ្មោយាយភួង បែរជាមកលាក់ខ្លួននៅក្នុងល្អាក់មួយនេះទៅវិញ?

- បងខេរិន! រំងាប់ចិត្តបន្តិចសិនទៅ! គឺអូនពិតជាមិនដឹងមែនណា! (ចាន់និយាយ តបទៅប្ដីវិញដោយចិត្តត្រជាក់)

- បងមិនជឿទេ! ចាន់! អូនមានអាថិកំបាំងអ្វីលាក់ជាមួយបងឬ? ប្រាប់មក! ប្រាប់បងមក ហើយអូនមានកំពុងមានគំរោងការអ្វី?

ត្រូវខេរិនសន្ធាប់ដោយសំលេងខ្លាំងៗពេក ចាន់ក្លាយទៅជាស្លន់ស្លោ រកនឹកពាក្យអ្វីមកឆ្លើយមិនទាន់ណាមួយកំពុងល្ហិតល្ហៃក្នុងខ្លួនផង :

- គឺ... គឺ..

- ចាន់! បើអូនមិនឆ្លើយប្រាប់បងទេនោះ   បងនឹងដើរចេញពីជីវិតអូនទៅ ឥលូវនេះ!

ថាហើយ  ខេរិនក៏ចាប់កញ្ឆក់សំពៀតដើរចេញទៅយ៉ាងរហ័ស ។ ចាន់ ឃើញដូច្នោះ រន្ធត់ចិត្តណាស់ក៏ស្ទុះរត់ទៅតាមពីក្រោយ អូសទាញដៃនាយ ឱ្យត្រលប់មកវិញ :

- ឈប់សិន! ខេរិន! បងទៅណាំហ្នឹង!

- ទៅណាក៏ស្រេចតែបង! អូនមិនបាច់មកខ្វល់ទេ ។

- តែអូនមិនអោយបងទៅណាទេ ទាល់តែយើងនិយាយស្ដាប់គ្នាបានសិន ។

- បងលែងចង់ស្ដាប់ហើយ លែងដៃបងភ្លាម...!

ខេរិនច្រលោតពេក ក៏កន្ត្រាក់បេះដៃចាន់ចេញពីខ្លួននាយ ហើយច្រាន នាងអស់ទំហឹង ។ ធិតាយើងដួលប្រួសអុកគូថលើដីយ៉ាងខ្លាំង ។ ខេរិនក៏ដើរ ចេញលឿនត្រុយលែងងាកក្រោយលែងអើពើថា តើចាន់ឥលូវនេះមានអាការៈយ៉ាងណាហើយ គ្រាន់តែដឹងថានាយបានឮនាងហៅខ្សោយទៅៗ តែប៉ុណ្ណោះ ។ ទោះជាយ៉ាងណា ភាពចចេសរឹងរូសឆេវឆាវរបស់នាយបាន លេចរូបផ្លោមកសាជាថ្មីម្ដងទៀតហើយ ហើយនាយក៏ប្រកាន់ភាពមានះ យកឈ្នះ

CHANBOKEO.COM

ប្រឹងដើរទៅមុខ បិទត្រចៀក មិនព្រមធ្វើដឹងឮ នូវពាក្យដង្ហោយ របស់ចាន់ឡើយ ។

បុរសយើងក៏ទុកបណ្ដោយអោយភរិយាដួលដេកក្រាប ស្ដូកនៅលើដីនៅធ្លាមុខផ្ទះតែម្នាក់ឯង...

ខេវិនដើររហូតមកដល់ភូមិជប់ ។ ពេលនោះ ព្រលប់ព្រាល១ មើល លែងច្បាស់ទៅហើយ ។ ចរាចរក៏ស្ងាត់ឈឹង រីអ្នកភូមិក៏បិទទ្វារចូលសំរាក តាមផ្ទះរៀង១ខ្លួនដែរ ។ ខេវិនឈររវេរាមួយស្របក់ ក៏សុញគំនិត មិនដឹង ថាចង់ទៅណា ។ រាល់ថ្ងៃ នាយតែងតែមានចាន់ជាមេគំនិតជានិច្ច ។ ពេល នេះ នាយប្រែជាត្រូវគិតធ្វើអ្វីដោយខ្លួនឯងវិញហើយ ។ ម្យ៉ាងទៀត នាយ យើងក៏អន់ខ្សោយខាងភូមិសាស្ត្រនៅស្រុកខ្មែរផង តើនាយត្រូវគិតធ្វើអ្វី តទៅទៀត ។ គិតចុះគិតឡើង ខេវិនក៏ដើរបកក្រោយវិញ ប៉ុន្តែ នាយមិន បានត្រលប់ទៅរកចាន់ទេ តែគេបែរជាដើរសំដៅទួលខ្មមយាយភួង ឯវាល ស្រែទៅវិញ ។ មកដល់ទីនោះភ្លាម នាយយើងក៏ប្រាសខ្លួនលើគ្រែរនាប កំពុក យកដៃគងថ្ងាសដកដង្ហើមធំ១ បន្ធូរការតប់ប្រមល់ក្នុងចិត្ត ។ គិតទៅ គិតមក៏ នាយហាក់ដូចជានឹកដល់ចាន់ចង់ត្រលប់ក្រោយម្ដង១តែភាពមានះ រឹងរូសរបស់នាយបានប្រទាញចិត្តឱ្យនាយចចេស ចង់អោយចាន់រត់តាម អង្វរទើបអស់ចិត្ត ។ អនិច្ចា! ខេវិនរងចាំទាំងអន្ទះសាតែនាងបែរជាមិន ព្រមតាមរកនាយដដែល ។ ហើយនាយក៏តែចាំ..ចាំ.. ចាំយូរទៅ កាន់តែ ខកចិត្តឡើងតប់ប្រមល់ឡើងជាលំដាប់ ។ មួយស្របក់ក្រោយមក ខេវិនក៏ ដើរទៅអង្គុយនៅលើដង្គត់ឈើមួយក្បែរខ្ទម យកដៃជ្រោងសក់ ឈ្ងីថ្ងាស លាងក្ដីកង្វល់ក្នុងអារម្មណ៍ ។ ប៉ុន្តែទោះជាធ្វើយ៉ាងណា ក៏ចិត្តនាយ នៅតែ តប់ប្រមល់ដដែលជាដដែល ។ រំពេចនោះ ស្រាប់តែមានដៃមួយមកគោះ ស្មានាយយើងបន្តើរ១ ។ ខេវិននឹកអរភើត ឧទានថា :

- ចាន់?

- មិនមែនចាន់ទេកូន! គឺម៉ែតើហ៏!

ខេវិនងាកបែរក្រោយផាំង ឃើញមីងចាបមកដល់ :

- ម៉ែ!

- អឺ! ម៉ែមកពីវត្តវិញមិនឃើញកូនទាំងពីរនៅផ្ទះ ទើបម៉ែមកតាម ។

ខេវិនឮដូច្នេះ ក៏នឹកឆ្ងល់ព្រួចក្នុងចិត្តតែម្ដងៈ

- ចុះអូនចាន់គេទៅណា?

- អូហ៏ ចាន់គេមិនបាននៅទីនេះជាមួយកូនទេហ៏?

- បាទ! អត់ទេហ៏ម៉ែ!

- អញ្ចឹង តើចាន់គេទៅណា?

ពេលនោះ ខេវិននឹកអន់ចិត្តណាស់ដែលចាន់មិននៅផ្ទះ តែនាយក៏នឹក បារម្ភខ្លាំងណាស់ដែរដែលនាងបាត់ពីផ្ទះទៅ ។ នាយក៏ងើបភ្លែត ដឹកដៃមីង ចាបត្រលប់ទៅផ្ទះវិញ ស្រាប់តែប្រទះនាយដួងនិងនាយឆ្នោតរត់ត្រហេប ត្រហបមកដល់ព្រមទាំងស្រែកប្រាប់ថា :

- ពូវិន ! បងចាន់ត្រូវអ្នកស្រុកដឹកទៅពេទ្យអំបាញ់មិញបាត់ទៅហើយ

CHANBOKEO.COM

ឮដូច្នោះ ខេរិនខឹងឆេវ លួចប្រចណ្ឌក្នុងចិត្ត ហើយលាន់មាត់ខ្សឹប១:

- ប្រហែលជាទៅបំរើក្មេងកំលោះកូនពៅតាជីវ៍មេភូមិនោះហើយ ។

ស្រាប់តែមីងចាបសួរក្មេងទាំងពីរថា :

- ហើយអានាងឯងដឹងថា អ្នកស្រុកគេដឹកបងចាន់ទៅពេទ្យធ្វើអីដែរ?

- គឺបងចាន់គាត់ដួលនៅមុខផ្ទះធ្លាក់ឈាមច្រើនណាស់ មានអ្នកស្រុកគេ ដើរមកឃើញ ក៏សង្គ្រោះដឹកយកទៅមន្ទីរពេទ្យនៅឯស្វាយបាត់ទៅ ។

ឮដូច្នោះ ខេរិនប្រែជាស្លុតស្មារតីព្រឺតតែម្តង :

- ពុទ្ធោ ចាន់! (ខេរិនហក់ភ្លែតធាក់កង់ចេញទៅ)

- អន្ទិតរិន! ហើយកូនបំរុងជិះកង់ទៅណាហ្នឹង?

- បាទ! គឺ..ចង់ទៅរកចាន់

- ហើយចុះឯងដឹងផ្លូវដែរ ថាទៅរកប្រពន្ធឯងនៅឯណា?

ខេរិនក៏ទុចង៉ក់ ។ មែនហើយ! នាយមិនដឹងទេថាមន្ទីរពេទ្យនោះនៅ ឯណាផង ។ ខេរិនក៏បែរក្រោយវិញ :

- ម៉ែ! កូនចង់ទៅរកចាន់ឥលូវនេះ សូមម៉ែនាំផ្លូវកូនផង!

មីងចាបក៏នាំកូនប្រសារទៅរកពឹងម៉ូតូអ្នកជិតខាង ចេញដំណើរទៅ មន្ទីរពេទ្យនៅសេរីសោភ័ណទាំងយប់ ។ តាមផ្លូវ មីងចាបឃើញខេរិនមាន កិរិយារសាប់រសល់ ក៏សួរថា:

- កូនរិន្ទ! ថ្ងៃនេះ ឯងមានរឿងអីជាមួយចាន់មែនទេ?

- បាទ... គឺ... ខ្ញុំម៉ូម៉ៅខ្លាំងពេក... បានជា...

- កូនអើយ! បើមានរឿងអី ពិគ្រោះគ្នាទៅ កុំយកកំហឹងនិងការមានះជា ត្រីមុខ ក្នុងការដោះស្រាយបញ្ហាវិវាទក្នុងគ្រួសារណ៎ាកូន!

ខេរិនឮហើយនៅស្ងៀមមិនហ៊ានស្រដីតទៅទៀត ត្បិតកំពុងតែនឹក ស្តាយក្រោយចំពោះកំហុសរបស់ខ្លួន ។ រីចិត្តនាយចង់តែហោះអោយទៅ ដល់ពេទ្យឱ្យឆាប់ៗ នឹងអាលខ្លួនបានទៅសុំទោសប្រពន្ធ ។ មកដល់មន្ទីរ ពេទ្យ ឃើញចាន់មានទឹកមុខស្លេកស្លាំង គេងបិទភ្នែកស្ងៀមស្ងាត់ហើយ មានបន្ទោងសេរ៉ូមផង នាយយើងស្ទុះរឹងទៅជិតយកដៃអង្អែលដៃប្រពន្ធ បន្តិចៗ ។ ចាន់ក៏បើកភ្នែកឡើង :

- បងខេរិន!... ម៉ែ!...

ឮនាងហៅឈ្មោះខ្លួនដូច្នោះ ខេរិនរំភើបចិត្តរហូតរលីងរលោងទឹក ភ្នែក ។ រីឯចិត្តដែលខឹងច្រលោតចំពោះនាងទាំងអំបាលម៉ានកាលពីព្រលប់ ក៏រលាយខ្សុរអស់រលីងពីបេះដូងនាយ :

- ចាន់! អោយបងសូមទោសផងណ៎ាអូន! បងសូមទោស!

- ចាន់មិនបានខឹងនឹងបងទេណ៎ាខេរិន! អូនត្រេកអរទៅវិញទេ... ដែលបង មិនបានទៅណាចោលអូន...

CHANBOKEO.COM

ខេរិនរន្ធត់ចិត្តណាស់ដែលឮនាងវាចាដូច្នោះ ហើយនឹកអាណិតប្រពន្ធ ស្ទើរខ្លោចបេះដូង ។ មាណពស្ទុះចាប់ដៃភរិយាមកកាន់យ៉ាងណែន :

- បងពិតជាមានវិប្បដិសារីណាស់ ដែលបងមិនចេះទប់អារម្មណ៍ ធ្វើឱ្យចាន់ទទួលរងគ្រោះដោយសារអារម្មណ៍ឆេវឆាវរបស់បង ។

ពេលនោះគ្រូពេទ្យបានចូលមក មានប្រសាសន៍ថា :

- សូមជួយត្រេកអរផងដែលទារកក្នុងផ្ទៃផុតពីគ្រោះថ្នាក់ ។ ដឹងទេ? ភាព ឆេវឆាវរបស់អ្នក រិះតែនឹងធ្វើអោយអ្នកក្លាយជាឃាតករសំលាប់កូនរបស់ ខ្លួនឯងទៅហើយ ។ ថ្ងៃក្រោយមានរឿងអ្វីក្នុងផ្ទះ សូមមេត្តារក្សាខន្តី ថ្នមដៃថ្នមជើងចំពោះភរិយាដែលកំពុងពផ្ទៃផងណា៎ ។

មានប្រសាសន៍ចប់លោកគ្រូពេទ្យក៏ដើរចេញទៅវិញ ។ ខេរិនថ្លោះទឹក មុខដែលត្រូវមាត់លោកគ្រូពេទ្យ តែក៏ភ្ញាក់ផ្អើលខ្លាំងណាស់ដែរ កាលបើ ដឹងថាចាន់កំពុងមានគភ៌ :

- ចាន់! យើងជិតមានកូនហើយ!... ចាន់! បងត្រេកអរណាស់!

ខេរិនអរកខិបកខុបស្រវាអោបភរិយាទាំងក្តីរំភើបបំផុត ។ កាលបើ ឃើញកូនចៅត្រូវរ៉ូវគ្នាវិញ មីងចាបដែលនៅឈរពីក្រោយ ក៏ញញឹមឡើង រំសាយការតានតឹងនៅក្នុងចិត្ត...

ពីរថ្ងៃក្រោយមក...

**ថ្ងៃ១៤មេសា២០០៦**

សុខភាពចាន់បានគ្រាន់បើហើយ ហើយក៏បានទទួលការអនុញ្ញាតឱ្យ ត្រលប់មករក្សាជំងឺនៅផ្ទះវិញដែរ ។ ដោយដឹងកំហុសរបស់ខ្លួន ខេរិនបាន ខិតខំបំរើប្រពន្ធយ៉ាងយកចិត្តទុកដាក់ ។ ឃើញដូច្នោះ ចាន់ក៏សួរថា :

- បងខេរិន! បងឈប់ខឹងនឹងអូនហើយមែនទេ?

ខេរិនដាក់ខ្លួនអង្គុយជិតភរិយា ហើយញញឹមៈ

- បងមិនបានខឹងនឹងអូនទេ ចាន់!

- ហើយចុះថ្ងៃមុននោះ ហេតុអ្វីបងច្រលោតគោតតូងអីក៏ខ្លាំងម្ល៉េះ?

- គឺមកពីបងហេវហាយពេក ហើយនឹកអន់ចិត្តនឹងអូនដែលយកពេលទៅ បំរើបុរសដទៃ ដែលមិនមែនជារូបបង ។

- ពុទ្ធោ! បងខេរិន! ថ្ងៃនោះ អ្នកភូមិគេមានធុរៈអាសន្ន!... យើងជួយ សំរាលទុក្ខធុរៈអ្នកភូមិផងរបងជាមួយ តើមានអ្វីចំលែកទៅ? ធ្វើចិត្តឱ្យ ទូលាយបន្តិចទៅណា៎! អំពើល្អរមែងនាំមកនូវសេចក្តីសុខ និងសេចក្តី ស្រលាញ់ជុំជិតខ្លួនជាការតបស្នងជានិច្ច ។ បងមានឃើញទេហ៏! ពេលបង ដើរចោលអូនបាត់ អ្នកភូមិគេក៏រត់ត្រហេបត្រហប មកជួយដឹកយកអូន ទៅមន្ទីរពេទ្យដោយគ្មានអារិចិត្ត ។ បើសិនជាគេមិនមានទឹកចិត្តទេនោះ ម្ល៉េះសមពេលនេះ អូនមិនដឹងជាយ៉ាងណាទៅហើយទេ...

ខេរិនឮដូច្នោះក៏ទំលាក់មុខឈ្ងោកចុះ មួយស្របក់ទើបងើបមុខឆ្លើយ មកប្រពន្ធវិញថា :

CHANBOKEO.COM

- បងពិតជាមានចិត្តចង្អៀតចង្អល់មែន! ប៉ុន្តែសូមអូនទុកពេលអោយបង ហាត់រៀនពត់ចិត្តខ្លះណាំអូន ថ្ងៃក្រោយបងលែងធ្វើ លែងគិតផ្ដេសផ្ដាស ខុសទំនងដូច្នេះទៀតហើយ ។

- អញ្ចឹង បងឈប់សង្ស័យពីអូនហើយមែនទេ?

ខេរិនឈ្ងោកមុខមួយស្របក់ ក៏បែរមើលមុខភរិយា :

- មិនទៀតទេ! ពេលនេះ អ្វីដែលសំខាន់ចំពោះបង គឺសូមឱ្យតែអូននិងកូន យើងបានសុខសប្បាយ ហើយសូមអោយអ្នកទាំងពីររួមរស់នៅក្បែរបង រហូតតទៅ នោះបងស្ងប់ចិត្តហើយ ។

ឮដូច្នេះ ចាន់ញញឹមទាំងរំភើបចិត្តហើយស្រវាអោបខេរិនយ៉ាងណែនៈ

- បើបងមិនដើរចេញពីយើងទាំងពីរទេ ចាន់និងកូនគ្មានថ្ងៃព្រាត់ទៅណា ពីបងដែរ...

ខេរិនអង្អែលខ្នងភរិយា :

- ចាន់! បងសន្យាថា បងលែងដើរចេញទៅណាទាំងអស់! អូនគឺជា បេះដូងរបស់បង បើគ្មានរូបអូន លោកនេះក៏គ្មានន័យអ្វីសំរាប់អោយបង រស់នៅឡើយ ។

មួយស្របក់ក្រោយមក ចាន់យកដៃស្ទាបថ្ពាល់ខេរិន :

- បងស្គមច្រើនណាស់! ប្រហែលជាបងនឿយហត់ពេកហើយ ។ តើបង ស្ដាយក្រោយទេ កាលដែលបានមករស់របៀបអ្នកក្រីក្រយ៉ាងនេះ?

- អត់ទេ! អោយតែគ្រួសារយើងមានសេចក្ដីសុខ ហត់ប៉ុណ្ណឹងបងទ្រាំបាន ជានិច្ចណាំអូន ។

ចាន់ញញឹមឡើង ដោយក្ដីរំភើប :

- អរគុណបងណាស់ ខេរិន!

ភ្លាមនេះមីងចាន់កាន់សំពៀតខៀវដើរចូលមកដល់ :

- អនិតវិនអើយ! តាជីវគាត់ឃើញឆ្កែវាអូសសំពៀតខៀវនេះនៅគំនរ ចំបើងក្បែរជង្រុកស្រូវក្រោយផ្ទះគាត់ ។ ដល់ឆែកមើលទៅឃើញរូបថត របស់ឯង ទើបគាត់អោយក្មេងយកមកអោយវិញតាំងពីប៉ុន្មានអាទិត្យ ហើយ តែម៉ែចេះតែភ្លេចប្រាប់ឯងនិងនាងចាន់! ហាំនេះ! ទទួលយកទៅ ។

ខេរិនភ្ញាក់ក្រញាងកាលបើឮដូច្នោះ ។ នាយលូកដៃទទួលសំពៀត ហើយ ក៏នឹកបន្ទោសខ្លួនសាជាថ្មី :

- អរគុណម៉ែ! (រួចហើយនាយក៏បែរទៅចាន់) សូមទោសណាំប្រពន្ធ សំលាញ់ដែល បងយល់ច្រលំពីថ្ងៃមុន ។

ចាន់ញញឹមឡើង :

- ចាន់មិនបន្ទោសបងទេ កុំអោយមានលើកទីពីរទៀតទៅបានហើយ ។

ខេរិនយកដៃអង្អែលកេសាភរិយា ហាក់ដូចជាចង់ប្រាប់ថា គ្មានទេ លើកទីពីរដែលនាងនិយាយនោះ ។ ស្រាប់តែចាន់នឹកដល់រឿងមួយៈ

CHANBOKEO.COM

- បងខេរិនចាំទេហ៎ា ថាយើងទើបតែរកឃើញខ្មោយចាស់របស់យាយចំនួន បី ហើយនៅបាត់មួយទៀត ។ បងមិនចង់តាមរកខ្មោយទីបួនទេហ៎ា?

- មិនចង់ទេ ព្រោះបងបានទទួលមរតកយ៉ាងវិសាលពីយាយរួចហើយ

- មរតកអ្វីទៅ អូនមិនដែលឃើញ?

- គឺរូបអូននោះអី? បើកុំតែសំបុត្រយាយទាក់ទាញចិត្តបង កុំអីបងមិន បានមកដល់ខ្ទមគាត់នៅព្រះនេត្រព្រះហើយមកជួបអូននេះដែរ អូនដឹង ទេហ៎ា! ថ្ងៃនេះ បងរិតតែដឹងជាក់ច្បាស់ថែមទៀត ថាបងពិតជាមាន សំណាងក្រៃលែងដែលបានមកជួបអូនចាប់ដៃគ្នាជាគូជីវិត...

ចាន់ញញឹមយ៉ាងស្រស់កាលបើឮខេរិនពោលដូច្នោះ ។ នាងក៏តបថា :

- ដូច្នេះយើងគួរតែធ្វើអ្វីមួយដើម្បីសងគុណគាត់វិញហើយ ។

- អូនជួយគិតបងមើល ថាតើ យើងគួរធ្វើអ្វីទៅ?

បន្តិចក្រោយមកទាំងពីរនាក់ក៏បានមកដល់ខ្ទមកំពុករបស់យាយភួង :

- គឺអូនចង់ជួសជុលសង់ខ្ទមនេះសាជាថ្មីដើម្បីរំលឹកគុណដល់គាត់នោះអី

ខេរិនក៏ញញឹមឡើង :

- មែនហើយ! ទីនេះជាចំណុចដែលនាំជីវិតបងមកជួបនឹងអូន... ពិតជា កន្លែងដែលបង្កប់នូវអនុស្សាវរីយ៍ដ៏មានតម្លៃឧត្តុង្គឧត្តមណាស់ ។

**ថ្ងៃ១៦មេសា ២០០៦**

ខ្ទមកំពុករបស់យាយភួងក៏បានប្រែក្លាយជាខ្ទមដ៏ស្អាតមួយ ដែល ខេរិនជួសជុលឡើងវិញដោយដៃឯង ។ នៅចំពោះមាត់ទ្វារខ្ទមខេរិនឈរ កាន់ដៃភរិយាអោនគោរពថ្វាយបង្គំបីដង ហើយវាចាថា :

- ពិតមែនតែចៅមិនដែលបានស្គាល់ដូនតារបស់ចៅ តែពេលនេះចៅក៏បាន ទទួលយកនូវពរជ័យសាធុការពីយាយតា ដ៏មានតម្លៃយ៉ាងមហាសាល លើសអ្វីៗទាំងអស់ក្នុងជីវិតរបស់ចៅ នោះគឺភរិយានិងកូនដែលនៅក្នុង ផ្ទៃ ។ អរគុណដូនតាណាស់ ដែលបានដឹកដៃចៅឱ្យមកដល់ទីនេះ!!

ខេរិនញញឹមដាក់ភរិយាដោយទទួលនូវសុភមង្គលមួយត្រចះត្រចង់ ។

រាត្រីនោះ...

ចាន់អង្គុយបត់ខោអាវនៅលើគ្រែ ។ ខេរិនអង្គុយគន់មើលភរិយាយ៉ាង ភ្លន់ភ្លឹកអស់រយៈពេលជាយូរ ហើយថែមទាំងលួចញញឹមផង មួយស្របក់ មកក៏លាន់មាត់ខ្សិបៗថា :

- និសា!...

ចាន់ហាក់ដូចជាចាប់ភ្លឹកនឹងសំដីរបស់ខេរិន ក៏បែរមកយ៉ាងរហ័ស :

- បងហៅឈ្មោះអ្នកណា?

CHANBOKEO.COM

ខេរិនក៏ងើបមកអង្គុយជិតភរិយា ហើយចាប់ភ្ជើយចង្កានាងឡើងផាត់ សក់ចេញពីផ្ទៃមុខថ្នមៗ ហើយសំលឹងនាងដោយកែវភ្នែកយ៉ាងស្រទន់មួយ ស្របក់ទើបស្រដីហៅថ្នមៗថា :

- និសា!... គឺបងចង់ហៅអូនដូច្នេះ តាំងពីថ្ងៃទីមួយដែលយើងបានជួបគ្នា នៅដីទួលខ្មយាយភួងមកម្ល៉េះ អូនដឹងទេ?

ស្រាប់តែចាន់បើកភ្នែក សំដែងអាការៈហាក់ដូចជាភ្ញាក់ផ្អើល :

- ខេរិន! បងនិយាយពីអ្វីហ្នឹង?

ស្រាប់តែខេរិនស្រវាអោបនាងយ៉ាងណែន :

- និសា! គឺបងចង់និយាយពីម្ចាស់ចិត្តបងណា៎!

ខេរិនទទ្រេញតែឈ្មោះមួយម៉ាត់នេះជាប់ៗគ្នាដដែលៗ រំភើបសប្បាយ រួចក៏ចាប់ភរិយាថើបម្តងហើយម្តងទៀត :

- អរគុណលោកយាយភួងណាស់ ដែលណែនាំនិសាមកអោយខេរិនវិញ!

មីងចាបឮសំលេងខេរិនស្រែកខ្លាំងដោយក្តីត្រេកអរក៏ស្ទុះចូលមក :

- អន្ទិតអើយ! មានរឿងអ្វីហ្នឹង បានជាឯងហោរកញ្ជ្រៀវខ្លាំងៗបែបនេះ?

ខេរិនដាក់ភរិយាលើគ្រែវិញថ្នមៗហើយឆ្លើយថា :

- ព្រោះកូនសប្បាយចិត្តពេកណា៎ម៉ែ ដែលមានប្រពន្ធដល់ទៅពីរក្នុងពេល ជាមួយគ្នា!

- ហ្អា៎ស? ឯងថាម៉េច? ម៉ែស្តាប់មិនបានទេកូន! ឯងមានប្រពន្ធដល់ ទៅពីរ? ចុះនរណាប្រពន្ធម្នាក់ទៀតរបស់ឯង? ហើយគេនៅឯណាដែរ?

- គឺនៅអង្គុយទីនេះទាំងពីរនាក់តែម្តងណា៎ម៉ែ!

មីងចាបបែរមើលជុំវិញមិនឃើញនរណាសោះក្រៅពីចាន់ ក៏ធ្វើភាំង :

- ខេរិន! ឯងដើរជាន់ពែរ ត្រូវដូនតាកាច់ ឬក៏ឯងកំពុងត្រូវខ្មោចលងហ្នឹង បានជាមានកិរិយាចំលែកយ៉ាងនេះ?

- ខេរិនមានស្មារតីធម្មតាតើហ៎ ម៉ែ...

ខេរិនស្ទុះមកទាញដៃគាត់អោយអង្គុយក្បែរចាន់ រួចស្រដីថា:

- ម៉ែ ចង់ស្តាប់រឿងកូនមួយទេហ៎?

- អឺ! អោយតែកូននិយាយប្រាប់ ម៉ែស្តាប់កូនជានិច្ច។

ខេរិនងើបឡើងទាញដៃប្រពន្ធយកមកកាន់ហើយក៏វាចាបន្តថា :

- ចាន់! គឺបងចង់អោយអូនដឹងយូរហើយ ថាហេតុអ្វីបងសំរេចលះបង់ ទឹកដីអាមេរិកដើម្បីប្រទេសខ្មែរ?

ចាន់សំលឹងមុខម្តាយ ហើយសំលឹងមុខខេរិន រួចតបវិញថា :

- មិនមែនដោយសារលិខិតមរតកនោះទេហ៎ បងខេរិន?

- មិនមែនទេ! ការពិត គឺមានរឿងមួយសំខាន់ជាងនោះទៅទៀត...

មីងចាបសំដែងទឹកមុខងឿងឆ្ងល់ :

CHANBOKEO . COM

- និយាយអោយក្បោះក្បាយចែកម៉ែស្តាប់បន្តិចមើល់កូន!

- បាទម៉ែ...

ចាន់ក៏យកដៃច្រត់ចង្កាសំលឹងមុខខេរិន លួចញញឹម ហើយបែរទៅ មើលម្តាយដែលកំពុងតែងឿងឆ្ងល់ បន្តិចមក ខេរិនក៏ចាប់រៀបរាប់រឿង រ៉ាវអតិតកាលរបស់នាយឡើងអោយអ្នកទាំងពីរស្តាប់យ៉ាងជក់អារម្មណ៍។

៩៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩៩

៩

CHANBOKEO . COM

# វគ្គទី៨
# បេះដូងជាប់ខ្នោះ

**ថ្ងៃ៣០មិនា ២០០៥ ម៉ោង៩យប់**

ក្រុងសេនផល រដ្ឋមិនិសូតា សហរដ្ឋអាមេរិក...

នៅក្នុងសង្កាត់មួយ ដែលអ្នកម្តុំនោះចំណាំហៅថាភូមិគីង្កក់ (Frog Town) ខេរិនរត់ផ្លោះរបងឆ្លងពីផ្ទះមួយទៅផ្ទះមួយ ដង្ហក់សឹងដាច់ខ្យល់ គេចពីក្រុមប៉ូលិសសំងាត់ ដែលតាមចាប់ខ្លួនអ្នកជួញដូរអាភៀន។ ថ្ងៃនោះ ខេរិនមិនបានចូលហ្វូងលក់អីនឹងគេទេ តែនាយត្រូវទៅទីនោះ ដើម្បីទៅ ទទួលយកផល្លីនដែលទើបដើរប្រមូលលុយកូនជំពាក់ ថៃដន្យកញ្ញាសោភា ក៏ត្រូវប៉ូលីសចាប់ឆែកកាត ហើយឆ្កែប៉ូលិសក៏ហិតឃើញលុយនៅក្នុង កាបូបរបស់ផល្លីននោះមានក្លិនអាភៀន។ នាយយើងក៏ រត់គេចប្រុយ ចោលនាងអោយនៅជាប់ខ្នោះតែម្នាក់ឯង ដោយគិតថានាងជាស្រី យ៉ាង ណាក៏មិនទទួលទោសធ្ងន់ដែរ។ កំពុងតែឈរដង្ហក់ខ្យល់ ឈរផ្អែកជញ្ជាំង ភោជនីយដ្ឋានខ្មែរមួយឈ្មោះ កុលាប សំលេងទូរសព្ទ័ដៃរបស់ខេរិន ក៏រោទិ៍ឡើង។ ខេរិនក៏លើកឆ្លើយ :

- Hello!
- ខេរិនឬក្មួយ?
- បាទ មីងពៅ! មានការអីឬមីង?
- អឺនែ៎ មីងចង់ប្រាប់ឯងថា ឥលូវនេះ បើឯងមានពេល ឯងមកផ្ទះមីង ម៉ាភ្លែត ត្បិតអីមានសាច់ញាតិយើងមកពីស្រុកខ្មែរគេទើបមកដល់។ មីង ចង់អោយឯងស្គាល់គ្នាណា៎។
- តែខ្ញុំកំពុងជាប់រវល់ណាស់មីង។ ចាំថ្ងៃក្រោយបានទេ?
- អើ បើគ្មានពេលទេ ចាំថ្ងៃក្រោយក៏បាន! ខេរិន! ឯងនិយាយដង្ហក់ៗ បែបនេះ ទើបរត់មកពីណា? កុំប្រាប់ណា៎ថាឯងកំពុងរត់គេចប៉ូលីស!
- អត់ទេ មីង! ខ្ញុំកំពុងរត់ហាត់ប្រាណតើហ៏ !
- អញ្ចឹង ថ្ងៃក្រោយទំនេរ ទូរសព្ទ័មកលេងមីងពូផង។
- បាទ!

ខេរិនក៏ទំលាក់ទូរសព្ទ័វិញហើយរអ៊ូថា :

CHANBOKEO.COM

- គ្រាន់តែអ្នកស្រុកខ្មែរមកលេង ក៏ចាំហៅអោយទៅជួបដែរ... យ៉ាប់ មែន! ច្បាស់ជាគ្មានពីណាទេ ក្រៅតែពីចាស់ៗគ្នាគាត់ ជួបគ្នាពេលណា និយាយគ្នាតែពីរឿងសម័យប៉ុលពតនិងរឿងព្រាត់បងព្រាត់ប្អូន យើងធុញ នឹងស្តាប់ណាស់! ម្យ៉ាងទៀតយើងក៏មិនដែលស្គាល់សាច់ញាតិនោះផង?

ខេវិនក៏ដើរត្រលប់ទៅរកបន្ទប់ដួលវិញ...

យប់នោះ នាយយើងយល់សប្តិឃើញស្ត្រីចាស់ម្នាក់មកអង្អែលក្បាល ហើយពោលទាំងភក្ត្រញញឹមថា :

- វិន្ទអើយ! ភ្ញាក់ឡើង! យាយមកលេងចៅណា៎!

ខេវិនភ្ញាក់កន្ត្រាក់ស្ទុះងើបឡើង ទើបដឹងថាកំពុងយល់សប្តិ។ នាយ ក៏រៀបខ្លួនបំរុងចេញទៅក្រៅ។ ថ្ងៃដន្យ ឡាននាយត្រូវប៉ូលីសអូសយក ទៅបាត់គ្មានអីជិះ នឹកចង់ទៅរកជួបផល្លីននៅមន្ទីរឃុំខ្លួនក៏មិនហ៊ានទៅ លុះដល់លូកប្រាក់ចេញមកក៏នៅតែប្រាំដុល្លារ ស្ទើរទិញអាហារមួយពេល មិនបាន។ ខេវិនហាក់ដូចជាទាល់ច្រកណាស់ មិនដឹងថាត្រូវធ្វើដូចម្តេច ទេ។ គិតទៅគិតមក នាយក៏ឡើងជិះរថយន្តក្រុងសំដៅផ្ទះពូវៃមីងពៅ ដែលរស់នៅឯក្រុងមួយឈ្មោះមេពិលវុដ (Maplewood) ជាយស្បៃក្រុង សេនផល។ ធម្មតា ផ្ទះមីងពៅមិនដែលចាក់សោរទេ ហើយក៏គ្មានសង់របង ជុំវិញផ្ទះដែរ ត្បិតតំបន់គាត់មិនដែលមានចោរឃ្មួញ មិនដូចនៅម៉ូដែល ខេវិននៅទេដែលសំបូរទៅដោយពួកឈាមរាវ។ មកដល់ភ្លាម ខេវិនក៏ បើកទ្វាររឹងដើរចូលទៅតាមទំលាប់ដែលនាយធ្លាប់ធ្វើរាល់ដង ស្រាប់តែ ទង្គិចនឹងមនុស្សម្នាក់ផាំង ហើយក៏ច្រលោតដួលព្រមគ្នាទាំងពីរនាក់ ទៅ លើធុងចិញ្ចឹមត្រីមាសលំអលំនៅមួយ។ កាលបើឃើញធុងត្រីដួលសង្កត់ មក ខេវិនក៏យកខ្លួនយកដៃរងកុំអោយធ្លាក់ទៅលើជននោះ តែទប់មិន ជាប់ក៏ភ្លាត់ជំហរដួល សង្កត់ទៅលើមនុស្សនោះរិតតែខ្លាំងលើសដើម។ ធុង ចិញ្ចឹមត្រីមាសដ៏ធំមួយនោះក៏រំលំបែកខ្ចាយទឹកព្រោងព្រាតឡើង ធ្វើឱ្យ មុតកំភួនដៃខេវិនចេញឈាមពីរបីកន្លែង។ ភ្លាមនោះ ខេវិនក៏ពោលឡើង យ៉ាងរហ័នថា :

- សូមទោសមីងពៅ ដែលខេវិនមិនបានប្រយត្ន័!

ថាហើយនាយក៏ស្រវាលើកជននោះឱ្យក្រោកឡើងស្រាប់តែឃើញខ្លួន គេនោះភ័យញ័រទទ្រើក។ លុះសំលឹងមុខទៅ ស្រាប់តែខេវិនភ្ញាក់ព្រើត ត្បិតម្នាក់នោះមិនមែនជាមីងពៅឯណា។ ការពិត គឺជានារីចំលែកម្នាក់ ដែលនាយមិនស្គាល់ពីមុនមកសោះ។ នាងមានមាឌតូចស្តើងពាក់វ៉ែនតា មីញ៉ូបយ៉ាងក្រាស់ កាត់សក់ប្រះស្មាទំលាក់សក់សេះមកលើថ្ងាស ទំនង ហាក់ដូចជាក្មេងសិស្សសាលាមួយរូប។ ពេលនោះ ខេវិនក៏ក្លាយជាភន្តំភាំង តែម្តង មិនដឹងថាត្រូវនិយាយអ្វីអោយសមទេ។ ធិតានោះក៏ស្ទុះក្រោក យ៉ាងរហ័សទាំងខោអាវទទឹកជោគ រត់ចូលបន្ទប់បិទទ្វារបាត់ទៅ ដោយ មិនស្រដីអ្វីមួយម៉ាត់ដាក់ខេវិនឡើយ។ នាយយើងបែរមើលតាមនាងធ្វើ មុខភាំង ភ្លេចគិតថាខ្លួនកំពុងរបួសដៃចេញឈាម។ មួយស្របក់ក្រោយ មក មីងពៅបើកឡានមកដល់ ឃើញខេវិនកំពុងអង្គុយរុំរបួសដៃ និង វាន់បែកបាក់រប៉ាត់រប៉ាយ ក៏លាន់មាត់ឡើង :

- ខេវិន! មានរឿងអីហ្នឹង?

CHANBOKEO.COM

ខេវិនងើបមុខឡើងឆ្លើយថា :

- គឺខ្ញុំមិនបានប្រយត្ន័ បានធ្វើអោយធុងចិញ្ចឹមត្រីមាសរំលំបែកអស់ ។

ខេវិនតបផងដេវ្យងកន្ទុយភ្នែកទៅម្ខាងផង លួចមើលទៅទ្វារបន្ទប់ ធិតាស្រាប់តែប្រទះឃើញកែវភ្នែកភ្លឺថ្លាផ្លេកៗមួយចំហៀង លួចមើលមក វិញតាមចន្លោះទ្វារ ។ លុះប្រទះនឹងកែវភ្នែកខេវិន ដែលកំពុងលួចសំលឹង មកដែរ នាងភ្ញាក់ព្រើតហើយក៏ផ្ទិបបិទទ្វារវិញយ៉ាងរហ័ស ។ ឃើញដូច្នោះ ខេវិនលួចធ្វើមុខញឹមៗ បន្តិចមកក៏រៀបឥរិយាបថធ្វើមុខស្មើៗ ដូចទំលាប់ ដើមរបស់នាយវិញដើម្បីកុំអោយមីងពៅចាប់ភ្លឹក ។ គ្រានោះខេវិននឹកឆ្ងល់ តែក្នុងចិត្តចង់ដឹងណាស់ថានារីក្មេងមួយរូបនោះជានរណា ។ បន្តិចមក មីង ពៅក៏ស្ទុះទាញអំបោសបោសសំអាតអំបែងកញ្ចក់ ស្រាប់តែខេវិនឃាត់ថា:

- មិនបាច់ធ្វើទេ មីង! Let me clean it up.

មីងពៅងើបមុខសំលឹងខេវិនទាំងចំលែកចិត្ត ត្បិតនាយមិនធ្លាប់មាន សន្ដានចិត្តទូលាយដល់ម្លឹង ។ កាលពីដើមសូម្បីតែខោអាវផ្ទាល់ខ្លួន ខេវិន មិនដែលបោកគក់ផង កុំថាឡើយដល់ទៅសំអាតផ្ទះនោះ ។ មីងក៏ព្រលែង អំបោសទុកឱ្យខេវិនសំអាតទីនោះយ៉ាងស្អាត ។ មួយសន្ទុះក្រោយមក គាត់ ក៏ហៅក្មួយមកសំណេះសំណាល :

- មីងមិនដែលឃើញមុខឯងច្រើនខែហើយ ជីវិតរបស់ឯងយ៉ាងណាដែរ?

- មិនអីទេមីង! Everything's okay.

- ហើយចុះមានដែលនឹកឃើញចង់ត្រលប់ទៅរៀនបញ្ចប់ការវិញទេ?

ខេវិនគ្រវីក្បាល :

- ខ្ញុំរៀនមិនចូលទេ ស្មារតីខ្ញុំអន់ណាស់ រៀនខាតតែពេលឥតប្រយោជន៍

- ខេវិន! កុំប្រមាថសមត្ថភាពខ្លួនឯងអី សូម្បីតែមនុស្សពិការក៏គង់នៅ រៀនចេះចាំបានខ្លះដែរ... បើឯងប្រឹងប្រែង ឯងពិតជាធ្វើបាន ។

- Whenever I'm ready, I'll do, Ming.

- អឺ! ថ្ងៃណាក៏បាន ។ មិនថាអាយុប៉ុន្មានទេ ឯងអាចត្រលប់ចូលរៀន បានជានិច្ច កាន់តែឆាប់កាន់តែប្រសើរ ។

- ចុះពូវៃទៅណាហើយមីង? (ខេវិនសួរបន្ថប់)

- ទៅធ្វើការហើយ ល្ងាចទើបមកដល់ ។ ថ្ងៃនេះ មីងសំរាកមួយថ្ងៃត្បិត មានភ្ញៀវ អូហ៍មែនហើយ! ឯងមានជួបគ្នាហើយឬនៅ?

- បាទ? ជួបនរណាគេទៅ?

មីងពៅមិនឆ្លើយទេ ។ គាត់ងើបទៅគោះទ្វារបន្ទប់ រួចហើយក៏អូសដៃ ធិតាមួយនោះចេញមកធ្វើការណែនាំ :

- និសា! នេះបងឯង ឈ្មោះខេវិន!... ខេវិន! នេះនិសា!

CHANBOKEO.COM

និសាលើកដៃសំពះសួរហើយឈ្ងោកមុខគេចទៅម្ខាង ទំនងដូចជាភ័យ ឬក៏ខ្មាស់អៀនចំពោះហេតុការណ៍អំបាញ់មិញនៅឡើយ ។ ខេរិនបែរសំលឹង មុខនាង រួចធ្វើមុខស្មើៗរួចនៅស្ងៀមមិនដឹងនិយាយអ្វី ។ ឃើញដូច្នោះ មីងពៅក៏ហៅនិសាអោយអង្គុយ ហើយណែនាំតទៅទៀត :

- ខេរិន! និសាទើបតែមកដល់ពីស្រុកខ្មែរម្សិលមិញ ។ គេត្រូវចូលហ្វឹកហ្វឺន ផ្នែកពេទ្យនៅ University Of Minnesota Hospital យើងនេះ ។ ឯងជួយណែនាំភូមិសាស្ត្ររដ្ឋយើងអោយប្អូនដឹងផងណា៎ ។

មិនទាន់និយាយចប់ផង ទូរសព្ទ័ខេរិនក៏រោទិ៍ឡើង ។ ខេរិនគេចទៅ ម្ខាងឆ្លើយទូរសព្ទ័រួចក៏បែរមកវិញ :

- ខ្ញុំមានការប្រញាប់ ត្រូវទៅសិនហើយមីង!

ថាហើយខេរិនក៏ដើបចេញទៅយ៉ាងរហ័ស ដោយមិនទាំងអើពើនិង និសាផង ។ មីងពៅលាន់មាត់លួងចិត្តនិសា :

- និសា! កុំប្រកាន់នឹងខេរិនណា៎! វាតែប៉ុនហ្នឹងឯង ពេលវាល្អវាល្អណាស់ តែបើពេលវាយ៉ាប់វិញ ក៏ពិបាកបើកភ្នែកមើលវាដូចឥលូវនេះអញ្ចឹង ។

បន្តិចក្រោយមក មីងក៏នាំនិសារៀនធ្វើ អាហារបែបអាគាំង ស្រាប់តែ ក្រលេកឃើញខេរិនឈររ៉េរ៉ៃនៅខាងក្រៅ ធ្វើអេះអុញមិនហ៊ានចូលមក វិញ ។ មីងពៅបើកទ្វារក្ងូកហៅ :

- ខេរិន! ចុះក្រែងឯងថា មានការប្រញាប់ ហេតុអ្វីក៏មិនទាន់ទៅទៀត?

ខេរិនស្រដីតបតិចៗថា :

- ខេរិនអត់មានលុយជិះឡានក្រុងទេ សុំពឹងពាក់មីងសិនបានទេ?

- ពុទ្ធោ! ប៉ុនហ្នឹងក៏ចាំបាច់ខ្សិប? ហើយ... ឯងដាច់ម៉ៃដល់ម្លឹង?

ខេរិនមិនឆ្លើយទេ តែបែរជាលួចចោលកន្ទុយទៅក្នុងផ្ទះ ។ មីងពៅ ហាក់ដូចជាកាត់យល់ក៏ស្រដីថែមថា :

- ខ្មាសក្រមុំស្រុកខ្មែរមែនទេ... ?

ឃើញមីងពៅចំអន់ ខេរិននៅស្ងៀម ។ មីងពៅសួរទៀត :

- ចុះឯណាឡានឯង ?

- ត្រូវប៉ូលីសអូសបាត់ទៅហើយ ។

- ទេវតា!... ហើយហេតុអីក៏យីអ៊ុនឯងវាដាក់ដល់ម្លឹង ។ ល្ហើយ បើយ៉ាប់ ពេក ឯងផ្លាស់មកនៅជាមួយមីងពូវិញមក កុំទៅរស់នៅរសាត់អណ្តែត អញ្ចឹងទៀតអី...

តែខេរិនឈ្ងោកមុខមិនឆ្លើយទេ ។ មីងពៅនឹកឃើញរឿងមួយ :

- អឺ! បើបានជាជ្រុលជិះឡានក្រុងទៅហើយ ឯងនាំនិសាទៅផង បង្រៀន គ្នាឱ្យដឹងផ្លូវទៅសាលា ព្រោះអាទិត្យក្រោយនិសាត្រូវចូលសាលាហើយ ។

ស្រាប់តែខេរិនបើកភ្នែក ហើយគ្រវីក្បាល :

- ខ្ញុំទៅទទួលផល្លីនពីគុក នាំនិសាឱ្យឃើញកន្លែងអញ្ចឹងៗមិនសមទេមីង

CHANBOKEO.COM

- ស្លាប់ហើយ ផល្លីនចូលកន្លែងចតទៀតហើយ? ហើយឯងទាំងពីរ កាល ណាបានឈប់រត់អាភៀនទៀត? នៅក្មេង ប្រព្រឹត្តផ្តេសផ្តាសយ៉ាងនេះ ស្តាយអនាគតខ្លួនណាស់!

ខេរិនឮហើយ នៅស្ងៀមមិនហ៊ានតប ។ មីងពៅចូលផ្ទះឆែកកាបូប ស្រាប់តែគ្មានប្រាក់នៅសល់ សល់តែកាតធនាគារ ក៏កួកហៅនិសា :

- នាងហ្នា! មានលុយរាយទេ មីងខ្ចីសិន ។

ធិតាឮហើយក៏លូកហោប៉ៅហុចអោយទៅគាត់ ។ មីងពៅក៏ហុចទៅ ខេរិនបន្ត ។ ខេរិនទទួលប្រាក់ហើយក៏ដើរចេញទៅ ។

ថ្ងៃ២មេសា២០០៥

និសាមិនទាន់បានចេញទៅណាមកណាទេត្បិតខ្លាចវង្វេង ។ នាងនៅតែ ផ្ទះ អានសៀវភៅកំដរពេលទំនេររង់ចាំថ្ងៃចូលរៀន ។ ប៉ុន្តែ ពីរបីថ្ងៃនេះ នាងក៏សង្កេតឃើញដែរថា ខេរិនបានមកដល់មុខផ្ទះមីងពៅពីរបីដងតែមិន ព្រមចូលសោះ ឃើញតែរ៉េរ៉េៗនៅខាងក្រៅហើយក៏ចេញទៅវិញ ។ ថ្ងៃនេះ មីងពូទៅធ្វើការបាត់ ។ និសាក៏ចេញទៅខាងក្រោយផ្ទះស្រោចផ្កា ។ លុះត្រលប់ចូលផ្ទះវិញ ក៏ភ្ញាក់ភើតពោះ ត្បិតឃើញខេរិននៅអង្គុយច្រងុកក្នុង បន្ទប់បាយធ្វើមុខមាំ ។ នាងមិនហ៊ាននិយាយអ្វីទេ ក៏ឈ្ងោកមុខដើរហួស បំរុងចូលបន្ទប់ ស្រាប់តែខេរិននិយាយវ៉ាសឡើង :

- យ៉ាប់ណាស់ អ្នកស្រុកខ្មែរ!

ថាហើយខេរិនក៏ដកលុយ២០ដុល្លារដាក់លើតុផាំង ហើយគំហកថា :

- នេះ២០ដុល្លារលុយក្លែងក្លាយរបស់នាង! យកវិញទៅ! លុយរបៀបនេះ ចាយមិនដាច់ទេនៅអាមេរិក ហើយក៏អាចនាំឱ្យចូលគុកចូលច្រវាក់ផង!

ថាហើយ ខេរិនក៏ដើរចេញទៅទាំងត្រមាត់ត្រមុយ ។ និសាភ្ញាក់ ក្រញាងបែរលូកដៃចាប់យក២០ដុល្លារយកមកមើល ឃើញខេរិនគូរពុក មាត់ស្រមាមបន្ថែមលើរូបប្រធានាធិបតីដែលផ្តិតនៅលើសន្លឹកប្រាក់ហើយ សរសេរថា :

- I Hate You!!

និសាធ្វើភ្នែកឡឹងឡង់ៗ ត្បិតនាងក៏មិនដឹងដែរ ថានោះជាក្រដាស ក្លែងក្លាយព្រោះអីនាងកាន់យកមកតាំងពីស្រុកខ្មែរ ជាប្រាក់សន្សំមិនដែល បានចាយយូរហើយ ។ នាងសំលឹងតាមក្រោយខេរិន រួចឧទានថា :

- រឿងតូចសោះ ម៉េចចាំបាច់ខឹងត្រមាត់ត្រមុយផងហ្ន៎? ឬមួយក៏កំពុង តែខឹងសង្សារទេដឹង ទើបមកជះកំហឹងខុសកន្លែងយ៉ាងនេះ?

**ថ្ងៃ ១៥មេសាឆ្នាំ ២០០៥...**

នៅវត្តមិនីសូតារាម រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

និសាឈរតំរង់ជួរទទ្ទឹមនិងមីងពៅដាក់បាត្រ ព្រមជាមួយពុទ្ធបរិស័ទ រាប់រយពាន់នាក់ ។ នាងលួចខ្សិបសួរមីងថា :

- មីង! ខេរិនមកធ្វើបុណ្យដែរទេថ្ងៃនេះ?

- ស្លាប់ហើយនិសា! ខេរិនឯណាវាស្គាល់វត្តស្គាល់វ៉ានោះ?

CHANBOKEO.COM

- ជាខ្មែរដែរ គួរណាស់តែមកធ្វើបុណ្យជូនអ្នកមានគុណ...

- ហ៊ឺ! នាងអើយ! មីងចាញ់ចេះនឹងកូនចៅមួយរូបនេះហើយ មិនដឹងថា ត្រូវធ្វើយ៉ាងណាដើម្បីកែវាបានទេ។

- ហើយចុះមីងដឹងទេ ថាគាត់រស់នៅឯណា?

- វាមិនដែលប្រាប់មីងទេ ឃើញជីវិតវាដូចអំពិលអំពែកអញ្ចឹង!

និសានៅស្ងៀម។ លុះដល់ពេលបាយថ្ងៃត្រង់ នាងក៏ជួសអាហារដាក់ ថាសដើរចែកចាយជូនយាយតាចាស់ៗ។ បន្តិចមក នាងក៏ដើរសំដៅទៅ បុស្បុកដែលសង់នៅកណ្តាលទីធ្លាមុខវត្ត ដើម្បីអុចធូបថ្វាយព្រះ ស្រាប់តែ ចាប់ភ្លឹកថា នាងដូចជាបានឃើញខេរិននៅអង្គុយក្នុងឡានជាមួយមិត្តភក្តិ ប្រុសៗពីរនាក់ ក៏នឹកគិតថានឹងយក២០ដុល្លារថ្មីទៅសងនាយវិញ ស្រាប់តែ ខេរិនក្រលេកចំមកឃើញនាងភ្លែត ហើយក៏កេះពួកម៉ាកថយឡានត្រលប់ ក្រោយចេញពីបរិវេណវត្តទៅ ទុកឱ្យនិសាឈរសំលឹងមើលពីក្រោយ គ្រវី ក្បាលទំនងជាខកចិត្ត។

អាទិត្យបន្ទាប់មក...

និសាបានស្ម័គ្រធ្វើការនៅសមាគមខ្មែរជួយធ្វើព្រឹត្តបត្រ័ផ្សាយប្រចាំ ខែ។ នាងមិនទទួលប្រៀវត្សទេ ព្រោះគិតថានាងគ្រាន់តែយកពេលវេលា ដែលទំនេរមកជួយ បណ្តុះបណ្តាលសង្គមខ្មែរអោយមានប្រយោជន៍តែ ប៉ុណ្ណោះ។ ថ្ងៃនេះមានមិត្តភក្តិមកទទួលនាងតាំងពីព្រលឹម។ ពូវៃមីងពៅ ឈប់មិនទាន់ចូលធ្វើការវិញនៅឡើយ។ ថ្ងៃត្រង់បន្តិច ខេរិនមកដល់ តែ មិនឃើញនាយធ្វើមាត់ម៉ាម៉ាត់សោះ ក៏ស្រាប់តែប្រាសដេកព្រួសលើព្រំក្នុង បន្ទប់ទទួលភ្ញៀវហើយក៏បិទភ្នែកសំងំស្ងៀម។ មីងពៅនិងពូវៃសំលឹងមើល មុខគ្នាទាំងចំលែកចិត្ត តែគាត់មិននិយាយអីដែរចេះតែ បណ្តោយឱ្យខេរិន នៅតែម្នាក់ឯងយ៉ាងយូរ។ ប្រហែលមួយម៉ោងក្រោយមក នាយក៏បើក ភ្នែកឡើងយកដៃគងថ្ងាស។ មីងពៅក៏សួរថា:

- ខេរិន! ឃ្លានបាយទេហ៎? មីងរៀបចំអោយ។

ខេរិនគ្រវីក្បាលហើយផ្ទេចទៅវិញ។ ស្រាប់តែមីងពៅលាន់មាត់សួរ :

- ឯងឈ្លោះគ្នាជាមួយផល្លីនទៀតហើយមែនទេហ៎?

នាយយើងនៅស្ងៀមមួយស្របក់ទើបតបថា :

- ខ្ញុំមិនអីទេមីង! បន្តិចទៀត ខ្ញុំអារម្មណ៍ល្អវិញហើយ។

- អូហ៍ និសាគេមានរបស់ទុកអោយឯង ( មីងពៅលាន់មាត់ ហើយក៏ស្រវ៉ា កញ្ចប់តូចមួយហុចអោយខេរិន)

មាណពទទួលយកហើយក៏ដាក់នៅក្បែរខ្លួន ហើយផ្ទេចភ្នែកសំងំដេក នៅលើកំរាលផ្ទះដដែល។

- ឯងមិនបើកមើលទេ? ( មីងពៅសួរ )

ដោយទើសទាល់ ខេរិនក៏ក្រោកអង្គុយ ហើយទាញប្រអប់មកកាន់ ដោយកិរិយារេរាទំនងមិនចង់បើកមើល។ ពូវៃក៏មានប្រសាសន៍ឡើង :

CHANDBOKEO.COM

- និសាគេមានសន្ដានចិត្ដចេះនឹកឃើញដល់យើង... ចូរក្មួយសំដែងការ គោរពដល់ទឹកចិត្ដរបស់គេផងណា៎ ។ វត្ថុបញ្ញើនេះប្រហែលជាមានតម្លៃតិច តួចពិតមែន តែទឹកចិត្ដគេវិញតើហ៎ដែលមានតម្លៃវាស់មិនបាន ។

ថាហើយ ពូវ៉ៃនាំមីងពៅទៅពិសារបាយ ។ ខេវិនអង្គុយសំលឹងប្រអប់នោះមួយស្របក់ក៏លូកដៃទៅចាប់បើកមើល ។ ភ្លាមនោះ នាយប្រទះឃើញបាក់២០ដុល្លារ ធូបបីសរសៃ និងសំបុត្រមួយសន្លឹកដែលសរសេរ ជាភាសាអង់គ្លេស (មានន័យជាខ្មែរ) ថា :

*- ខេវិន! ខ្ញុំសូមសងប្រាក់អ្នកវិញ២០ដុល្លារវិញ ជំនួសប្រាក់ក្លែងក្លាយថ្ងៃមុន ហើយឈប់ខឹងទៀតទៅណា៎ នាំតែជីវិតអាប់អួរឥតប្រយោជន៍ ដោយសារតែប្រាក់បន្ដិចបន្ដួច ។ កាលពីថ្ងៃបុណ្យចូលឆ្នាំ ខ្ញុំចង់ហៅអ្នកមក អុជធូបជូនលោកយាយលោកតាពុកម៉ែយើង តែអ្នកត្រលប់ទៅវិញលឿន ពេក ទើបអាក់ខានទៅ ។ ធូបបីសរសៃនេះ និសាសូមផ្ញើជូនខេវិន បើមាន ពេលទំនេរ សូមអុជធូបជូនលោកកុំខាន នោះលោកនឹងប្រទានពរល្អៗដល់ជីវិតយើង! ហើយកុំភ្លេចញញឹមផងណា៎! ញញឹមអោយបានច្រើនបំផុត... នោះបរិយាកាសជុំវិញខ្លួន រួមទាំងដួងចិត្ដរបស់យើងផងនឹងបានជួបភាព ស្រស់បំព្រងភ្លឺថ្លាមិនខានឡើយ ។ និសា!*

អានចប់ ខេវិនហាក់ដូចជាមានអារម្មណ៍យ៉ាងចំលែកតែម្ដង! មែន ហើយ ត្រឹមតែ២០ដុល្លារសោះ ម៉េចក៏នាយចាំខឹងម៉ូម៉ៅស្អប់នាងច្រើនថ្ងៃ យ៉ាងនេះ? ពេលនោះនាយយើងក៏លាតក្រដាស២០ដុល្លារឡើង ឃើញនិសាគូរស្នាមញញឹមយ៉ាងធំមួយលើផ្ទៃមុខប្រធានាធិបតីដែលបោះពុម្ពនៅ លើប្រាក់ ព្រមទាំងសរសេរថា :

- Smile!!

ស្រាប់តែខេវិនញញឹមនឹកចង់អស់សំណើច តែក៏ខំទប់ហើយរៀបបួក ធម្មតាមកវិញ ។ គេនឹកឆ្ងល់ណាស់ថា ហេតុអីក៏និសាមិនបានខឹងតបនាយ វិញ មិនតែប៉ុណ្ណោះ នាងបានសរសេរកោតយ៉ាងពិរោះថ្នមចិត្ដនាយថែម ទៀត ។ តាមការពិតទៅ ខេវិនជាមនុស្សកំបុតកំបុយបន្ដិចនោះ ក៏ព្រោះតែនាយជាមនុស្សដែលខ្វះការកក់ក្ដៅផ្លូវចិត្ដតាំងពីកុមារភាពម្ល៉េះ ។ កាលបើ និសាសំដែងភាពទន់ភ្លន់ត្រលប់មកនាយវិញ ខេវិនហាក់ទន់ចិត្ដនឹកស្ដាយ ក្រោយបន្ដិចដែរ ។ គេគិតថា មើលទៅប្រហែលជានាងគ្មានចេតនាអោយ ប្រាក់ក្លែងក្លាយមកនាយទេ គ្រាន់តែជារឿងចៃដន្យប៉ុណ្ណោះ ។ ម្យ៉ាង វិញទៀត នៅថ្ងៃបុណ្យចូលឆ្នាំ និសាមានចិត្ដមកបបួលនាយឱ្យទៅអុជធូបជូនអ្នកមានគុណ តែនាយបែរជារត់គេចពីនាងប្រផាប់ប្រភីងទៅវិញ... គិតទៅ គួរអោយអាមាសមែនហ្ន៎!

- ចុះ និសាទៅណាហើយមីង? (ខេវិនសួរមីងពៅ)

- គេទៅជួយការងារឯសមាគមខ្មែរបាត់ទៅហើយ ។

ថ្ងៃនោះ ខេវិននៅអែអង់រង់ចាំជួបនិសាដែរ តែម៉ោង៨យប់ហើយ និសាក៏មិនទាន់ត្រលប់មក ។ ដោយខ្លាចខកជើងឡានក្រុង ខេវិនក៏ត្រលប់ ទៅវិញដោយមិនបានជួបគ្នា ។

**ថ្ងៃ២៨មេសា ២០០៥**

CHANBOKEO.COM

ពូវៃមីងពៅចេញទៅលេងរដ្ឋកាលីហ្វរញ៉ា ចំនួនមួយអាទិត្យហើយ ចុងសប្ដាហ៍នេះទើបត្រលប់មកវិញ ។ និសានៅផ្ទះម្នាក់ឯងហើយជិះឡាន ក្រុងទៅរៀនដូចប្រក្រតី ។ ថ្ងៃនេះ ខេវិនទឹកភ្នកទិញផ្កាកុលាបមួយទង បំរុងថានឹងទៅលេងផ្ទះមីងពៅ ស្រាប់តែ ឃើញផល្លីនរត់តាំង១មកដល់ :

- ទិញផ្កាឱ្យខ្ញុំមែនទេ ខេវិន?

ផល្លីន ថាផង ឆក់យកផ្កាពីខេវិនផង ធ្វើអោយនាយភ្ញាក់ស្រលាំង កាំង ស្រាប់តែផល្លីនស្រវាអោបថើបថ្ពាល់តាមរបៀបអាគាំង :

- ឈប់ខឹងនឹងផល្លីនហើយឬបានជាទិញផ្កាមកអោយ?

ខេវិនមិនមាត់តបទេ គ្រាន់តែដើរឡើងឡានក្រុងទៅ ។ ផល្លីនរត់ ឡើងតាមពីក្រោយដែរហើយបែរសួរនាយជាអង់គ្លេសថា :

- ខេវិន! Where're you going? Can I buy you a lunch?

ខេវិនមិនឆ្លើយទេ ត្បិតទើសទាល់ក្នុងចិត្ត ហើយនាយក៏មិនមែនជា បុរសដែលចេះស្ដីច្រើនផង ។ គេក៏ចេះតែបណ្ដោយអោយផល្លីនអូសទាញ តាមតែចិត្តទៅ ។ ការពិត នាយយើងក៏ជំពាក់សគុណផល្លីនច្រើនណាស់ ដែរ ។ ពិតមែនតែនាងកាចឆ្នាសមិនសូវមានរបៀប ប៉ុន្ដែនាងតែងតែយក ខ្លួនការពាររារាំងមិនអោយខេវិនត្រូវប៉ូលិសចាប់ខ្លួនបានឡើយ ។ កំពុងតែ បរិភោគអាហារនៅហាងបាយខ្មែរមួយ ស្រាប់តែមានបុរសស្ត្រីក្មេង១មួយ ហ្វូងចូលមកដល់ ។ ផល្លីនឃើញហើយស្ទុះខ្សឹបប្រាប់ខេវិនថា :

- ផល្លីនកំពុងមានរឿងជាមួយក្រុមមួយនេះ ត្រូវគេចខ្លួនទៅហៅគ្នា មកការពារសិន ខេវិននៅទីនេះសិនហើយណាំ!

ថាហើយ នាងក៏គេចខ្លួនបាត់ទៅ ។ ខេវិនឃើញស្ថានការណ៍មិនល្អ ក៏ហុចប្រាក់ រួចដើរចេញមករកទិញផ្កាកុលាបថ្មីមួយទងទៀតទើបឡើងជិះ ឡានក្រុងសំដៅទៅផ្ទះមីងពៅ ។ ពេលនោះ ម៉ោងជាង៩យប់ទៅហើយ និសាក៏មិនទាន់មកដល់ផ្ទះ ។ ខេវិនគិតថា ប្រហែលជានាងរៀនថ្នាក់ពេល យប់ហើយ ។ មាណពនៅរេរាមួយស្របក់ នឹកចង់ដាក់ផ្កាលើតុធ្វើទុកក្នុង ផ្ទះអោយនិសា តែហាក់ដូចមិនសម នឹងយកទៅវិញក៏មិនកើត ព្រោះនាយ ប្រាថ្នាយកមកអោយនាងដើម្បីជាការលាងកំហុសរបស់ខ្លួនដែលបានគំរោះ គំរើយដាក់នាង ។ ចាំយូរពេក មិនឃើញនិសាមក ខេវិនក៏ជិះឡានក្រុង ត្រលប់ទៅផ្ទះ ។ លុះឡានចូលដល់ទីក្រុង ខេវិនក៏ចុះនៅចំណតមួយបំរុង នឹងឡើងឆ្លងទៅឡានមួយទៀត សំដៅទៅផ្ទះខ្លួនទៅហើយ ស្រាប់តែ ប្រទះក្មេងជំទង់១ស្បែកខ្មៅស្បែកស មួយហ្វូងកំពុងប្រវាយប្រតប់មនុស្ស ស្រីម្នាក់ដណ្ដើមសំពៀតដែលនាង ស្ពាយនៅលើខ្នងនៅកាច់ជ្រុងវិថីមួយ ។ ពេលនោះយប់ជ្រៅបន្តិចហើយ អាកាសធាតុក៏ត្រជាក់ណាស់ដែរ ឯចរាចរ វិញក៏ស្ងាត់ច្រៀប ។ ខេវិនបត់ផ្កាញាត់ក្នុងហោប៉ៅអាវរងា ហើយហក់ស្ទុះ ទៅចាប់បំបែកក្មេងទាំងនោះចេញ ។កាលបើឃើញខេវិនមានមាឌធំកំលាំង ដូចខ្លាចូលមកដល់ ក្មេងទាំងនោះក៏រត់បំបែកហ្វូងឆ្លងថ្នល់គេចខ្លួនបាត់អស់ ទៅ ។ ឯពន្លឺភ្លើងគោមតាមផ្លូវក៏ភ្លឺមិនសូវច្បាស់ រកតែនាយយើងចំណាំមុខ ពួកក្មេងទាំងនោះក៏មិនបាន ។ ម្យ៉ាងទៀត រដូវនេះជាដើមរដូវផ្ការីក ។

អាកាសធាតុពេលយប់នៅត្រជាក់នៅឡើយ មិនអាចនៅរេរ៉េបានទេ ខេរិន ក៏ស្ទុះទៅត្រកងស្រីម្នាក់នោះឡើង តែខ្លួននាងបែរជាទន់ល្វក់ ងើបឈរមិន រួចឡើយ ។ នាងត្រូវក្មេងៗវាយឡើងទ្រោម ហូរឈាមពីមាត់ពីច្រមុះ ប្រលាក់ពេញមុខមើលមិនយល់ទៅហើយ ។ ខេរិនបែររកមើលជុំវិញខ្លួន ក្រែងលោមានរថយន្តបរកាត់ នឹងអាលសុំគេជិះយកស្រីនោះទៅពេទ្យ តែសំណាងមិនល្អសោះ ។ មន្ទីរពេទ្យនៅឆ្ងាយប្រហែលជិតពីរគីឡូងណោះ ខេរិនមិនដឹងធ្វើម៉េចក៏ស្រវាំសំពៀតនាងមកភ្ជាក់លើស្មាហើយ ក៏លើកបី ស្រីម្នាក់នោះ ដើរកាត់ស្បែរអព្ទុំដីត្រជាក់ដែលកំពុងធ្លាក់យ៉ាងក្រាស់នោះ សំដៅទៅមន្ទីរពេទ្យ Regions Hospital ។ ទំរាំទៅដល់ ខេរិនហត់សឹងដាច់ខ្យល់ស្លាប់តាមផ្លូវម្ដង១ទៅហើយ ។ ភ្នាក់ងារព្យាបាល អាសន្នក៏រត់ព្រួ អូសគ្រែស្នែងមកទទួលយកស្រីម្នាក់នោះ ពីខេរិនទៅកាលបើឃើញខេរិន បីអ្នករបួសមកដល់មាត់ទ្វារពេទ្យ ។ គេក៏យកនាងចូលបន្ទប់ព្យាបាលយ៉ាង រហ័ស ក្នុងឱកាសដែលបុគ្គលិកម្នាក់ទៀត សាកសួរខេរិនរកអត្តសញ្ញាណ របស់ជនរងគ្រោះ ។ ខេរិនក៏ទាញសំពៀតស្រីនោះចេញមក បើកមើលរក កាតផ្សេង១ ក៏ឃើញComputerLabTopមួយបែកខ្ទេចខ្ទីរ ។ នាយក៏ទាញ កាតមួយចេញមកទំនងជាកាតកូនសិស្សនិស្សិត ស្រាប់តែប្រទះរូបថតជា នារីក្មេងម្នាក់ពាក់វ៉ែនតាមីញ៉ូបយ៉ាងក្រាស់ កាត់សក់ខ្លីទំលាក់សក់សេះ ខាងមុខ ។ ខេរិនក៏លាន់មាត់ឡើង :

- និសា...?

ស្រាប់តែចិត្តនាយក្លាយជាតក់ស្លុតរន្ធត់លើសដើមតែម្ដង រហូតអាន អ្វីលែងដាច់អស់រលីង ក៏ប្រគល់សំពៀតទាំងអស់នោះ ទៅបុគ្គលិកពេទ្យ ប្រចាំការទីនោះអោយចាត់ចែងដោយផ្ទាល់ ។ បន្តិចក្រោយមក បុគ្គលិក ពេទ្យម្នាក់ចេញមកប្រាប់នាយថា :

- បន្តិចទៀត មានប៉ូលីសមកសាកសួរដំណឹងពីលោក នូវហេតុការណ៍ដែល ធ្វើអោយស្រីម្នាក់នោះរងរបួសជាដំណំ លោកកុំទាន់ទៅណាអោយសោះ!

ប៉ុន្តែ.. ខេរិនមិនចូលចិត្តអោយប៉ូលីសជួបមុខទេ ត្បិតនាយជាគោ ដំបៅខ្នងយូរហើយ ។ គ្រាន់តែឮបុគ្គលិកពេទ្យប្រាប់ដូច្នោះ នាយក៏រកផ្លូវ គេចមុខភ្លាម ដោយមិនទាំងទាន់ដឹងដំណឹងពីលោកគ្រូពេទ្យផងថា និសា មានសុខទុក្ខយ៉ាងណានៅឡើយ ។

ស្អែកឡើង **ថ្ងៃ២៩មេសា២០០៥**

ថ្ងៃនេះខេរិនតុបតែងខ្លួនយ៉ាងប្លែក ។ ផល្លីនប្រទះឃើញក៏សួរ :

- ខេរិន! ខ្ញុំមិនដែលឃើញបងស្លៀកពាក់ត្រឹមត្រូវអញ្ចឹងទេ មានការ ទៅណាហ្នឹង?
- អត់មានទេ! គ្រាន់តែចង់ទៅមើលអ្នកជំងឺនៅឯមន្ទីរពេទ្យ
- អ្នកណាគេ?
- គឺ បងប្អូនរបស់ខេរិន...

ផល្លីនជ្រួញចិញ្ចើមធ្វើភាំង :

- ខេរិនមានបងប្អូនដែរ? ម៉េចផល្លីនមិនដែលដឹងអញ្ចឹង?

CHANBOKEO.COM

ខេរិនមិនតបវិញទេ ក៏ហក់ឡើងឡានក្រុងចេញទៅ។ ផល្លីនក៏នៅ ឈរមើលពីក្រោយដោយឆ្ងល់ថានរណាជាបងប្អូនខេរិន។ ការពិត ខេរិនប្តូរសំលៀកបំពាក់ គឺដើម្បីកុំឱ្យប៉ូលីសចាប់ភ្លឹកតាមរកនាយទេតើ។ ទៅដល់មន្ទីរពេទ្យ ខេរិនបានចូលទិញផ្កាមួយបាច់យកទៅផ្ញើអ្នកជំងឺ។ ចៃដន្យ និសាទើបតែលេបថ្នាំបំបាត់ការឈឺចាប់ហើយគេងលក់ទៅ។ ខេរិន នៅរេរាយ៉ាងយូរមិនឃើញនាងភ្ញាក់សោះ ក៏មិនហ៊ានរំខាន ណាមួយកំពុង តែជាប់រវល់មានការផងថ្ងៃនោះ ម្ល៉ោះហើយ នាយក៏ទុកបាច់ផ្កាចោលនៅ លើតុក្បែរគ្រែអ្នកជំងឺ រួចក៏ត្រលប់ទៅវិញទាំងខកចិត្ត។

**ថ្ងៃទី៣០មេសា២០០៥...**

មីងពៅពូវ៉ៃហក់ចុះពីរថយន្តយ៉ាងលឿន ដើរត្រហេបត្រហបមកដល់ ឃើញនិសាអាចក្រោកដើរបាន គាត់ក៏ធូរទ្រូងខ្យាក។ មីងពៅសួរថា :

- និសា! ក្មួយដឹងទេហ៎ ថាតើនរណាដែលមកជួយសង្គ្រោះនាង?
- ចាំសអត់ស្គាល់ទេ យប់ងងិតពេកហើយខ្ញុំកំពុងវិលមុខបែកអំពិលអំពែក ទើបមិនបានចំណាំថាជានរណាទេ។
- ហើយ... តើយើងធ្វើម៉េចនឹងអាចទៅអរគុណគេបាន?

ភ្លាមនោះ ពូវ៉ៃឃើញបាច់ផ្កានៅលើតុ ទំនងរាងក្រៀមបន្តិចហើយ :

- ច្បាស់ជាម្ចាស់បាច់ផ្កានោះហើយ។

មីងពៅទាញកាតដែលចងបាច់ផ្កាមកអាន តែមិនឃើញមានឈ្មោះ អ្នកផ្ញើទេ។ ទាំងបីនាក់ក៏មើលមុខគ្នាធ្វើឡឹងឡង់។ តាមផ្លូវត្រលប់ទៅផ្ទះ និសាអង្គុយនៅបាំងខាងក្រោយតែម្នាក់ឯង។ នាងក៏ទាញកាតជូនពរនោះ ពីបាច់ផ្កាមកអានម្តងទៀត ឃើញសរសេរជាងអង់គ្លេសថា :

- Hope you get well soon! Smile!

និសាមិនឃើញហត្ថលេខារបស់អ្នកផ្ញើទេ ប៉ុន្តែនាងចាប់ភ្លឹកឃើញរូប គំនូរព្រះអាទិត្យមួយដែលមានរង្វង់មាត់ញញឹមយ៉ាងស្រស់ ដែលគូរដោយ ទឹកប៊ិកកាពណ៌ខៀវ។ ទោះបីគំនូរនោះគ្រាន់តែជាគំនូរខ្សៀក១មិនស្អាត តែក៏មានអត្ថន័យគ្រប់គ្រាន់នឹងអាចយល់បានយ៉ាងងាយ។ ពេលនោះ ស្រាប់តែនិសាលើកកាតនោះមកក្តាប់ ហើយញញឹមឡើងតែម្នាក់ឯង។

**ថ្ងៃ ៣ កក្កដា ២០០៥**

ពូវ៉ៃឃើញមីងពៅដុតនំសំរាប់ពិធីបុណ្យខួបកំណើតក៏សួរថា :

- ខេរិនវាមកទេហ៎ថ្ងៃនេះ?
- ត្រូវតែមក ព្រោះខ្ញុំបានផ្តាំដាច់ខាតថាអោយមកកុំខាន ត្បិតថ្ងៃនេះជា ថ្ងៃខួបកំណើតរបស់វា ( មីងពៅឆ្លើយវិញ)

ពូវ៉ៃឃើញនិសារៀបខ្ចប់វត្ថុអនុស្សាវរីយ៍អោយខេរិនក៏សួរថា :

- និសាបានអីអោយបងឯងហ្នឹង?

CHANBOKEO.COM

- របស់កំប៉ិកកំប៉ុកតិចតួចដែលធ្វើអោយគាត់ចេះញញឹមណាំពូ!

- អញ្ចឹងល្អហើយ! ពូមីងឯងមិនដែលឃើញខេវិនញញឹមជាយូរឆ្នាំហើយ ល្មមដល់ពេលវាត្រូវរៀនញញឹមខ្លះហើយទេដឹង?

ម៉ោងប្រហែលជា៧ល្ងាចទើបខេវិនមកដល់ ។ ឃើញមុខក្មួយប្រុស ភ្លាម ពូមីងក៏ចាប់ផ្ដើមអុជទៀនខួបកំណើត ។ តែខេវិនបែរជាពោលថា :

- ចាំបាច់ធំដុំម្ល៉េះមីងពូ កូនសំណល់ពីសម័យអាពតដូច្នោះ ងាប់រស់តាមតែ វាសនាទៅ ។

- ម៉េចក៏ឯងពោលដូច្នោះខេវិន? មីងពូស្រលាញ់ឯងជាកូនជាចៅណាំ មិនមែនក្មេង កំព្រាទេ ។

ខេវិនព្វហើយនៅស្ងៀម ។ ភ្លាមនេះ នាយបែរមើលទៅក្នុងផ្ទះ ទំនងរកនរណាម្នាក់ ។ មីងចាន់ហាក់ដូចជាយល់ចិត្តក៏ពោលឡើង :

- និសាមិននៅទេ ។ ពួកសមាគមខ្មែរគេមានការពឹងពាក់ជាបន្ទាន់ ។ គេចេញទៅ តាំងពីព្រឹក ប្រហែលបន្តិចទៀត មកវិញហើយ ហើយថ្ងៃនេះ ម៉េចក៏ក្រមកដល់ម្ល៉េះ?

- ព្រោះបាត់នាឡិកាអត់អីមើលម៉ោងណាមីង (ខេវិនឆ្លើយយកលេស)

មីងពៅខ្លាចនាយភូតក៏ទាញដៃនាយមកមើលឃើញបាត់នាឡិកាមែន

- យកទៅលក់ឬក៏បញ្ចាំ? (មីងពៅសួរ)

- គឺបាត់មែនណាំ ខ្ញុំមិនភូតទេ ។

ការពិតខេវិនបានបាត់នាឡិកាមែន តែនាយក៏មិនដឹងដែរថាបាត់តាំងពី អង្កាល់ ។ មីងពៅគ្រវីក្បាលហើយនៅស្ងៀម ។

បន្ទាប់ពីផ្លុំទៀនហើយ ស្រាប់តែខេវិនក៏ទាញសំពៀតរបស់នាយ យក Computer LapTop មួយចេញមក ។ ពូវៃក៏សួរទាំងត្រេកអរ :

- អីយ៉ាឥលូវឯងចូលរៀនវិញហើយឬខេវិន? បានជាកាន់LapTop តាម ជាប់ខ្លួនយ៉ាងនេះ?

- អត់ទេ! គឺទិញមកផ្ញើមីងពូតើហ៎!

- ងាប់! ពូមីងឯងនេះសរសេរតែឈ្មោះខ្លួនឯងមិនត្រូវផង រឿងអីទៅចេះ ប្រើComputer ដែរនោះហ្អាំស?

- រៀនលេងៗទៅណាំពូ ក្រែងចេះ ។

រំពេចនោះមីងចាន់យកកាដូមកហុចអោយ :

- នេះជាវត្ថុអនុស្សាវរីយ៍ពីមីងពូ ហើយមួយនេះមកពីនិសា

- និសាដឹងថាខ្ញុំមានខួបកំណើតថ្ងៃនេះដែរ? (ខេវិនឧទានទាំងភ្ញាក់)

- ថីមិនដឹង! (មីងឆ្លើយ) តែអាល័យមានការប្រញាប់នៅក្រសួងទើបមិន បាននៅជូនពរដោយផ្ទាល់បាន ។

ខេវិនលើកដៃទទួលយកមក ហើយក៏ទាញអាវរងាមកពាក់ ។

- ប្រញាប់ទៅវិញម្ល៉េះខេវិន? (ពូវៃសួរ)

- ខ្ញុំសុំគេឈប់សំរាកបានតែម៉ាភ្លែតទេ ដល់ម៉ោងត្រូវធ្វើការវិញហើយ ។

CHANBOKEO.COM

- អូហ៏ ឥលូវឯងធ្វើការហើយហ្អែស? ( មីងពៅលាន់មាត់)

តែខេវិនមិនឆ្លើយទេ។ នាយក៏លូកក្នុងហោប៉ៅអាវរងាទាញយកកាត

សំរាប់ជិះឡានក្រុងចេញមក ស្រាប់តែជ្រុះផ្កាកុលាបក្រៀមមួយក្នុក ទៅ លើកំរាលផ្ទះក្បែរមាត់ទ្វារ។

ពេលនោះខេវិនមិនបានចាប់ភ្លឹកទេ។ ចំណែក មីងពៅពូវៃក៏មិនបានចាប់ភ្លឹកដែរ។ នាយយើងក៏ដើរចេញទៅ។

**ពីរម៉ោងក្រោយមក...**

បុគ្គលិកសមាគមខ្មែរម្នាក់បានបរឡានជូននិសាដល់ផ្ទះ ហើយក៏បរ ចេញទៅ។

និសាបើកទ្វារចូលមកស្រាប់តែដើរជាន់លើបន្លាផ្កាកុលាប ក្រៀមមួយទងដែលជ្រុះនៅមាត់ទ្វារ។ នាងក៏ឱនរើសកាន់បំរុងយកទៅ

ចោលនៅក្នុងធុងសំរាមឯផ្ទះបាយ ស្រាប់តែមីងពៅក្រលេកឃើញហើយ ក៏សួរឡើងថា :

- ចុះពីណាគេចំលែកម្ល៉េះ ទិញផ្កាក្រៀមផ្ញើក្មួយនិសា?

- មិនមែនទេមីង! គឺខ្ញុំដើរជាន់វាមុតជើងឯមាត់ទ្វារទើបរើសយកចោល

- ហ្អាក? មីងពូមិនដែលទិញផ្កាផង ម៉េចក៏ផ្ទះយើងមានផ្កា?

និសាក៏បោះផ្កាក្រៀមចូលក្នុងធុងសំរាម ស្រាប់តែផ្លាកដែលចងនៅ

កផ្កាក៏ក្រលាប់ឡើងចេញអក្សរល្អិត១ចារលើនោះជាភាសាអង់គ្លេស។ នឹក

ឆ្ងល់ពេក និសាក៏រើសយកមកអានលេង :

- Thanks for being so thoughtful of me. Smile.

និសាភ្ញាក់ព្រើតតែម្តង។ ប៉ុន្តែលើក្រដាសនោះគ្មានស៊ីញ៉េឈ្មោះទេ

ឃើញតែគំនូររូបព្រះអាទិត្យដែលកំពុងញញឹមរីករាយប៉ុណ្ណោះ។ និសានឹក ភ្នកឃើញអីម្យ៉ាង ក៏រើសផ្កាយកទៅក្នុងបន្ទប់។

ពូវៃមីងពៅសំលឹងតាម ទាំងងឿងឆ្ងល់ថាហេតុអ្វីនិសាបោះផ្កាចោលហើយរើសយកមកវិញ។ នៅ ក្នុងបន្ទប់

និសាយករូបគំនូរព្រះអាទិត្យញញឹមនៅលើផ្កាកុលាប និងគំនូរ មួយទៀត ដែលនៅលើបាច់ផ្កាដែលនាងយកមកពីមន្ទីរពេទ្យ

មកដាក់ ផ្ទៀបគ្នាឃើញដូចគ្នាបេះដាក់ បានន័យថាជាគំនូរដៃតែមួយ។ រីឯអក្សរ

ដែលសរសេរទៀតសោតក៏ជាស្នាដៃមនុស្សតែមួយដែរ។ ធិតាក៏ចាប់ភ្លឹក ភ្លាមថាម្ចាស់ផ្កាជានរណាហើយ។

លុះធិតាចេញពីបន្ទប់មកវិញ ស្រាប់តែពូវៃហៅ :

- និសា! ណេះ យកអា Computer មួយនេះទៅប្រើទៅ!

- ពូទើបតែទិញឱ្យខ្ញុំមួយថ្ងៃមុនសោះ ឥលូវទិញមួយទៀតហើយ?

- ព្រោះអាមួយនេះវាល្អជាងមុនណា៎ ( ពូវៃឆ្លើយ)

- និសាកុំជឿ! ការពិត Computer មួយនេះជារបស់ខេវិនទេ។ គេបាន ទិញមកអោយពូវារៀន។

មីងពៅឆ្លើយឡើង។ ពូវៃក៏សើចខឹក១ :

- ទិញអោយពូរៀនស្អី? អាវិនវាចង់ទិញអោយនិសាហ្នឹងណា៎ តែវាអៀន

CHANBOKEO . COM

ដៃមិនហ៊ានហុចអោយនិសាដោយផ្ទាល់ បានជាវាប្រើដៃពូជំនួស ។

- យី! ម៉េចក៏ពូវាឯងដឹង? ( មីងពៅសួរ)

- ចឹមិនដឹង ! កាលខ្ញុំញ៉ែមីងវាឯងពីក្មេង ក៏ប្រើអាក្បួនកាច់កុងហ្នឹងដែរ ។

ថាហើយពូវើក៏សើចកក្អឹកលើសដើម ។ មីងពៅសំលក់ពូ រួចហើយក៏បែរមកលើក Computer ហុចអោយទៅនិសា :

- និសាយកទៅប្រើទៅ មីងពូមិនដឹងទុកធ្វើអីទេ ។

- អរគុណពូ! អរគុណមីង!

និសាទទួលហើយ ក៏លើកទៅដាក់នៅលើតុរៀនក្នុងបន្ទប់គេងរបស់ នាងហើយក៏ចុចកុងតាក់បើក Computerបំរុងប្រើ ស្រាប់តែឃើញកាត១ មានរូបព្រះអាទិត្យរះញញឹម សៀតនៅចន្លោះ Computer នោះទៀត ហើយ ។ នាងក៏ឧទានខ្សិបៗថា :

- ខេរិន! ហេតុអ្វីក៏អ្នកធ្វើអ្វីៗ ដើម្បីខ្ញុំម្ល៉េះ?...

ពេលនេះ ចិត្តាក៏រឹតតែចាប់អារម្មណ៍លើខេរិនកាន់តែខ្លាំងឡើងដែរ...

និយាយពីខេរិនម្តង...

មកដល់ផ្ទះវិញ ខេរិនក៏បើកប្រអប់កាដូរបស់និសាមើលភ្លាម ស្រាប់ តែឃើញនាឡិកាដៃរបស់នាយនៅក្នុងនោះ ។ ខេរិនក៏ទាញកាតមួយសន្លឹក ដែលចារជាភាសាអង់គ្លេសមកអាន មានសេចក្តីថា :

*- អ្នកគឺទេវតាមួយអង្គ ដែលយាងមកប្រោសជីវិតអោយខ្ញុំផុតគ្រោះភ័យ! អរគុណណាស់! បើមានឱកាស យើងទៅវត្តធ្វើបុណ្យជុំគ្នាម្តងបានទេ ដើម្បីអោយខ្ញុំមានឱកាសអរគុណអ្នកដោយផ្ទាល់... និសា...*

*បន្ថែម: ពេលបុគ្គលិកពេទ្យគេយកសំពៀតខោវមកឱ្យ ខ្ញុំក៏បានប្រទះ នាឡិការបស់អ្នកជ្រុះនៅក្នុងសំពៀត ទើបខ្ញុំសូមផ្ញើមកសងជូនវិញ ។*

ប្រយោគនិសាដ៏មានន័យ បានធ្វើអោយខេរិនញញឹមឡើង :

- និសា! ម៉េចនាងដឹងថា នាឡិកាមួយនេះជារបស់ខ្ញុំ? ឬក៏... នាងកំពុង ចាប់អារម្មណ៍អំពីរូបខ្ញុំ ដូចខ្ញុំចាប់អារម្មណ៍ចំពោះនាងដែរ?

ខេរិនអារម្មណ៍ពិភាល់ណាស់ដែរថា ហេតុអ្វីបានជាខ្សែជីវិតរបស់នាយ ចេះតែមានជំពាក់ខ្សែគ្នាជាមួយនិសាម្លេះ ។ រួចពេលណាដែលនាងសរសេរ មកនាយម្តងៗ សំដីរបស់នាងតែងធ្វើអោយនាយមានអារម្មណ៍ត្រជាក់ ស្ងប់ក្នុងចិត្តហើយរីករាយជានិច្ច ។ ម្យ៉ាងទៀត ពេលនាយនឹកដល់និសា ពេលណា ខេរិនតែងនឹកឃើញទៅដល់រូបព្រះអាទិត្យរះញញឹមពព្រាយនិង ពាក្យថា Smile!! ដែលនិសាធ្លាប់សរសេរតបមកនាយ ពេលនោះ ស្រាប់ តែនាយញញឹមតែម្តងដោយឯកឯង ហើយក៏មានអារម្មណ៍ថាពិភពលោក ជុំវិញខ្លួនហាក់ដូចជាមានពន្លឺរស្មីពណ៌ភ្លរាយយ៉ាងត្រកាលទៀតផង ។

ចាប់តាំងពីពេលនោះមកខេរិនតែងតែឡើងជិះរថយន្តក្រុងទៅផ្ទះមីង ពៅស្ទើរតែរាល់ថ្ងៃ តែលុះទៅដល់ហើយបែរជាមិនហ៊ានដើរចូល គ្រាន់តែ ឈរអើតអើមៗពីចំងាយហើយក៏ឡើងឡានក្រុងត្រលប់មកវិញ ។ រីឯនិសា

CHANBOKEO.COM

ក៏បានប្រទះក្រសែភ្នែករបស់នាយពីចំងាយជាញយដងដែរ តែឆ្ងល់ណាស់ ដែលខេវិនមិនព្រមចូលលេងសោះ ។ ការពិតខេវិនចង់ជួបនាងណាស់ដែរ តែលុះដល់ប្រទះនឹងក្រសែភ្នែករបស់និសា ខេវិនចេះតែញាប់ញ័ររន្ធត់ក្នុង ចិត្តខុសធម្មតា ។ ម្យ៉ាងទៀត នាយមិនធ្លាប់មានសំដីទន់ភ្លន់ដាក់នរណាផង ម្ល៉ោះហើយ មិនដឹងថាត្រូវធ្វើដូចម្ដេចទើបសម... ក៏ចេះតែគេចវិញទៅ ។

**ថ្ងៃ២០សីហា ២០០៥...**

ថ្ងៃនេះ នៅវត្តមិនីសូតាមានប្រារព្ធពិធីបុណ្យខួបវត្ត ដោយមានការ សំដែងសិល្បៈ មានលក់ដូរទំនិញ និងវត្ថុអនុស្សាវរីយ៍ ដោយមានប្រជា ពលរដ្ឋខ្មែរមកចូលរួមរាប់រយពាន់ ។ តាមទំលាប់ អ្នកស្រុកតែងតែចូល អុជធូបនៅបុស្បុក ដែលមានតំកល់ព្រះពុទ្ធបដិមារយ៉ាងធំអស្ចារ្យមួយ សង់នៅកណ្ដាលធ្លាមុខវត្ត ដើម្បីឧទ្ទិសជូនបុព្វការីជន ។ និសាក៏តម្រង់ជួរ ព្រមជាមួយពុទ្ធបរិស័ទដ៏ណែនណាន់ខ្នាន់ខ្នាប់ ។ ស្រាប់តែនាងហាក់ដូចជា មានអារម្មណ៍មានមនុស្សម្នាក់មកឈរក្បែរ ។ នាងក៏ងើបមុខឡើងបែរ មើល ស្រាប់តែនាងឧទានឡើងថា :

- ព្រះអើយ! ស្មានថាអ្នកមិនមកហើយតើហ៎?

មែន! ការពិតគេនោះគឺជាខេវិន ដែលនិសាទន្ទឹងរង់ចាំជួបជាយូរថ្ងៃ មកហើយ ។

- ព្រោះតែនិសា... ទើបខ្ញុំដាច់ចិត្តមកអុជធូប.... ជាលើកដំបូង ( ខេវិន ឈ្ងោកខ្សិបតិចៗតបទៅនិសាវិញ)
- និសាត្រេកអរណាស់ដែលអ្នកអាចមកបាន ( និសាស្រដីទាំងញញឹម)

ខេវិននៅស្ងៀម រកពាក្យអ្វីមកនិយាយមិនចេញតទៅទៀតសោះ ។ អណ្ដាតនាយហាក់ដូចជារឹងកកអស់តែម្ដង កាលបើបានជួបភក្ត្រនិសា ។ ហេតុអីទៅហ្ន៎ ដែលស្រីក្មេងចំលែកម្នាក់ មើលទៅធម្មតាៗ មិនស្រស់ស្អាត ទាល់តែសោះ កាត់សក់តែងខ្លួនជាកូនសិស្សរបៀបបុរាណៗបន្តិច ប៉ុន្តែបែរ ជាមានឥទ្ធិពលអង្រួនបេះដូងរបស់នាយឱ្យញាប់ញ័ររណ្ដំដល់ម្លឹង ។ និសា បេះធូបបីសរសៃហុចឱ្យទៅខេវិនរួចវាចាថា :

- សូមអ្នកអធិដ្ឋានទៅហើយក្លិនធូបនេះនឹងទៅជំរាបប្រាប់ជូនតាថា អ្នក កំពុងនឹកលោកណាស់ ហើយលោកនឹងចុះមកជូនពរ អោយអ្នកបានជួបតែ សេចក្ដីសុខជានិច្ច ។

ប្រយោគនេះមានន័យទូលំទូលាយមែន ។ ខេវិនឮហើយក៏ញញឹម រួច លូកដៃទទួលយកធូបភ្លាម ។ រីឯនិសាក៏លើកធូបឡើងវាចាថា :

-នាងខ្ញុំនិសា សូមឧទ្ទិសកុសលមគ្គផលទាំងឡាយ ជូនអ្នកមានគុណទាំង អស់ ទោះបីលោកបានចែកឋានទៅហើយឬលោកនៅមានជីវិតក្ដី...

និសាឈប់ង៉ក់បែរមើលខេវិន ទំនងជាចង់អោយនាយទទួលដឹងថា នាងកំពុងមានវាចាសំដៅដល់នាយដែរ រួចហើយក៏ពោលបន្តថា:

- សូមលោកបានប្រកបតែបរមសុខនិងសេចក្ដីសុខតរៀងទៅ ។

រួចហើយនិសាក៏ក្រាបសំពះបីដង ។ ខេវិនក៏ធ្វើតាមដូចគ្នាដែរ ។ នៅឯ ខាងលើវិហារ ពូវៃនិងមីងពៅញញឹម កេះគ្នាលួចមើលមកអ្នកទាំងពីរ ពីចំងាយ ។ ពូវៃលាន់មាត់ថា :

CHANBOKEO.COM

- ហេតុអីបានជាខេវិនវាចេះមកវត្តដោយមិនបាច់ហៅ ថែមទាំងចេះអុជ ធូបថ្វាយបង្គំព្រះទៀតផង?

- ប្រហែលមកពីខេវិន បានរកឃើញភាពកក់ក្តៅនៅក្នុងបេះដូងរបស់គេ ហើយទេដឹង?

- មែនហើយ!... បើខេវិនអាចផ្លាស់ប្តូរជីវិតមកសុក្រិតវិញបានពិតមែន យើងទាំងពីរត្រូវតែត្រលប់ទៅស្រុកវិញធ្វើបុណ្យ៧វត្តហើយ ។

ថ្ងៃនោះ ពិតមែនតែខេវិននិយាយស្តីជាមួយនិសា បានតែមួយឃ្លា ហើយមិនទាំងហ៊ានសំលឹងមុខនាងផងតែនាយដូចជាមានអារម្មណ៏រីករាយក្រៃលែងថែមទាំងសំដែងភាពញញឹមនៅលើផ្ទៃមុខខុសប្លែកធម្មតា ។

ចាប់តាំងតែពីថ្ងៃនោះមក...

ខេវិនហាក់ដូចជាចាប់ផ្តើមណាយ នឹងជីវិតដែលពាក់ពន្ធ័ទៅនឹងសង្គម អាភៀនមួយថ្ងៃបន្តិច១ ។ មិនតែប៉ុណ្ណោះ គេបានទៅលួចរកការធ្វើមិនឱ្យ ពូមីងដឹង ដើម្បីទិញបញ្លើផ្សេង១ផ្ញើនិសាតាមរយៈពូមីងទៀតផង ។ ហេតុ អ្វីនាយយើងធ្វើដូច្នេះ? ខេវិនមិនយល់ចិត្តខ្លួនឯងឡើយ ។ ចំពោះផល្លីនវិញ មានតែផល្លីនទេដែលផ្គាប់ចិត្តខេវិនជានិច្ច ។ ឯរឿងដែលថាខេវិនទៅញ៉ាំញីញ៉ាំញ៉ីនឹងផល្លីនគឺគ្មានសោះឡើយ ។ ពេលនេះហេតុអ្វីនាយបែរជាទៅចាប់អារម្មណ៏ពីនារីចំណូលថ្មីម្នាក់ដែលនាយទើបតែស្គាល់យ៉ាងស្រពេចស្រពិល ដូច្នេះទៅវិញ? ខេវិនជាមនុស្សរសំដីតិច ហើយត្រមាត់ត្រមុយតាំងពីក្មេង មិនដែលចេះញញឹមដាក់នរណាម្នាក់ទេ តែពេលនេះ ពូវៃមីងពៅសង្កេត ឃើញថា ទោះបីខេវិនមិនសូវស្រដីក៏ពិតមែន តែឃើញនាយចេះញញឹម ស្រស់ស្រាយហើយដូចជាទន់ភ្លន់ជាងមុនច្រើនណាស់ ជាពិសេសពេលគេ បានជួបនិសាម្តង១...

៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩

៩

CHANBOKEO.COM

# វគ្គទី៩

# បេះដូងវង្វេងស្នេហ៍

ពេលថ្មីៗនេះ ខេវិនបានទៅធ្វើការនៅរោងចក្រ សន្សំលុយទិញបាន ឡានកញ្ចាស់មួយ  គ្រាន់នឹងហាក់ទៅហាក់មករវាងផ្ទះនាយ នឹងផ្ទះមីង ពៅ ។ ចំណែកមីងពៅពូរ៉ៃក៏សង្កេតឃើញដែរថា ខេវិនហាក់ដូចជាអើតមុខ អើតមាត់មកផ្ទះគាត់ញឹកញាប់ខុសធម្មតាដែរ ទោះបីពេលខ្លះ នាយគ្រាន់ តែអើតមិនបានពីរនាទីក៏ដោយ ជួនកាលមិនទាំងនិយាយអ្វីផង គ្រាន់តែ មកដល់ហើយក៏ចេញទៅវិញដោយឥតហេតុផល ។ ចាស់ៗទាំងពីររូបហាក់ ដូចជាចាប់ភ្លឹកអំពីកិរិយាខេវិនកាន់តែខ្លាំងឡើងៗ...

**ថ្ងៃ ២២សីហា ២០០៥**

រ៉ុងៗ ទូរសព្ទ័រោទិ៍ឡើង...

- មីងពៅមែនទេហ៎? នេះជាទូរសព្ទ័ពីរោងចក្រ័ ជំរាបថា ខេវិនមានគ្រោះ ថ្នាក់នៅកន្លែងធ្វើការ ឥលូវយកទៅមន្ទីរពេទ្យហើយ ។

មីងពៅឮហើយក៏រត់ផាស់ដៃផាស់ជើង    ហៅពូរ៉ៃនិងនិសាទៅមើល នាយភ្លាម ។ ការពិតខេវិនបានរងរបួសដោយសារមានការផ្ទុះអាគារដោយ ឧប្បដិហេតុមួយតែនាយត្រូវបានគេសង្គ្រោះទាន់ពេល ។

នៅក្នុងមន្ទីរពេទ្យ  WoodWind Hospital...

ខេវិនគេងស្តូកស្តឹងនៅលើគ្រែ ដោយមានដាក់ម៉ាស៊ីនអុកស៊ីសែនជួយ ដង្ហើមផង ជួយបេះដូងផង ។ មីងពៅភិតភ័យរហូតដល់យំលែងឮ ។ ពូរ៉ៃក៏ នាំគាត់ត្រលប់ទៅផ្ទះវិញទុកឱ្យនិសានៅកំដរ ។ ប៉ុន្តែខេវិនរបួសធ្ងន់ណាស់ គេងបាត់ស្មារតីដល់ទៅ៨ថ្ងៃទើបដឹងខ្លួនមកវិញ ។ និសាតែងតែទៅកំដរ នាយមិនដែលខានរាល់ពេលនាងចេញពីសាលា ។

**ថ្ងៃ ៣១សីហា ២០០៥**

- និសា.... （ខេវិនប្រែខ្លួនឡើងឧទានខ្សិបៗ)
- បងនិយាយថាម៉េចខេវិន?
- និសា...
- នរណាជានិសា? ប្រាប់ផល្លីនម្តងទៀតមើល៍?

CHANBOKEO.COM

ផល្លីនឈ្ងោកដាក់ត្រចៀកផ្ទិបនឹងមាត់នាយផ្ទៀងស្ដាប់ស្រាប់តែនាយ ឈប់ពោលតទៅទៀត ។ ផល្លីនក៏លាន់មាត់ :
- ពុទ្ធោអើយ! បាត់ដំណឹងប៉ុន្មានថ្ងៃ ស្រាប់តែដល់ដឹងថ្ងៃនេះ បែរជាមក ឃើញនៅក្នុងពេទ្យហើយគេងដូចមនុស្សស្លាប់អញ្ចឹងទៅ? ខេរិន!ឆាប់ ដឹងខ្លួនឡើងមើល៍... អីក៏ទន់ខ្សោយម្ល៉េះ? ដឹងទេហ៏ថាខ្ញុំអផ្សុកណាស់ កាលបើ អត់មានខេរិនកំដរ ។

ផល្លីនដើរទៅដើរមកមួយស្របក់ ទ្រាំមិនបានក៏ចេញទៅ ។ ប្រហែល ជាមួយម៉ោងក្រោយមក និសាក៏មកដល់ ។ ភ្លាមនោះធិតាចាប់ភ្លឹកថាខេរិន កំរើកមាត់កំរើកដៃបានហើយ ។ នាងត្រេកអរណាស់ ក៏យកដៃទៅស្ទាប ទ្រូងខេរិនហើយវាចាខ្សិប១ ទៅនាយថា :
- ខេរិន! យើងទាំងអស់រង់ចាំខេរិនអោយភ្ញាក់ពីដំណេកមកវិញ ។ យើង បារម្ភពីអ្នកណាស់ សូមអ្នកឆាប់ដឹងខ្លួនឡើងណា៎! បើអ្នកអាចញញឹមបាន ជីវិតយើងគ្រប់គ្នានៅទីនេះនឹងទទួលនូវភាពស្រស់បំព្រងបំផុត ។

ស្រាប់តែខេរិនហើបមាត់ខ្សិប១តិច១:
- និសា...

និសាឮហើយត្រេកអរណាស់ក៏ញញឹមឡើង :
- និសានេះទីនេះហើយ! ខេរិន អ្នកដឹងខ្លួនហើយ! ខ្ញុំសប្បាយចិត្តណាស់ ។

និសាក៏ស្ទុះរឹងទៅទូរសព្ទ័ប្រាប់មីងពៅពូវីរ៉ៃភ្លាម ។

ខេរិនបើកភ្នែកឡើង ឃើញមុខពូវីរ៉ៃនិងមីងពៅទាំងស្រពេចស្រពិល - ខេរិន! មីងពូត្រេកអរណាស់ដែលឯងផុតគ្រោះថ្នាក់ ។

ខេរិនបែររកមើលជុំវិញខ្លួនហើយសួរថា :
- និសាមកទេ?
- និសាគេទើបត្រលប់ទៅរៀនអំបាញ់មិញនេះ ។ កុំខកចិត្តអីណា៎ ការពិត និសាមកកំដរឯង៨ថ្ងៃជាប់១គ្នាហើយ ។

ខេរិនហាក់ដូចជាស្រពាប់ស្រពោនយ៉ាងណាមិនដឹង ពេលមិនបាន ឃើញនិសានៅទីនោះ ។ ថ្វីបើនាយមិនសូវជិតដិតស្និទ្ធស្នាលជាមួយនិសា ក៏ដោយ ប៉ុន្តែ... នៅក្នុងជំរៅចិត្តរបស់នាយ និសាគឺជាមនុស្សដែលនាយ ចាប់អារម្មណ៏ជាងគេបំផុត ។ ខេរិនមិនដែលមានមិត្តទេ ក្រៅពីផល្លីនសំដី ចច្រិចមួយរូបនោះ ។ គេទៅមកនឹងគ្នាក៏ព្រោះគេជាអតិតក្មេងកំព្រាធ្លាប់ នៅជំរំជាមួយគ្នា មានប្រវត្តិជូរចត់ប្រហាក់ប្រហែលគ្នា តែផល្លីនជាមនុស្ស រហ័សរហួនខុសពីខេរិនដែលទុយមុយធ្មឹងថ្មៃបំផុត ។ ក្រៅពីនោះខេរិនមិន មាននរណាឡើយ ព្រោះគេអាចទ្រាំបាននឹងឫកពាដ៏ត្រមាត់ត្រមុយគោក១ របស់នាយឡើយ ។ រីនិសាវិញគឺជាមនុស្សដំបូងបង្អស់តែម្នាក់ដែលខេរិន ចាប់អារម្មណ៏បំផុត ព្រោះនាងតែងតែយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់ នាយជានិច្ច ទោះបីជាពេលខ្លះ នាយគំរោះគំរើយដាក់នាងបន្តិចក៏ដោយ ក៏និសាតែងតែធ្វើអីមួយប្លែក១ឱ្យខេរិនញញឹមឡើងវិញបានរហូត ។

បន្តិចមក ពូមីងក៏នាំគ្នាចេញទៅបាត់ ។ ខេរិននៅរង់ចាំមើលផ្លូវនិសា ឡើងផ្សាភ្នែកអស់ហើយ ។ ព្រលប់ងងិត ទើបមាណពឃើញនិសាមកដល់ គ្រាន់តែក្រលេកឃើញវ៉ែនតាក្រាស់១មួយគូ ក្រោមសក់សេះខ្មៅរលើប ខេរិនក៏ចាំបានភ្លាមថា នោះគឺជាមនុស្សដែលបេះដូងរបស់នាយកំពុងតែ ដង្ហោយហៅរកគ្រប់ពេលវេលា :

CHANBOKEO.COM

- និសា!... (ខេវិនខ្សឹបតិចៗក្នុងមាត់ហៅរកនិសា)

និសាញញឹមឡើង បញ្ចេញថ្ពាល់ខួចទំនងហាក់ដូចជារំភើបចិត្តយ៉ាង ខ្លាំងដែលឃើញខេវិនហៅឈ្មោះរបស់នាងជាញឹកញាប់ ។ ថ្វីបើធិតាយើង មានឫកពាទំនងមិនជាស្និទ្ធស្នាលនឹងខេវិនក៏ដោយ ក៏កិរិយាបថរបស់នាង បានបញ្ជាក់ថាប្រាប់យ៉ាងជាក់ច្បាស់ណាស់ថា នាងក៏បារម្ភអំពីខេវិនមិនតិច ដែរ ។ រំពេចនោះ ខេវិនលើកដៃឡើងទំនងសុំកាន់ដៃនិសា ។  ធិតាមាន កិរិយាអេះអុញមួយស្របក់ ទើបដាច់ចិត្តហុចដៃរបស់នាងអោយខេវិន កាន់ ។ មាណពទទួលហើយក៏ក្ដាប់យកទៅដាក់នៅលើដើមទ្រូងរបស់នាយ ហើយ ក៏ធ្មេចនេត្រាសំងំគេងទៅវិញ ។ គ្រានោះ ខេវិនមានអារម្មណ៍ថា បេះដូងរបស់នាយបានទទួលនូវការកក់ក្ដៅ ហើយស្ងប់សុខបំផុតក្នុងជីវិត ជាលើកដំបូង ។ និសានៅអង្គុយឈ្ងោកមុខធ្វើអៀនៗ ត្បិតមិនដែលមាន បុរសណាមកកាន់ដៃនាងសោះពីមុនមក ។ ចៃដន្យ នៅក្នុងបន្ទប់ព្យាបាល មានតែរូបនាងនិងខេវិន កុំអីមិនដឹងជាខ្មាសគេយ៉ាងណាទេ បើសិនជាគេ មកឃើញខេវិនគេងកាន់ដៃរបស់នាង ។ ម្យ៉ាងទៀត នាងក៏មិនយល់ដូចគ្នា ដែរ ថាហេតុអ្វីនាងចាប់អារម្មណ៍ចំពោះខេវិនខុសប្លែកធម្មតាដូច្នេះ ។

**ថ្ងៃ១២កញ្ញា២០០៥**

ថ្ងៃនេះ ពូរ៉េ មីងពៅ និងនិសា បានប្រញាប់ប្រញាល់ទៅទទួលខេវិន ដែលបំរុងចេញពីមន្ទីរដើម្បីទៅសំរាកព្យាបាលនៅផ្ទះ ។ មកដល់មន្ទីរពេទ្យ អ្នកទាំងបីខកចិត្តស្លុក ត្បិតលោកគ្រូពេទ្យប្រាប់ថា ផល្លីនបានមកទទួល នាយចេញទៅមុននោះប្រហែល១០នាទី ។ ទាំងបីនាក់មើលមុខគ្នាទៅវិញ ទៅមកត្បិតមិនដឹងថាទៅតាមរកខេវិននៅឯណា ។ អ្នកទាំងបីវិលមកផ្ទះ វិញទាំងខកចិត្ត ។ ពេលនោះ ពូរ៉េមីងពៅបានសង្កេតឃើញថា និសាហាក់ ដូចជាស្រងូតស្រងាត់ណាស់ កាលបើខេវិនបាន ចាកចេញទៅដោយគ្មាន ដំណឹង ។ មែនហើយ និសានឹកបារម្ភពីខេវិនក្រៃលែង ចង់ទៅរកបុរសយើង ដល់ផ្ទះតែមិនដឹងថាទៅរកនាយនៅឯណាឱ្យឃើញទេ ត្បិតនាយមិនដែល ប្រាប់នាងម្ដងណាឡើយ ថាគេរស់នៅឯណា ។

**ថ្ងៃបុណ្យភ្ជុំ២០០៥** នៅវត្តមិនីសូតារាម...

ថ្ងៃនេះ វត្តខ្មែរប្រារព្ធពិធីយ៉ាងមហោឡារិកណាស់ តាំងពីព្រហាម រហូតព្រលប់យប់ជ្រៅ ។ ដោយមាននិស្ស័យជាពុទ្ធបរិស័ទ និសាមិនដែល ភ្លេចមុខនាទីជាកូនចៅធ្វើបុណ្យឧទ្ទិសកុសលជូនបុព្វការីជនឡើយ ។ ព្រឹក នេះ នាងបានទៅអង្គុយនៅបុស្បុករង់ចាំមើលក្រែងខេវិនគេអាចមកចូល រួមពីធីបុណ្យភ្ជុំនឹងគេ តែចាំបាត់...ចាំបាត់... ធិតាហាក់ដូចជាមានអារម្មណ៍ រសេះរសោះដៃជើងយ៉ាងណាមិនដឹង ។ ព្រលប់បន្តិច ធិតាក៏ទៅជួយបោស សំអាតសាលាឆាន់ជាមួយស្រីក្មេងៗពីរបីនាក់ទៀត ស្រាប់តែដាក់ភ្នែក ក្រលេកទៅក្រៅឃើញមានស្រមោលបុរសម្នាក់ឈរនៅស្ងៀមស្ងាត់តែឯង ឯខាងមុខបុស្បុក ។ នាងនឹកសង្ស័យក្នុងចិត្តក៏ទំលាក់កិច្ចការចុះ រួចហើយ ដើរយ៉ាងលឿនសំដៅទៅរកបុរសនោះ ។

- ខេវិន? ... (ឆវីលាន់មាត់ហៅតិចៗ)

CHANBOKEO.COM

មែនហើយ គេគឺជាខេវិនមែន ។ គ្រាន់តែក្រលេកឃើញនិសាភ្លាម ខេវិនក៏ញញឹមឡើងយ៉ាងបំព្រង ហើយស្ទុះយកឈើច្រត់ដើរទប់ខ្លួនមករក នាងទាំងតតេះតតះ ។ និសាឈរធ្វើភាំង ត្បិតមិននឹកស្មានថានាងនឹងបាន ជួបខេវិននៅថ្ងៃនេះឡើយ ។ ធិតាយើងញញឹមឡើងទាំងចិត្តញាប់ញ័រ :

- ខ្ញុំសប្បាយចិត្តណាស់ដែលខេវិនមកបាន!
- និសា! I miss you! I really do!

ខេវិនថាហើយ ក៏ស្រាប់តែស្រវាអោបនិសាយ៉ាងណែនពេញរង្វង់ដៃ ។ ស្រាប់តែនិសាឧទានឡើងថា :

- ខេវិន! នេះជាវត្តអារាម! សូមអ្នកកុំធ្វើដូច្នោះអី មិនសមរម្យទេណា៎!

ឮដូច្នោះ ខេវិនក៏ប្រញាប់ដកខ្លួនថយវិញយ៉ាងរហ័សរួចហើយក៏ចាប់ ដៃនាងអោយអង្គុយនៅក្បែរនាយលើកាំជណ្តើរបុស្បុក រួចវាចាថា :

- និសា! ខ្ញុំសូមទោសណា៎ដែលមកធ្វើបុណ្យយឺតពេល
- មិនអីទេ... អោយតែចិត្តនឹកអំពីបុណ្យ អ្នកក៏បានទទួលកុសលដែរណា៎

ពេលនោះ ថ្ងៃលិចទៅហើយ ។ នៅឯទីធ្លាលើខ្នងទួលមុខព្រះវិហារដ៏ ស្កឹមស្កៃ មនុស្សម្នាកកកុញបានមកកំសាន្តពិធីបុណ្យ ដោយមានការលក់ ដូររបស់របរផ្សេងៗចំណីចំណុកប្លែកៗ និងជាពិសេសគឺការសំដែងសិល្បៈ រាត្រីសមោសរដែលមានអ្នកចំរៀងខ្មែរ គឹងសុរិយា និងអ្នកចំរៀងប្រចាំរដ្ឋ មិនីសូតា ច្រៀងផ្គោះផ្គងគ្នាយ៉ាងសប្បាយរីករាយទៀតផង ។ ប៉ុន្តែ គ្មាន នរណាម្នាក់ចាប់ភ្លឹកនឹងវត្តមានរបស់និសានិងខេវិន ដែលអង្គុយស្ងៀម ស្ងាត់នៅឯខាងមុខបុស្បុកឡើយ ។ ខេវិននៅស្ងៀមមួយស្របក់ក៏សួរថា :

- និសា! សុខសប្បាយទេហ៎?
- ចាំស ធម្មតា! ប៉ុន្តែគួរតែខ្ញុំវិញទេដែលត្រូវសួរខេវិនថាសុខទុក្ខយ៉ាងណា ហើយពេលនេះ?

ខេវិននៅស្ងៀម ។ និសាក៏ពោលបន្ត :

- អ្នកដឹងទេហ៎ ពូមីងគាត់បារម្ភពីអ្នកណាស់ ។ ព្រឹកមិញ គាត់បានប្រស់ទឹក ឧទ្ទិសសូមអោយអ្នកឆាប់ជាសះស្បើយផង ។

ស្រាប់តែខេវិនបែរមកសួរនាងវិញ:

- ចុះនិសាឧទ្ទិសអ្វីដល់ខ្ញុំទេ?
- ចាំស! និសាបានឧទ្ទិសបន់សូមអោយអ្នកបានធ្វើបុណ្យជុំគ្នានៅទីនេះ...
- ឥលូវបំណន់របស់និសាបានក្លាយជាការពិតហើយ ព្រោះខេវិនក៏បានមក ដល់ទីនេះមែន...
- តែ.. យឺតបន្តិច...!
- យឺត ក៏គង់ប្រសើរជាក់អាក់ខានរហូតដែរ មិនមែនទេ?

CHANBOKEO.COM

និសាញញឹមឡើង កាលបើឮខេរិននិយាយដូច្នោះ ។ ភ្លាមនោះខេរិនក៏ លូកដៃមកចាប់ដៃនិសាស្រវាកាន់ជាប់យ៉ាងណែន តែមិនឮនាយស្រដីអ្វី តទៅទៀតទេ ។ ពេលនោះ និសាក៏រកនឹកអ្វីមកសន្ទនាទៀត មិនឃើញដូច គ្នាដែរ ។គេទាំងពីរក៏អង្គុយញញឹមដាក់គ្នាទៅវិញទៅមកទាំងឱរាញាប់ញ័រ ក្រៃលែង ហើយក៏គ្មាននរណាសួរនរណាតទៅទៀតដែរ គ្រាន់តែគេដឹងថា ខ្លួនគេកំពុងជាប់ឃុំនៅក្នុងចំណងសំណាញ់នៃសេចក្តីស្នេហា យ៉ាងជ្រាល ជ្រៅក្នុងបេះដូងចំពោះគ្នាទៅវិញទៅមក ។

**ថ្ងៃ ២៥វិច្ឆិកា ២០០៥**

ថ្ងៃនេះ នៅអាមេរិក គេធ្វើបុណ្យ Thanksgiving ដើម្បីរំលឹកគុណ កុលសម្ពន្ធ័ម្ចាស់ដី ដែលបានជួយស្រោចស្រង់ជីវិតពួកស្បែកសអោយផុតពី សេចក្តីស្លាប់នាគ្រាមួយនៅអតីតកាល ។ ក្រុមគ្រួសារមីងពៅក៏ប្រារព្ធនឹង គេដែរ ។ និសាចេះតែលួចដកកសំលឹងតាមបង្អួចទៅក្រៅ ។ ពូវៃសង្កេត ឃើញដូច្នោះក៏កេះមីងពៅតែគាត់មិចភ្នែកមិនអោយនិយាយអ្វីទេ ។ ប៉ុន្តែ ខេរិនមិនឃើញអើតមុខមកឡើយពេញមួយថ្ងៃ ធ្វើអោយនិសាស្រងូត ស្រងាត់ខុសធម្មតា ។

ថ្ងៃស្អែកឡើង...

ខេរិនក៏បើកឡានកញ្ចាស់របស់នាយមកដល់មុខផ្ទះមីងពៅ ហើយក៏ ចុះដើរចូលផ្ទះទំនងដូចជាមានសុខភាពគ្រាន់បើបន្តិចហើយ ត្បិតនាយអាច ដើរបានដោយមិនបាច់មានឈើច្រត់ទប់ខ្លួន ។ លុះបែរមើលជុំវិញផ្ទះ មិន ឃើញឡានមីងពៅនិងពូវៃសោះ ខេរិនក៏នឹកចង់ប្តូរចិត្តត្រលប់ទៅវិញ ។ ស្រាប់តែនឹកភ្នកយ៉ាងណាទេ នាយក៏បែរដើរចូលទៅក្នុងផ្ទះសាជាថ្មី ។ ម្តង នេះនាយបើកទ្វារថ្នមដៃជាងរាល់ដង ដោយមិនបើកកញ្លក់កញ្លែងដូចមុន ឡើយ ។ លុះទ្វាររបើកឡើងយឺត១ ខេរិនឃើញនិសាអង្គុយធ្មេចភ្នែកគេង លក់ស្ងៀមស្ងាត់ក្នុងសាលុង អោបសៀវភៅនៅក្នុងលើខ្លួនតែម្នាក់ឯង ។ មាណពលួចគន់មើលឡើងភ្លឹកតែម្តង ។ នេះជាលើកទីមួយហើយដែល ខេរិនបានឃើញមុខនាងចំពីមុខ មិនដូចរាល់ដងដែលនាយឃើញមុខឆាប ចំហៀង១បាំងសក់អស់នោះទេ ។ ខេរិនលួចសំលឹងអស់ជាយូរ រួចក៏ដើរ លប១ទៅជិត លូកដៃបំរុងនឹងដោះវ៉ែនតារបស់នាងចេញពីភ្នែករបស់នាង ដើម្បីអោយមាណពបានឃើញមុខនាងកាន់តែច្បាស់ ។ ការពិត ខេរិនស្អប់ វ៉ែនតាមីញ៉ូបគែមខ្មៅនោះណាស់ ត្បិតវាបានបាំងមុខបាំងសោភ័ណរបស់ នាងអស់ពាក់កណ្តាលមុខឯណោះ ។ រំពេចនោះ ស្រាប់តែនាងកំរើកប្រែខ្លួន ខេរិនដកដៃមកវិញយ៉ាងរហ័ស នឹកក្នុងចិត្តថា :

- និសា! ខេរិនពិតជាចង់ឃើញមុខមាត់ពិតប្រាកដរបស់នាង ដើម្បីអោយ ខេរិនបានចងចាំរូបនាងរហូតតទៅ...

ពេលនេះ ស្រាប់តែនឹកភ្នកដូរចិត្ត ចង់ថើបថ្ពាល់នាងជំនួសវិញ ។ នាយ ក៏ឈ្ងោកនាសាបំរុងនឹងផ្តិតក្លិនថ្ពាល់ធិតាទៅ ហើយស្រាប់តែ :

- អាហ៊ែម! (សំលេងគ្រហែម)

CHANBOKEO.COM

ខេវិនស្ទុះងើបយ៉ាងរហ័ស ហើយបែរក្រោយមើលម្ចាស់សំលេងដែល គ្រហែមអំបាញ់មិញ ក៏ប្រទះឃើញមីងពៅឈរច្រត់ចង្កេះសំលក់នាយ ។ ខេវិនភ្ញាក់ព្រើត នឹកខ្មាសខ្លួនណាស់ ក៏ងើបដើរគេចទៅអង្គុយនៅផ្ទះបាយយ៉ាងលឿន ។

- ខេវិន! ម្សិលមិញ ម៉េចឯងមិនមកផ្ទះ?

ខេវិនឈ្ងោកមុខនៅស្ងៀមមិនឆ្លើយ ។ ការពិតខេវិនត្រូវផល្លីនក្របួច រករឿងនាយប៉ុន្មានថ្ងៃមកហើយរកដកឃ្លាមិនរួចសោះណាមួយ ខេវិន ខ្លាចនាងតាមដានមកដល់ទីនេះរករឿងនិសា ទើបនាយចេះតែបង្វេងដាន ទៅកន្លែងផ្សេងទៅ ។ ឃើញខេវិនមិនមាត់ មីងពៅសួរថា :

- ថ្ងៃនេះឯងទំនេរទេហ៎?

ខេវិនងក់ក្បាល ។ មីងពៅក៏មានប្រសាសន៍បន្ត:

- អញ្ចឹងនាំនិសាទៅក្រៅម្តងទៅ ។ នាងមិនដែលបានទៅណាទេ តាំងពី មកដល់អាមេរិក ហើយក៏មិនដែលមានពេលសំណេះសំណាលនឹងឯងដែរ តាំងពីជួបគ្នាមក ។ មើលទៅនិសា គេអផ្សុកហើយ ។ ដូចឯងដឹងស្រាប់ហើយថាពូមីងរវល់ធ្វើការគ្មានទំនេរ មិនអាចពេលជូននាងទៅណាមកណា

ដំបូង ខេវិនឃើញមីងច្រត់ចង្កេះដាក់នាយ ស្មានថាត្រូវមាត់ហើយតើ ស្រាប់តែពេលនេះគាត់បែរជាបើកភ្លើងខៀវអោយនាយនិងនិសាទៅវិញ ខេវិននឹកត្រេកអរក្នុងចិត្តមិនហ៊ានមាត់ក ។ ពូមាត់ជជែកគ្នា និសាក៏ភ្ញាក់ឡើង ។ កាលបើឃើញខេវិននៅក្នុងផ្ទះ នាងនឹកខ្មាស់ក្នុងចិត្តដែលនាងបាន បណ្តោយខ្លួនអោយគេងលក់ឥតមារយាទ ក៏លើកសៀវភៅបាំងមុខ ងើប ដើរចូលបន្ទប់របស់នាងបាត់ ដោយមិនមាននិយាយរកខេវិនអីមួយម៉ាត់ ។ ឯខេវិនក៏សំលឹងតាមនាងឥតព្រិចឡើយ ។ ឃើញខេវិនមានកិរិយាដូច្នោះ មីងញញឹមហើយក៏មានប្រសាសន៍តទៅទៀតថា :

- ឯងនាំគេចេញទៅក្រៅ ដើរលេងតាមបែបឯងក្មេងៗចុះណា៎ ។ និសា គេមិនមានថ្នាក់រៀនទេ អាទិត្យនេះ ដើរលេងអោយសប្បាយចុះណា៎!

មួយស្របក់ក្រោយមកខេវិនក៏នាំនិសាចេញទៅ ។ ថ្ងៃនេះ ខេវិនមាន អារម្មណ៍រំភើបយ៉ាងចំលែកបំផុត ។ អស្ចារ្យណាស់! គេទាំងពីរអន្ទះសាចង់ ឃើញមុខគ្នា តែលុះដល់មកជួបមុខគ្នា ម្នាក់ៗបែរជានិយាយលែងចេញ តែម្តង ។ និសាចង់ឱ្យខេវិននិយាយមុន ថែដន្យខេវិនជាបុរសមិនសូវសំបូរ ពាក្យនិយាយស្រាប់ លុះមកជួយនិសា គេរិតតែកកអណ្តាតលើសដើមទៅ ទៀត ។ រីឯនិសាជាមនុស្សរួសរាយ សំបូរពាក្យពេចន៍សរសេរមិនខ្វះ តែពេលនេះពាក្យពេចន៍ទាំងអំបាលម៉ាន ក៏រត់គេចបាត់ពីស្មារតីនាងអស់រលីង ដូចគ្នា ។ គេញញឹមធ្វើអៀនប្រៀនដាក់គ្នាយ៉ាងយូរ ទំរាំដាច់ចិត្តសួរគ្នាថា តើគេចង់នាំគ្នាទៅដើរលេងឯណា?

នៅក្នុងមណ្ឌលប្រជុំហាងទំនិញដ៏ធំជាងគេបង្អស់នៅពិភពលោក មាន ហាងទំនិញធំៗរាប់រយ ដើររាប់ថ្ងៃមិនជុំ ឈ្មោះថា Mall Of America ខេវិនបានកាន់ដៃនាងនិសាចូលហាងមួយដែលមានដាក់តាំងលក់គ្រឿងវត្ថុ អនុស្សាវរីយ៍តូចៗស្អាតៗក្នុងទូកញ្ចក់ ។

CHANBOKEO.COM

នាយក៏ទិញកូនកែវរន្ទះមូលថ្លា មួយដែលមានឆ្លាក់រូបផ្កាកុលាបមួយទងនៅខាងក្នុង រួចក៏ហុចកូនកែវនោះ ទៅអោយនិសា ព្រមទាំងនិយាយថា :

- និសា! រូបនាងដូចជាកែវភ្លឺថ្លាមួយនេះអញ្ចឹង រាល់ថ្ងៃតែងតែបញ្ចេញពន្លឺ អោយបេះដូងខ្ញុំរីករាយសប្បាយជានិច្ច ។

ថាហើយ ខេវិនក៏ហុចកែវនោះអោយទៅនាង :

- នេះជាវត្ថុអនុស្សាវរីយ៍ពីមីនីសូតាណា៎!! បើនិសាបែកឃ្លាតទៅណា សូម ចងចាំមីនីសូតាផង ។

និសាសំលឹងមុខខេវិន ហើយលូកដៃត្រងយកកែវនោះពីនាយយើង ដោយរំភើបចិត្ត ស្រាប់តែមានដៃមួយមកប្រច្រានខេវិនពីក្រោយខ្នង ក្នុង ឱកាសដែលនាយកំពុងហុចកែវទៅនិសា បណ្តាលឱ្យកែវរបូតពីដៃខេវិន ជ្រុះទៅលើកំរាលអិដ្ឋបែកខ្ចាយព្រោងព្រាតតែម្តង ។ និសាភ្ញាក់ក្រញាង ។ ឯខេវិនវិញក៏ថ្ពោះទឹកមុខឡើងស្លេកមួយរំពេច ។ ភ្លាមនោះ និសាឃើញ នារីស៊ិចស៊ីមួយរូបបានលេចធ្លោឡើងយកដៃចង្អុលមុខនិសា រួចសំលក់នាង ដោយក្រសែភ្នែកយ៉ាងកាច ។ តែឆវីនោះមិនឡូឡាដាក់និសាទេ តែបែរជា ទៅប្រច្រានទ្រូងខេវិនផាំងៗ ស្ទើរផ្ងាកដួល ហើយគំហកអោយនាយថា :

- ហ្នឹងឬដែលប្រាប់ផល្លីនថា ទៅជួបពេទ្យ? ពេទ្យរំបល់យក៏អីនៅកន្លែង នេះអញ្ចឹង? ខេវិន! មានអីដោះសារទេ?

ពេលនោះខេវិននិយាយមិនចេញទេ ព្រោះអាល័យតែភន្ត័ភាំង ។បន្តិច មក ខេវិនក៏អួសដៃផល្លីនចេញទៅយ៉ាងលឿន ដោយខ្លាចនាងឆ្មាសនៅ អុកឡុករំខាននិសា ។ ផល្លីនក៏ស្រែកធ្វើមាត់ចេចចាចៗ លាន់រំពងចេញ ទៅ ។ មនុស្សម្នាទាំងឡាយដែលនៅទីនោះក៏នាំគ្នាឈរមើលយ៉ាងចំលែក ចិត្ត ។ និសាខ្មាសគេណាស់ ក៏ឈ្ងោកដើរចេញទៅរកទូរសព្ទ័ហៅមីងពៅ ទាំងអារម្មណ៍មួហ្មង...

**ថ្ងៃ២៥ធ្នូ ២០០៥**

ថ្ងៃនេះជាថ្ងៃបុណ្យ Christmas...

ខេវិនកាន់កញ្ចប់អនុស្សាវរីយ៍មួយយ៉ាងស្អាត ចេញពីឡានដើរសំដៅ ចូលផ្ទះមីងពៅក្នុងកិរិយារីករាយ ។ ចូលទៅដល់ ខេវិនឃើញមីងពៅកំពុង រៀបអាហារលើតុ ហើយពូវីរកំពុងនិយាយទូរសព្ទ័ជាមួយបងប្អូនឯស្រុក ខ្មែរ ។ នាយដាក់ភ្នែកទៅក្រោមដើម Christmas Tree ស្រាប់តែឃើញ ប្រអប់វត្ថុអនុស្សាវរីយ៍ចំនួនបី នាយក៏យកកាដូរបស់នាយទៅដាក់នៅទី នោះដែរ ក្នុងចិត្តសង្ឃឹមថា នឹងបានសប្បាយជួបជុំគ្នាជាក្រុមគ្រួសារម្តង ហើយ ។ លុះឃើញមីងពៅរៀបចានបាយសំរាប់តែបីនាក់ នាយក៏វាចាថា :

- ខ្ញុំសូមបាយញ៉ាំម៉ាពេលដែរមីង!

- អឺ! យើងកំពុងរៀបអោយហើយតើហ៎! (មីងពៅឆ្លើយ)

- អូហ៎ យើងបរិភោគតែបីនាក់ទេ? ចុះនិសា?

- និសាគេមិននៅទេ ។

- គេទៅណាមីង...? (ខេវិនសួរទាំងនឹកឆ្ងល់)

មីងពៅនៅស្ងៀម ។ ស្រាប់តែពូវីរដាក់ទូរសព្ទ័ហើយឆ្លើយថា :

CHANBOKEO.COM

- និសាទៅស្រុកខ្មែរវិញបាត់ទៅហើយណាំខេរិន!

ខេរិនភ្ញាក់ក្រញាង ភើតពោះស្លុតស្មារតីស្ទូតបំពង់កអស់រលីងតែម្តង កាលបើឮដូច្នោះ ។ នាយក៏សួរបន្តថា :

- គេទៅពីអង្កាល់? ម៉េចបានខ្ញុំមិនដឹង? ហើយ... កាលណាគេមកវិញ មីងពៅ?

- នែ៎ សួរញាប់ពេកអញ្ចឹង មីងហត់ស្លាប់ហើយ ឆ្លើយមិនទាន់ទេ ។

ឃើញមីងពៅមិនប្រាប់ ខេរិនធ្វើមុខក្រមូវ បាត់រីករាយមួយរំពេច រួច ក៏មិនបរិភោគអាហារដែរ ។ នាយស្ទុះទៅទាញវត្ថុអនុស្សាវរីយ៍មកមើល ក៏ គ្មានមួយណាជារបស់នាយដែលនិសាផ្ញើឱ្យសោះ ។ ខកចិត្តពេក ខេរិនដាក់ខ្លួនអង្គុយចុះឈ្ងោកមុខសំលឹងក្តារហើយយកដៃឈ្លីសក់ មួយស្របក់ ក៏ ងើបបើកឡានចេញទៅ ដោយមិនទាំងបរិភោគបាយ ហើយក៏មិនជំរាប លាមីងពូទៀតផង ។

**ថ្ងៃ ២៨ធ្នូ ២០០៥**

លុះត្រជាក់ចិត្តបន្តិច ខេរិនក៏ត្រលប់មកផ្ទះមីងពៅសាជាថ្មី តែថ្ងៃនេះ ពូមីងមិននៅទាំងពីរនាក់ ។ ខេរិនដើរត្រេះត្រុះក្នុងផ្ទះម្នាក់ឯង ចុះឡើងៗ ។ យប់បន្តិច ទើបមីងពៅនិងប្តីគាត់ក៏បានមកដល់ផ្ទះវិញ ។ ឃើញមុខខេរិន ភ្លាម មីងក៏សួរឡើងថា :

- ចង់បានដំណឹងពីនិសាទេ ខេរិន?

តែខេរិនបែរជាឆ្លើយថា :

- អផ្សុកមិនដឹងទៅណា បានជាចេះតែដើរៗទៅ...

- សួរគោឆ្លើយក្របី?(ពូរ៉ៃសួរជាន់កែង) សង្ស័យថាឯងនឹកពូនឹកមីងដល់ កំណត់ហើយខេរិនអើយ!

ឮពូរ៉ៃចំអន់ដូច្នោះ ខេរិនក៏ង៉ក់ងភ្លែតលែងចង់ស្រដីតទៅទៀត ក៏ហក់ ឡើងឡានចេញទៅ ។ មីងពៅបន្ទោសពូរ៉ៃថា :

- ពូវាឯងដៀមដាមដូច្នេះ ក្មេងវាអន់ចិត្តណាំ

- វាមិនទៅណាវាទេ បន្តិចវាមកវិញហើយ (ពូរ៉ៃឆ្លើយអោយព្រងើយ)

**ថ្ងៃ១មករា ២០០៦**

ខេរិនក៏មកម្តងទៀតដូចពាក្យពូរ៉ៃថាមែន ។ នាយនៅសំកុកយ៉ាងយូរ តែមិនសួរអីមីងពូទេ ក៏ត្រលប់ទៅវិញតាមតែទំលាប់របស់នាយដែលតែង តែចេញចូលស្រេចតែនឹកឃើញ ។ ស្អែកឡើង ខេរិនក៏ត្រលប់មកសាជាថ្មី ។ ឃើញខេរិនត្រេះត្រុះចុះឡើងពេក ពូរ៉ៃក៏សួរនាយថា :

- ខេរិន! ឯងចង់ទៅស្រុកខ្មែរទេ?

- ទៅធ្វើអី បើខ្ញុំមិនមានស្គាល់នរណាម្នាក់ផង? (ខេរិនឆ្លើយវិញ)

- តែឯងមានបងប្អូនសាច់សាលោហិតនៅរស់ច្រើនណាស់

- បងប្អូនមែន តែយើងមិនដែលស្គាល់គ្នា...

CHANBOKEO.COM

- ហើយចុះ ឯងមិនចង់តាមទៅរកនរណាម្នាក់ទេឬអី?

- រកនរណាគេទៅ?

- នរណាដែលបេះដូងឯងកំពុងយំហៅនោះអី?

- ចេះតែថាហើយពូ... អត់មានទេ!

- អឺ... អោយតែដូចមាត់ទៅ!!

ខេរិននឹកខ្មាសពូវៃដេញកែងក៏ស្ទុះរត់ចេញទៅវិញបាត់សាជាថ្មីទៀត ។

នៅក្នុងបន្ទប់គេង ខេរិនយកដៃគងថ្ងាសនឹកទៅដល់និសា :

- និសា! តើនាងមាននឹកខ្ញុំដូចដែលខ្ញុំកំពុងនឹកនាងឬទេ? ហេតុអ្វីក៏យើង បែកគ្នាដោយមិនបានលាគ្នាមួយម៉ាត់សោះអញ្ចឹង? តើពេលណាទៅទើប ខ្ញុំបានជួបនាងម្តងទៀត? ដឹងទេថាពេលបាត់រូបនាងទៅ ជីវិតខេរិនក្លាយ ជាងងឹត ឥតរស្មីទាល់តែសោះ? និសា! តើនាងនឹងត្រលប់មកវិញទេ? ឬក៏ខ្ញុំត្រូវបែករូបនាងរហូតទៅ..? ទេ!... ទេ!... ជីវិតរបស់ខ្ញុំពិតជា មិនអាចបាត់និសាបានទេ... និសា! ពេលនេះ តើនាងនៅឯណា?... សូមត្រលប់មកវិញឆាប់ៗផងណា៎ និសា! ខ្ញុំពិតជានឹកនិសាណាស់ នឹកពន់ ពេកក្រៃរកអ្វីមកប្រៀបមិនបានឡើយ...

ប៉ុន្មានថ្ងៃបន្តបន្ទាប់មក ខេរិនតែងតែទៅវត្តមីនីសូតា សំកុកនៅមុខ បុស្បុករាល់ថ្ងៃ កណ្តាលអាកាសធាតុដ៏សែនត្រជាក់ ក្រោមស្បៃព្រិលស ធ្លាក់រោយពីមេឃ ហាក់ប្រាថ្នាសូមទទួលពរពីទេវតាដើម្បី អោយបានជួប និសាជាថ្មីម្តងទៀតឆាប់ៗនេះ ។

**ថ្ងៃ១៩មករា ២០០៦**

រ៉ឹងៗ ទូរសព្ទរោទិ៍ឡើង ។ ខេរិនក៏លើកទទួល ស្រាប់តែឮសំដីមីងពៅ:

- ខេរិន! ចង់ទៅលេងនិសានៅស្រុកខ្មែរទេហ៏ មីងទិញសំបុត្រអោយ ។

ឮដល់ឈ្មោះនេះ ខេរិនក៏នឹកតូចចិត្តភ្លាម ហើយក៏ឆ្លើយបញ្ចោះថា :

- អ្នកដែលទៅដោយមិនបានលាខេរិន ត្រូវតែត្រលប់ក្រោយមកលាខេរិន សាជាថ្មីដោយខ្លួនឯង... ខេរិនមិនទៅតាមទេ ។

ការពិតខេរិនកំពុងតូចចិត្ត ដែលនិសាមិនសរសេរមកសួរសុខទុក្ខនាយ សោះ ។ លុះដល់នាយឮមីងពៅមានប្រសាសន៍ដូច្នេះ នាយក៏នឹកង៉ក់ក្នុងចិត្ត ទំលាក់ទូរសព្ទ័មិនព្រមនិយាយជាមួយមីងពៅទៀត ។ ស្រាប់តែផល្លីនដើរ មកដល់ ឮខេរិនប្រកែកជាមួយមីងពៅ ក៏សួរថា :

- ខេរិន? មីងពៅដេញអោយបងទៅស្រុកខ្មែរធ្វើអ្វី?

- មិនដឹងទេ សួរមីងពៅទៅ! (ខេរិនឆ្លើយទ្រគោះ)

ផល្លីនកញ្ឆក់យកទូរសព្ទ័ពីដៃខេរិន លើកហៅមីងភ្លាម :

- មីងពៅ! ហេតុអ្វីបានជាមីងបង្ខំអោយខេរិនវាទៅស្រុកខ្មែរផង?

- យើងមិនបានបង្ខំទេ តែ... (មីងពៅឆ្លើយអាក់ៗ) មានរឿងសំខាន់មួយ

- រឿងអីទៅមីង?

CHANBOKEO.COM

- គឺ... គឺ.. យាយនៅស្រុកខ្មែរផ្ញើសំបុត្រមកឱ្យខេវិន

- សំបុត្រអីទៅ ដែលសំខាន់ចាំបាច់អោយខេវិនទៅស្រុកខ្មែរផង មីង? ប្រហែលជាសំបុត្រមរតកពីយាយរបស់ខេវិនទេដឹង?

- យី! ចុះឯងក៏ប៉ិនទាយម្ល៉េះផល្លីន? អញ្ចឹង!ប្រាប់ខេវិនផង អោយមក ជួបមីងឆាប់កុំខានណា៎!

ផល្លីនដាក់ទូរសព្ទ័ហើយក៏លាន់មាត់ថា :

- បើមានលិខិតមរតកដូច្នេះ.. គាត់ច្បាស់ជាអ្នកមានស្តុកស្តម្ភហើយ! តោះ យើង! ទៅផ្ទះមីងពៅ! ( ផល្លីនអូសដៃខេវិន) ទៅយកលិខិតមរតក...!

៩៩៩៩៩៩៩៩៩៩៩៩៩៩៩

៩

CHANBOKEO . COM

# វគ្គទី១០

# បណ្ដាំមរតក

ក្រោមពន្លឺភ្លើងដ៏ក្រហមស្រទន់ មីងចាបសំរាន្តកើយខ្នើយក្បែរចាន់ ស្តាប់ខេរិននិទានប្រវត្តិរបស់នាយពិរោះទៅៗ ហើយមានហាក់បីដូចជា គាត់កំពុងទស្សនាល្ខោនយីកេបុរាណមួយ... ភ្លាមនោះ គាត់ក៏លាន់មាត់ :

-អញ្ចឹង កូនឯងមកស្រុកខ្មែរដើម្បីតែមរតករបស់ជីដូនតែម្យ៉ាងទេហ៎?

ខេរិនសំលឹងទៅចាន់ទាំងមុខញញឹមហើយឆ្លើយថា :

- មិនមែនទេ ម៉ែ! ការពិត ខ្ញុំមិនជឿថា មានលិខិតមរតកទេ ត្បិតជីដូនខ្ញុំ បានចែកឋានទៅយូរឆ្នាំហើយ មិនដែលឮមីងពៅនិយាយប្រាប់អ្វីសោះពី មុនមក សុខៗស្រាប់តែរឿងសំបុត្រមរតកក៏លេចចេញមក ទើបខ្ញុំសង្ស័យ ថា ប្រហែលជា...

- សង្ស័យអ្វីទៅ កូន?

- គឺខ្ញុំគិតថា ប្រហែលគ្រាន់តែជាគំនិតរបស់មីងពៅនិងពូវៃដុកដាន់អោយ ខ្ញុំចេញមកស្រុកខ្មែរ ដើម្បីតាមរកបេះដូងរបស់ខ្ញុំដែលរបូតបាត់ទៅនោះ តើហ៎ ព្រោះគាត់ដឹងថាខេរិនកំពុងតែរលាកដួងចិត្ត...

- ហើយចុះយ៉ាងម៉េចបានជា  ឯងសំដែងឫកពាដូចជាតាមរកលិខិតមរតក យ៉ាងតក្កហលបែបនោះ?

ខេរិនលួចដៀងមើលប្រពន្ធសាជាថ្មីហើយឆ្លើយថា :

- ការពិត ខ្ញុំកំពុងតាមរកម្ចាស់បេះដូងរបស់ខ្ញុំតើហ៎ ម៉ែ! លុះដល់ខ្ញុំបានជួប ចាន់នៅឯទួលខ្មោយាយភួងថ្ងៃដំបូង បេះដូងរបស់ខ្ញុំក៏បានទទួលចំលើយ រួចហើយថា ម្ចាស់ដួងចិត្តដែលខ្ញុំកំពុងតាមរកនោះ បានមកដល់ចំពោះមុខ ដូចបំណន់ប្រាថ្នារបស់ខ្ញុំហើយ! (ខេរិនពោលទាំងញញឹម)

- ហេតុអ្វីទៅដែលធ្វើអោយបងគិតដូច្នេះ ខេរិន? (ចាន់សួរ)

- ថ្វីត្បិតតែអូនឈប់ពាក់វ៉ែនតា ហើយផ្លាស់ប្តូរការតុបតែងខ្លួន តែបងនៅ តែចំណាំអូនបានជានិច្ច គឺគំនិតនឹងចរិយារបស់អូនមិនបានផ្លាស់ប្តូរទេ ជា ពិសេស គឺការសំដែងកតញ្ញូចំពោះអ្នកមានគុណ និងការយកចិត្តទុកដាក់

CHANBOKEO.COM

ចំពោះសុខទុក្ខរបស់ខេរិន ។ ហើយដែលបងរកលេសតាមរកលិខិតមរតក នោះ គឺបងរំភើបចិត្តពេកពេលបងបានជួបអូន ហើយក៏ចេះតែរកលេស ដើម្បីឱ្យមានពេលនៅតែពីរនាក់ជាមួយអូនតើហ៎!

- ពុទ្ធោ! មែនហ្អែស? (ចាន់លាន់មាត់) ចាន់ចាញ់បោកខេរិនស្អាតតែម្តង

ខេរិនសើចខឹកៗ ហើយស្ទុះទៅបើកកន្ត្រាំងដាក់ម៉ូលដេររបស់និសា រួច ទាញផ្កាកុលាបក្រៀមមួយទងចេញមក ថែមទាំងស្រដីថា :

- បងក៏ចំណាំបានថា ផ្កានេះនៅក្នុងហោប៉ៅរបស់បង ឯអាមេរិក.. សុខៗក៏ ផ្កានេះធ្វើដំណើរមកដល់ភូមិព្រះនេត្រព្រះ ដូចជាចំលែកណាស់ ។

ចាន់ក៏សើចខឹកៗឡើង :

- ចាន់ចង់ឱ្យបងដឹងយូរណាស់ហើយ តែបងមិនព្រមហើបមាត់សួរសោះ ។

ពេលនោះ ខេរិនលូកសំពៀតខៀវចេញមក ហើយស្រដីថា :

- មីងពៅបានប្រាប់ខ្ញុំមុនពេលចេញដំណើរថា បើរកផ្ទះជីដូនរបស់ខ្ញុំឃើញ ខ្ញុំក៏រកម្ចាស់សំពៀតនេះឃើញដែរ ។ គាត់ថាម្ចាស់វាបានភ្លេចចោលនៅផ្ទះ មីងពៅមុនពេលចេញមកស្រុកខ្មែរវិញ ហើយគាត់ផ្តាំអោយខ្ញុំយកមកសង គេវិញ ។ ពេលនោះហើយដែលខ្ញុំដឹងថា មីងពៅកំពុងតែជួយណែនាំផ្លូវ អោយខ្ញុំតាមម្ចាស់បេះដូងមកវិញទើបខ្ញុំប្រថុយប្រថានតាមមកដល់ទីនេះ តែម្តងទៅ ។

ពេលនោះមីងចាបសើចខឹកៗ ហើយមានប្រសាសន៍ឡើង :

- គ្រាន់បើណាស់តើហ៎ ខេរិន! ប៉ុន្តែ ឯងមានគិតទេថាលិខិតមរតករបស់ ជីដូនឯងមានពិតមែន?

- អត់ទេ? ស្រុកខ្មែរបានឆ្លងកាត់សង្គ្រាម និងការព្រាត់ប្រាសវេទនាបែប ហ្នឹង តើធ្វើម៉េចជីដូនខ្ញុំអាចរក្សាសម្បត្តិមហាសាលរបស់គាត់បានទៅ?

- តែម៉ែគិតថា វាអាចទៅរួចណាដែលលិខិតមរតកវាមានពិតមែន ។

- ដែលកូនមកស្រុកខ្មែរពេលនេះ មិនប្រាថ្នាអ្វីទេម៉ែ ក្រៅពីតាមរកនិសា របស់កូនតែប៉ុណ្ណោះ ឥលូវកូនបានជួបគេហើយ ។ ដូច្នេះ រឿងលិខិតមរតក ទុកជាមោឃៈ ។ នៅសល់តែរឿងមួយទេ ដែលកូនមិនទាន់អស់ចិត្ត...

- រឿងអ្វីទៅ កូនប្រុសម្តាយ?

- គឺថា.. បើម៉ែនិងអូនចាន់ក្រីក្រម្លឹងៗ ហើយរស់នៅស្រុកស្រែចំការយ៉ាង នេះ ហេតុដូចម្តេច អូនចាន់អាចមានទុនទៅរៀនដល់អាមេរិក តើអូនចាន់ រៀនបានដល់កំរិតណា? ហើយបានទុនមកពីណា? ហើយហេតុដូចម្តេច នៅសុខៗក៏ឈប់រៀនហើយរត់មកស្រុកខ្មែរវិញ? មិនតែប៉ុណ្ណោះ ចាន់បែរ ជាមកពួនសំងំលាក់ខ្លួនឯងចុងកាត់មាត់ញក ដូចភូមិព្រះនេត្រព្រះនេះទៅ វិញ? ខ្ញុំដូចជាមិនយល់ទេ ។

ដល់ពេលនោះ មីងចាបក៏មើលមុខកូនស្រីហើយក៏មានប្រសាសន៍ថា :

- ប្រហែលជាចាន់អាចពន្យល់កូនបានច្បាស់ជាងម៉ែហើយ ។

CHANBOKEO.COM

ខេវិនស្ទុះទៅជិតចាន់ហើយអង្អែលខ្នងនាងបន្ដើរ :

- ប្រាប់បងបានទេ ប្រពន្ធសំលាញ់?

ចាន់ញញឹមខ្ញិបហើយប្រាប់ថា :

- ចាំស្អែក បានទេ? អូនក៏មានរឿងប្លែក១ ចង់ជំរាបបងដូចគ្នា ។

**ថ្ងៃ ១៨មេសា២០០៦**

ចាន់អង្គុយសិតសក់តុបតែងខ្លួនរៀបចំនាំខេវិនទៅភ្នំពេញ ។ នៅក្បែរ នោះខេវិនអង្គុយសំលឹងភរិយាដោយក្ដីរំភើប ។ ភ្លាមនោះនាយក៏សួរឡើងៈ

- និសា! ហេតុអីក៏អូនឈប់ពាក់វ៉ែនតាហើយនៅតែអាចមើលឃើញដូច ធម្មតាអញ្ចឹង?

ចាន់បែរមុខមកនាយ ហើយឆ្លើយថា :

- គឺ មីងពៅបាននាំខ្ញុំទៅព្យាបាលភ្នែកដោយប្រើកាំរស្មី Laser នៅមុន ពេលដែលអូនចេញដំណើរត្រលប់មកស្រុកខ្មែរវិញ ។ កាលនោះ បងក៏បាត់ មុខមិនដែលឃើញមកជាយូរ ទើបអូនគ្មានឱកាសប្រាប់បងនោះអី...

បន្ដិចក្រោយមក ចាន់ និងខេវិន ក៏ឡើងតាក់ស៊ីចេញដំណើរ ។

ចាន់ក៏បាននាំខេវិនមកដល់វិឡាមួយ ដែលខេវិនចំណាំបានថាធ្លាប់បាន ចូលទីនេះម្ដង កាលនាយមកដល់ស្រុកខ្មែរថ្ងៃដំបូង ស្រាប់តែនិសាទាញ កូនសោរចាក់ទ្វារចូលទៅ ។ ខេវិនលាន់មាត់ :

- និសាមានសោរដែរ? អូនជាអ្នករស់នៅក្នុងផ្ទះនេះ មែនទេហ៏?

- ចាសបង មែនហើយ (នាងឆ្លើយទាំងញញឹម)

ខេវិនភ្ញាក់ក្រញាងតែម្ដង តែមិនទាន់ហ៊ាននិយាយអ្វីទេ ត្បិតចង់តាម ដានសាច់រឿងតទៅទៀត ។ លុះចូលមកដល់ក្នុងផ្ទះ ខេវិនក៏បានប្រទះ បុរសស្ត្រីចំណាស់ពីរនាក់នៅអង្គុយក្នុងបន្ទប់ទទួលភ្ញៀវ ។ នាយក្រលេក ឃើញគាត់ទាំងពីរភ្លាម ក៏ឧទានឡើងថា :

- ពូវៃ មីងពៅ?

ខេវិនស្ទុះរត់ទៅអោបគាត់ទាំងចិត្តត្រេកអររំភើបក្រៃលែង បន្ដិចមក ក៏ពោលទៅកាន់គាត់ថា :

- ខេវិនអរគុណពូមីងណាស់ ដែលជ្រោមជ្រែងចូកចៃជីវិតខេវិនរហូតមក ពេលនេះ ខេវិនយល់ហើយថាពូមីងស្រលាញ់ខេវិនហើយធ្វើអ្វី១ ដើម្បី ខេវិនជានិច្ច ។ អោយខ្ញុំសូមទោសផង ដែលពីដើមខ្ញុំធ្មេចភ្នែកមិនព្រម ទទួល ស្គាល់គុណបំណាច់និងសន្ដានចិត្តដ៏ថ្លៃថ្លារបស់ពូមីង...

មីងពៅអង្អែលក្បាលក្មួយប្រុសបន្ដើរ១ :

- មិនយឺតពេលទេ ក្មួយដែលឯងបានដឹងពីទឹកចិត្តរបស់មីងនិងពូនៅពេល នេះ ហើយមីងពូក៏សប្បាយចិត្តដែរ កាលបើដឹងថា ឯងមានចាប់ផ្ដើមមាន សេចក្ដីសុខក្នុងជីវិត ដូចគេដូចឯង ។

CHANBOKEO.COM

ភ្លាមនោះខេវិនបែរទៅមើលនិសានិងមីងចាប ហើយបែរមកសួរមីង

ពូវិញថា :

- តើមីងពូអាចពន្យល់បានទេហ៎ ពីរឿងនិសាថានាងជានរណាពិតប្រាកដ?

ហេតុដូចម្ដេចបានជានាងមានទំនាក់ទំនងនឹងម្ចាស់ផ្ទះនេះ?

- នៅក្នុងលិខិតមរតកទីបួនរបស់ជីដូនឯង មានចារគ្រប់នូវចំលើយដែល ឯងចង់ដឹងនៅពេលនេះ ។

ចូរទៅតាមរកអោយឃើញទៅ ។

- មីង... មីងលលេងនឹងខ្ញុំ ឬក៏លិខិតមរតកនោះមានពិតប្រាកដមែន?

- មិនបានលលេងទេ ។ លិខិតទីបួននោះជាបណ្ដាំពិតប្រាកដរបស់យាយភួង ជីដូនរបស់ខេវិនហើយ ។

លើកនេះ ខេវិនមានទឹកមុខហាក់ដូចជាខកចិត្ត :

- ហេតុអ្វីសាំញ៉ាំម្ល៉េះ? មីងឆ្លើយជំនួសមិនបានទេ?

- មិនបានទេ ព្រោះមីងក៏មិនដែលបានឃើញបានអានសំបុត្រមួយនោះដែរ

- មីងមិនបានអានសំបុត្រមួយនោះទេ.. បានន័យថា.. មីងបានអានសំបុត្រ ដទៃទៀត? ម៉េចអញ្ចឹង?

- ខេវិន! ចាំដល់ឯងរកឃើញសំបុត្រទីបួននោះមីងនឹងឆ្លើយសរុបរឿងឱ្យ ឯងបាត់ឆ្ងល់ ព្វហើយនៅ?

**ថ្ងៃ១៩មេសា ២០០៦**

ខេវិននាំចាន់ត្រលប់មកព្រះនេត្រព្រះវិញទាំងមុខស្មើក ។ ចាន់ឃើញ

ដូច្នោះក៏លួងលោមថា :

- ខេវិន! ចាំបាច់អីទៅសោកសៅដល់ម្លឹង? ការពិតមីងពូគាត់មានបំណង ល្អលើបងតើហ៎ ។

- មែនហើយ! ប៉ុន្តែហេតុអ្វីចាំបាច់កាច់កុងមានអាថិកំបាំងដល់ម្លឹងទេហ្ន៎?

- មិនអីទេបង! ថ្ងៃនេះយើងទៅផ្ទះក្មេងឃ្វាលគោទាំងហ្នឹងម្ដងទៀត សួរ ដំណឹងសាជាថ្មី ម៉ោះ!អូនជូនទៅ!

ខេវិននិងចាន់បានជួបក្មេងទាំងប្រាំនាក់ដដែល ។ អាង៉ែតនិងអាកណ្ដុប ឆ្លើយព្រមគ្នាទៅអ្នកទាំងពីរថា :

- អត់ទេបងចាន់ ពូវិន! តាដឺរីនិងពូគ្រុឌបានមកយកខ្មើយទាំងអស់នោះពី ពួកយើងអស់ហើយគ្មាននៅសល់មួយទេ ។

ចាន់និងខេវិន មើលមុខគ្នា ។ ខេវិនលាន់មាត់ឡើង :

- តែថ្ងៃនោះ តាដឺរីយកមកអោយយើងតែមួយទេ ចុះមួយទៀតបាត់ទៅ ណាទៅ?

ចាន់ក៏អូសដៃខេវិនដល់ផ្ទះតាដឺរី ។

- ឯណាខ្មើយចាស់របស់យាយភួង តាមេភូមិ? (ចាន់សួរ)

- អញអោយមីនាងឯងហើយតើហ៎ ! ម៉េចមកសួររកទៀត?

- ឃើញបានទទួលតែមួយទេ ចាន់មិនបានទទួលខ្មើយពីរឯណា?

- អញ្ចឹងទៅសួរនាយគ្រុឌ មើល? ក្រែងវាច្រលំដៃទុកផ្ដេសផ្ដាស ។

CHANBOKEO.COM

ខេរិនតិងចាន់ក៏ដើរដល់ផ្ទះពូគ្រុឌ តែគាត់បែរជាគ្រវីក្បាល :

- អញដាក់អោយវិញអស់ហើយមិនបានលាក់ទុកទេ ត្រលប់ទៅមើលឯផ្ទះវិញមើល ក្រែងច្រលំដៃដាក់ត្រង់ណា...

ប្រកែកមិនឈ្នះ អ្នកទាំងពីរក៏ត្រលប់មកផ្ទះវិញ ។

រាត្រីនោះ...

- ចាន់! តើយើងរកខ្មៅយឃើញឬក៏អត់?

- ច្បាស់ជាឃើញ... កុំអាលអស់ទឹកចិត្តអីណាំបង!!

ស្រាប់តែខេរិនដាក់ភ្នែកទៅចំខ្មៅយមង្គលដែលចាស់ៗរៀបចំឱ្យនាយ និងចាន់ផ្សំដំណេក ស្រាប់តែចាប់ភ្លឹករឿងមួយឡើង :

- ប្រហែលជាលាក់ខ្លួននៅទីនេះទេដឹង ចាន់?

ថាហើយ នាយក៏ស្ទុះទៅស្រាយស្រោមខ្នើយមួយជាន់ហើយមួយជាន់ ទៀត រលាក់យកខ្នើយចេញមក ។ ចាន់សំលឹងតាមខេរិនធ្វើភាំង ។ រំពេច នោះ ខ្នើយចាស់មួយក៏ធ្លាក់ចេញមក ។ ទាំងពីរនាក់ក៏ស្រែកហ៊ោរឡើង ព្រមគ្នា :

- ជយោ! ពិតជាខ្នើយនេះហើយ!

គេក៏ប្រញាប់ហែករកលិខិតខាងក្នុងយកចេញមកភ្លាម ។ ចាន់ក៏ចាប់ លើកយកមកអាន មានសេចក្ដីថា :

- *មកដល់ ឫទ្ធីរិទ្ធ ចៅប្រុសទោលសំលាញ់ចិត្ត! បើសិនជាចៅមាននិស្ស័យជាមួយស្រុកទេសខ្លួនឯងហើយត្រលប់មកវិញទាន់ពេលវេលា នោះចៅពិតជាបានទទួលនូវមរតកដែលឪពុកម្ដាយនិងជីដូនទុកអោយមិនខាន ។ តាម ការពិតយាយមានកូនស្រីតែម្នាក់ទេ គឺម្ដាយរបស់ចៅរួចបានចិញ្ចឹមកូនស្រី ធម៌ពីរនាក់ទៀតគឺនាងចាបនិងនាងពៅ ។ គេទាំងបីជាកូនស្រីដ៏ល្អបំផុត របស់យាយ ។ ថៃដន្យអភព្វ ម្ដាយចៅបានធ្វើមរណកាលទៅ កាលពីឆ្នាំ ១៩៧៨ក្រោយពីប្រសូត្រចៅឯងហើយ រីឯឪពុកនិងបងប្រុសរបស់ឯងក៏ចែកឋានព្រម១គ្នាគ្រានោះដែរ ។ នាងពៅក៏បានយកចៅមកចិញ្ចឹមរហូត មកព្រោះគេគ្មានកូនសោះតាំងតែពីរៀបការនាយវៃ ។ ក្រោយមកមីងពៅ ពូវៃក៏ទៅរកស៊ីតាមទល់ដែន ។ មីងពៅក៏យកចៅទៅផ្ញើអ្នកជិតខាងដើម្បី ចេញទៅរែកទឹករីឯពូឯងចេញទៅជួញដូរ ថៃដន្យពេលនោះមានការវាយ ប្រហារតាមទល់ដែន ធ្វើឱ្យមនុស្សម្នារត់បែកខ្ញែកក្រុមគ្រួសារអស់ ។ រូបចៅក៏បានអង្គការគេសង្គ្រោះយកទៅ ។ រីនាងពៅនិងប្ដីរបស់គេក៏មិនដែលបោះបង់ការតាមរករូបចៅឡើយរហូតដល់រកឯងឃើញរួចយកទៅរស់នៅ ជាមួយឯសហរដ្ឋ ។ ចំណែកនាងចាបវិញគេនៅបំរើយាយរហូតមក ទោះ បីគេបានរៀបការជាមួយមនុស្សល្អម្នាក់ហើយក៏ដោយ ។ ក្រោយមកប្ដីនាងក៏ស្លាប់ទៅដោយទុកនៅកូនស្រីមួយ ។ យាយក៏បានដាក់ឈ្មោះឱ្យនាងថា ចន្ទ័និសា ។ រីឯវិឡាមួយខ្នងនៅទួលគោកនោះគឺជាមរតកដែលឪពុក ម្ដាយបង្កើតរបស់ចៅបានបន្សល់ទុកអោយ ។ គេបានសង់វិឡានោះនៅ ឆ្នាំ១៩៧៣ ។ លុះឆ្នាំ១៩៧៩ យាយបាននាំនាងចាបនិងប្ដីគេត្រលប់មក នៅទីនោះវិញ ហើយក៏ចាប់ជួសជុលថែទាំវិឡានេះអោយស្អាតដូចកាលសម័យដែលឪពុកចៅនៅរស់អញ្ចឹង ។ ដោយហេតុថាយាយមានកំណើត នៅស្រុកព្រះនេត្រព្រះ*

CHANBOKEO.COM

យាយតែងតែវិលមកលេងស្រុកវិញរៀងរាល់ឆ្នាំ ជាពិសេសនៅពេលសាលាវ៉ាកង ដើម្បីអោយនិសានិងនាងចាបអាចតាម
មកបំរើផង ។ យាយក៏បានសាងប្រាង្គដ៏ស្អាតមួយ ទុកនៅលើកំពូលភ្នំព្រះ នេត្រព្រះឈ្មោះថា ប្រាង្គបារមីបុណ្យ
ដើម្បីទុកជាគោលរំលឹកដល់សាច់សា លោហិតញាតិសន្តានរបស់យើងផង និងជាកន្លែងណាត់ជួបធ្វើបុណ្យរបស់
ញាតិយើងទាំងឡាយគ្រប់គ្នាផង ។ បើមានឱកាស សូមចៅឆ្លៀតឡើងទៅ ទីនោះកុំខាន
ត្បិតនៅលើជញ្ជាំងប្រាង្គមានឆ្លាក់ឈ្មោះសាច់ញាតិនិង បុព្វការីជនទាំងអស់របស់ចៅនៅទីនោះ ពេលនោះ ចៅនឹងបានដឹងថាវង្ស
ត្រកូលនិងសាច់ញាតិរបស់ចៅធំទូលាយយ៉ាងណា គឺចៅពិតជាមិនឯកា កណ្ដោចកណ្ដែងទៀតឡើយ
បើសិនជាឯងបានមកដល់ស្រុកកំណើតពិត មែន ។  ម្យ៉ាងទៀតពេលនាងពៅនិងប្ដីគេមកលេងស្រុកខ្មែរ គេតែងតែ
ប្រាប់យាយថាឯងជាប់រៀនសូត្រ មិនអាចដកឃ្លាមកលេងស្រុកបានទេ ។ យាយក៏ចេះតែទន្ទឹងផ្លូវចៅមួយថ្ងៃហើយមួយថ្ងៃទៀត
តែក៏បាត់ចៅមិន ឃើញមកលេងយាយដដែល ។ ពេលនោះ យាយអស់សង្ឃឹមណាស់ ។ ដោយចង់ដឹងសុខទុក្ខរបស់ចៅពេក
យាយក៏ពឹងឱ្យសាលីរតន៏ជាកូនស្រី របស់សារិតនិងនាងសុមាលីឱ្យទៅអាមេរិកចំនួនមួយខែ ដើម្បីទៅស៊ើបរក
ដំណឹងចៅអោយយាយដឹង ។ បន្ទាប់ពីត្រលប់មកដល់ស្រុកខ្មែរវិញ នាងក៏ ប្រាប់យាយថាមិនដែលបានជួបឯងទេ
ត្បិតឯងចេញទៅរស់នៅរដ្ឋក្រៅ ដោយមិនជំរាបពូមីងរបស់ឯងសោះ ។ យាយក៏កើតទុក្ខសាជាថ្មីរហូតដល់ ធ្លាក់ខ្លួនឈឺជាទំងន់ ។
ក្រោយមកចន្ទនិសាបានទទួលអាហារូបករណ៍ដើម្បី ទៅរៀនបន្តនៅUCLA  រដ្ឋកាលីហ្វ័រញ៉ា ។ ដោយនាងឃើញយាយទ្រុឌ
ទ្រោមមួយថ្ងៃបន្តិច១ គេក៏ស្មគ្រ័ចិត្តដូរសាលាទៅរៀននៅU of M  រដ្ឋ មិនីសូតាវិញ ដើម្បីតាមរកឯងមកឱ្យយាយវិញ
តែក៏មិនបានជោគជ័យ ដដែល ។ នាងបានត្រលប់មកពីអាមេរិកវិញដោយដៃទទេ ។ ពេលនេះ
យាយកាន់តែអស់សង្ឃឹមមែនទែនហើយ ។ ម្ល៉ោះហើយ យាយក៏សរសេរ
សំបុត្រមួយច្បាប់នេះទុកការពារក្រែងចៅមកមិនទាន់ដង្ហើមយាយ នោះ ចៅនឹងបានទទួលដឹងពូនូវប្រវត្តិពិត
ដែលទាក់ទងអំពីជីវិតរបស់ចៅ កុំឱ្យ ភន្ត័ច្រលំថា ខ្លួនជាមនុស្សកំព្រាគ្មានពំនាក់គ្មានញាតិសន្តានតទៅទៀត ។ ការពិត
ឯងមានសាច់ញាតិច្រើនណាស់ ខ្លះក្រីក្រ ខ្លះធូរធារ ខ្លះរៀនបាន តិច ខ្លះក៏បានខ្ពង់ខ្ពស់ តែគេរស់មានសេចក្ដីសុខណាស់ ។
ពួកគេមិនចង់បាន អ្វីពីចៅទេក្រៅតែពីការវិលត្រលប់វិញរបស់ចៅប៉ុណ្ណោះ ។ យាយសង្ឃឹម
ថាចៅច្បាស់ជាវិលមករកពួកយើងនាថ្ងៃណាមួយ ។ បើយាយគ្មានសំណាង នៅរស់ទាន់ដំណើរវិលត្រលប់របស់ចៅទេនោះ
យាយសូមចងដៃចៅនូវ មាណវីដ៏ល្អមួយរូប គឺចន្ទ័និសា ដែលយាយបានចិញ្ចឹមថែរក្សាអប់រំដោយ ផ្ទាល់ដៃ ។
យាយគិតថាបើចៅបានជួបនាង ចៅក៏ប្រហែលជាពេញចិត្ត ហើយស្រលាញ់នាងដូចជាយាយស្រលាញ់នាងអញ្ចឹងដែរ
ព្រោះចន្ទ័និសា ជាកុលធិតាដ៏ប្រពៃម្នាក់ ។ ម្យ៉ាងទៀតក្រោយពេលនាងត្រលប់ពីអាមេរិក វិញ យាយក៏បានសង្កេតឃើញថា
នាងហាក់ដូចជាមានចំណងសម្ពន្ធ័មនោ សញ្ចេតនាជាមួយនឹងចៅយ៉ាងជ្រាលជ្រៅដែរ ទើបយាយសរសេរសំបុត្រ នេះ
សុំផ្ញើនាងជាមួយនឹងចៅផង ហើយសូមចៅថែរក្សាចន្ទ័និសាឱ្យបានល្អ បំផុត នោះយាយស្លាប់ទៅបិទភ្នែកជិតហើយ ។ ប៉ុន្តែ
បើសិនណាចៅមាន គូស្រកររួចហើយយាយក៏សូមឱ្យចៅរាប់រកនាងជាបងប្អូនផងណា៎! ហើយ
ឈប់គិតថាខ្លួនជាមនុស្សកំព្រើកំព្រាញាតិសន្តានតទៅទៀត..! ពីយាយ ដែលនឹករលឹកហើយស្រលាញ់ចៅបំផុត... យាយភួង!

CHANBOKEO.COM

ខេវិនឈ្ងោកមុខរលីងរលោងទឹកភ្នែក... និយាយមិនរួចឡើយ ។ ការ
ពិត នាយបានដើរផ្លូវខុសធ្ងន់ណាស់ក្នុងជីវិតបណ្តាលឱ្យនាយឃ្លាតចាករង្វង់ គ្រួសារដ៏កក់ក្តៅ
ដែលនាយគួរណាស់តែបានជួបគ្នាតាំងពីយូរឆ្នាំមកហើយ ទាំងអស់នោះមិនមែនជាកំហុសរបស់មីងពៅពូវ៉ៃទេ គឺមកពីនាយតែម្នាក់
ដែលលិចលង់ទៅក្នុងទុទិដ្ឋិឆន្ទៈ សំលឹងមើលតែផ្លូវជីវិតអវិជ្ជមាន មិនព្រម បែរចាប់យកនូវអ្វីដែលមីងពៅពូវ៉ៃណែនាំឡើយ
គឺចេះតែធ្វើផ្ទុយ គិតផ្ទុយ ពីការណែនាំរបស់គាត់ជានិច្ច ។ ពេលនេះនាយយល់ច្បាស់ហើយនូវបំណង ល្អរបស់គាត់ទាំងពីរ
ថ្វីត្បិតតែគាត់មិនបានបញ្ជាក់ប្រាប់ដោយពាក្យសំដីក៏ ដោយក៏ទង្វើទាំងឡាយរបស់គាត់ បាននាំលទ្ធផលល្អដល់ជីវិតរបស់នាយ
យ៉ាងជាក់ស្តែង ។ ខេវិនងើបមុខឡើងសំលឹងមុខភរិយាហើយស្រវាអោប នាងយ៉ាងណែនពេញរង្វង់ដៃ :

- និសា! លោកយាយពិតជាមានភ្នែកមុតណាស់ ដែលគាត់ជ្រើសរើសរូប អូនសំរាប់បង ។ បងពិតជារំភើបចិត្តអ្វីម្ល៉េះទេ!
មែនហើយ ចំពោះបង ពេលនេះ មរតកអ្វីក៏គ្មានតម្លៃចំពោះជីវិតបងស្មើនឹងរូបអូនដែរ និសា!
អូនគឺជាកំណប់ទ្រព្យមរតកដ៏មហាសាលបំផុត! ពេលនេះ បងនឹកស្តាយ
ក្រោយណាស់ដែលបងមិនបានប្រព្រឹត្តខ្លួនជាក្មេងកតញ្ញូ!...

និសាយកដៃអង្អែលខ្នងខេវិន ហើយវាចាយ៉ាងស្រទន់ទៅវិញថា :

- មិនយឺតពេលទេ ខេវិន! បើបងពិតជាចង់សំដែងនូវទឹកចិត្តកតញ្ញូចំពោះ អ្នកមានគុណរបស់យើងមែននោះ...
- អូនថាម៉េច..? បងពិតជាមិនយឺតពេលមែន?

ធិតាងក់ក្បាល ។ ខេវិនឃើញហើយក៏ជ្រួញចិញ្ចើមមួយស្របក់ក៏យក
ដៃទះថ្ងាសហើយលាន់មាត់ថា :

- មែនហើយ! ជីដូនរបស់បងទើបតែសរសេរលិខិតនេះនៅក្រោយពេល អូនត្រលប់ពីអាមេរិកវិញ... ដូច្នេះ
គាត់មិនមែនជាជីដូនរបស់បងដែលបាន
អនិច្ចកម្មទៅជាង១០ឆ្នាំមុននេះទេ ។ យាយភួងជាជីដូនខាងម្តាយបង បើ
ដូច្នោះជីដូនដែលអនិច្ចកម្មទៅប្រាកដជាខាងឪពុកបងហើយ... ហេតុអ្វីបាន បងនឹកមិនឃើញតាំងពីយូរមកហើយអញ្ចឹង?

រំពេចនោះ នាយយើងក៏ស្ទុះចាប់ដៃភរិយា ហើយសួរថា :

- ចាន់! ពេលនេះបងដឹងហើយ ថាយាយមិនទាន់អស់បុណ្យនៅឡើយទេ អូនប្រាប់បងមក៏ ថាយាយរបស់បងនៅឯណា?

ចាន់ញញឹមឡើងហើយឆ្លើយវិញថា :

- ចាន់ធ្លាប់ជាអ្នកនាំមុខផ្លូវជីវិតអោយខេវិនយូរហើយ ថ្ងៃនេះ ចាន់ចង់ដឹង ថា តើខេវិនអាចមានសមត្ថភាពរកយាយឃើញ
ដោយមិនបាច់ចាន់នាំមុខ បានដែរឬទេហ្ន៎?

មែនហើយ... ខេវិនក៏ដឹងដែរថា នាយតែងតែយកចាន់ជាអ្នកដឹកនាំ ជីវិតរបស់នាយរហូត
តែមិនដែលគិតស្វែងរកជីវិតសុក្រឹតដោយខ្លួនឯង ម្តងណាសោះ ។ ល្មមដល់ពេលហើយ ដែលនាយត្រូវសំដែងនូវទឹកចិត្តកូន ប្រុស ។
ខេវិនស្ទុះទៅអោបភរិយាហើយស្រដីថា :

CHANBOKEO.COM

- អរគុណណាស់ដែលអូនជួយជាកំលាំងចិត្តដល់បងរហូតមក ។ ពេលនេះ
ខេរិននឹងចេញស្វែងរកជីវិតសុក្រឹត ដោយខ្លួនឯង ។ សូមអូនជួយផ្តល់
កំលាំងចិត្តដល់បងផងណា!

ចាន់វាចាតបរិញ្ញយ៉ាងទន់ភ្លន់ :

- យើងជាប្តីប្រពន្ធនឹងគ្នា ប្រៀបហាក់ដូចជាជីវិតតែមួយ... ចាន់ពិតជាមិន
បណ្តោយអោយបងត្រូវប្រទះនឹងការខកចិត្តទៀតឡើយ ។

**ថ្ងៃ២០មេសា២០០៦**

ខេរិនហក់រឹងដល់បាត់ដំបង ។ មកដល់ផ្ទះតាយាយដែលនៅឯជើងវត្ត កំផែង
នាយយើងក៏បានទៅក្រាបសំពះសួរសុខទុក្ខតាយាយហើយក៏ជំរាប សួរដំណឹងថា :

- យាយ... គឺជាយាយភួងជីដូនរបស់ខេរិន មែនទេហ៎?

- មិនមែនទេចៅ! (ដូនចាស់គ្រវីក្បាល) យាយឈ្មោះយាយផាត់ ប្អូនស្រី របស់យាយភួង ហើយនេះតាសែមជាប្តីរបស់យាយ ។ តាយាយមានកូនស្រី ម្នាក់គឺនាងសុមាលីដែលមានប្តីឈ្មោះលោកសារិតនោះអី ហើយសាលីរតន៍ ជាចៅស្រីបង្កើតរបស់យាយ ។

ខេរិនឮហើយបើកភ្នែកធំៗធ្វើកិរិយាហាក់ដូចជាខកចិត្ត តែពេលនោះ នាយក៏សប្បាយចិត្តដែរដែលដឹងថា
ខ្លួនមានឱកាសបានមកសំពះសាច់ញាតិ របស់ម្តាយ ។ មុននឹងចេញមកវិញ យាយផាត់តាសែមបានជូនពរខេរិន
យ៉ាងច្រើនទៀតផង ។ ល្ងាចបន្តិច នាយក៏បានមកដល់ផ្ទះវិញ ។ ពេលនោះ ចាន់ក៏ស្ទុះចេញទៅទទួល :

- បងមានអារម្មណ៍យ៉ាងណាដែរ ខេរិន?

- គឺសប្បាយចិត្តផង ខកចិត្តផង

- បន្តិចទៀត បងនៅសល់តែសេចក្តីសប្បាយក្នុងចិត្តប៉ុណ្ណោះ ។ រីឯការខក
ចិត្តនឹងបាត់រូបទៅវិញដោយឯងៗហើយ (ចាន់និយាយលួងលោម)

ខេរិនយកដៃអង្អែលកេសាភរិយាចាន់បន្ថើរៗ ស្រាប់តែនឹកភ្នកដល់
រឿងមួយ :

- ចាន់! បងគិតថា បងចង់ឡើងទៅវត្តឯលើកំពូលភ្នំព្រះនេត្រព្រះ...

- ឥឡូវនេះឬបង? ដើម្បីអ្វីទៅ? ពេលនេះរសៀលបន្តិចហើយ យកចង្ហាន់ ទៅវត្តមិនសមទេ...

- គឺបងចង់ទៅឃើញប្រាង្គបារមីបុណ្យនោះណាស់

ចាន់ឮខេរិនពោលដូច្នោះក៏ញញឹមភ្លាម ។

**ថ្ងៃ២១មេសា ២០០៦**

ខេរិនកាន់ដៃភរិយាដើរឡើងកាំជណ្តើរ សំដៅទៅលើកំពូលភ្នំព្រះ
នេត្រព្រះដែលមានអមដោយបង្កាន់ដៃរូបនាគក្បាច់យ៉ាងប្រណិត ។ លុះ ទៅដល់ដែនសីមាវត្ត ខេរិនក៏សង្កេតមើលម្តុំនោះសាជាថ្មី ។

CHANBOKEO.COM

មែនហើយ! កាលដែលនាងចាន់នាំខេរិនមកទីនេះលើកដំបូង មាណពមិនបានសង្កេតអ្វី

ឡើយក្រៅតែពីបណ្ដោយអោយចាន់ជាអ្នកដឹកដៃនាំមុខទាំងអស់ ។ ពេល នេះនាយនាំមុខខ្លួនឯងមកដល់ទីនេះ

ហើយក៏បានឃើញអ្វីច្បាស់លាស់ជាង មុន ។ លុះនាយនាំភរិយាដើរចូលហួសក្លោងទ្វារវត្តបន្តិច ក៏ប្រទះនឹងប្រាង្គ

ដ៏វិចិត្រមួយនៅស្ដាំដៃ ហើយមានឆ្លាក់អក្សរនៅលើក្លោងទ្វារផង ។ ខេរិន មិនចេះអានអក្សរខ្មែរទេ ក៏លួចខ្សិបចាន់ថា :

- បងកាត់យល់ហើយថា ទីនេះជាប្រាង្គបារមីបុណ្យ...

- ហេតុអីក៏បងដឹង? (ចាន់សួរ)

- គឺ បងសង្កេតឃើញថានៅទីនេះមានតែកុដិលោក ព្រះវិហារ សាលាឆាន់ និងចេតិយពីរបី តែឃើញមានតែប្រាង្គមួយគត់

ដូច្នេះបងគិតថាជាប្រាង្គ

បារមីបុណ្យប្រាកដណាស់ ។

- ខេរិន! បងកាន់តែឆ្លៀវឆ្លាតជាងមុនហើយ ។

ខេរិនញញឹមភ្លាម  កាលបើឮចាន់សរសើរ ។  គេទាំងពីរនាំគ្នាដើរចូល ទៅក្នុងប្រាង្គ

ស្រាប់តែប្រទះនឹងព្រះសង្ឃមួយព្រះអង្គគង់នៅទីនោះ ព្រម

ទាំងឃើញតារាងរាយនាមបុព្វការីជននៅលើជញ្ជាំងយ៉ាងច្រើនទៀតផង ។ មាណពក៏នាំភរិយាចូលទៅក្រាបបង្គំព្រះគ្រូ

រួចហើយក៏សុំឱ្យចាន់អាន ឈ្មោះរបស់បុព្វការីជនទាំងឡាយរបស់នាយ ដែលមានសរសេរនៅលើ ជញ្ជាំងប្រាង្គឱ្យស្ដាប់ ។

មួយស្របក់ក្រោយមក ទើបនាយមានក្រាបបង្គំសួរ ព្រះគ្រូថា :

- ខ្ញុំព្រះករុណាជាមនុស្សវង្វេងសាច់ញាតិ កំពុងស្វែងរកជីដូនរបស់ខ្លួន ដែលមានឈ្មោះថា យាយភួង

សូមព្រះតេជគុណជួយណែនាំផង!

ស្រាប់តែព្រះសង្ឃមួយអង្គនោះសំដែងព្រះភក្ត្រញញឹមតែម្ដង ហើយ ក៏មានដីការតបវិញយ៉ាងរីករាយថា :

- លោកយាយកំពុងស្នាក់ចមិនៅកុដិមួយជិតសាលាឆាន់ឯណោះ ។ ញោម ឆាប់ទៅពេលនេះទៅ នឹងបានជួបហើយ ។

ពេលនោះ   ខេរិនអរភើតតែម្ដងដែលដឹងថា  ជីដូនរបស់ខ្លួននៅមាន

ជីវិតនៅឡើយ ។ នាយក៏ស្ទុះងើបយ៉ាងរហ័ស ដឹកដៃចាន់តំរង់ទៅទីនោះ ភ្លាម ។ ពេលនោះ

ខេរិនក៏បានប្រទះឃើញដូនជី៣អង្គកំពុងសំរាន្ត អាន សៀវភៅធម៌ ។ ស្រាប់តែមួយដូនជី១អង្គ ក្រលេកឃើញអ្នកទាំងពីរដើរ

ចូលទៅភ្លាម ក៏ស្រែកលាន់មាត់ហៅឈ្មោះនាយយើងចំៗតែម្ដង :

- ឫទ្ធិរិទ្ធ! មកលេងយាយមែនទេចៅ?

ខេរិនភ្ញាក់ព្រើត នឹកមិនយល់សោះថាហេតុអ្វីបានជាគាត់ស្គាល់ឈ្មោះ

របស់នាយៈ

- បាទ!... លោកយាយជាជីដូនរបស់ខ្ញុំមែនទេ?

CHANBOKEO.COM

- ត្រូវហើយ! យាយធ្លាប់បានឃើញចៅមកទីនេះជាមួយចាន់ម្តងហើយ តែកាលណោះចៅមិនបានដឹងទេ
ថាយាយជាជីដូនរបស់ឯង ។ ប៉ុន្តែ ដោយ យាយឃើញចៅកំពុងមានសុភមង្គល ទើបយាយមិនទាន់ហ៊ានរំខានចិត្ត ចៅ
ហើយស៊ូនៅរង់ចាំរហូតដល់ថ្ងៃដែលចៅត្រៀមចិត្តទទួលយាយបាន ។
- លោកយាយ... (ខេរិនក៏ឱនក្រាបក្បាលប្រណម្យសំពះយាយ ហើយក៏ អួលដើមក និយាយអ្វីមិនរួច
បានត្រឹមតែស្រវាអោបជើងលោក ដោយក្តី រំភើបញ្ជាប់ញ័រក្នុងចិត្ត)

ដូនជីក៏យកដៃអង្អែលក្បាលខេរិនទាំងរលីងរលោងទឹកភ្នែក :

- វិន្ទចៅយាយ... យាយរង់ចាំចៅយូរឆ្នាំហើយ ចៅដឹងទេ? យាយនឹកចៅ ណាស់ ចៅយាយ!

ខេរិនឮដូច្នោះ ក៏អួលដើមកថែមទៀត រកស្តីអ្វីតទៅទៀតក៏មិនរួច ឡើយ...

មួយស្របក់ក្រោយមក...

ខេរិនងើបមុខសំលឹងដូនជីហើយឈ្ងោកមុខមកវិញ សំដែងការសោក
ស្តាយក្នុងចិត្តដែលនាយបង្ហួសពេលវេលាចោលឥតប្រយោជន៍នៅអាមេរិក យូរអើយសែនយូរ
វិះតែនាយលែងមានឱកាសជួបជីដូនរបស់ខ្លួនទៅហើយ មាណពក៏សំដែងគារវកិច្ច ហើយក៏សំណេះសំណាលជាមួយជីដូនរហូតដល់
ថ្ងៃរៀបលិចទើបត្រលប់មកផ្ទះវិញ ។ មុននឹងចុះពីភ្នំមក ដូនជីបានផ្តាំខេរិន និងចាន់ ថា :
- កុំសោកស្តាយអីណាចៅ ដែលយាយគ្មានមរតកអីសំខាន់ចែកដល់ចៅ
ក្រៅតែពីខ្ទមកញ្ចាស់នៅលើទួលកណ្តាលវាលស្រែមួយនោះ ។ វាជាកេរ្តិ៍តែ មួយគត់ដែលនៅសេសសល់
ពីសម័យសង្គ្រាមប្រល័យសាសន៍ខ្លួនឯង! ជីតារបស់ចៅធ្លាប់មកដេកចាំស្រែនៅក្នុងខ្ទមនោះ ។ ពិតមែនតែវាជាខ្ទម កំពុកមួយ
តែខ្ទមនោះក៏បានបង្កប់នូវអនុស្សាវរីយ៍ដ៏មានតម្លៃបំផុតចំពោះ យាយតា និងចំពោះឪពុកម្តាយរបស់ឯងដែលធ្លាប់រស់នៅទីនោះ
ហើយក៏ ស្លាប់នៅទីនោះដែរ ។ ដូច្នេះសូមចៅថែរក្សាទីនោះជំនួសយាយផង នៅ ពេលណាដែលយាយអស់បុណ្យទៅ...

ខេរិនក្រាបសំពះដូនជីហើយក៏តបវិញថា :

- ចៅសូមទទួលមរតករបស់យាយដោយដួងចិត្តរំភើបបំផុត ព្រោះទីនោះ ក៏ជាចំណុចអនុស្សាវរីយ៍រវាងចន្ទនិសានិងចៅដែរ ។
ចៅមិនខកចិត្តទេដែល ចៅបានមកដល់ទីនេះ ហើយស្វែងរកឃើញប្រវត្តិពិតរបស់ខ្លួនឯង ។ ពេល នេះតទៅ
ចៅនឹងកែប្រែខ្លួនសាជាថ្មី ដើម្បីឱ្យក្លាយជាចៅប្រុសដ៏ល្អមួយរូប
របស់យាយ និងដើម្បីអោយសក្តិសមនឹងចៅស្រីដែលយាយបានសរសើរថា
ជាកុលធិតាដ៏ប្រពៃមួយរូប ។ ចំពោះចៅ ចន្ទនិសាគឺជារង្វើដ៏ពណ្ណរាយ បំភ្លឺ ផ្លូវជីវិតចៅអោយដើរក្នុងផ្លូវសុក្រឹតបំផុត ។

ថាហើយ នាយក៏លូកដៃភរិយាមកកាន់យ៉ាងណែនដោយសេចក្តី ស្រលាញ់និងការពេញចិត្តចំពោះភរិយា ។ ឃើញដូច្នោះ
ដូនជីក៏ញញឹម ឡើងរួចក៏មានវាចាថា :

CHANDBOKEO.COM

- ជីដូនសប្បាយចិត្តណាស់ដែលជីដូនមានឱកាសបានឃើញចៅទាំងពីររួម រស់ជាមួយគ្នាដោយមានសេចក្ដីសុខបំផុត ។ សូមអោយចៅថែរក្សាគ្នា ដោយសេចក្ដីស្រលាញ់ និងការអត់ឱនអធ្យាស្រ័យ ។ បើមានពេលទំនេរ សូមចៅកុំភ្លេចឡើងមកលេងនឹងជីដូននៅលើភ្នំម្ដងម្កាលផងណា!!

បន្ទាប់មក ខេវិននិងចាន់ក៏សំពះលាជីដូនមកដល់ផ្ទះវិញ ។ លុះគេដើរ មកដល់មុខទីធ្លាមុខផ្ទះ ស្រាប់តែភ្ញាក់ស្មារតីព្រើតដូចគេចាប់គ្រវែងតែម្ដង ត្បិតអី នៅទីនោះមានការតុបតែងវេទិកាយ៉ាងស្អាត ហាក់ដូចជាកំពុងតែមានពិធីបុណ្យអីមួយអញ្ចឹង ។ អ្នកទាំងពីរក៏បែរមើលមុខគ្នាទាំងងឿងឆ្ងល់ ហើយក៏ស្ទុះដើររឹងចូលទៅ ។ ពេលនោះ ខេវិនប្រទះឃើញតាដឺរមេភូមិ កំពុងតែស្រែកហោកហាក ។ មាណពក៏សួរគាត់ឡើងថា :

- តាមេភូមិ ថ្ងៃនេះមានបុណ្យអីហ្នឹង?

- ទៅសួរមីងពូឯងទៅ បើចង់ដឹង ( តាដឺរឆ្លើយ)

ភ្លាមនោះ មីងពៅពូវៃក៏ដើរមកដល់ ។ មីងពៅឃើញខេវិននិងចាន់ មកដល់ហើយសំដែងការភ្ញាក់ផ្អើល ក៏ឆ្លើយឡើងយ៉ាងរហ័ស :

-មីងឃើញឯងមានសេចក្ដីសុខ ក៏នឹកភ្នកចង់ធ្វើអ្វីសប្បាយៗចែកអ្នកស្រុក អោយបានសប្បាយដែរណា ។

ខេវិនក្រលេកមើលចាន់ហើយក៏ញញឹមឡើងទាំងពីរនាក់ព្រមគ្នា ។

ពិធីចាប់ផ្ដើមហើយ...

តាដឺរក៏ឡើងប្រកាសថា :

- ជំរាបតាយាយពុកម៉ែមាមីងទាំងអស់! យាយភួងធ្លាប់បានសន្យានឹងពួក យើងថានឹងធ្វើបុណ្យអបអរ៧យប់៧ថ្ងៃ បើសិនចៅប្រុសគាត់ត្រលប់មក ស្រុកវិញហើយរៀបការនឹងនាងចាន់ ។ ឥលូវអ្វីៗក៏បានក្លាយជាការពិតដូច បំណងរបស់យាយមែន ដូច្នេះ ដល់ពេលដែលយើងត្រូវជប់លៀងហើយ ។

ភ្លាមនោះពូគ្រុឌស្រដីថា :

- ប៉ុន្តែ យើងបានជប់លៀងអស់ពីរដងហើយ ។ ពេលនេះនៅសល់ប្រាំដង ទៀតទើបគ្រប់ចំនួន មែនទេបងប្អូន?

អ្នកស្រុកក៏នាំគ្នាហោកញ្ជ្រៀវឡើងលាន់ឮរំពង ក្នុងបរិយាកាសយ៉ាង រីករាយមនោរម្យអមជាមួយតន្ត្រីស្រុកស្រែ ដោយមានទ្រខ្មុយស្គរដៃប្រគំ រណ្ដំពិរោះជាប់សោតា ។ ភ្លាមនោះ ខេវិនបែរសួរមីងពៅថា :

- មីង! ប្រាប់ខេវិនបានទេ? ថាតើនរណាទៅ ជាអ្នកផ្ដើមគំនិតរឿងលិខិត មរតក ទាំងនោះ?

- មានពីណាក្រៅពីផល្លីនមិត្តស្រីរបស់ឯងនោះទេណា?

- ហ្អាក់ ម៉េចអញ្ចឹងទៅវិញ?

- គឺកាលណោះ មីងឃើញឯងជាមនុស្សមានបេះដូងព្រៃក រឹកពុនមិនដឹង

CHANBOKEO.COM

ទិសតំបន់ មិនដឹងថានរណាមួយទៅដែលឯងជ្រើសរើសជាម្ចាស់ដួងចិត្តពិត ប្រាកដ។ មីងក៏ចង់ពិសោធន៍ចិត្តឯងមើល ដោយសំរេចចិត្តអោយនិសា ឈប់រៀនបណ្តោះអាសន្នហើយត្រលប់មកស្រុកខ្មែរវិញ ចង់ដឹងថាតើ ឯងគិតយ៉ាងណាចំពោះនាង។ តែឯងមាត់រឹងណាស់ ទោះបីបេះដូងនឹក និសាយ៉ាងណាក៏ដោយ ក៏នៅតែប្រកែកមិនព្រមទទួលស្គាល់នូវអារម្មណ៍ ដែលឯងមានយ៉ាងពិសេសចំពោះនិសានេះឡើយ។ ថ្ងៃមួយ និសាបាន សរសេរសំបុត្រមកលេងក្មួយឯង។ លុះមីងក៏លើកទូរសព្ទ័ហៅឯងឱ្យមក យក ស្រាប់តែឯងបែរជាឱ្យផល្លីនមកទទួលជំនួសទៅវិញ ទើបមីងពួខក ចិត្ត ហើយក៏បែកប្រាជ្ញាភូតភរលេងបន្តសាច់រឿងទៀតទៅ យូរៗទៅក៏ ធ្លោយផ្លូវភូតវែងអន្លាយបែកជាអូហូរជាស្ទឹង រហូតដល់តួឯកខេរិនខ្លួនឯង ធ្លាយដល់ភូមិព្រះនេត្រព្រះតែម្តងនេះអី!

ស្រាប់តែមីងចាបពោលបន្តឡើងថា :

- កាលនោះ ខ្ញុំឃើញចាន់គេតប់ប្រមល់ពេក ក៏នាំកូនមកលេងជីដូនដែល នៅស្នាក់ធមិលើភ្នំព្រះនេត្រព្រះ ដើម្បីអោយនាងរសាយចិត្តពីការនឹក រលឹកខេរិន... ថៃដន្យ បងពៅក៏ទូរសព្ទ័មកលួម ប្រាប់ថាអោយចាំទទួល ខេរិនផង។

ខេរិនឮដូច្នោះ ក៏លួចសំលឹងមើលមុខភរិយាហើយញញឹម រួចក៏ឈ្ងោក ខ្សិបសួរនាងថា:

- អូនពិតជានឹកបង រហូតដល់ចាស់ៗសង្កេតឃើញដល់ម្លឹង?

ចាន់នឹកខ្មាស់ពេក ក៏យកដៃមួលចង្កេះប្តី :

- រឿងរបស់ខ្ញុំទេ... បងកុំចេះ!

ខេរិនញញឹមហើយថើបនាងខ្សឹតហើយស្រដីថា :

- មកពីចិត្តយើងដូចគ្នាតើហ៎ ទើបយើងបានជួបគ្នាថ្ងៃនេះនោះអី ណាំអូន!

មីងចាបក៏មានប្រសាសន៍បន្តថា :

- លុះចាន់គេឡើងភ្នំព្រះនេត្រព្រះជំរាបយាយភួងថាចៅវិន្ទមកលេងស្រុក គាត់សប្បាយចិត្តពេកក៏ប្រាប់ដល់អ្នកភូមិគ្រប់គ្នា។ តាដឺរីមេភូមិឮដូច្នោះ ក៏សុំអនុញ្ញាតិយាយភួងទទួលខេរិន ដោយវិធីសប្បាយៗតាមបែបគាត់។ ពេលនោះខ្ញុំមិនដឹងថា តាដឺរីមានគំរោងទទួលខេរិនយ៉ាងណាទេ។

- ចុះនរណាទៅជាអ្នកផ្តើមគំនិតសរសេរលិខិតមរតកទាំងបួនច្បាប់នោះ? ជីដូនរបស់ខ្ញុំមែនទេ? (ខេរិននៅតែនឹកឆ្ងល់ ក៏សួរថែម)

- មិនមែនទេ... ការពិតយាយភួងសរសេរតែមួយច្បាប់ទេ ឯបីច្បាប់ទៀត គឺជាស្នាដៃរបស់...

ស្រាប់តែមីងពៅទុចង់ក់មិនបញ្ចប់សេចក្តីទេ រួចបែរមើលចាន់ដើម្បី ឱ្យនាងឆ្លើយជំនួស។ ចាន់ឃើញហើយក៏ចង្អុលទៅមីងចាប តែមីងចាបបែរ ជាគ្រវីក្បាលហើយចង្អុលទៅពូគ្រុឌ។ ពូគ្រុឌប្រកែកញ៉ាញឡើង :

- មិនមែនយើងទេវើយ! គឺជាគំនិតតាដឺរីមេភូមិទេតើហ៎ !

រំពេចនោះ ទាំងអស់គ្នាក៏នៅស្ងៀមស្ងាត់ឈឹងសំលឹងតាមេភូមិគ្រប់ៗ គ្នា។ កាលបើឃើញក្រសែភ្នែកមនុស្សរាប់រយសំលឹងមកដូច្នោះ តាមេភូមិ ក៏សើចខឹកៗហើយ មានប្រសាសន៍ឆ្លើយថា :

CHANBOKEO.COM

- ប៉ុន្តែ... មុននឹងតាជីវរៃយើងសរសេរ យើងក៏បានឡើងទៅសុំច្បាប់យាយ

ភួងរួចហើយណា៎! មិនមែនផ្ដើមធំទេវ៉ើយ!!

- ហើយចុះតាជីវរៃសរសេរសំបុត្របីទៀត ដើម្បីអីទៅ? (ពូវៃសួរ)

- អើហ៎ ចុះបើសំបុត្រយាយភួងវាកំសត់ពេកធ្វើអី? ស្រុកគេសុខសប្បាយ ប៉ុណ្ណោះទៅហើយ

ហើយកូនចៅក៏បានមកដល់ស្រុកជួបជុំគ្នាដែរ ដូច្នោះ រឿងអីត្រូវឃាត់យើងមិនអោយយើងធ្វើបុណ្យសប្បាយ? ត្រូវតែធ្វើអ្វីឱ្យ

ប្លែកអារម្មណ៍ខ្លះ មិនថាអញ្ចឹងហ្អែស? ហ៉ែសៗ ហាសហា!

យើញតាជីវរៃមេភូមិសើចខ្ចាស់ៗ អ្នកស្រុកក៏សើចគិលឡើងដែរ។ ពេលនោះខេវិនជ្រួញចិញ្ចើមហើយសួរថា :

- ដូច្នេះគឺតាមេភូមិជាអ្នកផ្ដើមគំនិតអោយគេទៅលួចសំពៀតខ្សែវិរបស់ ខ្ញុំនោះមែនទេ?

- មិនមែនទេ (តាជីវរៃឆ្លើយ) ការពិតគឺឆ្កែដាងរបស់នាយគ្រុឌវាទៅពាំមក យកមកអោយតា។ កាលនោះ

តាក៏មិនដឹងរឿងដូចតែគ្នាដែរ ប្រហែលជា អាដាងវាចង់អោយតាចុះកំណត់ស្ថិតិប្រជាជនបន្ថែមក្នុងភូមិយើងទេដឹង?

អ្នកស្រុកឮដូច្នោះក៏សើចគិលម្ដងទៀត។ ខេវិនក៏សួរបន្ថែមថា :

- ហើយចុះផ្លាកព្រួញដែលចង្អុលទិសទៅរកខ្ទមយាយភួងជាស្នាដៃនរណា ដែរទៅ តាមេភូមិ?

- គឺនាយគ្រុឌវាកំប្លែងជាមួយឯងហ្នឹងណា៎ ព្រោះវាធ្លាប់ឮថាឯងជាក្មេង រើសអើង ទំយើខ្លួន

ក៏បែកប្រាជ្ញរកឱបាយធ្វើបាបឯងលេងនោះអី!

ពូគ្រុឌញាក់ចិញ្ចើមព្រើតៗ ហើយសើចកក្អឹករួចឆ្លើយថា :

- ចុះនរណាប្រើអោយឯងធ្វើបាបចិត្តនាងចាន់ ក្មួយស្រីរបស់យើង អោយ

ទូលទុក្ខរាប់ខែធ្វើអី? ត្រូវតែរៀបជើងព្រួលសងសឹកខ្លះទើបបាន។

- ហើយចុះមីងទូលអុសជានរណាដែរ ពូគ្រុឌ? (ខេវិនសួរ)

- ជាប្រពន្ធពូហ្នឹងណា៎។ គ្រាន់តែតាសែមយាយផាត់ទូរសព្ទមកពូភ្លាម ថា ឯងចេញដំណើរមកព្រះនេត្រព្រះ

យើងក៏រៀបគំរោងការស្ទាក់ឯងលេង ទៅ ណាចង់មើលមុខកំលោះអាមេរិកផង ថាតើអាចទ្រាំនឹងការលំបាកនៅ

ស្រុកស្រែបានប៉ុនណាដែរ? បើទ្រាំមិនបាន យើងមិនលើកនាងចាន់ឱ្យទេ។

អ្នកស្រុកក៏សើចគិលថែមឡើង ធ្វើអោយខេវិនទឹកខ្មាសនិយាយលេង ចេញ។ បន្តិចមក នាយក៏សួរបន្ថែមថា :

- ចុះរឿងធ្វើអំណោយទៅក្រសួងសង្គ្រោះកុមារនោះ ជាការពិតដែរទេ?

- ពិត! ម៉េចក៏ថាមិនពិត... គឺបានធ្វើអំណោយមែន (តាជីវរៃឆ្លើយ)

- បើពិតមែន តើតាទៅបានប្រាក់ពីណាដល់ទៅរាប់សែនដុល្លារដាក់ទានជា

អំណោយដល់គេទៅ?

- ការពិត តួលេខតែប្រាំម៉ឺនដុល្លារប៉ុណ្ណោះ តែយើងអានពន្លើសរហូតដល់ ប្រាំសែន! ហែសៗ

គ្រាន់តែចង់លលេងស្ទង់ទឹកចិត្តរបស់ឯងហ្នឹងណា៎ ចង់ ដឹងថាឯងមានចិត្តលោភលន់ចង់បានទ្រព្យសម្បត្តិ ឬក៏ឯងស្រលាញ់នាង

CHANBOKEO.COM

ចាន់ដោយស្មោះពិតមែន ។ ការពិតទៅ ចំនួនលុយនោះគឺតែពីរម៉ឺនប្រាំពាន់ ដុល្លារទេដែលយកទៅបង់ជាអំណោយ ហើយទាំងនោះក៏ជាប្រាក់របស់ មីងពៅពូវៃទាំងអស់ដែរ...

ខេរិនភ្ញាក់ព្រើតបែរមើលពូមីង ស្រាប់តែឃើញគាត់ញញឹមហើយងក់ក្បាលទាំងពីរនាក់ :

- មីងហ៊ានចំណាយដល់ម្លឹងដើម្បីពិសោធន៍ចិត្តរបស់ក្មួយ? (ខេរិនឧទាន)

- កុំបាច់ភ្ញាក់ផ្អើលអីខេរិន! ចំណាយសំរាប់ជាអំណោយមនុស្សធម៌ប៉ុនហ្នឹង ក៏នៅតិចពេកណាស់ សំរាប់ប្តូរយកឯងអោយវិលត្រលប់ចូលមកក្នុងរង្វង់ គ្រួសាររបស់យើងវិញ ហើយថែមទាំងបានខេរិនដ៏ល្អប្លែកជាងមុនទៀត នោះ ។ ជាពិសេសទៅទៀត កាលបើពូមីងក៏មានឱកាសបានឃើញផ្ទាល់ ភ្នែកថាឯងបានជ្រើសរើសចន្ទ័និសាដោយសេចក្តីស្នេហាដ៏បរិសុទ្ធពីបេះដូង មិនមែនដោយសារទឹកប្រាក់ទ្រព្យសម្បត្តិជានុយបង្ខំចិត្ត ពូមីងរិតតែមាន សទ្ធាចង់ធ្វើបុណ្យយ៉ាងច្រើនមហិមាជាងហ្នឹងទៅទៀត ។

ខេរិនឮដូច្នោះក៏រំភើបចិត្តអនេកកប្បការ ។ នាយក៏សំរុតខ្លួនចុះហើយ ក្រាបក្បាលដល់ដី បង្គំសំពះមីងពៅនិងពូវៃ :

- អោយកូនសូមទោសអ្នកមានគុណទាំងពីរផងដែលមិនបានធ្វើខ្លួនជាក្មេងកតញ្ញូចំពោះពូនិងមីង ។ ខេរិនមានការសោកស្តាយណាស់ ។ គ្រានេះខេរិនយល់រិតតែច្បាស់ហើយនូវបំណងដ៏ល្អរបស់ពូមីងចំពោះខេរិន ។ បើ សិនជាគ្មានពូមីងទេជីវិតរបស់ខេរិនក៏មិនបានយល់ពន្លឺរស្មីនៅថ្ងៃនេះដែរ ។ សូមមេត្តាអនុញ្ញាត្ត អោយខ្ញុំមានឱកាសហៅអ្នកមានគុណទាំងពីរ ថា.... ជា **ពុក ម៉ែ** ផង... !

ឮដូច្នោះ ពូវៃនិងមីងពៅត្រេកអររំជួលចិត្តរហូតដល់រលីងរលោងទឹក ភ្នែក ។ មីងពៅក៏មានប្រសាសន៍ឡើងថា :

- ម៉ែចង់អោយកូនហៅថា ម៉ែៗបែបនេះតាំងពីយូរហើយណាំកូនម្តាយ...

ខេរិនក៏ស្រវាអោបមីងពៅយ៉ាងណែន :

- ម៉ែ! (ហើយក៏បែរទៅសំពះពូវៃ ហៅគាត់ថា...) ពុក!

ពូវៃក៏យកដៃបបោសក្បាលខេរិនថ្នមៗ ដោយចិត្តស្រលាញ់យ៉ាង លើសលប់បំផុត ។ នៅទីនោះ ទាំងនាងចាន់ ទាំងមីងចាប និងគ្រប់ៗគ្នា ទាំងអស់ក៏ញញឹមឡើងយ៉ាងបំព្រង ។

តន្ត្រីក៏ចាប់ប្រគំឡើងយ៉ាងពិរោះរណ្តំសាជាថ្មី លាយឡំនឹងស្នូរសំលេងហ៊ោរកញ្ជ្រៀវរបស់អ្នកភូមិ បានក្លាយទៅជាបំណាចផ្កាពរជ័យយ៉ាងមហោឡារិកបំផុតចំពោះចាន់និងខេរិនរបស់យើង ។ គូជីវិតទាំងទ្វេហាញញឹម ឡើងទទួលយកនូវពន្លឺសុភមង្គលមួយយ៉ាងស្រស់បំព្រង ។ ខេរិនឈរកាន់ ដៃភរិយាសំលឹងទៅអ្នកទាំងឡាយ ដែលកំពុងតែស្រែកហ៊ោរប្រជែងគ្នា ជូនពរអ្នកទាំងពីរទ្រហឹងអឹងកង ហើយក៏ពោលតបទៅគេវិញថា :

- នេះហើយជាសេចក្តីសុខដែលខេរិនតាមរកអស់រយៈជាយូឆ្នាំមកហើយ!

CHANBOKEO.COM

គឺពិតជារមនាណាស់! ខេរិនសូមថ្លែងអំណរគុណចំពោះអ្នកមានគុណទាំង អស់! សូមអរគុណពុកនិងម៉ែរបស់ខ្ញុំទាំងពីរនាក់...

ពូរ៉ៃមីងពៅមើលមុខគ្នាហើយ ក៏ទះដៃឡើងដែលខេរិនហៅគាត់ថា ម៉ែពុកពេញមាត់ ។ ខេរិនក៏បន្តទៅទៀតថា :

- ខេរិនសូមអរគុណញាតិមិត្តបងប្អូនភូមិផងរបងជាមួយទាំងឡាយ ដែល បានស្វាគមន៍ទទួលខេរិនជាញាតិម្នាក់ក្នុងរបស់ភូមិព្រះនេត្រព្រះនេះ... អរ គុណជាពិសេសចំពោះចន្ទ័និសាដែលភរិយាដ៏ប្រពៃរបស់ខ្ញុំ ព្រមទាំងម៉ែ ចាប ដែលបានផ្តល់ឱកាសអោយខេរិនបានកែខ្លួនជាមនុស្សប្រពៃសាជាថ្មី ឡើងវិញ ។

អ្នកភូមិក៏បេះផ្កាដូងបាចព្រោងព្រាតឡើងសាជាថ្មី ទៅលើគូគាប់ទាំង ទ្វេហា ព្រមទាំងហ៊ោរកញ្ជ្រៀវលាន់ពួរំពងអឺងអាប់...

ពេលនោះខេរិនស្រម័យថា ខ្លួននាយគឺជាទេវបុត្រមួយអង្គដែលកំពុង បានទទួលការសំរេចដូចបំណងសព្វបែបយ៉ាង ដោយមានទេពធិតានាម ចន្ទ័និសា ជាគូនៃបប្រាណ មានឪពុកម្តាយដែលស្រលាញ់នាយក្រៃលែង មានជីដូនដែលជាម្លប់ធមិដ៏ត្រជាក់ និង ញាតិសន្តានទាំងឡាយដែលតែង តែជ្រោមជ្រែងលើកកំលាំងចិត្តនាយរាល់វេលាដែលនាយត្រូវការ ។ ពីថ្ងៃ នេះទៅ ខេរិនសច្ចានៅក្នុងចិត្តថានឹងកែខ្លួនសាជាថ្មី ប្រឹងរៀនសូត្រ ប្រឹង ធ្វើការ និងខិតខំតម្រែតម្រង់ផ្លូវជីវិតរបស់នាយ អោយប្រកបទៅដោយ សុក្រឹតភាព ដើម្បីជាគំរូល្អនិងជាពំនាក់ដ៏មាំមួន ដល់កូនចៅរបស់ខ្លួននៅនា អនាគត...

# ចប់

CHANBOKEO .COM

# វាចាចុងក្រោយ

- មានតែសេចក្តីស្រលាញ់និងការអធ្យាស្រ័យទេ ដែលនាំឱ្យគូជីវិតរក្សា សេចក្តីសុខនិងសុភមង្គលក្នុងគ្រួសារបានដោយជោគជ័យ ។
- កាលបើមនុស្សវង្វេងក្នុងជីវិតឧក្រិដ្ឋ មិនមែនមានន័យថា គេជាមនុស្ស ដែលមានបេះដូងឧក្រិដ្ឋទេ ។ សូមផ្តល់ឱកាសអោយគេបានបញ្ចេញនូវ សេចក្តីល្អ ដែលកប់នៅក្នុងបេះដូងរបស់គេនោះផង ។
- ជួនកាលយើងគិតថា បើយើងមានប្រវត្តិប្រហាក់ប្រហែលគ្នា ប្រហែល ជាយើងអាចយល់ចិត្តគ្នាជាក់ច្បាស់ ប៉ុន្តែនោះក៏អាស្រ័យនៅលើការមាន និស្ស័យចំពោះគ្នាទៅវិញទៅមកដែរ ។ បើខ្វះចំណងសម្ពន្ធ័និស្ស័យផ្លូវចិត្ត ចំពោះគ្នាហើយ យើងក៏មិនអាចក្លាយជាគូជីវិត ដែលប្រកបដោយ សុភមង្គលពេញលេញបានដែរ ។
- ការសំដែងនូវសេចក្តីស្រលាញ់របស់អ្នកមានគុណចំពោះបុត្រ មិនមែន ស្ថិតនៅលើបបូរមាត់ទេ តែស្ថិតនៅលើការប្រព្រឹត្តរបស់អ្នកមានគុណ ថា តើលោកបានបូជាអ្វីខ្លះក្នុងជីវិត ដើម្បីកូនចៅជាទីស្រលាញ់របស់លោក ។
- បើយើងបើកចិត្តសំលឹងមើលអ្វីៗជុំវិញខ្លួន ដោយសុទិដ្ឋិឆន្ទៈ នោះយើង នឹងសំគាល់ឃើញថា សុភមង្គលតែងតែអន្ទោលតាមយើងគ្រប់ទីកន្លែង ។

អ្នកស្រីកែវចន្ទ័បូរណ៏

ថ្ងៃ ២៤មករា ២០០៦

CHANBOKEO . COM